# ការផ្លាស់ប្តូរបទពិសោធន៍ ដើម្បី អនាគតល្អ

# EXCHANGE EXPERIENCES FOR A BETTER FUTURE



២១៩.
៣៣

ការផ្សាយរបស់
ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ជាមួយការឧបត្ថម្ភដោយ
មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ, ប្រទេសអាល្លឺម៉ង់
A publication of *Buddhism for Development*
Supported by the Konrad-Adenauer-Foundation, Germany

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh     www.elibraryofcambodia.org**


www.budinst.gov.kh     www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY
BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

ការផ្លាស់ប្តូរបទពិសោធន៍
ដើម្បី អនាគតល្អ

**EXCHANGE EXPERIENCES FOR
A BETTER FUTURE**

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

២១៩.២៥

# ពុទ្ធសាសនា

# និង

# ការអភិវឌ្ឍន៍សង្គមខ្មែរ

- ដំណើរការនៃសិក្ខាសាលាជាតិ ស្តីពី
« ពុទ្ធសាសនា និង ការអភិវឌ្ឍន៍សង្គមខ្មែរ »
ប្រជុំនៅរាជធានីភ្នំពេញ, ពីថ្ងៃទី ២១ ដល់ ២៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៤

សិក្ខាសាលាជាតិ និង ការបោះពុម្ពផ្សាយសៀវភៅនេះ
ត្រូវបានឧបត្ថម្ភដោយ
មូលនិធិ-ខុនរ៉ាដ-អាដេណូអ៊ែរ, ប្រទេសអាល្លឺម៉ង់

បណ្ណាល័យ
LIBRARY
BUDDHIST INST
១៥០/៩៥
06-12

ការផ្សាយរបស់
*ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍*
ក្នុងកិច្ចសហប្រតិបត្តិការជាមួយ
ក្រសួងធម្មការ និង សាសនា និង ពុទ្ធសាសនបណ្ឌិត្យ
អន្លង់វិល / ភ្នំពេញ
១៩៩៥

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# BUDDHISM AND THE DEVELOPMENT OF KHMER SOCIETY

**- Proceedings of the National Seminar on „Buddhism and the Development of Khmer Society" held in Phnom Penh, 21 - 23 November 1994 -**

The national seminar and the publication of this book
were supported by
the Konrad-Adenauer-Foundation, Germany

A publication of
*Buddhism for Development*
in cooperation with
the Ministry of Cults and Religions and the Buddhist Institute

Anlongvil / Phnom Penh

1995

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

២១៩.៣៣

# ការផ្លាស់ប្តូរបទពិសោធន៍
# ដើម្បី អនាគតល្អ

- ដំណើរការនៃសិក្ខាសាលាជាតិ លើកទី៤ ស្តីពី

<< ពុទ្ធសាសនា និង ការអភិវឌ្ឍន៍សង្គមខ្មែរ >>

ប្រជុំនៅក្រុងស្វាយរៀង, ពីថ្ងៃទី ២៤ ដល់ ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

សិក្ខាសាលាជាតិ និង ការបោះពុម្ពផ្សាយសៀវភៅនេះ ត្រូវបានឧបត្ថម្ភដោយ
មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ, ប្រទេសអាល្លឺម៉ង់

ការផ្សាយរបស់
*ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍*

BUDDHIST INSTITUTE LIBRARY
៤២៦៤/៩៩

អន្លង់វិល
១៩៩៨

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# EXCHANGE EXPERIENCES FOR A BETTER FUTURE

**- Proceedings of the 4th National Seminar on „Buddhism and the Development of Khmer Society" held in Svay Rieng town, 24-30 November 1997 -**

The national seminar and the publication of this book were supported by the Konrad-Adenauer-Foundation, Germany

A publication of *Buddhism for Development*

Anlongvil

1998

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# មាតិកាអត្ថបទ

**ចំណងជើង** **ទំព័រ**


| | |
|---|---|
| ១. ព្រះរាជសារព្រះបាទសម្តេច ព្រះនរោត្តម សីហនុ | ១ |
| ២. ព្រះសង្ឃថារបស់ព្រះតេជគុណ ញ៉ែម គីមតេង | ២ |
| ៣. សុន្ទរកថារបស់លោក ភីធ័រ ស្មៀវ | ៦ |
| ៤. សុន្ទរកថាឯឧត្តម ឡូយ សូផាត អភិបាលខេត្តស្វាយរៀង | ១២ |
| ៥. សង្ឃថារបស់ព្រះតេជគុណ យស ហ៊ុត | ១៥ |
| ៦. របាយការណ៍ស្តីពីការអនុវត្តសេចក្តីសំរេចចិត្តរបស់សិក្ខាសាលាជាតិលើកទី ២ និងលើកទី ៣ | ១៨ |
| ៧. តួនាទីរបស់ព្រះសង្ឃក្នុងសង្គមបច្ចុប្បន្ន | ៣០ |
| ៨. បទពិសោធន៍ស្តីពីធនាគារស្រូវ | ៣៤ |
| ៩. បទពិសោធន៍ស្តីពីការធ្វើឥណទាន និង សន្សំប្រាក់ | ៧៨ |
| ១០. បទពិសោធន៍ស្តីពីការដាំរុក្ខវប្បដ្ឋាន និង ធ្វើជីកំប៉ុស្ត | ១១៣ |
| ១១. បទពិសោធន៍អំពីការអប់រំយុវជនសីលធម៌ | ១២១ |
| ១២. ព្រះពុទ្ធសាសនិក និង ការបោះឆ្នោត | ១២៨ |
| ១៣. ព្រះរាជសារបិទសិក្ខាសាលារបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ | ១៣៩ |
| ១៤. សន្ទរកថាបិទសិក្ខាសាលារបស់ លោក ភីធ័រ ស្មៀវ | ១៤៦ |
| ១៥. សន្ទរកថាបិទសិក្ខាសាលារបស់ឯ.ឧ. ហៀន វណ្ណារ៉ុ | ១៥២ |


www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| ១៦. | របាយការណ៍បិទសិក្ខាសាលារបស់ ព.ឆ.អ. | ១៥៥ |
| ១៧. | សន្ទរកថាបិទសិក្ខាសាលារបស់ ឯ.ឧ. ឡូយ សុផាត | ១៦០ |
| ១៨. | សេចក្ដីសំរេចចិត្តរួមរបស់សិក្ខាសាលាជាតិលើកទី៤ | ១៦៤ |


www.budinst.gov.kh www.elibraryofcambodia.org

**ព្រះរាជសារ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**ក្នុងឱកាសបើកសិក្ខាសាលាជាតិលើកទី ៤ ពីថ្ងៃ ២៤-៣០ វិច្ឆិកា ១៩៩៨**

*អានដោយ ព្រះតេជគុណ ញ៉ៀម គឹមតេង នាយកអង្គការ សន្តិសេនា*

*ប៉េកាំង, ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៩៧*

ខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយ និងជូនសេចក្តីសរសើរដ៏កក់ក្តៅ ដោយគោរព និងជាទីស្រឡាញ់បំផុតចំពោះព្រះសង្ឃ លោកអាចារ្យ ជូនជី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បងប្អូនកូនចៅ ព្រមទាំងលោក គីធ័រ ស្បៀរ នៃខុនរ៉ាដ អាដិនណៅអ៊ែរ Foundation អង្គការ NGO ដែលធ្វើសិក្ខាសាលាដ៏ប្រសើរបំផុត ជាឧត្តមប្រយោជន៍សំរាប់ប្រជាជាតិប្រជាជនកម្ពុជា នៅក្រោមម្លប់ព្រះពុទ្ធសាសនា ហើយលើកតម្កើងឋានៈជីវភាពប្រជារាស្ត្រ អភិវឌ្ឍន៍ប្រទេសជាតិ តាមព្រះធម៌ព្រះពុទ្ធបរមគ្រូ ។

ខ្ញុំព្រះករុណាខ្ញុំ និងសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ សូមថ្វាយ និងជូនពរសព្ទសាធុការដ៏វបរ សូមឱ្យមានមហាជោគជ័យដល់សិក្ខាសាលាដ៏ឧត្តុង្គឧត្តមនេះ ។

នរោត្តម សីហនុ

www.budinst.gov.kh www.elibraryofcambodia.org

## សន្តុជាព្រះភិក្ខុ ទជីវប្បញ្ញា ឡឿម តឹមឆេង
## នាយកអង្គការសន្និសីទនាក្នុងឱកាសបើកសិក្ខាសាលាជាតិលើកទី ៤
## ២៤- ៣០ វិច្ឆិកា ១៩៩៧

- សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមចំរើនពរឯឧត្តម លោក-លោកស្រី និងភ្ញៀវជាតិ អន្តរជាតិ
- សូមចំរើនពរញាតិញោម និងពុទ្ធបរិស័ទទាំងឡាយជាទីមេត្រី

ថ្ងៃនេះ ជាទិវាប្រកបដោយនក្ខត្តឫក្ស ដែលយើងទាំងអស់គ្នាជាបព្វជិត និងគ្រហស្ថបាននិមន្ត និងអញ្ជើញមកពីខេត្តផ្សេងៗគ្នាក្នុងព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងសិក្ខាសាលាជាតិលើកទី ៤ ស្តីអំពី " ព្រះពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គម " ដើម្បីចែកចាយបទពិសោធន៍ ដែលធ្លាប់បានអនុវត្តកន្លងមក និងស្វែងរកគន្លឹះសំរាប់អនុវត្តដ៏ត្រឹមត្រូវមួយ ដើម្បីអនាគតល្អនៃសង្គមខ្មែរ ។

ខ្ញុំព្រះករុណាអាត្មាភាព ក្នុងនាមគណៈកម្មការរៀបចំសិក្ខាសាលាជាតិលើកទី ៤ មានបីតិ និងមោទនភាពយ៉ាងក្រៃលែង ចំពោះវត្តមានរបស់ព្រះថេរានុត្ថេរៈ ឯកឧត្តម លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងញាតិញោមទាំងឡាយក្នុងឱកាសនេះ ពិតជាសារៈសំខាន់ និងមានតំលៃមិនអាចកាត់ថ្លៃបាន ។ វត្តមានទាំងនេះ ត្រូវបានលិខិតទុកក្នុងទំព័រប្រវត្តិសាស្ត្រនៃដំណើរការព្រះពុទ្ធសាសនាខ្មែរ សំរាប់សតវត្សរ៍នេះ និងសតវត្សរ៍បន្តបន្ទាប់ ដូចជាការបើកសង្គាយនារបស់ព្រះពុទ្ធសាសនាដែលធ្លាប់បានធ្វើពីអតីតកាល ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាសាលាជាតិលើកទី៤នេះបានរៀបចំឡើងដោយអង្គការសន្តិសេនា និងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ដែលជាអង្គការពុទ្ធសាសនាខ្មែរយើង និងដោយមានការជួយឧបត្ថម្ភថវិកាពីមូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ, ប្រទេសអាល្លឺម៉ង់ ។

ខ្ញុំព្រះករុណាអាត្មាភាពក្នុងនាមគណៈកម្មការរៀបចំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ភីធ័រ ស្ប៉ៀរ តំណាងអចិន្ត្រៃយ៍នៃមូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ, ប្រទេសអាល្លឺម៉ង់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសហការីទាំងអស់ និងលោក យី ធន់ ទីប្រឹក្សាក្រសួងធម្មការនិងសាសនា ដែលបានជួយឧបត្ថម្ភអស់ពីកំលាំងកាយចិត្តដល់ដំណើរការសិក្ខាសាលាជាតិលើកទី ៤ នេះ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះស្ថានទូតនៃសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាមានលោកស្រី*ស៊្វី ហ្សាន រចារ៍មែន* ជាលេខាទី១របស់ស្ថានទូតដែលបានផ្តល់នូវការឧបត្ថម្ភនិងការលើកទឹកចិត្តដល់ការបើកសិក្ខាសាលាជាតិលើកនេះក៏ដូចជាដល់អង្គការសន្តិសេនាដែរ ។

ព្រះថេរានុត្ថេរៈ ឯកឧត្តម លោក-លោកស្រី ញាតិញោមទាំងឡាយ ឥឡូវនេះយើងទាំងអស់គ្នាងាកក្រោយក្រឡេកមើលទៅ អតីតកាលរបស់ខ្លួនយើងដោយស្ងប់ចិត្ត យើងពិតជាមានបីតិមួយកើតឡើងក្នុងចិត្តដោយសារតែយើងបានឃើញនូវភាពរុងរឿង ថ្កុំថ្កើង ថ្លៃថ្នូរនៃសង្គមជាតិយើងក្នុងសម័យកាលមួយ ។ ប៉ុន្តែយើងគួរឱ្យស្តាយដោយក្រោយមកភាពរុងរឿង ថ្កុំថ្កើង និងភាពថ្លៃថ្នូរនេះត្រូវលិចបាត់បន្តិចម្តងៗពីសង្គមខ្មែរ ។ សព្វថ្ងៃនេះព្រលឹងខ្មែរអង្គរពិតប្រាកដមិនមាននៅក្នុងរូបខ្មែរទេ ដោយខ្មែរអស់ជំនឿលើខ្លួនឯង

www.budinst.gov.kh www.elibraryofcambodia.org

ខ្មែរច្បាំងគ្នាឯងដើម្បីអំណាចគិតពីអត្តទត្ថភាពច្រើនជាង ប្រយោជន៍ប្រទេសជាតិ រហូតដល់ប្រទេសខ្មែរយើងឥឡូវនេះជាប់ជាចំណាត់ថ្នាក់ថាជាប្រទេសក្រីក្រលើពិភពលោក ។

ព្រះពុទ្ធសាសនាជា សាសនាវិទ្យាសាស្ត្រ ជាសាសនាមនុស្សនិយម ។ សាសនានេះបានផ្សាយចូលមកក្នុងប្រទេសខ្មែរតាំងពីអំឡុងសតវត្សរ៍ទី៣ នៃពុទ្ធសករាជគឺមុនគ្រឹះសករាជរវាង២៦៩ឆ្នាំ ដោយព្រះភិក្ខុជាសមណទូតពីរអង្គគឺព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ ។ បានសេចក្តីថាព្រះពុទ្ធសាសនាផ្សាយចូលមកក្នុងប្រទេសកម្ពុជាយើងក្នុងយុគសម័យបុរេប្រវត្តិគឺមុនសតវត្សរ៍ទី ១ មកម្ល៉េះ ។ ប៉ុន្តែគេសង្កេតឃើញថា ក្នុងសម័យអង្គរ (គ.ស.៨០២-១៤៣១) ព្រះបាទជ័យវរ្ម័នទី២ជាបឋមក្សត្រក្នុងយុគសម័យនោះបានធ្វើឱ្យព្រះពុទ្ធសាសនាមានឥទ្ធិពលខ្លាំងដល់ការកសាងប្រទេសជាតិ ។ ក្នុងសម័យនោះព្រះពុទ្ធសាសនាមានមុខងារយ៉ាងសំខាន់ក្នុង ឆាកនយោបាយ ការគ្រប់គ្រង និង ការកសាងប្រទេសជាតិ ។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ (១១៨១)ព្រះពុទ្ធសាសនាមានមហាវិទ្យាពីរកន្លែងគឺរាជមហាវិហារ(ប្រាសាទតាព្រហ្ម ) ព្រមទាំងមានព្រះសង្ឃថ្នាក់បណ្ឌិត ចំនួន ១៨អង្គ និងមានព្រះសង្ឃជាសាស្ត្រាជាន់ខ្ពស់ចំនួន២,៧៤០អង្គផងដែរ ។ ជារៀងរាល់ថ្ងៃព្រះភិក្ខុសង្ឃចំនួន ៤៣៩ អង្គនិមន្តចូលកាន់ព្រះបរមរាជវាំងមហានគរដើម្បីពិគ្រោះការងារកសាងប្រទេសជាតិនិងរំដោះទុក្ខវេទនារបស់ប្រជារាស្ត្រហើយនិងរិះរកយុទ្ធសាស្ត្រថ្មីៗដើម្បីអនុវត្ត ។ ព្រះភិក្ខុសង្ឃទាំងនោះគឺជាយុទ្ធិកដ៏សកម្មប្រឆាំងនឹងគ្រោះអត់ឃ្លាន និងគ្រោះអវិជ្ជាដែលជាមូលដ្ឋាននៃភាពក្រីក្រ ។ សម័យនោះខ្មែរយើងចំរើនរុងរឿងដល់ថ្នាក់កំពូលនៅក្នុងទ្វីបអាស៊ី ។

ព្រះថេរានុត្ថេរៈ ឯកឧត្តម លោក លោកស្រី ញាតិញោមទាំង ឡាយ

www.budinst.gov.kh www.elibraryofcambodia.org

យោងតាមស្ថានភាពដែលសង្គមខ្មែរយើងកំពុងតែជួបប្រទះនូវវិបត្តិសេដ្ឋកិច្ច សីលធម៌ចរិយាធម៌ពិសេសគឺភាពក្រីក្រដែលកំពុងរាតត្បាតដល់សង្គមបរិស័ទយើង ។ យើងទាំងអស់គ្នាត្រូវទាមទារឱ្យមានយុទ្ធសាស្រ្តល្អមួយដើម្បីដោះស្រាយបញ្ហាដែលកំពុងប្រឈមមុខហើយក៏ត្រូវការយុទ្ធិកដ៏ក្លាហានឈ្លាសវៃ និងមានសមត្ថភាពគ្រប់គ្រាន់ផងដែរដើម្បីអនុវត្តយុទ្ធសាស្រ្តនោះ ។ យុទ្ធិកដ៏ជាទីទុកចិត្តនោះគឺព្រះសង្ឃ អាជ្ញាធរដែនដី ដ៏ស្មោះត្រង់នៃយើង។ ការបើកសិក្ខាសាលានេះគឺជាការផ្លាស់ប្តូរបទពិសោធន៍ ដើម្បីស្វែងរកយុទ្ធសាស្រ្តដ៏ល្អមួយសំរាប់ដោះស្រាយនូវភាព ក្រីក្រ និងអភិវឌ្ឍន៍សង្គមខ្មែរ ។ យុទ្ធសាស្រ្តមួយប្រកបដោយអង្គ ៣ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានរកឃើញ ហើយទ្រង់បានបង្រៀនដល់បរិស័ទរបស់ទ្រង់ដើម្បីជាគន្លឹះក្នុងការអនុវត្តព្រះធម៌ គឺទី ១ ទូរបាតី បាញ់ឱ្យឆ្ងាយ មានន័យថា កុំបាញ់ជិត គឺកុំបាញ់ចិត្តគំនិត គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន អត្តទត្ថភាព កុដិអញ វត្តអញ វិហារអញគឺត្រូវពិនិត្យទៅលើពុទ្ធបរិស័ទដែលនៅជុំវិញខ្លួន និងក្នុងសង្គមទាំងមូលថាតើកំពុងមានបញ្ហាអ្វីកើតឡើងខ្លះ ? ហើយត្រូវស្វែងរកគន្លឹះជួយដោះស្រាយបញ្ហានោះ ដើម្បីជាសេចក្តីសុខ សេចក្តីចំរើនទាំងអស់គ្នា ។ ទី២ អក្ខណវេទី បាញ់ឱ្យចំ គឺបាញ់ឱ្យចំទៅលើបញ្ហា មានន័យថាត្រូវសិក្សាឱ្យបានដឹងច្បាស់ថា តើបញ្ហាអ្វីខ្លះដែលកំពុងកើតមានចំពោះបរិស័ទ ឬសង្គម ? ហើយបញ្ហាណាមួយដែលធំចំបងជាងគេ គួរដោះស្រាយបញ្ហានោះមុនគេ ។ ឧទាហរណ៍ : បើអ្នកស្រុកអត់បាយ ត្រូវដោះស្រាយឱ្យ មានបាយហូប បើខ្វះទឹកស្អាតហូប ត្រូវរៀបចំឱ្យមានទឹកស្អាត ។ល។ និង ។ល។ មិនមែនអ្នកស្រុកខ្វះបាយហូប ខ្វះទឹកស្អាតផឹក ខ្វះផ្លូវដើរ យើងនាំគ្នាកសាងព្រះវិហារថ្មពីរបីជាន់នោះទេ ។ ដំណោះស្រាយរបៀប នេះហៅថាបាញ់ខុស

www.budinst.gov.kh www.elibraryofcambodia.org

ជួយគឺវាងាយស្រួលក្នុងការអនុវត្ត ។ តែបើយើងខិតខំដំណើរការទៅមុខបានដោយខ្លួនឯងហើយបែរជាគ្មានជំនួយពីបរទេសឬពីរដ្ឋាភិបាលទេក៏យើងអាចដំណើរការទៅមុខបានដែរ ។ កិច្ចការសំខាន់គឺការអនុវត្តនូវសកម្មភាពដោយខ្លួនយើងផ្ទាល់នៅក្នុងកន្លែងដែលយើងរស់នៅ ដើម្បីដោះស្រាយបញ្ហាសង្គមដែលប្រជាពលរដ្ឋកំពុងជួបប្រទះ ។ កត្តាកំណត់ការអភិវឌ្ឍន៍ជនបទគឺសហគមន៍ គឺព្រះតេជគុណ អស់លោកដែលមានមុខនៅទីនេះ ដែលបានអញ្ជើញមកពីសហគមន៍រៀងៗខ្លួនជាអ្នកកំណត់នូវការរីកចំរើន។ ជាក់ស្តែងដូចព្រះតេជគុណ មុំ សយ ព្រះអង្គបានខិតខំបង្កើតដោយ ព្រះអង្គផ្ទាល់ដោយគំនិតប្រាជ្ញាព្រះអង្គផ្ទាល់ពុំមានជំនួយពីបរទេសឡើយ ។ ពោលគឺព្រះអង្គបានបង្កើតវត្តវប្បដ្ឋានមួយ ដើម្បីស្តារឡើងវិញនូវផ្ទៃដីព្រៃឈើមួយចំនួនធំ ។ ចាប់ពីឆ្នាំ១៩៩៤ មកមានព្រះសង្ឃក្រោកឈរធ្វើសកម្មភាពដោយខ្លួនឯងច្រើនណាស់តែបើយើងប្រៀបធៀបចំនួនព្រះសង្ឃទៅនឹងចំនួនវត្ត ឃើញថា យើងមិនទាន់ប្រៀបធៀបបានទេ ពីព្រោះចំនួននោះវានៅខុសគ្នាឆ្ងាយណាស់។ ឥឡូវនេះដោយនៅមានព្រះសង្ឃជាច្រើននៅមានគំនិតប្រកាន់ភ្ជាប់រឹងហៅថាគំនិតបុរាណនោះគឺលោកផ្តោតព្រះទ័យទុកដាក់ទៅលើការកសាងវត្តកសាងព្រះវិហារតែប៉ុណ្ណោះ។ ប្រសិនបើយើងក្រឡេកមើលជីវិតរស់នៅរបស់ព្រះពុទ្ធវិញ យើងអាចនិយាយបានថានៅក្នុងមួយព្រះជន្មរបស់ព្រះអង្គ ( ព្រះសមណគោតម ) គឺព្រះអង្គបានលះបង់មិនថាតែទ្រព្យសម្បត្តិក្នុងឋានៈជាស្តេច ឬជាអ្វីទេ សូម្បីតែ កូន ប្រពន្ធ ក៏ព្រះអង្គបានលះបង់ដែរ ហើយការលះបង់នេះគឺជាការលះបង់ដើម្បីសង្គម ។ ដូច្នេះនៅក្នុងសង្គមថ្មីរបស់យើងនេះយើងឃើញថាប្រសិនបើយើងកសាងព្រះវិហារដ៏ធំមួយធ្វើវត្តដ៏ល្អមួយតើវាជាការសំខាន់ដែរឬទេសំរាប់សង្គមជាតិយើង?

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះយើងត្រូវតែយល់ពាក្យថា: មេត្តា, ករុណា និងឧបេក្ខាឱ្យបានច្បាស់។ មេត្តាមានន័យថាយើងជួយអ្នកដទៃឱ្យបានច្រើនមិនមែនមានន័យថាគិតតែនាំគ្នាកសាងវត្តឱ្យបានល្អស្អាតនោះទេ។ ប្រទេសកម្ពុជាយើងសព្វថ្ងៃនេះមានកម្មវិធីជាច្រើននៅក្នុងការអនុវត្តការងារតាមបែបព្រះពុទ្ធសាសនាក៏ដូចជាយើងបានធ្វើសិក្ខាសាលាជាច្រើនលើកមកហើយដែរ ហើយយើងក៏បានលើកយកកម្មវិធីទាំងនោះមកនិយាយផងដែរ ។ អង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ជាអង្គការមួយដែលកំពុងបន្តនូវកម្មវិធីលើការងារអភិវឌ្ឍន៍ ដើម្បីជួយដល់សង្គម ។ ជាមួយគ្នានេះដែរក៏មានអង្គការដទៃជាច្រើនទៀតមានកម្មវិធីផ្សេងៗបានអនុវត្តនូវការងារ និងបានទទួលនូវជោគជ័យក្នុងកម្មវិធីរបស់ខ្លួនដែរដូចជាអង្គការ ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ដែលកំពុងធ្វើសកម្មភាពជួយដល់សង្គមនៅផ្នែកខាងលិចនៃប្រទេស ហើយក៏មានអង្គការសនិសេនាដោយមានព្រះតេជគុណ ញ៉ែម គឹមតេង ដឹកនាំនៅទីនេះ និង អង្គការដទៃទៀតដែលដឹកនាំដោយព្រះសង្ឃកំពុងតែធ្វើសកម្មភាពនៅក្នុងប្រទេសជាប់ព្រំដែនភាគខាងកើតហើយនិងអង្គការមួយទៀតដែលមានឈ្មោះថា GTZ កំពុងធ្វើសកម្មភាពក្នុងផ្លូវសាសនាដែរនៅភាគខាងជើងនៃប្រទេស ហើយភាគខាងត្បូង និង និរតីក៏មានសកម្មភាពរបស់ព្រះសង្ឃជួយដល់សហគមន៍ដែរដូចជានៅខេត្តកំពត, កំពង់សោមជាដើម។ល។ យើងមានមោទនភាពខ្លាំងណាស់ថ្ងៃនេះបើសិនជាយើងងាកមើលទៅក្រោយវិញពោលគឺនៅឆ្នាំ១៩៩៤ ពេលដែលមូលនិធិយើងចាប់ផ្តើមធ្វើសកម្មភាពជាមួយ អង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍យើងបានទទួលគំនិតថា យើងត្រូវតែបំផុសចលនាឱ្យមានការស្ម័គ្រចិត្តចេញពីព្រះសង្ឃដើម្បីជួយដល់សង្គម។ ចាប់ពីពេលនោះហើយដែលកើតមានសិក្ខាសាលាជាតិលើកទី១ដែលធ្វើនៅភ្នំពេញហើយមានប្រធានបទថា :

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ។ សិក្ខាសាលាជាតិលើកទី ២ ក៏បានប្រារព្ធធ្វើឡើងនាឆ្នាំបន្ទាប់ ដោយបានបំផុសទៅលើគំរោងដែលយើងបានធ្វើកាលពីសិក្ខាសាលាជាតិលើកទី១។ នៅក្នុងសិក្ខាសាលាជាតិលើកទី២នេះយើងអាចមើលឃើញថាតើអ្វីខ្លះដែលអាចជួយដល់ប្រជាពលរដ្ឋបាន ? បានដល់ពុទ្ធបរិស័ទចំណុះជើងវត្ត ? ដូចជាការអប់រំផ្នែកស្មារតីការផ្តល់សម្ភារៈបញ្ហាជំនួយផ្សេងទៀតសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃ ។ល។ នៅឆ្នាំ១៩៩៦ សិក្ខាសាលាជាតិលើកទី៣ ក៏បានប្រារព្ធធ្វើឡើងនៅក្នុងវត្តអន្លង់វិលខេត្តបាត់ដំបង ដោយផ្តោតទៅលើប្រធានបទថា*ដាក់អាវុធ ចាប់យកព្រះធម៌* ហើយនិងថាតើបរិស័ទអាចចូលរួមក្នុងសកម្មភាពណាខ្លះដើម្បីធ្វើឱ្យមានសន្តិភាពនិងស្ថេរភាពសង្គម ? ពេលនោះយើងបានឃើញថាសកម្មភាពនៅចុងឆ្នាំ១៩៩៦និងដើមឆ្នាំ១៩៩៧នេះគឺឈរលើគោលការណ៍បង្រួបបង្រួមជាតិយើងក៏ឃើញថាមានសកម្មភាពជាច្រើនឆ្លើយតបទៅនឹងសិក្ខាសាលានេះ។ ដូចជាការធ្វើធម្មយាត្រាឆ្លងកាត់ ក្រុងប៉ៃលិន ជាដើមហើយពេលនោះក៏មានបង្កើតជាគណៈកម្មការមួយដើម្បីដោះស្រាយបាតុភាពមិនប្រក្រតី ដើម្បីបញ្ឈប់នូវជំលោះប្រដាប់អាវុធនៅខេត្តបាត់ដំបង ។ ពេលបញ្ចប់សិក្ខាសាលាជាតិលើកទី៣យើងបានចេញនូវសេចក្តីសំរេចរួមមួយដោយមានការចុះហត្ថលេខាពីមន្ត្រីសង្ឃនិងមន្ត្រីស៊ីវិលជាន់ខ្ពស់ផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយតែលទ្ធផលនៅដើមខែកក្កដាវាបានធ្វើឱ្យចំណងជើង *ដាក់អាវុធចាប់យកព្រះធម៌* បានដើរទៅដល់គោលដៅដែលយើងបានដៅទុកមកហើយ ។ សិក្ខាសាលានេះមានរយៈពេលមួយសប្តាហ៍ពេញ ហើយខ្ញុំមិនចង់បានច្រើនលើសលប់ទេនូវជោគជ័យដែលយើងសំរេចបានតែ ខ្ញុំចង់បាននូវអ្វីដែលជាការបរាជ័យក្នុងការអនុវត្តការងារ ដើម្បីយកមកពិភាក្សាគ្នាឱ្យបានច្រើនក្នុងការរកដំណោះស្រាយ

www.budinst.gov.kh www.elibraryofcambodia.org

ថាតើអ្វីដែលយើងធ្វើមិនបានយើងគួររកផ្លូវធ្វើយ៉ាងណាដើម្បីសំរេចឱ្យបាន? មនុស្សគ្រប់រូប,អង្គការគ្រប់អង្គការធ្វើអ្វីតែងតែមានកំហុសជានិច្ចតែវាមិនជាបញ្ហាសំខាន់ទេ បញ្ហាសំខាន់គឺចេះកែប្រែកំហុសដោយសេចក្តីក្លាហានដោយមានគំនិតព្យាយាមដើម្បីកែប្រែនូវកំហុសនោះ ។ ដូច្នេះអ្វីដែលយើងធ្វើខុសគឺជាការដកពិសោធន៍ជាមេរៀនរបស់យើងដែលយើងត្រូវតែរៀន។ នេះជាអនាគតដ៏ល្អរបស់យើងជាមេរៀនដែលត្រូវតែខិតខំប្រឹងប្រែងរកឱ្យឃើញនូវអ្វីដែលយើងមិនអាចធ្វើបានដើម្បីជួយដល់អ្នកដទៃ។ នេះហើយជាន័យរបស់ពាក្យមុទិតា។ ដូច្នេះសិក្ខាសាលាលើកនេះយើងអាចនិយាយបានថាវាជាការដកពិសោធន៍រកចំណុចខ្លាំង ចំណុចខ្សោយ គុណសម្បត្តិ និងគុណវិបត្តិក្នុងការអនុវត្តការងាររបស់យើង ដែលត្រូវយកមកបង្ហាញគ្នា ផ្លាស់ប្តូរគ្នាក្នុងគោលបំណងរកនូវវិធីដោះស្រាយ នូវអ្វីដែលយើងមិនអាចធ្វើបានកន្លងមក ។ មូលនិធិរបស់យើងខ្ញុំគឺគាំទ្រនូវការផ្សព្វផ្សាយដើម្បីអប់រំចំណេះដឹងផ្នែកសីលធម៌, ចរិយាធម៌ ចំពោះប្រជាពលរដ្ឋគាំទ្រនូវការគោរពសិទ្ធិមនុស្ស និងគាំទ្រការបង្កើតឡើងនូវប្រទេសមួយដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ ដើម្បីឱ្យទៅជានិតិរដ្ឋ ។

ខ្ញុំព្រះករុណាសុំហើយសុំទៀត អង្វរហើយអង្វរទៀតសុំឱ្យសិក្ខាសាលានេះមានសកម្មភាពកើតឡើងជាបទពិសោធន៍,ជាសំណួរ ហើយសុំឱ្យមានការពិភាក្សាគ្នាឱ្យបានផុសផុល និង សុំកុំឱ្យមានគំនិតភ័យខ្លាចឱ្យសោះហើយបើមានសំណួរអ្វីឬមានចម្ងល់អ្វី សូមអញ្ជើញសួរភ្លាមកុំញញើតញញើមឱ្យសោះ គឺថាក្រោកឈរសួរភ្លាម ។

សូមអរព្រះគុណ និងសូមអរគុណ ។

www.budinst.gov.kh www.elibraryofcambodia.org

## សុន្ទរកថា ឯកឧត្តម អភិបាលខេត្តស្វាយរៀងក្នុងឱកាសបើក សិក្ខាសាលាជាតិលើកទី ៤ ស្តីអំពី ព្រះពុទ្ធសាសនានិងការអភិវឌ្ឍន៍សង្គមខ្មែរ

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ :

- ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីសក្ការៈ
- សូមគោរព លោក លោកស្រី តំណាងអង្គការជាតិអន្តរជាតិជាទីគោរព
- សូមគោរពលោក លោកស្រី ព្រមទាំងឧបាសក ឧបាសិកាតំណាងប្រតិភូតាមបណ្តាខេត្តទាំងអស់ ជាទីគោរព !

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំបាទ ក្នុងនាមអភិបាលខេត្ត មានសេចក្តីរំភើបរីករាយឥតឧបមារ ដោយបានទទួលនូវការអញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលាជាតិលើកទី ៤ ដ៏ឧត្តុង្គឧត្តម ដែលរៀបចំឡើងដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ និងបានការជួយឧបត្ថម្ភពីមូលនិធិខុនរ៉ាដ អាដិនណោវែរ ប្រទេសអាល្លឺម៉ង់ ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំព្រះករុណាសូមថ្លែងអំណរព្រះគុណនិងអរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងធម្មការនិងសាសនា អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ និងលោក ភីធ័រ ស្មៀរ តំណាងអចិន្ត្រៃយ៍នៃមូលនិធិខុនរ៉ាដ អាដិនណោវែរ ដែលបានផ្តល់កិត្តិយសដ៏ឧត្តុង្គឧត្តមដល់ខេត្តស្វាយរៀងយើងខ្ញុំនេះ ហើយបានសំរេចជ្រើសរើសកន្លែងនេះធ្វើសិក្ខាសាលាជាតិលើកទី ៤ ស្តីពី "ព្រះពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ " ហើយនេះជាលើកដំបូងបង្អស់សំរាប់សិក្ខាសាលាថ្នាក់ជាតិ ផ្នែកព្រះពុទ្ធសាសនានៅក្នុងខេត្តយើងខ្ញុំផងដែរ ។ សូមឆ្លៀតឱកាសនេះដែរ ខ្ញុំព្រះ

www.budinst.gov.kh www.elibraryofcambodia.org

ករុណាខ្ញុំបាទសូមស្វាគមន៍យ៉ាងកក់ក្តៅនិងស្មោះស្ម័គ្របំផុតចំពោះព្រះវត្តមាន និងវត្តមានរបស់ព្រះតេជគុណគ្រប់ព្រះអង្គ លោក លោកស្រី លោកតា លោកយាយ ចាស់ព្រឹទ្ធាចារ្យ តំណាងប្រតិភូទាំងអស់ សូមបាន សេចក្តីសុខ សេចក្តីចំរើនគ្រប់ប្រការនិងសំរេចបានដោយជោគជ័យក្នុងបេសកកម្មនៅលើ ទឹកដីនៃខេត្តស្វាយរៀងយើងខ្ញុំ ។

តាងនាមឱ្យថ្នាក់ដឹកនាំខេត្តមន្ត្រីរាជការគ្រប់ថ្នាក់ប្រជាពលរដ្ឋ ព្រះសង្ឃ ទូទាំងខេត្ត និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់សូមសំដែងនូវសេចក្តីគោរពនិងកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ ព្រះតេជគុណ អស់លោកតំណាងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ព្រះតេជគុណញ៉ែម គីមតេង នាយកអង្គការសន្តិសេនានិងសហការី លោក ភីធ័រ ស្បៀរ និងសហការីដែលបាន សហការរៀបចំសិក្ខាសាលាជាតិដ៏មានសារៈសំខាន់នេះ បានបង្ហាញឱ្យឃើញច្បាស់នូវការចូលរួមយ៉ាងសកម្មពីសហគមន៍ជាតិនិងសហគមអន្តរជាតិ ស្តីពី ព្រះពុទ្ធសាសនា និង ការអភិវឌ្ឍន៍សង្គមខ្មែរ ។

អង្គសិក្ខាសាលាទាំងមូលជាទីមេត្រី !

ជាការពិតប្រទេសកម្ពុជាគឺជាប្រទេសមួយ ដែលសកលលោកធ្លាប់បាន ទទួលស្គាល់ថាជាប្រទេសដែលសំបូរទៅដោយសម្បត្តិធម្មជាតិដ៏មានតំលៃឥតគណនានិងមានវប្បធម៌ដ៏ចំណាស់នៅអាស៊ី ។ ប៉ុន្តែជាការគួរឱ្យស្តាយនោះ គឺដោយសារការបែកបាក់សាមគ្គីផ្ទៃក្នុង នៃសង្គមជាតិខ្មែរប៉ុន្មានសតវត្សរ៍ចុង ក្រោយបន្ទាប់ពីសម័យមហានគរនោះមក សង្គមខ្មែរបានចាប់ផ្តើមចុះខ្សោយ បន្តិចម្តងៗ។ ឯប្រទេសជិតខាងវិញគេបានឆក់ឱកាសនេះដើម្បីសាបព្រោះនូវ មនោគមវិជ្ជានិងមហិច្ឆតាមកលើសង្គមខ្មែរទាំងមូល។

អាស្រ័យដោយទស្សនៈដែលបានពោលមកខាងលើនេះ ខ្ញុំព្រះករុណា-

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំយល់ឃើញថាសិក្ខាសាលាជាតិលើកទី៤ដែលរៀបចំឡើងនាពេលនេះគឺពិត ជាមានសារៈសំខាន់ណាស់ដែលអាចរកឃើញនូវ រូបមន្ត ដ៏មានប្រសិទ្ធិភាព ដែលជាបទពិសោធន៍ដ៏ល្អដើម្បីអនាគតក្នុងការផ្សារភ្ជាប់រវាង ព្រះពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ ។ ខ្ញុំព្រះករុណា ខ្ញុំសង្ឃឹមថាតាមរយៈសិក្ខាសាលាជាតិលើកនេះព្រះសង្ឃនិងបានពង្រីកថែមទៀតនូវតួនាទីនាំមុខក្នុងការដឹកនាំបំផុសចលនាប្រជាពលរដ្ឋឱ្យចូលរួមកសាងនិងអភិវឌ្ឍន៍នូវសង្គមជាតិមាតុភូមិជាទីស្នេហារបស់យើងពីមួយឆ្នាំ ទៅ មួយឆ្នាំឱ្យចេះតែរីកចំរើនល្អលាស់ទៅមុខឥតឈប់ឈរជាមិនខានឡើយ ។

ជាថ្មីម្តងទៀតខ្ញុំព្រះករុណា ខ្ញុំជំនួសមុខឱ្យប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តស្វាយរៀងសូមសំដែងនូវការដឹងគុណចំពោះប្រជាពលរដ្ឋ និងរដ្ឋាភិបាលអាល្លឺម៉ង់ដែលបានផ្តល់ជំនួយដ៏មានប្រសិទ្ធិភាព និង ទាន់ពេលវេលាក្នុងកិច្ចជួយសង្គ្រោះស្តារនិងអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ ។

សូមសំដែងនូវការដឹងគុណចំពោះ មូលនិធិ-ខុនរ៉ាដ-អាដិនណៅអែរ ជាពិសេសលោក ភីធ័រ ស្មៀរ មិត្តសំលាញ់ដ៏ល្អរបស់ខ្ញុំដែលជានិច្ចជាកាលតែងគាំទ្រដល់កម្មវិធីទ្រទ្រង់ព្រះពុទ្ធសាសនា និងកម្មវិធីអភិវឌ្ឍន៍ទាំងឡាយក្នុងខេត្តស្វាយរៀង ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំសូមប្រគេនពរ និងជូនពរប្រគេនព្រះតេជគុណគ្រប់ព្រះអង្គ ចំពោះឯកឧត្តម លោក លោកស្រី លោកតា លោកយាយ ចាស់ព្រឹទ្ធាចារ្យទាំងអស់ សូមប្រកបដោយពុទ្ធពរទាំង ៥ ប្រការ គឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ និងបដិភាណៈ កុំបីឃ្លៀង ឃ្លាតឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

## សន្ទរកថាព្រះតេជគុណ យស ហ៊ុត ក្នុងឱកាសបើកសិក្ខាសាលាជាតិលើកទី៤

សូមថ្វាយបង្គំ និងសូមចំរើនពរ !

ខ្ញុំព្រះករុណាបានស្តាប់សុន្ទរកថារបស់លោកកីធ័រ ស្សេរ និងលោកអភិបាលខេត្តក្នុងឱកាសសិក្ខាសាលាជាតិលើកទី ៤ នេះ ដែលមានចំណងជើងថា “ ការផ្លាស់ប្តូរបទពិសោធន៍ ដើម្បីអនាគតល្អ ” ។ ខ្ញុំព្រះករុណាចាប់អារម្មណ៍ចំពោះពាក្យនេះណាស់ ព្រោះបើនិយាយពីការផ្លាស់ប្តូរពាក្យនេះគេនិយមប្រើជាទូទៅហើយ សូម្បីតែអ្នកខាងលើៗឬខាងឧទ្ទេសបាយផ្សាយពត៌មានក៏ប្រើពាក្យនេះដែរ ។ តែខ្ញុំព្រះករុណាយល់ថាពាក្យដែលប្រើត្រូវច្រើនជាងគេគឺគេប្រើថា *ការប្តូរបទពិសោធន៍* មិនផ្លាស់ប្តូរទេពាក្យផ្លាស់ប្តូរវាមានន័យផ្សេងមួយទៀត ដូចពាក្យបាំងអង់គ្លេសក៏មានពាក្យពីរផ្សេងគ្នាដែរ ។ ពាក្យផ្លាស់និងពាក្យប្តូរនេះប្តូរគឺយើងប្តូរយោបល់គ្នា ប្តូរទស្សនៈគ្នាប្តូរគំនិតប្តូរបទពិសោធន៍ មិនមែនផ្លាស់ប្តូរទេ Exchange and Change ។ ប្តូរបទពិសោធន៍ដើម្បីអនាគតល្អទាញយកមេរៀនពីអតីត ដើម្បីបច្ចុប្បន្នធ្វើល្អនិងអនាគតធ្វើល្អ ហើយដើម្បីឱ្យ អនាគតល្អ ទាល់តែបច្ចុប្បន្នល្អ ទីនេះកាលវេលានេះទាល់តែអំពើល្អរបស់យើងដោយកាយវាចាចិត្តអំពើអ្វីក៏ដោយការងារអ្វីក៏ដោយគឺស្ថិតនៅក្នុងមេត្តា ករុណា បញ្ញា នៅក្នុងអលោភៈ អទោសៈ អមោហៈ ។ បានសេចក្តីថាអហឹង្សាក្នុងការងារដែលកំពុងធ្វើកំពុងគិត កំពុងនិយាយនោះទើបធានាបានអនាគតល្អគឺបច្ចុប្បន្ននេះឯងធានាអនាគត ហើយអតីតវាកន្លងទៅហើយវាជាមេរៀនរបស់យើង ហើយវាជាអ្នកបញ្ចេញផ្លែផ្កាបញ្ចេញផលបានមកជាអញ្ចឹង ។ ដែលហៅថាអតីតហៅថាបុព្វេហៅថាជាតិមុនគឺចាប់ពីមួយវិនាទីមួយខណៈដែលកន្លងទៅ ហើយដែល

www.budinst.gov.kh www.elibraryofcambodia.org

ហៅថាបច្ចុប្បន្ន គឺអ្វីៗដែលយើងកំពុងធ្វើ កំពុងគិត កំពុងតែនិយាយនេះឯង ហើយចាប់ពីមួយវិនាទី មួយខណៈ ខាងមុខ តទៅដល់មួយម៉ោង ល្ងាចនេះ ស្អែក ឆ្នាំមុខ ជាតិក្រោយ គឺចាប់ចូលទៅក្នុងអនាគត ចូលក្នុងលោកខាងមុខ បរលោកទាំងអស់ ។ ដូច្នេះបច្ចុប្បន្ន គឺមានន័យថាអ្វីៗដែល យើងកំពុងតែធ្វើ កំពុងតែគិត កំពុងតែនិយាយ អំពើរបស់យើង ដោយកាយវាចាចិត្ត កាយកម្ម វចីកម្ម មនោកម្ម ។ ហេតុនេះហើយ បានជាព្រះពុទ្ធសាសនាបង្រៀនឱ្យមានសម្មាសតិឱ្យរលឹកត្រូវ គឺរលឹកឱ្យទាន់ ដឹងខ្លួនទាន់ មានសតិសម្បជញ្ញៈជួយនៅក្នុងការងារដែលកំពុងតែធ្វើកំពុងគិតនេះ ។ ដូច្នេះមនុស្សជាម្ចាស់នៃការងារនៃអំពើរបស់ខ្លួនជាម្ចាស់នៃវាសនារបស់ខ្លួនជាម្ចាស់នៃអនាគតរបស់ខ្លួនពីព្រោះបច្ចុប្បន្នធានា។ មានតែកម្មវិធីនេះទេដែលមានប្រសិទ្ធិភាពដើម្បីអនាគតល្អគឺទាល់តែបច្ចុប្បន្ននេះខណៈនេះយើងធ្វើដោយសតិសម្បជញ្ញៈ ។ នរណាក៏ដោយនៅម្នាក់ឯងក៏ដោយដឹងខ្លួនទាន់ទាំងអស់ក្នុងអំពើរបស់ខ្លួន ។ នេះជាគោលដៅអប់រំបែបព្រះពុទ្ធសាសនាបណ្តុះបណ្តាលអភិវឌ្ឍន៍ខាងផ្លូវចិត្តដែលហៅថាភាវនា ។ រឿងនេះជាគន្លឹះជាឫសគល់នៃដំណោះស្រាយក៏ដូចជាឫសគល់នៃបញ្ហានៅក្នុងចិត្តរបស់យើង *មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា* ។ សុខ ទុក្ខ, ល្អ អាក្រក់, បុណ្យ បាប, ចំរើន វិនាស, សង្គ្រាម សន្តិភាព ទាំងអស់នេះគឺវានៅក្នុងចិត្តវាចាប់ផ្តើមពីក្នុងចិត្ត។អញ្ចឹងអភិវឌ្ឍន៍បែបព្រះពុទ្ធសាសនាគឺអភិវឌ្ឍន៍បែបកាយវាចាចិត្តនេះឯងហើយនេះជារឿងដែលយើងបាននិយាយគ្រប់សិក្ខាសាលា។ នៅក្នុងសង្គមមនុស្សវាមិនមែនជ្រុះមកពីលើមេឃទេ ហើយក៏គ្មាននរណាធ្វើឱ្យយើង បើយើងមិនបានចូលរួមធ្វើ ចូលរួមដឹង ចូលរួមយល់ ចូលរួមបដិបត្តិនោះ ។ ឧទាហរណ៍ជាក់ស្តែងនៅទូទាំងប្រទេសនៅលើសកលលោកទាល់តែមានការ

www.budinst.gov.kh www.elibraryofcambodia.org

ចូលរួមរបស់ប្រជាពលរដ្ឋការចូលរួមរបស់យើង ទើបធ្វើឱ្យសំរេចដល់គោលដៅដែលយើងចង់បាន។ នេះច្បាស់លាស់ណាស់ខ្ញុំព្រះករុណាគ្មានសង្ស័យទេ អ្វីទាំងអស់នៅក្នុងស្រុកយើងនេះដើម្បីកែ ដើម្បីតំរង់ លុះណាតែយើងទាំងអស់គ្នាចូលរួមហើយដើម្បីចូលរួមបានត្រូវតែដឹង ត្រូវតែយល់ព្រោះយើងចេះតែនិយាយថាឱ្យនាំគ្នាគោរពរដ្ឋធម្មនុញ្ញ គោរពច្បាប់ទាំងមេដឹកនាំតែងរំលឹកដែរថាឱ្យពលរដ្ឋយើងគោរពច្បាប់ មិនមែនតែយើងទេគឺទាំងអស់គ្នា ជាពិសេសបើយើងធ្វើមេគេយើងត្រូវគោរពជាគំរូព្រះសង្ឃក្តី គ្រហស្ថក្តីដើម្បីគោរពឱ្យបានល្អទាល់តែដឹងទាល់តែមើល ។ ចុះបើមិនដឹងថារដ្ឋធម្មនុញ្ញ ច្បាប់នោះយ៉ាងណាផង តើការគោរពយ៉ាងម៉េចកើតទៅ ?

អាត្មាមានសំណូមពរសូមមេត្តាគិតរឿននេះថាជារឿងសំខាន់ព្រោះកាលណាយើងធ្វើការងារជាមួយព្រះធម៌ រស់នៅជាមួយព្រះធម៌ វត្ត អារាម ព្រះសង្ឃជាគំរូជាក់ស្តែងក្នុងការងារក្នុងសំដីរបស់យើងនេះយើងអាចសំរេចបានជោគជ័យមានសេចក្តីសុខសប្បាយដោយសារយើងចេះគោរព ចេះប្រតិបត្តិទាំងអស់គ្នា ចូលរួមដឹង ឮ កសាង ស្មើ របៀតដល់តវ៉ា ទាមទារដោយអហឹង្សាក្នុងន័យ មេត្តា ករុណា និង បញ្ញាដោយគ្មានអគតិធម៌ដោយមិនលំអៀងដែលនៅជាកណ្តាលគឺនៅជាអព្យាក្រិត្យ ។ ពាក្យនេះអ្នកខ្លះស្តាប់មិនយល់ទេអាត្មាស្តាប់ឮច្រើនណាស់ហើយពាក្យថានៅជាអព្យាក្រិត្យគឺកុំធ្វើអ្វី ។ នេះខុសហើយព្រោះថានៅជាកណ្តាលគឺមិនលំអៀងមិនមានអគតិទាំង ៤ : ឆន្ទាគតិ, ទោសាគតិ, មោហាគតិ និងភយាគតិ ។ មិនលំអៀងគឺត្រូវតែធ្វើមិនមែននៅស្ងៀមដេក ទទូរភួយ រអ៊ូ អន់ចិត្ត ត្រូវគេរំលោភដោយអយុត្តិធម៌ហើយក្តៅក្រហាយតែម្នាក់ឯងគ្មានបានការអ្វីទេ គឺកាន់តែបាបថែមទៀតទេ។ ត្រូវតែធ្វើ ត្រូវតែដើរ ត្រូវក្រោកឡើង ហើយត្រូវបោះជំហានទៅមុខ ។

www.budinst.gov.kh www.elibraryofcambodia.org

ប៉ុន្តែត្រូវនៅជាកណ្តាលមិនលំអៀង ។ នេះជាពាក្យថានៅអព្យាក្រិត្យ ។ ខន្តី ក៏មិនមែននៅស្ងៀមដែរ។ អ្នកខ្លះបកស្រាយថានៅស្ងៀមខុសហើយតាមពិត ខន្តី មានន័យថា តស៊ូ អត់ធន់ ក្នុងការធ្វើការងារ ។

សូមអនុមោទនាសិក្ខាសាលាត្រឹមប៉ុណ្ណោះ ។

**លោក ឃឹ ធន់ នីប្រឹក្សាក្រសួង ធម្មការ សាសនា រាយការណ៍ ពីការខារកន្លងមកតាមសេចក្តីសំរេចចិត្តនៃ សិក្ខាសាលាជាតិលើកទី ៣**

- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ
- សូមគោរពឯកឧត្តម លោក លោកស្រី សមាជិក សមាជិកា នៃអង្គសិក្ខាសាលាជាទីស្នេហា

មុននឹងជំរាបជូននូវអ្វីដែលយើង នឹង ធ្វើសំរាប់ការវាយតំលៃលើសិក្ខាសាលាជាតិលើកទី ៣ យើងគួររំលឹកឡើងវិញអំពីដំណើរការនៃអង្គសិក្ខាសាលាពីដើមមកសិន។ ព្រឹកមិញនេះលោក ភីធរ ស្មៀវ បានរំលឹកខ្លះៗមកហើយថាអង្គសិក្ខាសាលាជាតិយើងនេះលើកទី១ធ្វើនៅភ្នំពេញក្នុងឆ្នាំ១៩៩៤ ហើយ ពេលនោះយើងបានជជែកគ្នាថាត្រូវកំណត់អំពីភារកិច្ចរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទឱ្យបានច្បាស់ក្នុងមួយឆ្នាំៗត្រូវមានភាពជាក់ស្តែង។

សិក្ខាសាលាជាតិលើកទី២កាលពីថ្ងៃទី ២១-២៥ វិច្ឆិកា១៩៩៥ យើងក៏បានចេញជាសេចក្តីថ្លែងការណ៍រួមមួយដែរ ។ បន្ទាប់មកទៀតសិក្ខាសាលាជាតិលើកទី៣ពីឆ្នាំទៅនេះថ្ងៃទី១៧-២១ធ្នូ ១៩៩៦ ធ្វើនៅបាត់ដំបងដែល

www.budinst.gov.kh www.elibraryofcambodia.org

ក៏យើងបានធ្វើជាសេចក្តីសំរេចចិត្តរួមមួយដែរហើយក្នុងនោះមានតំណាងគ្រប់ជាន់ថ្នាក់នៃអ្នកនយោបាយ អ្នកកាន់ព្រះពុទ្ធសាសនា និងអង្គការក្រៅរដ្ឋាភិបាលក៏បានអញ្ជើញមកចូលរួមផងដែរ។ សេចក្តីសំរេចនោះមានបំណងចង់ឱ្យអង្គសិក្ខាសាលារបស់យើង ផ្សព្វផ្សាយ និង ណែនាំអនុវត្តនៅក្នុងរង្វង់ក្របខ័ណ្ឌខេត្ត-ក្រុង ឧបាសក ឧបាសិកាចំណុះជើងវត្ត និង នៅក្នុងរង្វង់ក្រុមគ្រួសារនិមួយៗ។ ហេតុនេះបានជានៅពេលនេះយើងចង់ឱ្យសិក្ខាសាលាជាតិលើកទី ៤ មានអ្នកឡើងមករាយការណ៍ដើម្បីបូកសរុបនូវសកម្មភាពការងារដែលបានអនុវត្តជាក់ស្តែងកន្លងមកនៅទូទាំងប្រទេស ។ ប៉ុន្តែដោយហេតុថាសមាជិក សមាជិកាយើងមានគ្នាច្រើនរហូតដល់ទៅ១៦០នាក់ទាំងព្រះសង្ឃ និងគ្រហស្ថ ។ ដូច្នេះបើយើងឡើងមករាយការណ៍ទាំងអស់គ្នា យើងគ្មានពេលទេ ហេតុនេះទើបយើងបានរៀបចំចងក្រងជាក្រុមៗទៅតាមតំបន់ដោយចែកជា៤តំបន់ ហើយការបែងចែកនេះគឺយើងមិនបានប្រកាន់ថាតំបន់នេះនៅខាងជើងឬខាងត្បូងទេគឺបែងចែកទៅតាមភូមិសាស្ត្រទឹកដី និងធម្មជាតិដែលមានភាពប្រហាក់ប្រហែលគ្នា ហើយម្យ៉ាងទៀតដើម្បីឱ្យសមស្របទៅនឹងការរៀបចំកម្មវិធីនេះផង ។ សេចក្តីសំរេចចិត្តនេះមាន ÷

ដោយឆន្ទៈមុះមុតនិងមានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីអនុវត្តឱ្យបាននូវប្រការទាំងឡាយដូចខាងក្រោម ÷

១-អនុវត្តនិងផ្សព្វផ្សាយពន្យល់ណែនាំឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋខ្មែរនូវគោលការណ៍ដាក់អាវុធចាប់យកព្រះធម៌ ។ នេះជាខ្លឹមសារទី១ដែលសិក្ខាសាលាជាតិលើកទី៣ លើកយកជាគោលមកពិភាក្សាក្នុងពេលនោះ។ ក្នុងនោះដែរយើងបានជជែកគ្នាយ៉ាងច្រើនដោយមានទាំងកងកំលាំងទើបតែផ្តាច់ខ្លួនមកពីម៉ាឡៃចូលរួមផង។ ការដាក់អាវុធនេះមិនមែនសំដៅលើ

www.budinst.gov.kh www.elibraryofcambodia.org

តែការដាក់អាវុធយុទ្ធភ័ណ្ឌនោះទេគឺសំដៅយកអាវុធដែលមាននៅក្នុងចិត្តក្នុងបេះដូងរបស់យើងឱ្យដាក់មុនគេ ។

២ -គឺអង្គសិក្ខាសាលាទាំងមូលសូមអំពាវនាវដល់គ្រប់ អ្នកនយោបាយកងកំលាំងប្រដាប់អាវុធ និង ប្រជាពលរដ្ឋទាំងអស់ មេត្តាដាក់អាវុធហើយចាប់យកព្រះធម៌ ដោយព្យាយាមដោះស្រាយទំនាស់ដោយសន្តិវិធី និងដោយការយោគយល់គ្នា និង អធ្យាស្រ័យគ្នាទៅវិញទៅមក ។ ចំណុចនេះសមាជិកអង្គសិក្ខាសាលាជាតិបានរួមគំនិតគ្នាទាំងព្រះសង្ឃ ទាំងគ្រហស្ថប្ដេជ្ញាចិត្តធ្វើការអំពាវនាវឱ្យគេដាក់អាវុធចុះ ហើយផ្សះផ្សាគ្នាដោយសន្តិវិធី និងដោយការយោគយល់គ្នា និងអធ្យាស្រ័យគ្នា ។ តើសកម្មភាពនេះ យើងធ្វើបានប៉ុន្មាន ? ធ្វើបាន ឬ មិនបាន ? ចំណុចខ្លាំង និង ចំណុចខ្សោយ ? សុំឱ្យតំណាងក្រុមនិមួយៗលើកយកមកបញ្ជាក់ ។

៣ -សូមឱ្យព្រះសង្ឃ លោកអាចារ្យ និងដូនជី បង្កើនចំណេះដឹងខ្លួនឯងទាំងខាងពុទ្ធចក្រនិងអាណាចក្រនិងប្រព្រឹត្តខ្លួនជាជនគំរូដើម្បីបំពេញតួនាទីប្រោសសត្វតាមផ្ទះដោយនិមន្តសាកសួរសុខទុក្ខ និង ផ្ដល់ឱវាទដល់ពុទ្ធបរិស័ទតាមផ្ទះឱ្យបានជាប្រចាំដើម្បីពង្រឹងសីលធម៌ព្រះពុទ្ធសាសនា និង កាត់បន្ថយនូវភាពហិង្សាក្នុងក្រុមគ្រួសារ ។ ចំណុចនេះគឺបណ្ដុះសន្តិភាពពីក្នុងរង្វង់គ្រួសារឡើងទៅដោយពឹងលើព្រះសង្ឃ អាចារ្យ និងដូនជី ឱ្យជួយចុះទៅណែនាំចុះទៅបណ្ដុះពូជនៃអំពើអហិង្សាតាមគ្រួសារ ។ សូមបញ្ជាក់ផងដែរថា តើព្រះសង្ឃបានចុះទៅសាកសួរសុខទុក្ខដល់ក្រុមគ្រួសារដែរឬទេ ? ហើយតើវត្តនិមួយៗខេត្តនិមួយៗមានគោលការណ៍ផ្សព្វផ្សាយដែរ ឬមិនទាន់មាន ? បើមានធ្វើហើយ តើលទ្ធផលយ៉ាងណាដែរ ?

www.budinst.gov.kh www.elibraryofcambodia.org

៤ - សូមឱ្យព្រះសង្ឃព្យាយាមទាក់ទងសាលារៀនដែលនៅជិត ឬនៅក្នុងវត្តដើម្បីអប់រំយុវសិស្សនៅរាល់ថ្ងៃសីលឬក្នុងឱកាសបុណ្យជាតិ អន្តរជាតិនិងបុណ្យព្រះពុទ្ធសាសនាផ្សេងៗ ។ ចំណុចនេះយើងបាននិយាយគ្នាច្រើនក្នុងសិក្ខាសាលាព្រោះបើគេមិនមកជិតវត្តមិនចូលវត្តសុំឱ្យព្រះសង្ឃចេញទៅក្រៅវត្តគឺចេញពីវត្តទៅកាន់សាលាដែលព្រះសង្ឃបានកសាងហើយធ្វើមុនគេ ។

៥ - គឺបន្តអនុវត្តឱ្យកាន់តែប្រសើរឡើងនូវសេចក្តីសំរេចចិត្តរបស់អង្គសិក្ខាសាលាជាតិលើកទី ២ ដែលមាន ៥ ចំណុចដែរ គឺ ÷

ក- សូមឱ្យព្រះសង្ឃ ដូនជី និងអាចារ្យលើកស្ទួយពុទ្ធបរិស័ទដែលមានជីវភាពក្រីក្រជុំវិញវត្ត ឱ្យមានគុណភាពទាំងសម្ភារៈ និងសីលធម៌ ។

ខ- ព្រះសង្ឃ ដូនជី និងអាចារ្យសូមជួយដឹកនាំពុទ្ធបរិស័ទឱ្យរួមគ្នាជួយការពារព្រៃឈើ និងដាំដើមឈើតាមផ្ទះ យ៉ាងតិចម្នាក់ៗឱ្យបាន ៣ ដើម ហើយគ្រប់វត្តទូទាំងប្រទេសត្រូវបង្កើតសួនបណ្តុះកូនឈើ និង ដាំដើមឈើដែលបំរុងបាត់ពូជនិងឈើគ្រប់មុខដែលមានប្រយោជន៍សំរាប់ហូបផ្លែ ឱសថ ផ្កា យ៉ាងតិចឱ្យបាន ៣០ដើមក្នុងមួយវត្តៗ ។

គ- សុំឱ្យដាក់បញ្ចូលកម្មវិធីសីលធម៌ព្រះពុទ្ធសាសនាទៅក្នុងកម្មវិធីសិក្សា ។

ឃ-គ្រប់វត្តត្រូវបង្កើតកម្មវិធីបង្រៀន សីល៥ ចំពោះពុទ្ធបរិស័ទចំណុះជើងវត្ត ។

ង- សូមជួយបង្កលក្ខណៈឱ្យដូនជីរៀនអក្សរឱ្យបានជ្រៅជ្រះ។

នេះជាសេចក្តីសំរេចចិត្តដែលយើងបានលើកឡើង ដើម្បីយកមកអនុវត្តក្នុងរយៈពេល១ឆ្នាំចាប់ពីខែមករាហូតមកដល់ពេលនេះហើយអ្នកឡើងរាយការណ៍សុំរាយការណ៍ក្នុ ១០ ចំណុចនេះតែយើងអាចផ្តុំមកនៅតែត្រឹមពីរបី

www.budinst.gov.kh www.elibraryofcambodia.org

ចំណុចវិញបាន គឺ:

១-ផ្នែកអប់រំសីលធម៌ដោយគិតទាំងរឿងហិង្សា,រឿងដាក់អាវុធជាដើម ផងហើយសកម្មភាពគឺមាននៅក្នុងវត្ត( បុណ្យទាន, ថ្ងៃសីល )និង ក្រៅវត្តដោយនិមន្តទៅធ្វើបុណ្យតាមគ្រួសារនិងតាមសាលារៀន ។

២-ការដាំដើមឈើនៅក្នុងវត្តដែលមានច្រើនប្រភេទបានប៉ុន្មានដើម ? ហើយចែកចាយឱ្យប្រជាពលរដ្ឋបានប៉ុន្មានដើម ? និងមូលហេតុ ដែលដាំមិនកើត ។

ដូច្នេះរឿងធំគឺមានតែពីរនេះទេ។ ឯរឿងលើកកំពស់ជីវភាពប្រជាពលរដ្ឋរឿងសង្គមកិច្ចមានរឿងធនាគារស្រូវ, ធនាគារប្រាក់ សមាគមទ្រទ្រង់វត្ត និងការជួយឧបត្ថម្ភទៅវិញទៅមក នេះជាចំណុចទី២ដែលត្រូវលើកយកមក បញ្ជាក់ថាតើសកម្មភាពនេះបានរីកសុះសាយនៅកន្លែងណា ។ តែសកម្មភាព នេះវាមិនទំលំទូលាយដូចសកម្មភាពពីរខាងលើទេ ព្រោះសកម្មភាពពីរខាង លើវាទូលំទូលាយហើយប៉ះពាល់ដល់គ្រប់វត្តតាមខេត្ត ។ ឯសកម្មភាពជួយ អ្នកក្រីក្រគឺមានតែខេត្តខ្លះៗទេដូចជាខេត្តកំពង់ធំ,កណ្តាល,កំពត, ស្វាយរៀង បាត់ដំបង, បន្ទាយមានជ័យ និងខេត្តពោធិសាត់ដែលមានខ្លះដែរតែមិនដឹងថា សព្វថ្ងៃនៅមានបន្តឬយ៉ាងណាទេ។

www.budinst.gov.kh www.elibraryofcambodia.org

**លោក ឆេព ធន់ នាយកមន្ទីរធម្មការខេត្តស្វាយរៀង តំណាងខេត្ត កំពង់ចាម, ព្រៃវែង, ក្រចេះ និង ស្វាយរៀងឡើងរាយការណ៍**

អង្គសិក្ខាសាលាជាទីគោរព តាងនាមខ្ញុំព្រះករុណាខ្ញុំតំណាងឱ្យ ខេត្តកំពង់ចាម, ក្រចេះ, ព្រៃវែង និងខេត្តស្វាយរៀង សូមធ្វើរបាយការណ៍ជូនអង្គសិក្ខាសាលាអំពីសកម្មភាពជាក់ស្តែង និងលទ្ធផលដែលបានសំរេចដូចខាងក្រោមនេះ ÷

ការអនុវត្តនូវសេចក្តីសំរេចចិត្តនៃអង្គសិក្ខាសាលាជាតិលើកទី២ សង្កត់ធ្ងន់ទៅលើការជួយដល់ប្រជាពលរដ្ឋក្រីក្រដែលរស់នៅជុំវិញវត្ត ដើម្បីលើកស្ទួយជីវភាព។ ជាពិសេសសង្កត់ធ្ងន់ទៅលើការបណ្តុះកូនឈើ។ ការបណ្តុះកូនឈើនេះគឺជាផែនការរបស់សិក្ខាសាលាជាតិ ដែលបានតំរូវឱ្យវត្តនិមួយៗដាំកូនឈើឱ្យបាន៣០ដើមនិងឱ្យមានថ្នាលបណ្តុះកូនឈើ។ ផែនការនេះខេត្តរបស់ ខ្ញុំព្រះករុណា ខ្ញុំបានអនុវតគ្រប់តាមផែនការរហូតមានវតខ្លះធ្វើលើសផែនការទៀតផងដូចជាព្រះតេជគុណញ៉ែម គឹមគេង ព្រះអង្គបានដាំកូនឈើបាន៦០០ហិកតានិងមានថ្នាលបណ្តុះកូនឈើយ៉ាងធំមួយនៅស្រុកចន្ទ្រាហើយប្រតិភូសិក្ខាសាលាជាតិលើកនេះប្រហែលជាបានទៅធ្វើទស្សនកិច្ចទៀតផង ។ ដោយឡែកនៅខេត្តក្រចេះលោកថា ព្រៃឈើនៅខេត្តលោកសំបូរណាស់ តែលោកនៅតែដាំនិងបណ្តុះនៅតាមវត្តតទៅទៀត ។

ឯចលនាជីកស្រះវិញខេត្តខ្ញុំព្រះករុណាបានជីកយ៉ាងគគ្រឹកគគ្រេងតាំងពីឆ្នាំ១៩៩៥បានចំនួន៨៧ស្រះដោយមានទំហំ៥០ម X ៥០ម ជំរៅ៣ម ។ ជាពិសេសនៅ វត្តល្ងើន ដែលមានលោកអភិបាលខេត្តសរសើរព្រោះនៅជុំវិញស្រះមានដាំកូនឈើគ្រប់ប្រភេទដែលធ្វើឱ្យស្រះមាន សោភ័ណភាពយ៉ាង

www.budinst.gov.kh www.elibraryofcambodia.org

ស្រស់បំព្រង។ ចលនាមួយទៀតគឺចលនាលើកផ្លូវលំ។ ចលនានេះមានសកម្មភាពខ្លាំងក្លាណាស់ដោយសុំឱ្យវត្តនិមួយៗលើកផ្លូវឱ្យបាន២គីឡូម៉ែត្រ ។

តាមការអនុវត្តនូវខ្លឹមសាររបស់សិក្ខាសាលាជាតិលើកទី ៣ លើប្រធានបទថាដាក់អាវុធ ចាប់យកព្រះធម៌នេះខ្ញុំព្រះករុណាបានសុំយោបល់ពីលោកអភិបាលខេត្តដើម្បីចុះតាមបណ្តាស្រុកធ្វើការផ្សព្វផ្សាយប្រគេន ជូនលោកអាចារ្យនិងគណៈកម្មការវត្ត ។ ក្នុងចលនា ដាក់អាវុធ ចាប់យកព្រះធម៌នេះខ្ញុំព្រះករុណាបានធ្វើការផ្សព្វផ្សាយចូលជ្រៅទៅក្នុងជួរព្រះសង្ឃ អាចារ្យ ឧបាសក ឧបាសិកាដោយយើងបានបញ្ចូលកម្មវិធីនេះទៅក្នុងការទេសនាតាមរយៈការធ្វើបុណ្យទានផ្សេងៗតែមិនបានផ្សព្វផ្សាយចូលទៅក្នុងជួរមន្ត្រីរាជការនិងកងកំលាំងប្រដាប់អាវុធទេ ។ ចំណែកខាង ខេត្តក្រចេះ កំពង់ចាម និងព្រៃវែង ចលនាផ្សព្វផ្សាយនូវសេចក្តីសំរេចចិត្តលើកទី ៣ នេះក៏មានសកម្មភាពប្រហាក់ប្រហែលគ្នានិងខេត្តស្វាយរៀងដែរ ។

សកម្មភាពធ្វើធនាគារស្រូវវិញ ក្នុងខេត្តខ្ញុំព្រះករុណាមានវត្តមួយចំនួនបានធ្វើដោយបានទទួលដើមទុនពីអង្គការក្រៅរដ្ឋាភិបាលដូចជា : វត្តស្វាយធំ, វត្តសំពោងពេជ្រ, វត្តឈើទាល, វត្តអំពិល, វត្តពោធិធំ, វត្ត ចន្ទ្រី និងវត្តសំបួរ ។ សកម្មភាពកន្លងមកឃើញថាធនាគារស្រូវនេះមានជិត១០វត្តហើយ ។ ចំពោះខេត្តព្រៃវែង, ក្រចេះ, និង កំពង់ចាម បើតាមការទទួលរបាយការណ៍ ឃើញថាមានសកម្មភាពប្រហាក់ប្រហែលគ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

**លោក ពុធ ខូច នាយកមន្ទីរធម្មការខេត្តតាកែវ តំណាង ខេត្តកណ្តាល, កំពង់ស្ពឺ, ក្រុងព្រះសីហនុ និង ខេត្តកំពត ឡើងរាយការណ៍**

ថ្ងៃនេះខ្ញុំព្រះករុណា ខ្ញុំបាទមានកិត្តិយសក្រៃលែងដោយបានឡើងមកធ្វើរបាយការណ៍ជូនអង្គសិក្ខាសាលាជាតិលើកទី៤ ។ ខ្ញុំព្រះករុណាសូមលើកយករបាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារជាក់ស្តែងតាមសេចក្តីសំរេចចិត្តរបស់សិក្ខាសាលាជាតិលើកទី ២ ទី៣ មានដូចតទៅនេះ ÷

នៅក្នុងសិក្ខាសាលាជាតិលើកទី៣សង្កត់ធ្ងន់ទៅលើប្រធានបទថា ដាក់អាវុធ ចាប់យកព្រះធម៌ ។ ដូច្នេះនៅក្នុងប្រធានបទនេះខេត្តទាំង៣ក្នុងភូមិភាគ ខ្ញុំព្រះករុណាបានយកទៅធ្វើការផ្សព្វផ្សាយតាមបណ្តាមូលដ្ឋាននិមួយៗដោយចែកចេញជា៣ជំហានទៅតាមអនុសំវច្ឆរៈលើកទី៦ ។ ឯលទ្ធផលនៃការផ្សព្វផ្សាយមានអ្នកចូលរួមចំនួន ៣៧៧៧៦រូប ក្នុងនោះមានព្រះសង្ឃចំនួន ៧,១៥០អង្គ ÷

- ខេត្តកណ្តាល = ១០,២២៤នាក់; ព្រះសង្ឃ = ២,៨៦៤អង្គ
- ខេត្តកំពត = ៧,៨៦១នាក់; ព្រះសង្ឃ = ១,០៥០អង្គ
- ខេត្តកំពង់ស្ពឺ= ៥៧៤នាក់; ព្រះសង្ឃ = ១២០អង្គ
- ក្រុងព្រះសីហនុ = ២៥៤នាក់ ; ព្រះសង្ឃ = ៥០អង្គ

ចំណុចមួយទៀត គឺការចុះសួរសុខទុក្ខ ជាទូទៅព្រះសង្ឃ អាចារ្យដូនជី តែងតែយកព្រះទ័យទុកដាក់ជាប្រចាំក្នុងការចូលរួមជាមួយមូលដ្ឋានដើម្បីពង្រឹងដល់ពុទ្ធបរិស័ទឱ្យស្ងប់រំងាប់តាមផ្លូវចិត្ត តាមរយៈការទេសនាក្តីនិងតាមពិធីបុណ្យទានផ្សេងៗក្តី ក្នុងគោលបំណងកាត់បន្ថយនូវភាពហឹង្សាក្នុងសង្គម។ បញ្ហាឱ្យព្រះសង្ឃបង្រៀនតាមសាលា ។ បញ្ហានេះមន្ទីរធម្មការ

www.budinst.gov.kh www.elibraryofcambodia.org

មិនអាចយកកម្មវិធីនេះដាក់ចូលទៅក្នុងកម្មវិធីសិក្សាបានទេ ទាល់តែក្រសួងធម្មការមានទំនាក់ទំនងជាមួយក្រសួងអប់រំយុវជន និង កីឡា ។

បញ្ហាឱ្យសិស្សសូត្របទ នមស្សការ ឬសុំសីល ៥ មុនចូលរៀនយោងតាមសំណូមពររបស់សិក្ខាសាលាជាតិលើកទី៣នោះយើងមិនទាន់បានធ្វើនៅឡើយទេ ។

ការដាំដើមឈើនៅក្នុងខេត្តទាំង៥នេះបានចែកជា៣ប្រភេទ:
ឈើសំណង់, ឈើហូបផ្លែ និងឈើធ្វើអុស ។ សរុបការដាំដើមឈើទាំង៥ខេត្តនេះបានចំនួន ១,៤៤១,៦៥០ដើម ក្នុងនោះមាន ÷

- ខេត្តកណ្ដាល = ៥៦៨,០៧០ដើម
- ខេត្តតាកែវ = ៣២១,០៨០ដើម
- ខេត្តកំពង់ស្ពឺ = ៤០១,០០០ដើម
- ខេត្តកំពត = ១២០,០០០ដើម
- ក្រុងព្រះសីហនុ = ៦,៥០០ដើម

ដោយឡែកនៅខេត្តកំពត ព្រះសង្ឃដាំដើមឈើបាន ១៨០ហិកតា។

សំណូមពរ :

បើសិនជាមានរៀបចំសិក្ខាសាលាជាតិលើកក្រោយគួរចាត់ឱ្យមានគណៈកម្មការមួយដើម្បីងាយស្រួលក្នុងការបូកសរុបរបាយការណ៍ និង ងាយស្រួលក្នុងការរាយការណ៍ជូនអង្គសិក្ខាសាលាឬក៏អាចជួយបំពេញបន្ថែមនូវការអនុវត្តដែលមិនបានធ្វើ ។

www.budinst.gov.kh www.elibraryofcambodia.org

## លោក គឹម សួ នាយកធម្មការខេត្តកំពង់ធំ តំណាងឱ្យ ខេត្ត បន្ទាយមានជ័យ, ខេត្តកំពង់ធំ, ខេត្តសៀមរាបឡើងរាយការណ៍

សកម្មភាពដែលខេត្តទាំង៣បានអនុវត្តកន្លងមកមានដូចខាងក្រោមនេះ÷

លទ្ធផលដែលយើងចុះគ្រប់ស្រុក គ្រប់វត្ត ព្រះសង្ឃ អាចារ្យ ដូនជី ពុទ្ធបរិស័ទ បានយល់ច្បាស់អំពីភាពហឹង្សា និងភាពអហឹង្សានេះ ហើយភាគច្រើនគេចង់បានតែសន្តិភាពទេ ។ ហេតុនេះខ្លឹមសារនៃអង្គសិក្ខាសាលាជាតិលើកទី ៣ បានធ្វើឱ្យព្រះសង្ឃ អាចារ្យ ដូនជីពេញចិត្តគេណាស់ហើយពួកគេនាំគ្នាអនុវត្តទៅតាមព្រះធម៌របស់ព្រះពុទ្ធ ពោលគឺ សីល ៥ ហើយបំបាត់នូវលោភៈ, ទោសៈ និងមោហៈ ។

បញ្ហាមួយទៀតគឺខេត្តទាំង៣បានរៀបចំបើកសិក្ខាសាលាដូនជីដោយបាននិមន្តចៅអធិការវត្ត, គណៈកម្មការ និងអាចារ្យ ដើម្បីផ្សព្វផ្សាយនូវសមាធិវិបស្សនា និង បានលើកឡើងពីខ្លឹមសាររបស់សិក្ខាសាលាជាតិលើកទី ៣ គឺដាក់អាវុធ ចាប់យកព្រះធម៌ ។ ក្រោយពីបានធ្វើសិក្ខាសាលានេះរួចមក មន្ទីរធម្មការបានចេញលិខិតទទួលស្គាល់ ហើយបែងចែកដូនជីឱ្យចុះបើកវត្តតាមបណ្តាស្រុកទូទាំងខេត្តទៀតផង ។

បញ្ហាសូត្រធម៌ នមស្សការ មុនពេលចូលរៀនមន្ទីរធម្មការនិងមន្ទីរអប់រំខេត្តបានពិភាក្សាគ្នាហើយហើយក៏បានប្រជុំជាមួយអនុគណគ្រប់ស្រុកផងដែរ តែវានៅមិនទាន់បានអនុវត្តបានល្អតែប៉ុណ្ណោះ ។

ការដាំដើមឈើគឺមានចលនាសកម្មនិងផុសផុលល្អណាស់ដោយបានឯកភាពជាមួយលោកអភិបាលខេត្ត និងមន្ទីរកសិកម្មខេត្តបណ្តុះកូនឈើចែកជូនអ្នកស្រុក ។ ឧទាហរណ៍ : វត្តខ្លះបានដាំដល់ទៅ២,០០០ដើមជាក់ស្តែងវត្ត

www.budinst.gov.kh www.elibraryofcambodia.org

សានគរហើយថ្មីៗនេះមានយកកូនគគីរទៅដាំបន្ថែមចំនួន១,០០០ដើមទៀត។ ក្រៅពីនេះមានវត្ត២ទៀតដែលលេចធ្លោជាងគេគឺវត្តវិហារ និង វត្តកំភ្លោត ដោយថ្មីៗនេះអាចារ្យគណៈកម្មការបានសហការជាមួយមេភូមិនៅវត្តវិហារ បានសុំដីពីរដ្ឋអំណាចបាន ២០០ ហិកតា ហើយកំពុងចាប់ដំណើរការដាំ និងថែរក្សាឈើដែលមាន និង កំពុងធ្វើថ្នាលបណ្តុះបន្ថែម ។

បញ្ហាជួយដល់ពុទ្ធបរិស័ទក្រីក្រគឺការកាត់បន្ថយនូវភាពក្រីក្របន្ទាប់ពីបានសិក្សាពីសិក្ខាសាលាជាតិលើក ទី២ ទី៣រួចមកខេត្តកំពង់ធំបានរៀបចំស្នើរតែគ្រប់វត្តឱ្យមានជង្រុកស្រូវដើម្បីជួយដល់ពុទ្ធបរិស័ទដែលក្រីក្រខ្វះពូជជាដើម ព្រោះរៀងរាល់ឆ្នាំព្រះអង្គតែងតែធ្វើបុណ្យពូនភ្នំស្រូវ និងដើរបិណ្ឌបាត្រស្រូវតាមភូមិជាដើម។ តែប្រការមួយដែលគួរឱ្យបារម្ភគឺពេលដែលបិណ្ឌបាត្រស្រូវបានហើយមិនបានទុកដាក់ឱ្យបានហ្មត់ចត់ទេ។ តែការបង្កើតធនាគារស្រូវនេះមានសកម្មភាពផុសផុលណាស់ដោយមានអង្គការ GTZ ជួយឧបត្ថម្ភហើយរហូតមកដល់សព្វថ្ងៃនេះយើងមានធនាគារស្រូវចំនួន២៩កន្លែងហើយ ។

ការបង្កើតសមាគមប្រាក់តាមវត្ត។ សព្វថ្ងៃនេះមានវត្តចំនួន១០(ក្នុងខេត្តកំពង់ធំ) និងមាន ២២ សមាគមហើយដែលមានការជួយឧបត្ថម្ភឥណទានពីអង្គការ GTZ ។ ថ្មីៗនេះព្រះបាទសម្តេចព្រះនរោត្តមសីហនុបានឧបត្ថម្ភទឹកប្រាក់ចំនួន២,០០០ដុល្លារអាមេរិក ។ សមាគមប្រាក់នេះគឺសំរាប់ឱ្យប្រជាពលរដ្ឋក្រីក្រខ្ចីដោយយកការថោកគឺ ២ទៅ៣ភាគរយបានន័យថាពុទ្ធបរិស័ទជួយវត្ត វត្តជួយពុទ្ធបរិស័ទវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

## លោក អ៊ុង ពិសិដ្ឋ នាយករងមន្ទីរធម្មការខេត្តកំពង់ឆ្នាំង តំណាងឱ្យ ខេត្ត បាត់ដំបង និង ពោធិសាត់ ឡើងរាយការណ៍

ក្នុងការអនុវត្តនូវសេចក្តីសំរេចចិត្តលើកទី៣ស្តីពីប្រធានបទថា ដាក់អាវុធ ចាប់យកព្រះធម៌គឺយើងគ្មានផ្លូវណាក្រៅពីគណបក្សព្រះពុទ្ធសាសនាទេ ព្រោះក្រៅពីគណបក្សនេះមិនមានគណបក្សណាធ្វើបានទេ។ ម្យ៉ាងទៀតសៀវភៅព្រះបាទធម្មិកនិងសៀវភៅសីល៥ដែលបានបោះពុម្ពចេញហើយនោះវាជាជំហានថ្មីមួយដែលនាំឱ្យមានការបំបាត់នូវភាពហឹង្សាចោល ។

ព្រះអង្គមេគណខេត្តកំពង់ឆ្នាំងកំពុងសន្ទនាធម្មសាកច្ឆារៀងរាល់ថ្ងៃសីល និយាយអំពីធម៌ហឹង្សាដើម្បីឱ្យពុទ្ធបរិស័ទយល់ដឹងពីបញ្ហានេះ ហើយទំហំនេះវានិងកាន់តែរីកធំឡើងៗជាមិនខាន ។

ដោយឡែកនៅខេត្តពោធិសាត់វត្តដែលផាំនិងបណ្តុះបានច្រើនជាងគេគឺវត្តពោធិសង្គ្រោះដែលជាវត្តរបស់ព្រះអង្គមេគណហើយវត្តព្រៃខ្លុងឃើញថាមានសន្ទុះខ្លាំងជាងគេវត្តពន្លៃមានរថយន្តមួយគ្រឿងសំរាប់ជួយដឹកនាំអ្នកជម្ងឺទៅព្យាបាលនៅមន្ទីរពេទ្យនិងដឹកកូនឈើទៅចែកចាយឱ្យអ្នកស្រុកដាំផង ។

ការលំបាក

- បញ្ហាពុទ្ធបរិស័ទមានការយល់ដឹងតិចនូវសីលធម៌
- ការដឹកនាំរបស់មន្ត្រីសង្ឃ មិនទាន់ទូលំទូលាយ និងមិនទាន់យល់ពីតួនាទី និងភារៈកិច្ចឱ្យបានច្បាស់លាស់ ។

សំណូមពរ

- សូមឱ្យក្រសួងជួយផ្តល់សៀវភៅគហិប្រតិបត្តិសំរាប់គ្រូ ៕

www.budinst.gov.kh www.elibraryofcambodia.org

## ចំណាប់អារម្មណ៍ព្រះតេជគុណ យឿន យឿត លើរបាយការណ៍

- តាមអាត្មាស្តាប់ទៅ ដូចជានៅខ្វះគ្រង់យុវជនសីលធម៌ ព្រោះទូទាំងខេត្ត បានបង្កើតយុវជនសីលធម៌រួចហើយ ដោយឱ្យឈ្មោះថា *យុវជនសក្យបុត្រ ដើម្បីអនាគតកូនខ្មែរល្អ* ។ យើងបង្កើតយុវជនសីលធម៌នេះដោយមានធនាគារសន្សំប្រាក់យុវជន ដើម្បីឱ្យពួកគេចេះបន្ថយការចំណាយហើយទុកសំរាប់តែពេលដែលពួកគេត្រូវការចាំបាច់ក្នុងការទិញសម្ភារៈសិក្សាដោយមិនពិបាកឱ្យគេទៅសុំឪពុកម្តាយរបស់គេសមដូចសុភាសិតមួយថែងថា: *អត្តាហិ អត្តនោ នាថោ* ដើម្បីឱ្យក្មេងចេះពឹងខ្លួនដោយខ្លួនឯង ។

## តួនាទីរបស់ព្រះសង្ឃក្នុងសង្គមបច្ចុប្បន្ន

ដោយ លោក យី ធន់

តួនាទីព្រះសង្ឃ - ដូនជី - ពុទ្ធបរិស័ទនៅក្នុងការអភិវឌ្ឍន៍សង្គមខ្មែរ

សូមព្រះតេជគុណគ្រប់ព្រះអង្គសមាជិក សមាជិកាអង្គសិក្ខាសាលាជាតិទាំងមូល កំណត់ឱ្យបានច្បាស់លាស់អំពីតួនាទី និង ភារកិច្ច ។ តែពេលនេះខ្ញុំព្រះករុណាមិនបានជំរាបជូនអំពីភារកិច្ចទេ គឺសូមជំរាបជូនអំពី តួនាទី ។ តួនាទីនិងភារកិច្ចគឺវាខុសគ្នា ហើយខ្ញុំព្រះករុណាមិនមែនទំលាក់ការងារនេះប្រគេនព្រះសង្ឃឱ្យធ្វើទាំងអស់ទេតែព្រះអង្គមានតួនាទីធ្វើ ។ ភារកិច្ចទាំងឡាយដែលគេពឹងដូចព្រះអង្គពឹងពុទ្ធបរិស័ទគឺអ្នកដែលដើរតាមព្រះពុទ្ធដើម្បីធ្វើសកម្មភាព ។ ភារកិច្ចដែលមានប្រយោជន៍ដល់សង្គមហើយតួនាទីនេះច្រើនជាតួនាទីរបស់ព្រះសង្ឃ ។ ដោយពេលវេលាខ្លីខ្ញុំព្រះករុណាមិនអាច

www.budinst.gov.kh www.elibraryofcambodia.org

ប្រគេននិងជំរាបជូនឱ្យបានក្បោះក្បាយព្រោះរឿងនេះវៀនដល់ទៅ៤-៥ឆ្នាំឯណោះទើបបានចប់ ។ តែពេលនេះខ្ញុំព្រះករុណាសុំលើកយកតួនាទី ២-៣ មកប្រគេនជូន ។ ឯកឧត្តមអភិបាលខេត្តបានមានប្រសាសន៍ពីព្រឹកមិញហើយថាព្រះសង្ឃមានតួនាទីសំខាន់ណាស់ក្នុងការកសាងសង្គម ។ បច្ចុប្បន្នព្រះសង្ឃគឺជាកង់ម្ខាងនៃអាណាចក្រ ហើយកង់ទាំងពីរនេះត្រូវមាំដូចគ្នានិងត្រូវវិលទន្ទឹមគ្នាដើម្បីឱ្យយន្តរបស់យើងរត់ទៅមុខបានព្រោះយើងមិនអាចខ្វះបានទេ។ ហេតុនេះដើម្បីមើលឱ្យឃើញច្បាស់ពីសង្គមខ្មែរដែលធ្លាប់តែល្បីល្បាញទាំងពុទ្ធសាសនានិងព្រហ្មញ្ញសាសនាយ៉ាងណា និង អំពីដើមកំណើតភាសាអក្សរខ្មែរដែលកើតឡើងដោយសារពុទ្ធសាសនានិងព្រហ្មញ្ញសាសនាដែលគេបានរក្សាទុកឱ្យយើងមើល តែដំបូងបំផុតសុំបញ្ជាក់ថាពុទ្ធសាសនាបានមកដល់ទឹកដីនេះយ៉ាងហោចណាស់ក៏តាំងពីសតវត្សរ៍ទី ២ នៃគ្រិស្តសករាជដែរ ។ ប្រសិនបើយើងជឿលើឯកសារឥណ្ឌា ដែលព្រះតេជគុណ ញ៉ែម គឹមតេង បានលើកឡើងនោះជំនាន់ព្រះបាទអសោកបានចាត់ព្រះថេរៈ២ព្រះអង្គឱ្យមកផ្សព្វផ្សាយពុទ្ធសាសនានៅទិសខាងកើតនេះជម្ពូទ្វីបនោះព្រះសោណត្ថេរ និងឧត្តរត្ថេរនោះ ។ ប៉ុន្តែរឿងនោះជារឿងមិនច្បាស់ថាសុវណ្ណភូមិនោះនៅត្រង់ណាខ្លះថានៅស្រុកមនខ្លះថានៅស្រុកថៃខ្លះថានៅភូមា ។ ប៉ុន្តែសិលាចារិកមួយនេះមានដើមកំណើតជាអក្សរព្រហ្មណីជាអក្សរឥណ្ឌាផ្នែកខាងកើតខាងត្បូងចង់ស្វែងយល់ពីវប្បធម៌និងអក្សរសាស្ត្រខ្មែរ ។ តែបើមិនចេះភាសាសំស្ក្រឹតទេគឺមើលមិនយល់ទេមិនដឹងថា គេចង់និយាយពីអ្វីទេព្រោះសិលាចារិកជាង១,០០០ផ្ទាំងសរសេរជាភាសាសំស្ក្រឹតទាំងអស់ ហើយសិលាចារិកទាំងនោះនិយាយពីពុទ្ធសាសនាព្រោះមានពាក្យអន្ទោលកើតស្លាប់។ ដូចជាសិលាចារិកនៅវ៉ូកាញ់ដែលគេរកឃើញនៅ ខេត្តញ៉ាត្រាង ប្រទេសវៀតណាមសព្វ

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃដែលពីដើមជាទឹកដីរបស់ខ្មែរ ហើយនៅខាងត្បូងខេត្តញ៉ាត្រាងបន្ទិចជាប្រទេសចាម។ សិលាចារិកនេះជាសិលាចារិករបស់ខ្មែរព្រោះខ្មែរបានទទួលឥទ្ធិពលពីឥណ្ឌាដោយផ្ទាល់ថែមទាំងមានឯកសារឥណ្ឌា-ចិនជាសំអាងទៀត ។ ត្រង់នេះបញ្ជាក់ថាពុទ្ធសាសនា បានចូលមកចាក់គ្រឹះនៅក្នុងប្រទេសខ្មែរយើងតាំងពីសតវត្សរ៍ទី២នៃគ្រិស្តសករាជ ។ តែសព្វថ្ងៃនេះសិលាចារិកទាំងនោះមិនដឹងជានៅទីណាទេ នៅស្រុកបារាំងក៏មិនដឹងស្រុកណាក៏មិនដឹងព្រោះគេលាក់ទុកមិនឱ្យយើងដឹង តែយើងមានសំណាងល្អដោយបារាំងគេបានផ្តិតរូបនិងបោះពុម្ពសៀវភៅទុក ហើយបាននៅគង់វង់រហូតដល់សព្វថ្ងៃនេះក៏ដោយសារតែព្រះសង្ឃជាអ្នកថែរក្សាទុកហើយក៏ជាកិត្តិយសរបស់ព្រះសង្ឃ និងជាមោទនភាពរបស់ព្រះសង្ឃ ដែលគ្មានអ្នកណាមួយអាចធ្វើជំនួសបាន គឺមានតែព្រះសង្ឃទេ ដែលអាចថែរក្សាទុកបានរហូតដល់សព្វថ្ងៃ ទាំងអក្សរច្រៀងអក្សរមូល អក្សរធម៌ និងអក្សរខម ហើយមានតែព្រះសង្ឃទេ ដែលចេះសរសេរ និងជាអ្នកធ្លាប់បួស ព្រោះមុនឆ្នាំ ១៨៦៣ អត់មានសាលារៀនទេមានតែរៀននៅតាមវត្ត ។ ដូច្នេះហើយបានជាគេសរសេរច្បាប់ក្រម និងចងក្រងតាំងពីជំនាន់នោះមក ហើយពីដើមលោកសង្ឃទាំងអស់ ត្រូវចេះច្បាប់ក្រម ព្រោះច្បាប់នេះគេទូន្មានឱ្យមានប្រយោជន៍ ៣យ៉ាង ÷

១. ប្រយោជន៍ចេះធម៌

២. ប្រយោជន៍ចេះច្បាប់

៣. ប្រយោជន៍បារមីនាំញាតិទាំងឡាយ នាំគេទាំងឯងឱ្យភ្លឺ

អក្សរដែលនៅសល់ទាំងនោះ ក៏ដោយសារតែព្រះអង្គចារទុកដែរ។ នៅសម័យអង្គរគេចារលើថ្ម សម័យក្រោយមកគេចារលើស្លឹករឹត ដោយព្រះសង្ឃដើររកខ្លួនឯង កាប់, ហាល, អូសបន្ទាត់, ខ្នាត និង ចារដោយខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

ឯង ។ លើសពីនេះទៅទៀតក្នុងសាស្ត្រាមួយៗលោកដឹងពីចំណុះពាក្យចំណុះអក្សរទៀត ។ នេះជាបច្ចេកទេសមួយដែលគ្មានអ្នកណាចេះទេគឺមានតែខ្មែរយើងទេដែលចេះមុនគេ។ តែសព្វថ្ងៃនេះគេប្រើកំព្យូទ័រហើយ ។

ម្យ៉ាងទៀត ព្រះសង្ឃ មិនមែនមានតួនាទីថែរក្សាអក្សរសាស្ត្រតែមួយមុខប៉ុណ្ណោះទេគឺមានតួនាទីសំខាន់ជាច្រើនទៀត ដូចជា ÷

១- ថែរក្សាសម្បត្តិវប្បធម៌ជាតិឱ្យនៅគង់វង់ដែលហៅថាសាសន៍នោះ ។
គេសួរថា តើអ្នកជាសាសន៍អ្វី ? គេចង់និយាយថា សាសនាអ្វី ? តើអ្នកណាបង្រៀនអ្នកឯង?សាសនៈប្រែថាបង្រៀនអ្នកណាបង្រៀនអ្នកឯងអញ្ចឹង ? គេសួរថា អ្នកឯង សាសន៍អ្វី ? អ្នកឯងជាតិអ្វី ? ដំបូងគេមិនដែលសួរជាតិទេ គេសួរសាសន៍មុន អ្នកកាន់សាសនាអ្វី ? ខ្មែរយើងថាសាសន៍ខ្មែរជាសាសនាព្រះពុទ្ធ ។

១. ថែរក្សាសិល្បៈ
២. ថែរក្សាវប្បធម៌ ទំនៀមទំលាប់ប្រពៃណី
៣. ថែរក្សាបរិស្ថាន
៤. ការអប់រំសីលធម៌សង្គមសម័យដើម ។ល។ និង ។ល។

www.budinst.gov.kh www.elibraryofcambodia.org

## ការបង្កើតធនាគារស្រូវរបស់អង្គការ ព. ជ. អ ខេត្តបាត់ដំបង
ដោយ លោក ស៊ិន សឿប នាយកកម្មវិធី

- សូមក្រាបថ្វាយបង្គំព្រះតេជគុណគ្រប់ព្រះអង្គ
- សូមគោរពឯកឧត្តម លោក លោកស្រី ជាសមាជិក សមាជិកា នៃអង្គសិក្ខាសាលាជាតិទាំងមូលជាទីគោរព

មុននឹងចូលដល់ខ្លឹមសារនៃការបង្កើតធនាគារស្រូវនេះខ្ញុំព្រះករុណា ខ្ញុំសូមទាញអារម្មណ៍ថែរថា : ដោយសារតែយើងមើលឃើញនូវ ទុក្ខវេទនារបស់អ្នកស្រុក និងដោយសារតែយើងចង់ជួយអ្នកស្រុកទើបយើងមានគោលបំណងសំខាន់ៗជាច្រើន ។ ហេតុនេះយើងក៏បានបង្កើតជាធនាគារស្រូវនេះឡើងដោយ :

ទី ១ ដូច ព្រះតេជគុណ ឯឧត្តម លោក លោកស្រី បានជ្រាបហើយថា ប្រទេសកម្ពុជាយើងជា ប្រទេសមួយស្ថិតនៅក្នុងសង្គ្រាមអស់រយៈកាលជាង ២ ទសវត្សរ៍មកហើយ ។ ពិសេសសង្គ្រាមនេះបានធ្វើឱ្យប្រទេសខ្មែរយើងធ្លាក់ចុះក្នុង គ្រោះទុរ្ភិក្សយ៉ាងធ្ងន់ធរ ។ នេះជាគោលបំណងទី ១ ដែលយើងត្រូវដោះស្រាយបញ្ហាស្បៀង ។

ទី ២ ហេតុដែលឱ្យកើតជាធនាគារស្រូវ គឺដោយយើងឃើញថាកន្លងមក ប្រពៃណីនៃការបរិច្ចាគស្រូវបានត្រឹមតែព្រះសង្ឃយកទៅកសាងវត្តអារាមតែប៉ុណ្ណោះ ។ ក្នុងន័យនេះយើងគិតថា ក្នុងពេលដែលអ្នកស្រុកកំពុងជួបប្រទះនូវភាពខ្វះខាត និងភាពក្រីក្រ ។ ហេតុនេះហើយយើងចង់ឱ្យព្រះទ័យរបស់ ព្រះសង្ឃតាមវត្ត ជួយទៅលើអ្នកស្រុកវិញដោយយកស្រូវដែលបានមកពី ការបរិច្ចាគ ការធ្វើបុណ្យទានផ្សេងៗបង្វែរឱ្យ

www.budinst.gov.kh www.elibraryofcambodia.org

ទៅអ្នកស្រុកវិញដើម្បីជួយដោះស្រាយបញ្ហាខ្វះខាត រួចហើយទើបយកមកកសាងជាជំហានទី ២ ។

ទី ៣ គឺចង់ឱ្យអ្នកស្រុករស់នៅក្នុងសហគមន៍ ចេះសាមគ្គីគ្នាដោយធ្វើការបរិច្ចាគស្រូវដើម្បីជួយអ្នកក្រីក្រឱ្យគ្នាមានជីវភាពគ្រប់គ្រាន់និងអាចធ្វើឱ្យគេមានទុនក្នុងសហគមន៍ព្រោះពេលដែលសហគមន៍ពុំទាន់មានទុនស្រូវ ឈ្មួញបានធ្វើសកម្មភាពបណ្តាក់ស្រូវយ៉ាងច្រើន ដោយយកការ ១៥០ ទៅ ២០០ភាគរយ ជាកំរិតការដ៏ខ្ពស់បំផុត ។

ការបង្កើតធនាគារស្រូវមានគោលការណ៍ ២យ៉ាង:

១. តាមរយៈព្រះសង្ឃ

២. ធ្វើតាមមេក្លោងសហគមន៍ ( មនុស្សដែលមហាជនស្រឡាញ់ច្រើន )

របៀបបង្កើតធនាគារស្រូវ:

១. ចុះទំនាក់ទំនងជាមួយនិងអាជ្ញាធរដែនដីមូលដ្ឋាន

២. ចុះស្ទាបស្ទង់អំពីបញ្ហាសហគមន៍ដែលមាន (អ្នកស្រុកត្រូវការអ្វី ខ្លះ ?)

៣. ស្រង់យកគំនិតរបស់អ្នកស្រុកមកពិភាក្សាក្នុងអង្គការរបស់យើង ឬក៏អាចនិមន្តព្រះសង្ឃ និងអញ្ជើញអាជ្ញាធរដែនដីចូលរួមផង

៤. ចុះប្រជុំដល់អ្នកភូមិ ដើម្បីផ្សព្វផ្សាយពីខ្លឹមសារដែលបាន ពិភាក្សារួម

៥. ត្រូវជ្រើសរើសគណៈកម្មការទាំងគ្រហស្ថ និងព្រះសង្ឃ ដើម្បី

៦. គ្រប់គ្រងកម្មវិធីនេះ (ដោយការបោះឆ្នោតជាសំងាត់)

៧. បង្កើតជាលក្ខន្តិកៈមួយដែលនិយាយអំពី :

-អត្រានៃការសង, អត្រានៃការយកការ

-ការជ្រើសរើសសមាជិក ដោយផ្តល់អាទិភាពឱ្យអ្នកក្រីក្រ

-លក្ខណ្ឌនៃការប្រមូល, ខ្ចីពីជង្រុកណាត្រូវដឹកសងដល់ជង្រុកនោះវិញ

www.budinst.gov.kh www.elibraryofcambodia.org

បន្ទាប់ពីចែកស្រូវបាន១ទៅ៣ខែហើយចាំបាច់ត្រូវចុះពិនិត្យ អង្គុតសមាជិកក្នុងសហគមន៍ព្រោះវាមានប្រយោជន៍ ៣ យ៉ាង គឺ ÷

១. អាចក្តាប់បញ្ហាបាន

២. អាចប៉ាន់ប្រមាណទៅលើការសងត្រឡប់មកវិញបាន

៣. អាចរិះរកវិធានការនៅពេលមានបញ្ហា

-បញ្ហាមួយទៀត ការប្រមូលក៏មានកំណត់ថ្ងៃខែដែរ

-បន្ទាប់ពីប្រមូលត្រូវធ្វើការប្រជុំវាយតំលៃ

អំពីកត្តាជោគជ័យ

១. ដោយមានព្រះសង្ឃ អាចារ្យ គណៈកម្មការវត្ត អាជ្ញាធរដែនដីចូលរួម

២. មានការរៀបចំគណៈកម្មការគ្រប់គ្រងជង្រុកស្រូវបានត្រឹមត្រូវនិងច្បាស់លាស់

៣. សមាជិកយល់ច្បាស់អំពីផលប្រយោជន៍ធនាគារស្រូវ

៤. មានលក្ខន្តិកៈច្បាស់លាស់

៥. គិតពីនិរន្តរភាពរបស់ខ្លួន

កត្តាបរាជ័យ

១. គ្រោះធម្មជាតិ

២. អង្គការពីរដែលយកអត្រាខុសគ្នា

៣. ការផ្លាស់ប្តូរគណៈកម្មការគ្រប់គ្រងជង្រុកស្រូវ

៤. កំរិតវប្បធម៌របស់គណៈកម្មការនៅទាប

៥. ការផ្លាស់ប្តូរអាជ្ញាធរដែនដី

៦. ការខ្វះខាតជង្រុកស្រូវ មិនគ្រប់គ្រាន់តាមមណ្ឌល

www.budinst.gov.kh www.elibraryofcambodia.org

## ការបង្កើតធនាគារស្រូវរបស់អង្គការសន្តិសេនា

ដោយ ព្រះតេជគុណ ញៀម គីមតេង នាយកអង្គការសន្តិសេនា

- សូមក្រាបថ្វាយបង្គំព្រះតេជគុណគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមចំរើនពរ ឯកឧត្តម លោក លោកស្រី ជាសមាជិក
- សមាជិកានៃអង្គសិក្ខាសាលាជាតិទាំងមូល ជាទីគោរព

ចំពោះវិធីសាស្ត្រ និងគោលការណ៍ផ្សេងៗ ក្នុងការបង្កើតធនាគារស្រូវនេះវាគ្មិនខាងខេត្តបាត់ដំបងបានលើកមកបង្ហាញរួចហើយ ហើយកិច្ចការនេះអាត្មាភាពបានឱ្យលោក ទេព សារ៉ិន ជាប្រធានធនាគារស្រូវភូមិព្រៃគគីរ ឃុំព្រៃគគីរ ស្រុកចន្ទ្រាគាត់ជាអ្នកគ្រប់គ្រងដោយផ្ទាល់ ។ កម្មវិធីធនាគារស្រូវនេះបានកកើតឡើងនៅក្នុងឆ្នាំ ១៩៩៤ ហើយមុន និងកើតវាជាចលនាផ្នែកបរិស្ថានទេ គឺសង្កត់ធ្ងន់ទៅលើព្រៃឈើរុក្ខវប្បកម្ម ជាពិសេសការដាំដុះដើម្បីពង្រីកព្រៃឈើ ។ ដោយពេលនោះអាត្មាភាពបានទទួលដីចំនួន ៦០០ ហិកតានៅ ស្រុកចន្ទ្រា ពីរដ្ឋាភិបាល ហើយដីនោះពីដើមជាដីព្រៃ ។ ក្នុងសម័យសង្គ្រាមប៉ុន្មានឆ្នាំនេះ ព្រៃទាំងនោះត្រូវបានកាប់បំផ្លាញអស់រហូតដល់សម័យអន្តរកាលគឺមុនពេលបោះឆ្នោតបន្តិច ។ ព្រៃដែលនៅសល់ពីមុនត្រូវបានកាប់បំផ្លាញបន្ថែមអស់ដែលសព្វថ្ងៃនេះគឺនៅសល់តែគល់និងដើមតូចៗប៉ុណ្ណោះ ។

ពេលដាំឡើងវិញអាត្មាជួបការលំបាកខ្លាំងណាស់ដោយអ្នកស្រុកចេះតែលួចកាប់គល់ទោះបីអាត្មាហាមក៏មិនឈ្នះដែរគឺមានកាប់ទាំងថ្ងៃទាំងយប់។ ពេលនោះអាត្មាបានតាមដានពីសកម្មភាពនេះរហូតដឹងថានេះមកពីគេអត់ ។ ហេតុនេះទើបអាត្មាបានចាប់ផ្តើមបង្កើតជាធនាគារស្រូវនៅតាមភូមិជិតៗនោះដើម្បីបន្ថយការកាប់ព្រៃឈើ។នេះជាគំនិតទី១។ ឯគំនិតទី ២ គឺអាត្មាគិតថា

www.budinst.gov.kh www.elibraryofcambodia.org

យើងជាសង្ឃតើត្រូវធ្វើធនាគារស្រូវយ៉ាងម៉េច ? តើមានការប៉ះពាល់អ្វីជាមួយសាសនានិងធម៌វិន័យទេ ? ទីបំផុតអាត្មាបានសំរេចថាឧបាសកព្រះសង្ឃត្រូវរួមសុខទុក្ខជាមួយគ្នា *សង្ឃេន សទ្ធិសមាន សុខទុក្ខា ហោតិ* ។ បើឧបាសកបានសុខព្រះសង្ឃក៏បានសុខបើឧបាសកមានទុក្ខព្រះសង្ឃក៏មានទុក្ខដែរ ។ ហេតុនេះព្រះសង្ឃមិនអាច ព្រងើយកន្តើយបានទេ ។

ការលំបាក

១. អ្នកស្រុកមិនទាន់យល់ពីធនាគារស្រូវ

២. រដ្ឋអំណាចមិនគាំទ្រទទួលគំនិតនេះ

៣. ឈ្មួញវាយតំលៃថា ព្រះសង្ឃធ្វើជំនួញ

ហូតមកដល់ពេលនេះអង្គការសន្តិសេនាបានពង្រីកធនាគារស្រូវបាន៨ភូមិហើយដោយដំបូងចាប់ផ្តើមសាកល្បងតែ២ភូមិទេ។ បន្តពីនេះសូមប្រគល់នាទីនេះជូនទៅលោក ទេព ស៊ាន អធិប្បាយបន្ថែម ។

## លោក ទេព ស៊ាន អធិប្បាយបន្ថែមពីបទពិសោធន៍ធនាគារស្រូវ

- សូមក្រាបថ្វាយបង្គំព្រះតេជគុណគ្រប់ព្រះអង្គ
- សូមគោរពឯកឧត្តមលោកលោកស្រីជាសមាជិកសមាជិកាអង្គសិក្ខាសាលា

ខ្ញុំព្រះករុណា ខ្ញុំឡើងមកនេះគឺសុំលើកយកមកបង្ហាញនូវរបៀបបង្កើតធនាគារស្រូវរបស់អង្គការសន្តិសេនាដូចតទៅ ៖

- ដំបូងយើងត្រូវធ្វើទំនាក់ទំនងជាមួយរដ្ឋអំណាចមូលដ្ឋានដើម្បីឱ្យគេដឹងពីសកម្មភាពរបស់យើង
- ឱ្យរដ្ឋអំណាចជួយគាំទ្រ និងជួយផ្សព្វផ្សាយឱ្យយើង

www.budinst.gov.kh www.elibraryofcambodia.org

- ឱ្យមានព្រះសង្ឃ អាចារ្យ គណៈកម្មការវត្ត និមន្ត និង អញ្ជើញចូលរួម
- ដើម្បីផ្សព្វផ្សាយ
- ជ្រើសរើសគណៈកម្មការ (ដោយការបោះឆ្នោតសំងាត់)
- រៀបចំគណៈកម្មការ ៤នាក់ សំរាប់គ្រប់គ្រងធនាគារស្រូវ និមួយៗ ដោយបែងចែកការកិច្ចផ្សេងៗពីគ្នា :
    - ប្រធានម្នាក់ សំរាប់គ្រប់គ្រងការងាររួម
    - លេខាធិការម្នាក់ ជាអ្នកគ្រប់គ្រងបញ្ជីស្នាម
    - គណនេយ្យម្នាក់ ជាអ្នកកត់ត្រាបញ្ជីចេញ-ចូល
    - អ្នកការពារឃ្លាំងម្នាក់ គ្រប់គ្រងសម្ភារៈប្រើប្រាស់

តាមការបូកសរុប យើងក៏អាចមើលឃើញនូវកត្តាដែលនាំឱ្យជោគជ័យរបស់ធនាគារស្រូវវាខុស និង ក្រុមឈ្មួញដែលរកស៊ីតាមភូមិតាមសហគមន៍កាលណាអត់មានអ្នកខ្ចី គឺ ជាជោគជ័យរបស់យើង ព្រោះអ្នកភូមិមានហូបគ្រប់គ្រាន់ ។ ឯនាយទុនឬអ្នករកស៊ីវិញបើមានអ្នកខ្ចីច្រើនគេក៏ទទួលជោគជ័យកាន់តែច្រើនឡើងៗ ។

កត្តាដែលនាំឱ្យមានការជោគជ័យ

១. អ្នកស្រុកយល់ច្បាស់ពីគោលការណ៍ធនាគារស្រូវ
២. មានការចូលរួមពីអ្នកស្រុក
៣. មានការគាំទ្រពីរដ្ឋអំណាចមូលដ្ឋាន
៤. គណៈកម្មការដែលបំរើការត្រូវមានកំរៃ
   ( ២ភាគរយនៃចំនួនស្រូវសំរាប់ម្នាក់ៗ )
៥. អ្នកស្រុកមានជំនឿទុកចិត្តលើគណៈកម្មការ
៦. ភ្នាក់ងារសន្តិសេនាចុះតាមមូលដ្ឋានឱ្យបានញឹកញាប់

www.budinst.gov.kh www.elibraryofcambodia.org

(ដើម្បីជួយតំរង់ទិសដៅ)

៧. គណៈកម្មការមានសមត្ថភាព

៨. មានការចូលរួមពីស្ត្រី

៩. មានការចូលរួមពីព្រះសង្ឃអាចារ្យគណៈកម្មការវត្តគ្រូបង្រៀន

ការលំបាក

- គ្រោះធម្មជាតិ ( ខ្ចីមិនបានសង ឬសងវិញយឺតយូរ )
- ឈ្នួញបំផុស ( ខ្ចីមួយថាំង យកវិញតែ ២ថាំង )

**លោក តុប ថាត បង្ហាញពីបទពិសោធន៍នៃការបង្កើតធនាគារស្រូវ**

- សូមក្រាបថ្វាយបង្គំព្រះតេជគុណគ្រប់ព្រះអង្គ
- សូមគោរពឯកឧត្តម លោក លោកស្រីជាសមាជិក សមាជិកា អង្គសិក្ខាសាលាជាតិជាទីគោរព

ថ្ងៃនេះ ខ្ញុំព្រះករុណាមានកិត្តិយសបានអង្គសិក្ខាសាលាអនុញ្ញាតឱ្យឡើងមកបកស្រាយនូវបទពិសោធន៍ធនាគារស្រូវនៅក្នុងអង្គការរបស់ខ្ញុំបាទ។

បទពិសោធន៍ធនាគារស្រូវ

កម្មវិធីធនាគារស្រូវបានកើតឡើងនៅក្នុងឆ្នាំ ១៩៩៤-៩៥ ក្នុងពេលដែលកសិករកំពុងជួបប្រទះនូវគ្រោះធម្មជាតិ ដែលជាហេតុធ្វើឱ្យមានការខ្វះខាតស្បៀង និងពូជ ។ ដោយយល់ពីស្ថានភាពបែបនេះ អង្គការ GTZ និងស្ថាប័ននានាក្នុងខេត្តកំពង់ធំទាំងមូល បានផ្តួចផ្តើមបង្កើតកម្មវិធីនេះឡើងដើម្បីពង្រឹងសមត្ថភាពគេឱ្យចេះសន្សំសំចៃពូជទុកនិងទប់ស្កាត់អត្រាការខ្ពស់ពីឈ្មួញ ។ បច្ចុប្បន្ននេះធនាគារស្រូវក្នុងខេត្តកំពង់ធំទាំងមូលមានចំនួន

www.budinst.gov.kh www.elibraryofcambodia.org

១២២គឺស្មើនឹង១២២ភូមិហើយតាមភូមិនិមួយៗមានអ្នកភូមិពី៧០ទៅ១០០គ្រួសារចូលរួម ។ បានន័យថា៧០ទៅ១០០ភាគរយជាសមាជិកធនាគារស្រូវ។ ទាំងនេះគឺមានការជួយឧបត្ថម្ភទុន និង សំរបសំរួលដោយ អង្គការ GTZ ។ ចំនួនធនាគារស្រូវទាំងនេះគឺមានការទទួលខុសត្រូវដោយឡែកៗពីគ្នា ដោយមានអង្គការ និង ស្ថាប័នផ្សេងៗដូចជា : អង្គការ ទស្សនៈពិភពលោក ( WorldVesion ) , អង្គការCWS, អង្គការគ្រឹះសាសនាការីតាស់និងអង្គការ GTZ របស់យើងខ្ញុំផ្ទាល់ហើយនិងសហគមន៍បង្កើតផ្ទាល់។ សហគមន៍នេះមានឈ្មោះថា *សហគមន៍ខ្មែរស្ម័គ្រចិត្តស្រុកសណ្តាន់* ។ គ្រប់អង្គការនិងស្ថាប័ននិមួយៗបានប្រមូលផ្តុំគ្នាបង្កើតអនុគណៈកម្មការមួយហៅថា *អនុគណៈកម្មការធនាគារស្រូវ* ។ អនុគណៈកម្មការនេះបង្កើតឡើងដើម្បីប្រមូលបទពិសោធន៍គ្នាថាតើយើងត្រូវបង្កើតធនាគារស្រូវរបៀបណា?ហើយតើត្រូវបង្កើតគោលការណ៍ស្រូវនោះដោយរបៀបណាដែរដើម្បីឱ្យសមស្របទៅនិងតំរូវការរបស់អ្នកស្រុក ? គោលការណ៍របស់យើងគឺប្រហាក់ប្រហែលគ្នាទៅនឹងគោលការណ៍របស់អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ដែរ ។

កត្តាជោគជ័យ

គឺអាស្រ័យទៅលើការចូលរួមរបស់សមាជិកធនាគារស្រូវយ៉ាងសស្រាក់សស្រាំហើយដើម្បីឱ្យគេបានចូលរួមគឺវាមានការពាក់ព័ន្ធដល់ក្រុមពាទៀតគឺ ÷

១. ក្រុមដៃគូរការងារដែលចុះទៅផ្ទាល់

២. ក្រុមគណៈកម្មការធនាគារស្រូវ

៣. ក្រុមសមាជិកធនាគារស្រូវ

បន្ថែមលើនេះអ្នកស្រី កាក់ ទុទ នឹងជំរាបជូនលំអិតអំពីការធ្វើសមាគមស្រូវតាមវត្តជូនជាបទពិសោធន៍ទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

## អ្នកស្រី ភាក ឆុន បកស្រាយបន្ថែមអំពីការធ្វើសមាគមស្រូវតាមវត្ត

បទពិសោធន៍សមាគមស្រូវតាមវត្ត

សមាគមននេះមានប្រវត្តិកើតឡើងតាំងពីសម័យ សង្គមរាស្ត្រនិយម មកម្ល៉េះហើយរលត់ទៅវិញនៅក្នុងសម័យប៉ុលពត។ នៅក្នុងឆ្នាំ១៩៨៦គណៈកម្មការបានស្រាវជ្រាវរកបទពិសោធន៍នេះយកមកអនុវត្តម្តងទៀត ហើយក៏បានកើតឡើងសារជាថ្មីម្តងទៀតរហូតមកដល់បច្ចុប្បន្នដែលមានសមាគមចំនួន១០ ហើយដើមទុន គឺ បានមកពីការធ្វើបុណ្យតូនភ្នំស្រូវការបិណ្ឌបាត្រនិងការធ្វើបុណ្យទានផ្សេងៗ ។ ពេលដែលប្រមូលបានស្រូវហើយព្រះសង្ឃនិងអាចារ្យបានជ្រើសរើសគណៈកម្មការតាមរយៈពុទ្ធបរិស័ទ ។ បន្ទាប់ពីមានគណៈកម្មការហើយយើងក៏ប្រកាសឱ្យអ្នកស្រុកខ្ចីស្រូវនេះបានដោយមានអត្រាការទាបបំផុតគឺ២០ ទៅ ៣០ ភាគរយតែប៉ុណ្ណោះ។ ក្នុងពេលខ្ចីស្រូវគណៈកម្មការបានរៀបចំជាក្រុមឱ្យខ្ចី ។ ជាក់ស្តែងនៅវត្តពោធិរោងដែលជាវត្តដែលនាងខ្ញុំទើបតែចាប់ផ្តើមធ្វើសកម្មភាពថ្មីជាងគេនៅក្នុង ឆ្នាំ១៩៨៦នេះកន្លងមកដោយមានដើមទុនផ្ទាល់ខ្លួនដែលបានមកដោយសទ្ធាជ្រះថ្លារបស់ឧបាសក-ឧបាសិកាចូលរួមមានចំនួន១៣០ថាំង គឺស្មើនឹង ៣១២០គ.ក្រ រួមជាមួយនឹងការជួយឧបត្ថម្ភរបស់អង្គការGTZ ២៥៣០គ.ក្រ ផងសរុបមានចំនួន៦០៥០គ.ក្រ ។ បន្ទាប់មកយើងបានយកទុនទាំងនោះទៅឱ្យអ្នកស្រុកខ្ចីមានចំនួន១៣១គ្រួសារដែលជាគ្រួសារខ្វះខាតពូជនិងស្បៀង។ ទង្វើទាំងនេះសរបញ្ជាក់ឱ្យឃើញថាគណៈកម្មការសមាគមស្រូវបានទទួលជោគជ័យព្រោះរាល់ការសំរេចចិត្តក្នុងការធ្វើអ្វីមួយយើងសុទ្ធតែបានធ្វើការប្រជុំប្តូរយោបល់គ្នាទៅវិញទៅមក។ វាជាការងាយស្រួលបំផុតសំរាប់ដោះស្រាយជីវភាពគ្រួសារនិមួយៗ ក្នុងការខ្ចី

www.budinst.gov.kh www.elibraryofcambodia.org

និងការសងត្រឡប់មកវិញទាំងដើមទាំងការ ទោះជាគ្រួសារនោះក្រីក្រយ៉ាងណាក៏ដោយក៏គេអាចរកមកសងយើងវិញបានដែរពីព្រោះគេជឿជាក់ថាស្រូវទាំងអស់នេះសុទ្ធតែស្រូវព្រះសង្ឃដែលបានមកពីការធ្វើបុណ្យ ។ ទន្ទឹមនិងការងាយស្រួលនេះនាងខ្ញុំក៏មានការលំបាកខ្លះៗដែរក្នុងការប្រមូលដោយអ្នកខ្ចីខ្លះៗបានជួបប្រទះនឹងគ្រោះទុរភិក្ស។នាងខ្ញុំសូមជំរាបផងដែរថាឆ្នាំកន្លងមកនេះខាងខ្ញុំពុំមានជួបបញ្ហា លំបាកទេតែឆ្នាំខាងមុខនេះមានគ្រោះទឹកជំនន់លិចហើយស្រូវនៅសល់បន្តិចបន្តួចត្រូវរាំងស្ងួតទៀត ។ ដូច្នេះនាងខ្ញុំពិបាកបន្តិចហើយនាឆ្នាំក្រោយនេះ។ លក្ខណៈបែបនេះគឺធ្វើឱ្យអ្នកខ្ចីមិនអាចរកស្រូវសងវិញបានគ្រប់ចំនួនហើយពេលនោះ ខ្ញុំបានប្រជុំជាមួយគណៈកម្មការសហគមដើម្បីធ្វើការពន្យាពេល ។ ការពន្យាពេលនេះគឺថាបើតំបន់ខាងខ្ញុំត្រូវរាំងស្ងួតហើយតំបន់ផ្សេងៗទៀតមានលទ្ធផលល្អអ្នកស្រុកបានប្តូរកំលាំងពលកម្ម ដើម្បីរកស្រូវមកសងសមាគមវិញ។ ទៅឆ្នាំមុខគណៈកម្មការសមាគមបានសន្សំការស្រូវទុកដើម្បីកសាងសមិទ្ធិផ្សេងៗដូចជាវត្តអារាម,ក្មេងកំព្រា ឬ ជួយអ្នកក្រីក្រដែលជួបប្រទះនឹងគ្រោះទុរភិក្ស។

តាមការពិនិត្យទៅលើពុទ្ធបរិស័ទ ដែលមានសទ្ធាជ្រះថ្លាលើការចូលរួមក្នុងពិធីបុណ្យដែលមិនទាមទារយកទៅវិញគណៈកម្មការសមាគម នៅតែបន្តសកម្មភាពនេះដដែលហើយនិងស្វែងរកកិច្ចសហការពីម្ចាស់ជំនួយនៅលើ វិស័យនេះតទៅទៀតដើម្បីឆ្លើយតបទៅនិងតំរូវការអ្នកខ្វះខាតស្បៀងខ្វះថវិកានិងខ្វះកំលាំងអូសទាញ។តាំងពីមុនមកយើងមិនដែលដឹងថាសារៈប្រយោជន៍នេះអាចកាត់បន្ថយនូវអត្រាខ្ចីបុលពីឈ្មួញនៃអ្នកក្រីក្រពី ៦០ភាគរយ មក ៣០ភាគរយទៅតាមបរិមាណស្រូវដែលសមាគមនាងខ្ញុំមាន ។

www.budinst.gov.kh www.elibraryofcambodia.org

## ព្រះតេជគុណ ពោធ ម៉ាន បទ្ធាញពីបទពិសោធន៍ធនាគារស្រូវ

- សូមក្រាបថ្វាយបង្គំព្រះតេជគុណគ្រប់ព្រះអង្គ
- សូមចំរើនពរ ឯឧត្តម លោក លោកស្រីជាសមាជិក សមាជិកា នៃអង្គសិក្ខាសាលាជាតិ ជាទីគោរព

អាត្មាភាព បានរៀបចំជាសហគមន៍មួយនៅតាមភូមិចំណុះជើងវត្តមាន ១១ភូមិ ។ ដំណើរការនៃការបង្កើតធនាគារស្រូវនេះគឺ កើតឡើងតាំងពីឆ្នាំ ១៩៩៤ ដោយបានរៀបចំជាសមាគមតូចមួយដែលមានឈ្មោះថា *សមាគមសង្គ្រោះចាស់ជរា* ។ កម្មវិធីនេះបានរៀបជាគណៈកម្មការចាស់ទុំព្រឹទ្ធាចារ្យដែលមានការលំបាក ការឈឺចាប់ កូនចៅអត់ឃ្លាន ។ល។ ហើយខ្ញុំព្រះករុណាបានធ្វើបុណ្យសង្គហៈក្នុងមួយឆ្នាំពី ៥ ទៅ ១០ដងដោយមានរៀបចំជាគណៈកម្មការ និង ពុទ្ធបរិស័ទចំណុះជើងវត្តទាំង ១០០០គ្រួសារ ដើម្បីធ្វើភត្តកិច្ចមួយក្នុងគោលបំណងប្រមូលបច្ច័យទាំងអស់នោះដោយមិនបានប្រគេនព្រះសង្ឃ និង អាចារ្យទេ ។

នៅក្នុងឆ្នាំ១៩៩៣ ខ្ញុំព្រះករុណាអាត្មាភាពបានមកសិក្សារៀនសូត្រនៅវត្តព្រៃឆ្លាក់អស់រយៈពេល២០ថ្ងៃហើយក៏បានយកបទពិសោធន៍ទាំងនោះទៅអនុវត្តនៅឯវត្តរបស់ខ្ញុំព្រះករុណាភ្លាម ។ ជំហានដំបូង ខ្ញុំព្រះករុណាអាត្មាភាពមានទុនស្រូវតែ២០០ថាំងទេសំរាប់ធ្វើសកម្មភាពជាបណ្តើរៗ ដោយចាត់តាំងជាគណៈកម្មការចំនួន៥រូបសំរាប់ភូមិនិមួយៗហើយគណៈកម្មការនេះ គឺទុកឱ្យអ្នកស្រុកគេរើសដោយខ្លួនគេនិងឱ្យគេពិនិត្យលើអត្តចរិក និងសីលធម៌ស្មោះត្រង់ព្យាយាមការងារពិតៗគឺឱ្យគិតពីខ្លួនឯងផងនិងគិតពីអ្នកដទៃផង ។ សកម្មភាពនេះចាប់ផ្តើមបានជោគជ័យនៅក្រោយពេលដែលខ្ញុំព្រះករុណាបាន

www.budinst.gov.kh www.elibraryofcambodia.org

ទៅទាក់ទងជាមួយអ្នកស្រី គូ កូ ជាជនជាតិជប៉ុន អង្គការ GTZ ហើយទំនាក់ទំនងបានដីមួយចំនួនទៀតដើម្បីចែកជូនអ្នកស្រុក ។

តាមរយៈគណៈកម្មការដែលរៀបចំហើយនោះក៏បានបង្កើតឡើងនូវធនាគារស្រូវដែលបានទទួលជោគជ័យ ៩០ភាគរយ គឺមានតែ ១០ភាគរយ ទេដែលមិនអាចទទួលជោគជ័យបានតែ១០%នេះសង្ឃឹមថាមិនបរាជ័យឡើយ ។ សព្វថ្ងៃនេះគណៈកម្មការបានទទួលកិច្ចការនេះអស់ហើយ ហើយអាត្មាភាពក៏បានអប់រំគណៈកម្មការជាមុនដែរដោយជំហានទី១ គឺរាល់ថ្ងៃសីលនៅក្នុងវត្តឱ្យស្គាល់ពីតួនាទីដែលគេសង្ឃឹមលើខ្លួន និងឱ្យស្គាល់ពីតួនាទីខ្លួនជាអ្នកឈានមុខគេ ដើរមុនគេ កុំឱ្យគេតូចចិត្ត ល្អក់ចិត្ត គំនិតមិនល្អ ធ្វើយ៉ាងណាឱ្យមានគុណភាពគ្នាទៅវិញទៅមក ។

ចូលឆ្នាំទី២គឺ ឆ្នាំ១៩៩៤ មកឃើញថាលទ្ធផលជោគជ័យដូចជាធ្វើបញ្ជីបានត្រឹមត្រូវនូវឈ្មោះអ្នកជំពាក់អ្នកសងអ្នកជំពាក់មិនសងតាមភូមិនិមួយៗ។

ការមិនបានជោគជ័យ១០ភាគរយមកពីវណ្ណ កប៉ុន្មានឆ្នាំមកហើយព្រោះអ្នកស្រុកខ្លះជំពាក់គេពីរបីឆ្នាំហើយគេមកជួយច្រូតជួយបែនយកតែម្តងហើយរត់មកពិគពុទ្ធិកាអាត្មាថា មិនទាន់បានសងស្រូវទេ ព្រោះគេយកអស់ហើយ។ ខ្ញុំព្រះករុណាយកមេក្រុមមួយដើរស្រែកក្នុងភូមិប្រមូលស្រូវដាក់ក្នុងភូមិបាន៥ឬ៨បាវទៀតដោយឥតមានយកការទេចាំឆ្នាំក្រោយចាំយក ។ តើឱ្យអាត្មាជួយអ្វីទៀត? អាត្មាសួរថាអ្នកឯងមានការងារស្អីធ្វើទៀត? អ្នកឯងចេះធ្វើស្អី ? ថាមិនចេះទេចេះតែឡើងត្នោត។ អញ្ចឹងអាត្មាបានបង្កើតជាធនាគារស្ករត្នោតដោយជួយទិញបង្អោងឱ្យ ហើយឆ្នាំនោះយើងបានស្ករ៩តោន ។

ឆ្នាំនេះទាំងដើមទាំងការបានសងរួចហើយនៅសល់តែ ១០គ្រួសារទៀតទេហើយអ្នកដែលចូលរួមចាប់កុសលតាមការទេសនា ការធ្វើបុណ្យឱ្យជួយគ្នា

www.budinst.gov.kh www.elibraryofcambodia.org

បើកក្អេកទៅឃើញសុទ្ធតែគ្នាយើងហើយការចាប់កុសលឆ្នាំនេះបាន២០គោន ធ្វើជង្រុកបាន ១៦ ក្នុងវត្តបាន៣ជង្រុក ដោយខ្ញុំព្រះករុណាជួយចេញពាក់កណ្តាលហើយជួយគិតគូរដល់អ្នកហាត់ឡើយ( គណៈកម្មការ )៣០ភាគរយ ដោយគេអាណិតលោកឃើញលោកហាត់ឡើយតែគាត់មិនយកទៀតដាក់ចូលជង្រុកទាំងអស់ ។

សិប្បកម្មតម្បាញហូល ផាមួង ក្រមា សឹង មានមួយអាគារ ។ បច្ចុប្បន្នមានរៀបចំជាអាគារកាត់ដេរ១ដោយអង្គការJSRC ជួយផ្តល់លទ្ធភាពឱ្យ ៕

## លោក មៀច សុខា អង្គការ JSRC រៀបរាប់ពីកត្តាជោគជ័យ និង បរាជ័យ

យើងខ្ញុំជួយទៅលើសាលារៀន និង ដោយមានគោលដៅមួយគឺធ្វើតាមការចូលរួមពីសមាគម"*ស៊ីក្ស៊ី* " ជប៉ុនជួយខាងសម្ភារៈហើយសមាគមជួយចេញឈ្នួលពលកម្ម ។ ក្នុងពេលសាងសង់អង្គការយើងបានសង្កេតមើលថាតើអង្គការណាដែលសកម្មហើយអាចបន្តការងារអភិវឌ្ឍន៍ជនបទតទៅទៀតបាន ។ ដោយការសង្កេតមើលទៅក្រោយពីការសាងសង់ហើយយើងក៏បានរើសយកសហគមន៍៧ក្នុងខេត្តកំពត, កណ្តាលជាក់ស្តែងខេត្តស្វាយរៀងដែលមានស្ពាន៥ ។ ហេតុការណ៍គឺខាងសហគមន៍ដំណើរការដោយផ្ទាល់ដោយយើងខ្ញុំគ្រាន់តែជាអ្នកផ្តល់គំនិតបច្ចេកទេសនិងផ្តល់ជាស្រូវក្នុងការធ្វើ ។ អ្វីដែលខ្ញុំបង្ហាញជូននេះវាជាគោលបំណងជាការងាយស្រួល ការលំបាក និង អំពីបទពិសោធន៍ប៉ុណ្ណោះ ។

ដំណើរការនៃការធ្វើធនាគារស្រូវនេះគឺមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងអង្គការសន្តិសេនា និង អង្គការ GTZ ដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

## សំណួររបស់ព្រះតេជគុណមេគណខេត្តបន្ទាយមានជ័យ

ខេត្តបន្ទាយមានជ័យរបស់ខ្ញុំព្រះករុណាអាត្មាភាពបានធ្វើកិច្ចការនេះរួចហើយ ប៉ុន្តែមិនបានថាជាធនាគារស្រូវស្អីទេគឺឱ្យតែដល់ពេលច្រូតកាត់មង១ ព្រះសង្ឃតែងតែទៅបិណ្ឌបាត្រស្រូវហើយវត្តខ្លះបិណ្ឌបាត្របាន ១០០-២០០ បាវដូចជាវត្តអាត្មាមានដល់ទៅ៥០០-៦០០បាវទៀតផង។ តែមិនថាជាធនាគារស្រូវទេព្រោះស្រូវនេះទុកឱ្យព្រះសង្ឃរៀនសូត្រ ។ តែជួនកាលមានពុទ្ធបរិស័ទក្រីក្រមកខ្ចីក៏ឱ្យ១-២បាវទៅ ។ លុះដល់ពេលសងបើមានក៏សងទៅ បើមិនមានក៏ហើទៅ ។ នេះបញ្ជាក់ថាខេត្តរបស់អាត្មាភាពបានធ្វើរួចហើយតែមិនបានហៅថាធនាគារស្រូវតែប៉ុណ្ណោះ ។ ពេលបញ្ចប់សិក្ខាសាលានេះទៅអាត្មាត្រូវតែធ្វើតាមក្រិតក្រមជំនាញបច្ចេកទេសរបស់ធនាគារស្រូវហើយ ។

ពេលនេះអាត្មាសុំសួរបន្តិចថា ៖ តើព្រះសង្ឃក្នុងវត្តអាចធ្វើជាជាងបានដែរឬទេដូចជាជាងចម្លាក់, ជាងផ្សា, ជាងគូ, ជាងឡូ ជាដើម ។ល។

## លោក យី ឆន់ បំភ្លឺសំនួរ

អាចធ្វើបានព្រះតេជគុណ មិនមានខុសពីវិន័យអ្វីទេ ព្រោះបើពិនិត្យទៅលើមង្គលសូត្រ ត្រង់មង្គលសូត្រទី ៧-៨ ថា *ពាហុសច្ចញ្ច សិប្បញ្ច* ព្រះពុទ្ធអង្គទ្រង់សរសើរដល់អ្នកដែលមានសិល្បៈ ដែលប៉ិនប្រសប់ឆ្លៀវឆ្លាតវាងវៃ ហើយជាអ្នកមានមង្គលសិរីសួស្តីដ៏ប្រសើរឧត្តមទៀតផង ។

www.budinst.gov.kh www.elibraryofcambodia.org

## ព្រះតេជគុណ ញៀម គីមតេង បន្ថែមបន្ថែម

អាត្មាសុំថែមទាក់ទងទៅនឹងព្រះតេជគុណមេគណខេត្តបន្ទាយមានជ័យ អំពីរឿងសិល្បៈ ។ សិល្បៈនេះបើយើងពិនិត្យទៅលើមង្គលសូត្រត្រង់មង្គលសូត្រទី៨។ មង្គលសូត្រទី៧ ថា ពាហុសច្ចញ្ច មង្គលសូត្រទី៨ថា សិប្បញ្ច បានសេចក្តីថាព្រះពុទ្ធទ្រង់សរសើរអ្នកដែលមានសិល្បៈដែលប៉ិនប្រសប់ដែលឈ្លាសវៃទៅលើកិច្ចការសិល្បៈថាជាអ្នកមានសិរីសួស្តី មានមង្គលដ៏ឧត្តម ។ ម្យ៉ាងទៀតទាក់ទងទៅលើវិន័យផ្នែកកឋិនត្ថារកិច្ច។ ពីសម័យពុទ្ធកាលរហូតមកគេមិនដែលយកស្បង់យកចីវរយកសង្ឃាដីដែលឆ្អែហើយទៅវេរជាកឋិនទេ គេយកសំពត់បានជា បាលីថា កឋិនទុស្សំ ។ កឋិនៈ គឺកឋិន, ទុស្ស គឺសំពត់ដែលមិនទាន់កាត់មិនទាន់ឆ្អែគឺនៅទាំងគី ទាំងត្បូង ហើយយករបស់នោះទៅវេរសង្ឃហើយព្រះសង្ឃយករបស់នោះមកបោក មកគក់មកជ្រលក់ មកកាត់មកដាន មកដេរ ឱ្យទៅជាស្បង់ ឱ្យទៅជាចីវរ ឱ្យទៅជាសង្ឃាដី ឱ្យទៅជាបរិក្ខាររបស់អ្នកបួសហើយក្រាលគ្រងឱ្យហើយក្នុងថ្ងៃហ្នឹងទៅ។ ឧទាហរណ៍: បើឧបាសកវេរថ្ងៃហ្នឹងត្រូវយកទៅធ្វើអោយ កាត់ ដេរ ជ្រលក់ បោកគក់ឱ្យហើយក្នុងថ្ងៃហ្នឹងក្រាលគ្រងក្នុងថ្ងៃហ្នឹងព្រោះបើហួសពីថ្ងៃហ្នឹង ចូលថ្ងៃស្អែកត្រឹមតែអរុណរះគឺសំពត់កឋិនហ្នឹងវាអត់បានការទេគេហៅថា កឋិនដាច់ ។ ដូច្នេះព្រះសង្ឃមួយអង្គៗត្រូវតែរៀនពីសិល្បៈ ព្រោះការកាត់ដេរនេះវាក៏ជាផ្នែកមួយនៃសិល្បៈដូចលោក យី ធន់ អានប្រកាសន៍ថាសិល្បៈហ្នឹងវាមានរាបរយ ។ ការកាត់ដេរវាជាសិល្បៈទៅហើយចុះបើសិនឧបាសកយកសំពត់មកវេរជាកឋិនហើយព្រះសង្ឃមិនចេះកាត់ដេរ មិនចេះរៀបចំសំពត់នោះឱ្យទៅជាស្បង់ ជាចីវរ ជាសង្ឃាដី សួរថាតើក្រាលជាកឋិនកើត ឬ មិនកើត ?

www.budinst.gov.kh www.elibraryofcambodia.org

ថាវាមិនកើតទេចុះបើវាមិនកើតថាតើវាត្រូវវិន័យទេ? ចុះបើលោកសង្ឃចេះកាត់ដេរចេះឆ្នៃសំពត់នោះឱ្យទៅជាស្បង់ ជាចីវរវាមិនត្រឹមត្រូវតាមវិន័យទៅហើយ ។ ដូច្នេះវាមានច្រើនបែបដូចព្រះតេជគុណមានពុទ្ធិការថាតាំងពីដាប់តាំងពីផ្លាក់អីហ្នឹងវាមិនខុសទេព្រោះវាជាសិល្បៈបើដាប់បើផ្លាក់វាខុសការកាត់ស្បង់ចីវរក៏វាខុសដែរដេរក៏វាខុសដែរហើយរឿងនេះមិនមែនទើបតែនឹងកើតឥឡូវនេះទេគឺកើតមានតាំងពីដើមពីសម័យពុទ្ធកាល ព្រះពុទ្ធអនុញ្ញាតឱ្យមានកឋិនអញ្ចឹងមក ទើបតែឥឡូវទេវាទៅជាកឋិនចីវរំ កឋិនចីវរ គេកាត់គេជ្រលក់ហើយស្រេចកុំឱ្យពិបាកលោកពេកលោកចាំតែទទួលហើយក្រាលគ្រងទៅព្រោះចិនវាធ្វើរួចស្រេចអស់ហើយ ។ នេះរឿងសិល្បៈចម្លាក់បែបបទអីហ្នឹងខ្ញុំព្រះករុណាសុំមានយោបល់ចូលរួមតែប៉ុណ្ណេះទេ ៕

## សំណួរព្រះតេជគុណ វៀម សំអាត ខេត្តបន្ទាយមានជ័យ

ខ្ញុំព្រះករុណាឡើងមកនេះមានសំណួរខ្លះចំពោះការបង្កើតធនាគារស្រូវនិងការបង្កើតជាសមាគមស្រូវនៅខេត្តកំពង់ធំ :

១. តើការចូលរួមរបស់អ្នកភូមិជាមួយអង្គការ GTZ មានអ្វីខ្លះ ?

២. តើអង្គការជួយបានប៉ុន្មានដែរ ?

៣. តើអង្គការចាត់ទុកសមាជិកដែលខ្ចីស្រូវពីធនាគារស្រូវ ជាសមា ជិក ឬជាអ្នកស្រុកប្រភេទណា ?

៤. តើមានបញ្ហាអ្វីខ្លះទេ ក្នុងការខ្ចីស្រូវពីសមាគម បើពុទ្ធបរិស័ទចំណុះជើងវត្តមានច្រើន មិនអាចចែកបានគ្រប់គ្នា ?

៥. ស្រូវដែលសមាគមសន្សំបាន បើសិនជាយកទៅសាងសង់ សំណង់ជាប្រ

www.budinst.gov.kh www.elibraryofcambodia.org

យោជសាធារណៈអ្វីមួយតើការសាងសង់នោះអាចមានបញ្ហាដែរឬទេ ?

## ចម្លើយរបស់អ្នកស្រី កាក ឌុន ខេត្តកំពង់ធំ

បើនិយាយពីធនាគារស្រូវ ខ្ញុំព្រះករុណាបានប្រគេននិងជំរាបជូនហើយថា : ការងារធនាគារស្រូវនេះជាការងារថ្មី ។ ដូច្នេះចំពោះរឿងខ្ចីគឺយើងឱ្យតែសមាជិកធនាគារស្រូវទេដែលខ្ចីបាន ។ ប៉ុន្តែបើមាននៅសល់ពីការខ្ចីរបស់សមាជិកហើយគណៈកម្មការអាចឱ្យអ្នកស្រុកដែលមិនមែនជាសមាជិកខ្ចីបាន ។ រឿនសមាគមស្រូវនេះសំរេចទៅលើពុទ្ធបរិស័ទជាអ្នកសំរេចដោយពឹងទៅលើព្រហ្មវិហារធម៌ទាំង ៤ គឺឱ្យអាទិភាពទៅលើអ្នកស្រុកក្រីក្រអ្នកខ្វះពូជនិងស្បៀងជាក់ស្តែង ។ ម្យ៉ាងទៀតយើងក៏បានអប់រំសតិអារម្មណ៍អ្នកស្រុកដែលមានស្រូវហូបគ្រប់គ្រាន់ហើយដើម្បីឱ្យពួកគេយល់ពីបញ្ហានេះ ។

ចំពោះបញ្ហាកសាងនូវសមិទ្ធិផលផ្សេងៗ មិនមែនតែនៅក្នុងវត្តខ្លួនឯងទេគឺជួយកសាងក្នុងភូមិដែលចំណុះជើងវត្តទៀតផង ។

## លោកអាចារ្យ ប្រាក់ ថា បំពេញបន្ថែមអំពី ធនាគា និង សមាគមស្រូច

ខ្ញុំព្រះករុណាខ្ញុំឡើងមកនេះ ដើម្បីជួយធ្វើអន្តរាគមន៍អំពីធនាគារ ស្រូវនិងសមាគមស្រូវព្រោះខ្ញុំព្រះករុណាខ្ញុំបាទពិតមែនតែមានឋានៈជាអាចារ្យវត្តតែបានចូលរួមយ៉ាងជ្រៅទៅក្នុងបញ្ហានេះ ដូច្នេះសុំឆ្លើយបន្ថែមលើយោបល់អ្នកស្រី កាក ឌុន ដែលបានឆ្លើយរួចមកហើយ ÷

១. បើស្រូវមានតិចហើយពុទ្ធបរិស័ទមានច្រើនតើការបែងចែកមានបញ្ហាដែរ

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY

ឬទេ ?

២. ចំពោះប្រាក់ដែលបានមកពីកំរៃរបស់សមាគមស្រូវហើយយើងយកប្រាក់នោះទៅសាងសង់សំរាប់ជាប្រយោជន៍សាធារណៈនៅក្នុងភូមិណាមួយដូចជាធ្វើស្ពានជាដើម ហើយមានភូមិជាច្រើនទៀតដែលមិនមានសាងសង់តើមានបញ្ហាចោទដែរឬទេ ?

ដូច្នេះខ្ញុំព្រះករុណាសូមបញ្ជាក់ជូនឱ្យខ្ញី ហើយងាយស្តាប់បានដូចតទៅនេះ ÷

១. បើស្រូវមានតិចហើយពុទ្ធបរិស័ទមានច្រើនតើការចែកចាយមានបញ្ហាដែរឬទេ? គឺគ្មានបញ្ហាអ្វីទាំងអស់ព្រោះគោលដៅទិសដៅនិងគោលបំណងនៃសហគមន៍ស្រូវនៅតាមវត្តនេះ បង្កើតឡើងមានគោលបំណងតែមួយគត់ គឺ ជួយពុទ្ធបរិស័ទដែលខ្វះខាតជាងគេដើម្បីកាត់បន្ថយនូវភាពក្រីក្រ ពិសេសពុទ្ធបរិស័ទណាដែលអត់ជាងគេត្រូវឱ្យបរិស័ទនោះ ។ ដូច្នេះពុទ្ធបរិស័ទណាដែលមានហើយ គឺគ្មានបញ្ហាអ្វីទេ ។

២. ក្នុងលក្ខន្តិកៈបានចែងថា កំរៃដែលបានមកពីសមាគមស្រូវគឺត្រូវយកទៅកសាងជាប្រយោជន៍សាធារណៈ ជាសេនាសនៈនៅក្នុងវត្តក្តីនៅក្នុងភូមិណាមួយក្តីមិនរើសមុខឱ្យតែមានលទ្ធភាពជួយកសាងបានដូចជាជីកស្រះធ្វើស្ពានជីកអណ្តូងជាដើម ។ល។ ទាំងអស់នេះអាចយកទៅប្រើការនៅទីណាក៏បានគឺគ្មានបញ្ហាអ្វីឡើយ ។

៣. ចំពោះសំណួរដែលថា តើវាអាចថយក្រោយដែរឬគ្មានទេ ? ខ្ញុំព្រះករុណាសូមបញ្ជាក់ជូនលោក យី ធន់ ដែលឆ្លើយថាបើបរាជ័យឱ្យច្បាស់ជាបរាជ័យ បើមិនបរាជ័យឱ្យច្បាស់ជាមិនបរាជ័យ ហើយសូមសមាគមប្រាក់តាមវត្តមួយចំនួនធំក៏មានសមាគមស្រូវផងដែរ ។ បញ្ហាសមាគមទាំងនេះតាមខ្ញុំព្រះករុណាបានដឹងនិងបានចុះជាប់ជាមួយសមាគមក្នុងវត្ត

www.budinst.gov.kh www.elibraryofcambodia.org

របស់ខ្ញុំដែលធ្វើនោះពុំទាន់មានសមាគមណាមួយបរាជ័យទេ ។

សំណូមពរ :

- ចំពោះព្រះសង្ឃ ព្រោះកង្វះខាតរបស់ព្រះសង្ឃមានច្រើន តាមខ្ញុំព្រះករុណាដឹងតាមពុទ្ធដីកាដែលព្រះតេជគុណ វ៉ែម គឹមតេង បានលើកឡើងថា : *សង្ឃេនសទ្ធឹ សមាន សុខា ទុក្ខា ហោតិ* ដែលកន្លងមកនេះព្រះសង្ឃមើលមិនឃើញនូវទុក្ខវេទនារបស់បរិស័ទទេ ។
- ចប់ពីសិក្ខាសាលានេះទៅសុំធ្វើយ៉ាងណាសូមព្រះតេជគុណមើលឃើញឱ្យ ច្បាស់អំពីពាក្យថា : *រួមសុខ រួមទុក្ខជាមួយពុទ្ធបរិស័ទផង ។*

## សំណួរលោក រស់ ថាន់សន សំរាប់ខាត្រីនទាំង ៣ ខេត្ត

- សូមក្រាបថ្វាយបង្គំព្រះតេជគុណគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមគោរព ឯកឧត្តម លោក លោកស្រី ជាសមាជិក សមាជិកា អង្គសិក្ខាសាលាជាតិទាំងមូលជាទីគោរព

តាមខ្ញុំព្រះករុណា ខ្ញុំបាទបានស្តាប់កន្លងមកនេះយើងនិយាយតែអំពីកត្តាជោគជ័យប៉ុណ្ណោះហេតុនេះខ្ញុំព្រះករុណាសូមមានសំណួរខ្លះៗដូចតទៅនេះ÷

១- តើយើងត្រូវដោះស្រាយយ៉ាងណាចំពោះជនខិលខូចប៉ុន្តែគ្នាជាអ្នកក្រីក្រ ហើយគោលការណ៍របស់យើងគ្រប់គ្នាគឺជួយជនក្រីក្រជួយ លើកស្ទួយពុទ្ធបរិស័ទជុំវិញវត្តចុះ តើយើងគិតដោះស្រាយយ៉ាងណាដែរបើសិនគ្នាខ្ចីហើយមិនសង ? ព្រោះយើងលើកពីព្រឹកមិញថា: មិនត្រូវមានតទៅទៀតទេត្រូវដេញចោល។ តើគោលការណ៍យើងដែលថាជួយជនក្រីក្រនោះយ៉ាងម៉េចដែរ ?

២- តើយើងត្រូវដោះស្រាយយ៉ាងណាដែរចំពោះអ្នកជំពាក់ស្រូវចិនច្រើន?

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះចិនយកការខ្ពស់ ហើយយើងយកការតិចដូចជានៅខេត្តស្វាយរៀងនេះ យកការតែ៣៥ភាគរយទេ នៅបាត់ដំបងយកការ៥០ភាគរយហើយចុះបើគ្រួសារនោះក្រហើយជំពាក់ចិនដល់កហើយនោះ ហើយគ្នាបានមកខ្ចីស្រូវពីធនាគារយើងដែលយកការតិចទៅសងចិនវិញដើម្បីឱ្យរួចការធ្ងន់តែគ្នានៅតែអត់ស្រូវហូបដដែល តើយើងត្រូវដោះស្រាយយ៉ាងម៉េចដែរចំពោះបញ្ហានេះ ?

៣- តើយើងមានគោលការណ៍យ៉ាងម៉េចដែរ ចំពោះស្រូវហូប និងស្រូវពូជ ប្រសិនបើគេមកខ្ចីថាយកទៅធ្វើពូជតែបែរជាយកទៅហូបវិញ?ហើយតើយើងគួរបែងចែកស្រូវទុកឱ្យខ្ចីសំរាប់ហូបនិងទុកសំរាប់ធ្វើពូជប៉ុន្មានដែរ ?

**ចំលើយរបស់ព្រះតេជគុណ ឡៀម គឹមតេង**

អាត្មាសុំសាកល្បងឆ្លើយនូវសំណួរទី ១ ។ ក្នុងបញ្ហានេះយើងពិនិត្យមើលលក្ខន្តិកៈរបស់ធនាគារស្រូវ ឬ របស់សមាគមព្រោះសមាគមស្រូវ ឬធនាគារស្រូវនិមួយៗគឺមានច្បាប់ឬលក្ខន្តិកៈខុសៗគ្នា ។ លក្ខន្តិកៈនេះកើតចេញពីការប្រជុំសំរេចរបស់សមាជិកធនាគារស្រូវនៅតាមកន្លែងនិមួយៗ មិនមែនគណៈកម្មការជាអ្នកសំរេចទេ ហើយតាមអាត្មាធ្លាប់ធ្វើកន្លងមកលក្ខន្តិកៈទាំងអស់សុទ្ធតែមានន័យនិងមានសេចក្តីតឹងតែងតែមានចំណុចខ្លះ ជាចំណុចអនុគ្រោះដែរ ដោយយោលទៅលើការពិនិត្យជាក់ស្តែង ។ ឧទាហរណ៍ : គ្រួសារឈ្មោះ ( ក ) ខ្ចះស្រូវហូបហើយបានមកខ្ចីពីធនាគារលុះពេលយកស្រូវទៅដល់ផ្ទះគាត់ក៏ស្លាប់ទៅ។ ដូច្នេះរបរកសិកម្មត្រូវធ្លាក់ចុះព្រោះគ្រួសារគាត់ខ្វះកំលាំងពលកម្ម ហើយស្រូវដែលខ្ចីបានទៅនោះក៏យកទៅចាត់ចែងធ្វើបុណ្យទៅ ។ ហេតុនេះទិន្នផលដែលពីដើមគ្រួសារនេះតែងតែទទួលបាន

www.budinst.gov.kh www.elibraryofcambodia.org

១០០ថាំងត្រូវធ្លាក់មកនៅត្រឹមតែ៤០ឬ៥០ថាំងតែប៉ុណ្ណោះ ។ លុះដល់ពេលសងប្រពន្ធគាត់គ្មានលទ្ធភាពសងហេតុនេះគណៈកម្មការត្រូវពិនិត្យមើលភាពជាក់ស្តែងរបស់គាត់។ ឧទាហរណ៍មួយទៀតគ្រួសារ( ខ )បានខ្ចីស្រូវដែរតែត្រូវគ្រោះធម្មជាតិរាំងស្ងួតឬទឹកលិចអស់ដល់ពេលសងគ្មានស្រូវសង។ ពេលនោះគណៈកម្មការក៏បានចុះទៅពិនិត្យមើលដល់ផ្ទះឃើញថាគាត់មិនមានស្រូវមែន ។ ដូចនេះគណៈកម្មការក៏មិនអាចបង្ខំឬចាប់គាត់ឱ្យសងបានទេព្រោះបើយើងបង្ខំខ្លាំងមានតែគាត់លក់ដីធ្លីឬទ្រព្យសម្បត្តិរបស់គាត់មកសង។ ដោយមានករណីអនុគ្រោះនេះហើយដែលយើងអាចពន្យា ពេលសងទៅឆ្នាំក្រោយបាន ឬក៏ឆ្នាំក្រោយទៀតដោយគ្មានគិតការទេ ។ លើសពីនេះទៅទៀតគណៈកម្មការអាចលប់ការជំពាក់នេះចោលបានក្នុងករណីដែលពិនិត្យទៅលើភាពជាក់ស្តែង ។ នេះក៏មកពីយើងមានគោលការណ៍ជួយអ្នកក្រីក្រ ។ តែបើគណៈកម្មការពិនិត្យទៅឃើញថា អ្នកខ្ចីនោះយកស្រូវទៅលក់លេងល្បែងវិញនោះគណៈកម្មការត្រូវតែបង្ខំឱ្យគាត់សងមកវិញដោយខានមិនបាន ។

**លោក តុប ថាត ឆ្លើយបន្ថែម**

ចំពោះកន្លែងខ្ញុំបាទគឺមានក្រុមធានា ហើយក្រុមធានានិមួយៗគេស្ម័គ្រចិត្តជួយចេញសង ។ តែក៏មានក្រុមធានាមួយចំនួនមិនស្ម័គ្រចិត្តចេញសងទេបានន័យថា អ្នកខ្ចីនោះអត់បានសងវិញទេ ដូចព្រះតេជគុណញ៉ែមគឹមតេងលើកឡើងហើយពីរឿងដែលសមាជិកធនាគារស្រូវសំរេចថាត្រូវពន្យាពេលនៅក្នុងករណីអ្នកនោះទទួលរងគ្រោះថ្នាក់ដោយប្រការណាមួយ ឬ ដោយទឹកជំនន់ហើយបើយូរទៅនៅតែមិនសងយើងក៏លប់បញ្ជីជំពាក់ចេញតែម្តង។មួយទៀត

www.budinst.gov.kh www.elibraryofcambodia.org

បើសមាជិកគ្មានស្រូវសងទេគេអាចដើរទៅរើសគួរស្រូវ ឬស៊ីឈ្នួលគេដើម្បីយកមកសងធនាគារស្រូវវិញ ។

## លោក កែវ សុជាតិ បន្ថែមលើសំណួរទី ២

ក្នុងអង្គការនីមួយៗបើយើងនិយាយពីរឿងគ្រប់គ្រងគឺមានលក្ខន្តិកៈ និងច្បាប់របស់គេ ។ ដូច្នេះក្នុងការងារធនាគារស្រូវនេះមិនមែនជាការងាររបស់អង្គការសុទ្ធទេគឺវាជាការងាររបស់គណៈកម្មការ ហើយគណៈកម្មការគ្រប់គ្រងនេះកើតឡើងដោយការជ្រើសរើសពីអ្នកស្រុកផ្ទាល់។
ហេតុនេះគេអាចដឹងពីសមាសភាពអ្នកប្រើប្រាស់ស្រូវហ្នឹងថា តើគេយកទៅប្រើខុសទិសដៅឬយ៉ាងណានោះគឺគេដឹង ។ តែក្នុងលក្ខន្តិកៈមិនបានចែងឱ្យសមាជិកខ្ចីយកទៅសងចិនទេហើយអ្នកដែលធ្វើរបៀបនេះគឺខុសនឹងលក្ខន្តិកៈ ហើយបើខុសពីលក្ខន្តិកៈខុសទឹងច្បាប់សហគមន៍នោះ គណៈកម្មការអាចមានសិទ្ធិរិបអូសយកស្រូវនោះមកវិញបាន ។

## ព្រះតេជគុណ ញៀម គឹមតេង ឆ្លើយសំណួរទី ៣

ចំពោះសំណួរទី៣ខាងអាត្មាមានតែធនាគារស្រូវពូជ គ្មានធនាគារស្រូវបរិភោគទេគឺឱ្យអ្នកស្រុកខ្ចីយកទៅធ្វើពូជដោយឱ្យឈ្មោះថា *ធនាគារស្រូវពូជ* តែដល់ពេលខ្ចីស្រូវទៅហើយស្រុករាំង ក៏បរិភោគពូជអស់ទៅ ។ លុះដល់ពេលសងមកវិញសងជាស្រូវសំរាប់បរិភោគ រហូតដល់ឥឡូវនេះវាក្លាយទៅជាធនាគារស្រូវសំរាប់បរិភោគទៅហើយបាត់ធនាគារស្រូវពូជអស់ហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

## លោក ម៉ៅ សារ៉េត នាយឧទ្ទេសខេត្តស្វាយរៀងចូលរួមមតិ

ទាក់ទិនទៅនិងសំណួរនេះខ្ញុំមាន៣ចំណុចដែលត្រូវលើកឡើងតែដោយបានស្ដាប់ព្រះតេជគុណនាយកសន្តិសេនាបកស្រាយហើយ ខ្ញុំព្រះករុណានៅសល់តែ២ចំណុចទេ ។ បញ្ហានេះវាទាក់ទងទៅនិងបញ្ហាបាតុភាពអសកម្ម ។ ចំពោះបញ្ហានេះខ្ញុំព្រះករុណាពិចារណាទៅឃើញថា ÷

- ដោយសារគ្រោះធម្មជាតិ
- បរិភោគហើយមិនសងដោយមានជម្ងឺ
- មានចេតនាមិនសង ( ស៊ីម៉ាង )

សំនួរទី១និង២ : ព្រះតេជគុណនាយកសន្តិសេនាបានបកស្រាយយ៉ាងពេញចិត្តខ្ញុំព្រះករុណាជាទីបំផុត ហើយជាវិធានការមួយដ៏ត្រឹមត្រូវបំផុតក្នុងការជួយសង្គ្រោះប្រោសប្រណីដល់អ្នកក្រីក្រ ។ តែបញ្ហាទី៣នេះគឺជាបញ្ហាខ្លីហើយមិនសងមិនមែនថាមិនមានទេតែមានហើយមិនសងហើយព្រះតេជគុណថាត្រូវតែមានវិធានការចាប់បង្ខំឱ្យសង។ តើការចាប់បង្ខំនេះធ្វើតាមវិធានការបែបណាទៅប្ដឹង ឬ ទៅទារឱ្យញឹកញាប់ ?

បញ្ហាទី២: សុំសួរទៅគណៈកម្មការធនាគារស្រូវឬក៏អង្គការនានាដែលយកចិត្តទុកដាក់ក្នុងការបង្កើតគណៈកម្មការធនាគារស្រូវឬសមាគមស្រូវ ។ ខ្ញុំព្រះករុណាសុំសួរថា តើសមាជិកមានការថ្នាំងថ្នាក់ជាមួយគណៈកម្មការឬទេ? ហើយតើដែលមានសមាជិកណាមួយសុំដកសមាជិកភាពពីធនាគារស្រូវដែរឬទេ ? ព្រោះកន្លងមកខ្ញុំព្រះករុណាធ្លាប់មានបទពិសោធន៍ក្នុងសម័យរដ្ឋកម្ពុជា ។ ដោយពេលនោះប្រជាពលរដ្ឋយើងមានការអត់ឃ្លានហើយរដ្ឋាភិបាលបានយកអង្ករមកចែកឱ្យគ្រប់គ្នា។ ដល់ពេលប្រមូលវិញគឺប្រមូលមិនបាន

www.budinst.gov.kh www.elibraryofcambodia.org

សោះ។ និយាយពីប្រធានភូមិ-ឃុំមុខមិនរីកឡើយរហូតដល់សព្វថ្ងៃគឺមិនបាន សងទេហើយមិនមានគុណទៀត។សុំសួរថាតើសមាគមធនាគារស្រូវមានសមាជិកប្រភេទនេះទេ ?

បទពិសោធន៍មួយទៀតគឺបងស្រីបង្កើតខ្ញុំព្រះករុណាម្នាក់ បងជីដូនមួយម្នាក់ ។ បងជីដូនមួយមកខ្ចីលុយពីបងស្រីបង្កើតខ្ញុំហើយធម្មតាអ្នកមកខ្ចីមានកាយវិការទន់ភ្លន់ណាស់តែងតែនិយាយថា : ខ្ញុំមិនដូចគេទេគេខ្ចីគេមិនសងតែខ្ញុំមិនដូចគេទេ ។ ដល់បានលុយទៅស្ងាត់ឈឹង ។ បងស្រីខ្ញុំទៅសួរម្តងជាពីរដងមុខនៅញញឹមដល់ឡើងដល់ប្អូនដប់ដងមុខស្មើ។ យូរទៅៗចេញពាក្យថា: យីស ! ពិបាកអីម៉េះ បើកុំតែឯងឱ្យអញខ្ចីអញក៏មិនជំពាក់ដែរ ។

## ព្រះតេជគុណ ភឿម គឹមតេង ឆ្លើយបំភ្លឺជូនអង្គសិក្ខាសាលា

លោក ម៉ៅ សាម៉េត បានសួរអំពីបញ្ហាដែលអ្នកខ្ចីហើយមិនព្រម សងថាតើអង្គការឬគណៈកម្មការធនាគារស្រូវមានវិធានការយ៉ាងណាខ្លះចំពោះអ្នកដែលខ្ចីហើយមិនសងនោះ ? ហើយតើវិធានការនេះត្រូវប្រើធម៌ក្តៅ ឬធម៌ត្រជាក់ ? បានសេចក្តីថាត្រូវចូលទៅឱ្យបានញឹកញាប់ឬក៏ត្រូវប្រើច្បាប់ ? តើកន្លងមកនេះដែលមាន សមាជិកធនាគារស្រូវណាម្នាក់សុំដកពាក្យចេញពីសមាជិកភាពដែរឬទេ ?. ហើយថាតើធ្លាប់មានសមាជិកណាមួយមានការថ្នាំងថ្នាក់ ឬ ក៏មានពាក្យមិនពីរោះ ឬ មើលងាយដល់គណៈកម្មការដែរឬទេ ?

ក្នុងសំណួរនេះ ខ្ញុំព្រះករុណា អាត្មាភាព សូមឆ្លើយដោយខ្លីៗទៅតាមស្ថានភាពដែលសន្តិសេនាបានជួបប្រទះកន្លងមក ។ កន្លងមកនេះការខ្ចីមិនសងតែងតែមានគឺវាស្ទើរតែនៅគ្រប់ភូមិទៅហើយ ជាពិសេសគឺអ្នកដែលមាន

www.budinst.gov.kh www.elibraryofcambodia.org

ទ្រព្យសម្បត្តិល្មមមិនជាក្រណាស់ណាទេ ពោលគឺអ្នកមានបរិភោគគ្រប់គ្រាន់មិនស្វរសេងទេ ហើយយើងបានប្រើវិធី ៣យ៉ាង គឺ ÷

១. យើងប្រើតាមរយៈប្រពៃណីយសាសនាដោយប្រើពាក្យថាបាប បុណ្យ ។ ឧទាហរណ៍ : ខ្ចីស្រូវមិនសង អ្នកនឹងត្រូវជំពាក់កម្មពៀរវេរានេះទៅជាតិមុខទៀតដោយជាតិមុនអ្នកនឹងត្រូវទូលស្រូវដើររកម្ចាស់គេគ្រប់ចំនួនគ្រាប់ស្រូវដែលខ្ចី ។

២. យើងចុះពន្យល់ឱ្យបានញឹកញាប់ដល់ផ្ទះស្តីពីទំនាក់ទំនង ពីគោលការណ៍ដើម្បីឱ្យអ្នកនោះយកស្រូវមកសងវិញ ។

៣. ពេលដែលសមាជិកគ្រួសារមួយមកខ្ចី យើងសុទ្ធតែមានចុះកិច្ចសន្យាមានលិខិតស្នាមជាលាយល័ក្ខអក្សរច្បាស់លាស់រវាងភាគីទាំងសងខាង ។

ចំណុចមួយទៀត ថាតើមានគេដកឈ្មោះចេញពីសមាជិកភាពទេ ? កន្លងមកនេះ ចំពោះអង្គការសន្និសេនាមិនទាន់មានអ្នកសុំដកសមាជិកភាពទេ តែមានអ្នកសុំចូលជាសមាជិក ដោយមិនចាំបាច់ខ្ចីស្រូវពីធនាគារ គឺគាត់សុំឱ្យតែមានឈ្មោះនៅក្នុងធនាគារស្រូវ ហើយគាត់និងបរិច្ចាគស្រូវគាត់មួយចំនួនដាក់ចូលក្នុងធនាគារស្រូវដើម្បីជាទុនទុកឱ្យអ្នកក្រីក្រខ្ចី ។ សរុបមកគឺគ្មានទេចំពោះការដកសមាជិកភាពចេញពីធនាគារស្រូវ ។

ចំពោះខាងពាក្យសំដីមិនសមរម្យមើលងាយមើលថោកដល់ គណៈកម្មការវិញជាការធម្មតាទេជួនកាលអ្នកនោះទៅតាមម្តងជាពីរដងទៅដូចលោកម៉ៅ សារ៉េត បានមានប្រសាសន៍រួចមកហើយ ។ តែក្រោយពីការយល់ពីបញ្ហានេះគេក៏លែងមានទំនាស់ជាមួយគណៈកម្មការទៀតដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

## សំណួរសិក្ខាកាមមកពីខេត្តកំពង់ធំ

១- ព្រះតេជគុណនាយកសន្តិសេនាបានផ្តល់អង្គរដើម្បីទប់ស្កាត់ការកាប់ដើមឈើហេតុនេះខ្ញុំចង់ដឹងដែរព្រោះខាងខ្ញុំព្រះករុណាការងាររកអង្គរនេះពិបាកណាស់ ?

២- ការធ្វើនេះ តើតាមរយៈវត្ត ឬចូលទៅក្នុងភូមិត្រង់តែម្តង

៣-ពេលមានគំរូអាក្រក់ដល់កន្លែងដទៃគេអាចយកគំរូតាមទេបើសិនណាគេបំផ្លាញរបស់លោកបន្តិចបន្តួចលោកអាចនឹងផ្តល់អង្គរឱ្យ ។ ដូច្នេះតើវាអាចជាមេរៀនមួយបានដែរឬទេ ?

ខ្ញុំព្រះករុណាសុំសួរខាងខេត្តបាត់ដំបងអំពីការបង្កើតធនាគារស្រូវដែលពាក់ព័ន្ធដាច់ខាតជាមួយអាជ្ញាធរមូលដ្ឋាន ។ ត្រង់នេះយើងខ្ញុំសូមឯកភាពព្រោះការងារនេះយើងមិនអាចចោលអាជ្ញាធរមូលដ្ឋានបានទេ តែខ្ញុំសូមសួរថាតើយើងពាក់ព័ន្ធជាមួយអាជ្ញាធរមូលដ្ឋានត្រឹមណាត្រឹមភូមិ ឃុំ ឬស្រុក ?

១. សួរថាចំពោះការពាក់ព័ន្ធអាជ្ញាធរនេះតើអង្គការដែលជាអ្នកទទួលខុសត្រូវទៅពាក់ព័ន្ធខ្លួនឯង ឬដៃគូដែលពាក់ព័ន្ធទៅធ្វើឱ្យ ។

២. យើងខ្ញុំចង់សួរទៀតថា បើយើងដឹកអង្គរយកទៅឱ្យឬក៏យើងផ្តល់លុយឱ្យទៅតើខាងនោះមានការជួបការលំបាកខ្លះទេ ?

៣. អំពីលទ្ធផលសំណាងឃើញថាបានរៀបរាប់ហើយ ។

៤. ចំពោះធនាគារស្រូវដែលកន្លងមកហើយខ្ញុំព្រះករុណាខ្ញុំបាទដឹងពីអត្រាបាត់បង់នូវស្រូវទាំងអស់ហ្នឹង តើមានការជួបលំបាកក្នុងការបាត់បង់លើអ្វីខ្លះ ? បាត់បង់មានប៉ុន្មានភាគរយ ? ព្រោះធម្មតាស្រូវបាត់បង់ទី ១ ដោយការស្រកចុះ ទី ២ ដោយកណ្តុរ ឬ មាន់ស៊ី ។

www.budinst.gov.kh www.elibraryofcambodia.org

សុំសួរទៅអង្គការជប៉ុន ( JSRC )ឃើញថាអង្គការជប៉ុនបានផ្តល់ច្រើនជាងអង្គការGTZខេត្តកំពង់ធំ។ ខាងកំពង់ធំផ្តល់មួយទល់នឹងមួយឯអង្គការជប៉ុនផ្តល់ ៣ ទល់នឹង ១ ឃើញថាច្រើនប្រជាពលរដ្ឋមិនមានក៏បានដែរគឺអាចទៅរួច ។ ផ្តល់ ៣ ទល់នឹង ១ តើផ្តល់នៅពេលណា ? ហើយមួយខាងប្រជាពលរដ្ឋតើត្រូវបានស្រូវបានអង្ករយកមកឃើញសិនឬក៏គ្រាន់តែមានគំរោងក្នុងក្រដាស់ទេ ?

## ចម្លើយរបស់តំណាងអង្គការសន្តិសេនា

ទី១-ការផ្តល់ស្រូវមាន៣ផងតើការផ្តល់ឱ្យនៅពេលណា? សុំឆ្លើយជូនគឺក្រោយពីមានការប្រជុំថ្នាក់សហគមន៍ហើយគឺសហគមន៍ប្រជុំសមាជិកហើយប្រកាសថាយើងប្រមូលស្រូវបាន១តោន អង្គការគេជួយ៣តោន ដល់អញ្ចឹងទៅខាងប្រជាពលរដ្ឋគេយកស្រូវមកដាក់មុនមួយគ្រួសារ១០គ.ក្រឬ២០គ.ក្រតាមសទ្ធាជ្រះថ្លា។ ដាក់ឃើញស្រូវទាំងបាវៗគរទុកនៅលើសាលាឆាន់ហើយបានកំណត់ថាយកចំនួនស្រូវដែលបានហ្នឹងទៅប្រគេនលោកៗក្នុងការប្រគេនគឺមិនប្រគេនជាសាច់ប្រាក់ទេគឺប្រគេនជាចំនួនស្រូវ ។ ឧបមាថាស្រូវ៣តោនប្រគេន៣តោនតែម្តងអញ្ចឹងបានន័យថាគឺប្រគេន ។ ក្រោយពីបានស្រូវដែលសមាជិកដាក់រួចហើយពេលវេលាដែលប្រគេននោះសំខាន់គឺពេលដែលសមាជិកមានមិនថាពេលណាទេព្រោះអស់លោកចង់បង្កើតនៅ ខែ១ ឬ ២ ឬ ៣ ក៏បានដែរ ។ ប៉ុន្តែក្នុងកន្លែងណាដែលយើងខ្ញុំសាងសង់សាលារៀនរួចមិនមែនបានគ្រប់កន្លែងទេ។ដូច្នេះឃើញថាសមាគមអាចដំណើរការអភិវឌ្ឍន៍ទៅបាន ព្រោះខាងយើងខ្ញុំមិនមែនជួយសាលារៀនហើយលែងដៃចោលទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយការកសាងសាលារៀនបន្តធ្វើការអភិវឌ្ឍន៍មានធនាគារស្រូវបណ្តុះកូនឈើជាហូរហែរដូចជាជួយដល់ព្រះតេជគុណ ពោធ ម៉ាន ជាដើម ។ មានន័យថា ជួយសាលារៀនហើយជួយពិនិត្យសកម្មភាពនេះទៀតថា តើសកម្មភាពនេះដើរទេអាចដំណើរការបានទេបើវាមានដំណើរការដល់ពាក់កណ្តាលផ្លូវដួលក៏មិនអាចជួយបានដែរ ។

## ព្រះតេជគុណ ញៀម គឹមតេង អធិប្បាយបន្ថែម

អំពីរឿងផ្តល់អង្ករសំរាប់ទប់ស្កាត់ការកាប់ឈើសូមជំរាបថាខាងអង្គការមនុស្សធម៌ អង្គការកម្មវិធីស្បៀងអាហារពិភពលោកគេមានខ្ទង់មួយគឺសំរាប់ជួយសង្គ្រោះដល់ជនរងគ្រោះដូចជា ទឹកលិច ឬ ក៏រាំងស្ងួត ឬ ខ្យល់ព្យុះហៅថារងគ្រោះដោយធម្មជាតិ ។ នៅឆ្នាំ១៩៩៤អង្គការហ្នឹងបានឈរជើងធ្វើសកម្មភាពនៅខេត្តស្វាយរៀងហើយដោយពេលនោះខេត្តស្វាយរៀងកំពុងទទួលរងគ្រោះរាំងស្ងួត។ ដូច្នេះហើយអង្គការសន្តិសេនាបានចុះធ្វើការស្រាវជ្រាវរកជនរងគ្រោះដោយធម្មជាតិនិងបានធ្វើជាបញ្ជីឈ្មោះគ្រួសារទាំងនេះដោយមានការបញ្ជាក់ពី រដ្ឋអំណាចមូលដ្ឋានត្រឹមត្រូវ ក៏បានដាក់ជូនទៅខាងអង្គការស្បៀងអាហារពិភពលោកដើម្បីជំនួយតាមសំណូមពរដែលយើងបានសុំ។ លុះដល់គេឱ្យស្បៀងមកយើងបានយកស្បៀងនោះទៅច្នៃធ្វើជាធនាគារស្រូវដើម្បីឱ្យបានជាទុនព្រោះបើឱ្យទទេៗទៅអ្នកស្រុកហូបអស់ ។ ហេតុនេះដើម្បីឱ្យបានជាផលប្រយោជន៍យូរអង្វែងយើងក៏បង្វែរជំនួយនោះជាធនាគារស្រូវវិញតាំងពីឆ្នាំ ១៩៩៤ រហូតមកដល់ ១៩៩៧នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ចំណុចមួយទៀតដែលសួរថាតើការផ្តល់តាមរយៈវត្តឬក៏តាមរយៈណា? គឺផ្តល់តាមរយៈអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកឬតាមរយៈសមាគមក្នុងស្រុក ព្រោះធម្មតាជំនួយជាស្បៀងដូចនេះគេមិនដែលឱ្យទៅបុគ្គលម្នាក់ៗបានទេ គេឱ្យទៅសមាគម ឬ អង្គការដែលមានក្របខ័ណ្ឌត្រឹមត្រូវហើយធ្លាប់មានបទពិសោធន៍និងទទួលស្គាល់ពីអាជ្ញាធរដែនដីទៀតផង។ លុះដល់គេផ្តល់ឱ្យហើយ ខាងសន្តិសេនាក៏ចាប់ផ្តើមបង្កើតជាគណៈកម្មការទទួលខុសត្រូវតែម្តងទៅ ។

## លោក ស៊ិន សឿប បកស្រាយបន្ថែមលើបញ្ហាដែលពាក់ព័ន្ធ

តាមផ្លូវច្បាប់មេភូមិមិនទាន់ជាផ្លូវការទេ គឺចាប់ពីថ្នាក់ឃុំឡើងទៅទើបមានច្បាប់ចាត់តាំងដែលហៅថាគណៈកម្មាធិការឃុំ ព្រោះគណៈកម្មការនោះជាស្ថាប័នរបស់រដ្ឋាភិបាល ។ ដូច្នេះមេភូមិគ្រាន់តែជាការតែងតាំងដើម្បីជួយការងារប៉ុន្តែមិនអាចយកជាផ្លូវការបានទេ ។ លោកប្រហែលជាជ្រាបហើយថា និតិវិធីដូចជាការផ្ទេរប្លង់ ឬ ការផ្ទេរសម្ភារៈអ្វីមួយជាផ្លូវការត្រូវឆ្លងកាត់ដល់ឃុំសិនព្រោះជាស្ថាប័នរបស់រដ្ឋាភិបាល ។ ដូច្នេះយើងមានទំនាក់ទំនងរហូតដល់ឃុំប៉ុន្តែឆ្លងតាមរយៈមេភូមិដែរ ។ សរុបសេចក្តីទៅការទំនាក់ទំនងការងារគឺត្រូវពាក់ព័ន្ធដល់ឃុំយ៉ាងទាប ។

តើការទៅទាក់ទងជាមួយរដ្ឋអំណាចទៅដោយខ្លួនឯង ឬ ក៏ឱ្យដៃគូទៅទាក់ទង ? ជាធម្មតាយើងជាអង្គការទៅបោះទីតាំងដូច្នេះត្រូវទៅទាក់ទងដោយខ្លួនយើងផ្ទាល់ ដើម្បីបង្ហាញពីគោលគំនិតនិងគោលបំណងរបស់យើងឱ្យអាជ្ញាធរគេបានដឹងងាយស្រួលឱ្យគេចូលរួមជាមួយយើងផង ។

តើអត្រានៃការបាត់បង់ប៉ុន្មានភាគរយ ? ជាទូទៅផលិតផលដែលទាក់

www.budinst.gov.kh www.elibraryofcambodia.org

ទងលើកសិផលឬលទ្ធផលខាងរុក្ខផលគឺតាមធម្មតាគេកាត់ចោល ៥ភាគរយ ហើយអ្វីក៏ដោយគ្រាន់តែលើកដាក់លើឡានហើយទំលាក់ចុះវិញដាច់ខាតត្រូវតែកាត់ចេញ៥ភាគរយតែបើតាមពាណិជ្ជកររគេកាត់ចោល៦ភាគរយ។ ដូច្នេះមិនត្រឹមតែស្រូវទេទោះបីពោត សណ្តែក ល្ង រហូតដល់ផ្លែឈើអ្វីក៏ដោយ ។ ចំណែកឯស្រូវវិញយើងកាត់ទៅលើការស្រកចុះស្វិតស្រពោនសត្វស៊ីរុះរោយ រិចរិលអស់៥ភាគរយអាចលើស ឬក៏ខ្វះបន្តិចបន្តួចតាមគុណភាពស្រូវដែលយើងទទួល ព្រោះបើស្រូវសើមនោះវាបាត់ច្រើនតែបើយើងទទួលស្រូវស្ងួតវិញវាក៏បាត់តិចដែរ ។

## ព្រះតេជគុណ យឿន យឿត ចន្ទ្រង្សីគិរី ខេត្តបាត់ដំបង ឆ្លើយបន្ត

តើការដឹកអង្ករទៅជួយឬទៅចែកតើមានបញ្ហាអ្វីកើតឡើង ? អាត្មាដឹងថាលោកចង់និយាយពីអ្វីហើយ ។ ប៉ុន្តែបញ្ហានេះវាមានខ្លះដែរក្នុងរឿងហ្នឹងតែយើងបានដោះស្រាយទៅវិញហៅថា ការយោគយល់គ្នាបង្ហាញអំពីរបៀបមនុស្សធម៌ថាតើរបស់នេះយើងបានមកពីណា?ឧទាហរណ៍: អំណោយខ្លះបានមកពីការមិនទទួលទានអាហាររបស់សប្បុរសជនមួយថ្ងៃ។ ដូចខាងសមាគមនិស្សិតសាលាខ្លះមួយថ្ងៃគេទទួលអាហារូបករណ៍ ១ដុល្លារ ហើយគេមានគ្នា ២០០ ឬ ៥០០នាក់គេអាចឈប់ទទួលទានមួយថ្ងៃដើម្បីសន្សំលុយមួយចំនួនទុកមកបរិច្ចាគជាទានដល់អ្នកអត់ឃ្លាន ។ ដូចនេះអំណោយដែលយើងបានទទួលនេះគឺជាទានដែលគេបរិច្ចាគមកអញ្ចឹងយើងពន្យល់ប្រាប់អាជ្ញាធរឱ្យគេមានការយោគយល់គ្នាទៅវិញទៅមកទៅឃើញថាបានស្រួលហើយ ។ ប៉ុន្តែកិច្ចការនេះគឺធ្វើតាមរយៈសាសនា គឺ ព្រះសង្ឃចំណែកខាងគ្រហស្ថមិនដឹង

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងម៉េចដែរទេ ។

**សំនួរព្រះតេជគុណ ហេង គឹមហុន ចន្ទពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង**

បច្ចុប្បន្ននេះយើងធ្វើធនាគារស្រូវតាមរយៈព្រះពុទ្ធសាសនា យើងថាល្អ សុំសួរថា តើទៅអនាគតវាមានការប៉ះពាល់ចំពោះកិត្តិយស ព្រះពុទ្ធសាសនាដែរឬទេ ?

**ចម្លើយព្រះតេជគុណ ឡឿម គឹមគេង**

រឿងនេះគឺអាស្រ័យទៅគុណសម្បត្តិរបស់ព្រះសង្ឃ ដូច្នេះយើងត្រូវវែកញែកដើម្បីឱ្យឃើញថាព្រះសង្ឃដែលមានគុណសម្បត្តិគួរលើកសរសើរ និងព្រះសង្ឃដែលពុំទាន់មានគុណសម្បត្តិតើគួរដាស់តឿនក្រើនរំលឹក? ខ្ញុំព្រះករុណា អាត្មាភាពសូមគាំទ្រគំនិតព្រះអង្គទាំងស្រុង ។

រឿងព្រះពុទ្ធសាសនាដូច ខ្ញុំព្រះករុណា បានទូលពីព្រឹកមិញម្តងហើយ កាលដែលព្រះសង្ឃ និង ពុទ្ធបរិស័ទជួយគ្នាទៅវិញទៅមកជារឿងមួយដែលមានក្នុងច្បាប់ព្រះពុទ្ធសាសនារួមសុខទុក្ខជាមួយគ្នាព្រះអង្គក៏អាចយល់ពីបញ្ហានេះហើយ បើយើងគិតពីបច្ចុប្បន្ននេះតើយើងត្រូវធ្វើ អ្វីខ្លះ ដើម្បីសង្គម ? ហើយពីមុនមកតើយើងបានធ្វើអ្វីខ្លះ?យើងក៏ត្រូវយល់ឱ្យច្បាស់ថាសង្គមយើងកំពុងតែកើតមានបញ្ហា ។ ដូច្នេះបើយើងមើលឃើញបញ្ហានោះហើយ យើងចាប់ផ្តើមរកឫសគល់នូវបញ្ហានេះមកដោះស្រាយតាមរបៀបអរិយសច្ចៈទាំង៤ ( ទុក្ខៈ, ទុក្ខសមុទយៈ, ទុក្ខនិរោធៈ និងទុក្ខ និរោធគាមិនី) បើយើងបដិបត្តិ

www.budinst.gov.kh www.elibraryofcambodia.org

តាមអរិយៈធម៌ទាំង៤ដែល ព្រះពុទ្ធបរមគ្រូបានត្រាស់ដឹង និងសំដែងទុកមក យើងឃើញថាពុទ្ធបរិស័ទសង្គមយើង កំពុងតែជួបប្រទះនូវភាពក្រីក្រកំពុងតែខ្វះអាហារទទួលទានជាដើមគឺយើងត្រូវរកឫសគល់នៃភាពក្រីក្រភាពខ្វះខាតស្បៀងអាហារនេះឱ្យឃើញ ហើយចាប់ផ្តើមដោះស្រាយនូវសមុដ្ឋានរបស់វាឱ្យជ្រះស្រឡះ។ សួរថាតើទៅអនាគតមានការប៉ះទង្គិចទៅលើព្រះពុទ្ធសាសនាដូចម្តេចខ្លះ ? ខ្ញុំព្រះករុណាយល់ថា ឥឡូវនេះមានសាសនាច្រើនចូលមកធ្វើសកម្មភាពផ្សព្វផ្សាយជំនឿនៅក្នុងប្រទេសយើងហើយការផ្សព្វផ្សាយរបស់គេភាគច្រើនធ្វើតាមរយៈជំនួយមនុស្សធម៌តាមការជួយផ្គង់ផ្គង់ជីវភាពប្រជាពលរដ្ឋជាដើម ហើយបើសិនជាយើងមិនចាប់អារម្មណ៍រឿងនេះទេយើងនៅតែស្ងៀមក្នុងវត្ត ខ្ញុំព្រះករុណាយល់ថាវាជាផលមួយមិនល្អទៅអនាគតព្រោះអ្នកស្រុកពិតជាមើលឃើញថា អ្នកណាខ្លះដែលចូលមកជិតគេអ្នកណាដែលបានជួយគេក្នុងពេលដែលគេកំពុងតែជួបប្រទះនូវការលំបាក។ ពេលនោះពុទ្ធបរិស័ទគេនឹងងាកចេញពីពុទ្ធសាសនា។ព្រះអង្គអាចយល់ពីទំព័រប្រវត្តិសាស្ត្រស្រុកខ្មែរយើងហើយតាំងពី សតវត្សរ៍ទី១ ពីបុរេប្រវត្តិរហូតមកដល់បច្ចុប្បន្ននេះ តើស្រុកខ្មែរយើងបានផ្លាស់ប្តូរសាសនាអស់ប៉ុន្មានដងហើយ ។ យើងឃើញថាមានការផ្លាស់ពីព្រហ្មញ្ញសាសនាទៅសាសនាហីនយានឬថេរវាទទៅជាសាសនាមហាយានក្រោយមកទៅជាព្រហ្មញ្ញក្រោយមកទៅជាហីនយាន។ ការផ្លាស់ប្តូរនេះគឺដោយសារសាសនានិមួយៗឬអ្នកដែលនៅក្នុងសាសនានោះគេបង្ហាញនូវគុណសម្បត្តិរបស់គេដើម្បីជួយដល់សង្គម ។ ដូច្នេះពេលនោះមនុស្សដែលរស់នៅក្នុងសង្គមដែលផ្តល់នូវផលប្រយោជន៍ដែលចាប់អារម្មណ៍លើបញ្ហារស់នៅរបស់គេហើយប្រសិនបើបច្ចុប្បន្នយើងជួយដល់ប្រជាពលរដ្ឋឱ្យបានខ្លាំងក្លាអនាគតយើងនឹងទទួលបាននូវផលល្អមែនទែន ហើយមិនត្រឹម

www.budinst.gov.kh www.elibraryofcambodia.org

តែពុទ្ធបរិស័ទ៩៥ភាគរយទេដែលគាំទ្រពុទ្ធសាសនា គឺអាចកើនឡើងលើស នេះទៅទៀតបើយើងប្រឹងប្រែងជួយដល់សង្គម ។ រឿងធនាគារស្រូវនេះពិត មែនតែមានទទួលនូវអត្រាការសងត្រឡប់វិញតែវាមិនមែនជាការធ្វើជំនួញទេ ហើយការយកការនេះ គឺ ÷

១- ដើម្បីទប់ស្កាត់ការបាត់ទៅវិញ

២- ដើម្បីបង្កើនទុនឱ្យកើនតទៅទៀត

ការពិតរឿងធនាគារស្រូវនេះយើងចង់គ្រប់គ្រងឱ្យមាន ស្ថិតិច្បាស់លាស់ថា តើក្នុងមួយឆ្នាំៗវាកើនឡើងបានប៉ុន្មានហើយថយចុះប៉ុន្មានព្រោះជួនកាល យើងធ្វើច្រើនស្មានដោយអាងថាវារបស់វត្ត ។ ដូច្នេះយើងត្រូវគិតគូរដល់ រឿងបាត់បង់ផង ។ ឧទាហរណ៍ព្រះអង្គទិញរថយន្តមួយគ្រឿងតំលៃ៤០០ ដុល្លារសំរាប់ជួយដល់ពុទ្ធបរិស័ទ ព្រះអង្គត្រូវគិតពីចំណូលខ្លះព្រោះរថយន្ត នោះវានឹងខូចនៅថ្ងៃណាមួយមិនខានគឺគ្មានអ្វីទប់ទល់វាទេ។ ហេតុនេះយើង ត្រូវរកវិធានការខ្លះដើម្បីរកចំណូលសំរាប់ទប់ទល់ពេលរថយន្តខូច ។ ដូច្នេះ បើយើងធ្វើធនាគារស្រូវក្នុងន័យមេត្តាករុណា ទៅថ្ងៃអនាគតមិនមានអ្វីដែល ប៉ះពាល់ដល់ពុទ្ធបរិស័ទទេប៉ុន្តែបើយើងធ្វើក្នុងន័យពាណិជ្ជកម្មរឿងនេះវាមាន ផលប៉ះពាល់ដល់ព្រះពុទ្ធសាសនា ។

**លោក គិន ណាន ឡើងបញ្ជាក់បន្ថែម**

តាមខ្ញុំគិតចាប់ពីថ្ងៃនេះទៅបើព្រះពុទ្ធសាសនាពុំស្វែងរកតួនាទីឡើងវិញ ទេនោះព្រះពុទ្ធសាសនានឹងស្លាប់បាត់ជាមិនខាន ព្រោះព្រះពុទ្ធលោកមានឥទ្ធិ ពលពីរទៅលើមនុស្សលោកយើងនេះ ÷

www.budinst.gov.kh www.elibraryofcambodia.org

១- សម្មាសម្ពោធិញ្ញាណ

២- បាដិហារ

សួរថាតើព្រះសង្ឃយើងមានសម្មាសម្ពោធិញ្ញាណឬទេ ? មានបាដិហារឬទេ? គឺថាអត់មានទេដើម្បីឱ្យរបស់យើងមានបានត្រឡប់មកវិញនោះហើយដើម្បីឱ្យទៅជាគ្រូគេឡើងវិញនោះ ។ យើងសព្វថ្ងៃឃើញថាគ្រាន់តែសង្គមមួយដែលគេដកយកពីយើងទៅមកពីយើងដឹងថាវាអស់លទ្ធភាពទូន្មានប្រៀនប្រដៅគេចំណេះយើងវាទាបបានជាគេដកយកទៅពីយើងអត់ចេះ យើងចេះតែត្រឹមស្រះអ ស្រះអា ករអើយក ចេះត្រឹមពញាយនាយ ម្ល៉ោះហើយបានជាគេដកវិញមកពីយើងវាមិនកើត ។ អញ្ចឹងធ្វើម៉េចដើម្បីឱ្យមានសម្មាសម្ពោធិញ្ញាណឡើងវិញឱ្យមានបាដិហារឡើងវិញ ? ថាអត់ទេយើងមិនអាចធ្វើបានដូចព្រះទេ យើងធ្វើត្រឹមតែប៉ុណ្ណោះបានហើយព្រោះសម្មាសម្ពោធិញ្ញាណមានន័យថានិយាយាបានពន្យល់គេបាន ។ បាដិហារមានន័យថាធ្វើកើតហើយធ្វើប៉ុណ្ណឹងបានអាចដណ្តើមតួនាទីបាន ដូចព្រះអង្គនាយកសន្តិសេនាមានពុទ្ធដីកាពន្យល់អ្នកស្រុកធ្វើកើត ។ ចុះតើការធ្វើនេះខុសធម៌វិន័យទេ ? ថាមិនមានខុសទេព្រោះយើងយកសង្គហធម៌ទាំង៤ : ទានវិយ អត្ថចរិយា សមានត្តតាការធ្វើនេះសុទ្ធតែក្នុងទានទាំងអស់ ឥតមានខុសវិន័យទេ ។ អនេសនៈ ២១ បាបធម៌ ៥ អត់មានចូលក្នុងនឹងផងយើងទៅភ័យព្រួយអ្វី ។ បើភ័យព្រួយដូចព្រះអង្គមានបន្ទូលថា ភ័យព្រួយព្រះពុទ្ធសាសនាគ្មានតួនាទីក្នុងសង្គមខ្មែរទៅអនាគត ។ តួនាទីសាសនាចាំតែទទួលពិធីការចាំតែមានខ្មោចគេមកនិមន្តគ្មានផលប្រយោជន៍អ្វីទេ យូរៗទៅគង់តែសាសនាកាតូលិកចូលមកយកទ្រព្យព្រះពុទ្ធសាសនារបស់យើង គេយកទានព្រោះគេថាសង្គមខ្មែរខ្វះទានហើយសាសនាយើងអត់គិតគូរទេអញ្ចឹងគេបោះបង់ចោលកុំទៅបន្ទោសថាគេមិនរាប់

www.budinst.gov.kh www.elibraryofcambodia.org

រកអញអាចដឹងខ្លួនឯងហើយ ។ ឥឡូវនេះចាប់គិតពីនឹងទៅនូវអ្វីដែលព្រះពុទ្ធមានដូចជា ÷ សមាសម្ពោធិញ្ញាណ ១, បាដិហា ១, ទោះបីយើងធ្វើមិនដូចព្រះពុទ្ធបានតែយើងធ្វើត្រឹមថាសមាសម្ពោធិញ្ញាណមានន័យថាអាចពន្យល់គេបាននិងបាដិហារអាចធ្វើខ្លួនឯងបានពីរហ្នឹងបានហើយ ។ បច្ចុប្បន្ននេះតួនាទីរបស់យើងមាន ២ ÷

១- ជីវភាពខាងសម្ភារ:

២- ជីវភាពខាងស្មារតី

ទាំងពីរដែលព្រះអង្គធ្វើនេះ គឺជាជីវភាពសម្ភារៈហើយគ្មានទើសទាស់ក្នុងព្រះវិន័យទៀតផង ។ បើអញ្ចឹងព្រះពុទ្ធសាសនាមាន២ហ្នឹងពន្យល់បាន , ធ្វើបានធ្វើកើត។ ចុះអ្វីទៅដែលហៅថាការអភិវឌ្ឍន៍? គឺការធ្វើឱ្យមានលុយចាយមានបាយបរិភោគមានផ្ទះនៅមានមន្ទីរពេទ្យមានសាលារៀនមានការងារធ្វើគឺធ្វើទៅតាមដំណើរទាំងនេះឥតមានខុសទេ ។ ទៅអនាគតយើងចាប់យកអ្វីតទៅទៀតគ្រាន់តែថាផ្នែកធនាគារស្រូវចប់យើងចាប់យកមុខរបរអ្វីទៀត ? ឧទាហរណ៍យើងដាំដើមឈើនេះក៏ជាផ្នែកមួយដែរ ។ ឥឡូវនេះនៅកំពង់ចាមគេដាំដើមផ្កាចំប៉ីហើយផ្កាចំប៉ីស្រស់១០គ.ក្រ បាន៣គ.ក្រ ក្រៀមហើយលក់បាន១ដុល្លារក្នុងមួយគីឡូក្រាមក្នុង១០០ដើមបាន៣០ទៅ៤០គ.ក្រ ហើយមានគេមកទិញទៀតនេះរិតតែឥតមានខុសវិន័យទៀត ។ អញ្ចឹងមនុស្សដែលអត់ការងារធ្វើខាងព្រះពុទ្ធសាសនាអាចដឹកនាំក្នុងរឿងទាំងអស់នោះបាន ។ ខ្ញុំព្រះករុណាសូមផ្ដាំនាយកសន្តិសេនាផងថា បើការងារល្អតលាស់ហើយគួរតែបញ្ជូនគ្នាយើងណាដែលមានលទ្ធភាពទៅសិក្សាស្រុកស្បៀម ពីរឿងផ្លែសាវម៉ាវ,ខ្នុរ,ត្រពាំងបាយជូរផងព្រោះស្រុកគេរីកចំរើនណាស់។ មើលប្រទេសអ៊ីស្រាអែល ក្នុងពិភពលោកទាំងមូលមានតែប្រទេសអ៊ីស្រាអែលទេដែលពូកែ

www.budinst.gov.kh www.elibraryofcambodia.org

ដាំដើមឈើជាងគេគឺដាំលើដីខ្សាច់។

បើយើងចេះតែល្ងូតលាស់ៗហើយគ្មានទើសវិន័យដល់ពេលហ្នឹងព្រះពុទ្ធសាសនាយើងដើរតួនាទីធំតែម្តងហើយគេស្រឡាញ់ជាមិនខាន ។ បើយើងមិនដែលផ្តល់អ្វីឱ្យអ្នកស្រុកចាំតែកុសលធម្មាអកុសលធម្មាគេនឹងបោះបង់យើងចោលរួចគេទៅចូលកាតូលិកហើយ ព្រោះគេបានជួយផ្តល់ឱ្យអ្នកស្រុកហើយពេលនោះយើងទៅដល់ត្រង់ណាអស់ត្រង់នោះវិចគេត្រង់នោះ អស់ប្រហុកអស់ផ្អកគេ គេឈប់រាប់អាន ហើយយើងនឹងស្លាប់ឯង ។

## សំណួរលោក ជឹម មុនី មន្ត្រីកម្មវិធីធនាគារស្រូវអង្គការ ព.ជ.អ

យោងតាមសំណួរនិងចំលើយជាច្រើនបានបំភ្លឺយ៉ាងច្បាស់លាស់អំពីការផ្លាស់ប្តូរបទពិសោធន៍នៅតាមបណ្តាខេត្តនីមួយៗ ឃើញថាមានន័យទូលំទូលាយហើយក៏ជាដំណោះស្រាយយ៉ាងសមរម្យដែរហើយ ខ្ញុំព្រះករុណាឡើងមកនេះគឺមានសំណួរមិនចំពោះខេត្តណាទេ បើសិនខេត្តណាមានកម្មវិធីធនាគារស្រូវនិងសមាគមស្រូវមេត្តាសុំជួយឆ្លើយបំភ្លឺផង ។ កន្លងមកនៅកន្លែងរបស់ខ្ញុំព្រះករុណាបានទទួលជោគជ័យគួរជាទីកត់សំគាល់ ដោយយើងមានកម្មវិធីនេះច្បាស់លាស់មានលក្ខន្តិកៈត្រឹមត្រូវនិងពិសេសដោយមានព្រះសង្ឃជាអ្នកដើរតួនាទីដឹកនាំកម្មវិធីនេះគួបផ្សំនិងអំណោយផលធម្មជាតិផង ។ តែជាអកុសលនៅឆ្នាំ១៩៩៤-៩៥ខេត្តបាត់ដំបងទាំងមូលបានទទួលរងនូវគ្រោះធម្មជាតិធ្វើឱ្យកម្មវិធីនេះស្រុតចុះមួយកំរិត។ ខណៈនោះអ្នកស្រុកជាប់ជំពាក់យ៉ាងច្រើននូវការខ្ចីបុលពីឈ្មួញផងពីសហគមន៍ផង ។ អ្នកស្រុកមួយចំនួនយល់ថា យើងគួរតែសងប៉ុន្តែត្រូវឱ្យលទ្ធភាពទៅឈ្មួញមុនព្រោះបើយើងមិន

www.budinst.gov.kh www.elibraryofcambodia.org

សោះហើយសំណួរនេះខ្ញុំចង់សួរថាតើការបែងចែកស្រូវពូជ និង ស្រូវហូប យ៉ាងដូចម្តេចចំពោះសមាគមក្តី អង្គការក្តី ដែលធ្វើធនាគារស្រូវ ? ខ្ញុំយល់ថាសំណួរនេះវាភ្ជាប់ទៅនឹងនិរន្តរភាពរបស់ធនាគារនោះដែរ ហើយមកដល់ពេលនេះខ្ញុំពុំទាន់បានឮវិធានការ ឬក៏ចំណាត់ការណាមួយក្នុងការអនុវត្តធនាគារស្រូវគ្រប់បណ្តាខេត្តដែលបានលើកឡើងនៅឡើយ។ ខ្ញុំសុំទាញអារម្មណ៍ថាការចែករបស់យើងឈរលើក គោលការណ៍ អ្វីចំពោះអ្នកដែលមកខ្ចី ? ឧទាហរណ៍: ក្នុងសមាគមមួយមានសមាជិក២០គ្រួសារ តើយើងបានធ្វើការសិក្សាទេថាតើក្នុងគ្រួសារនិមួយៗនោះមានផ្ទៃដីប៉ុន្មានហិកតាសំរាប់ធ្វើស្រែ ? តើយើងគ្រប់គ្រងបញ្ហានេះបានដែរឬទេ? ចំពោះអ្នកដែលកំពុងធ្វើសកម្មភាពធនាគារស្រូវ ? ប្រសិនបើគ្រួសារនិមួយៗមានតែកន្លះហិកតាប៉ុន្តែមកខ្ចីស្រូវដល់ទៅ ៤ ឬ ៥បាវ ។ តាមពិតពូជសំរាប់កន្លះហិកតាវាអស់តែ១បាវទេ ៤បាវទៀតគាត់ប្រាកដជាយកទៅបរិភោគ។ ដូច្នេះតើយើងចាប់អារម្មណ៍ទៅលើបញ្ហានេះទេ? តែប្រសិនបើយើងគ្រប់គ្រងទៅលើបញ្ហានេះបាននោះនិរន្តភាពវានឹងទៅមុខ ព្រោះយើងអាចបែងចែកស្រូវពូជទៅតាមផ្ទៃដីសំរាប់សមាជិកមួយៗបាន ។ បញ្ហាមួយទៀតតើយើងមានបានចុះទៅសិក្សាអំពីកំលាំងផលិតកម្មនិងកំលាំងពលកម្មនៅក្នុងគ្រួសារនិមួយៗដែរឬទេ ? ឧទាហរណ៍ គ្រួសារមួយមានស្ត្រីមេផ្ទះមកខ្ចីស្រូវពូជពីធនាគារយើងឱ្យភ្លាម ឬ មុននឹងឱ្យយើងបានចុះទៅធ្វើការសិក្សានៅក្នុងគ្រួសារនោះសិន ។ បើសិនជាគ្រួសារនោះមានកូនតូចច្រើនហើយនៅតែម្តាយឯឪពុកទៅធ្វើជាកម្មករ ឬលក់កំលាំងពលកម្មនៅទីប្រជុំជនហើយគ្រួសារនោះគ្មានមធ្យោបាយអូសទាញទៀតហើយ បើយើងជឿតែគាត់ថាហើយឱ្យស្រូវទៅគាត់ខ្ចី ។ ខ្ញុំជឿថាគាត់ប្រាកដជាយកស្រូវនោះទៅហូបហើយ ពីព្រោះគ្មានកំលាំងពលកម្មគ្មានកំលាំងអូសទាញប្តី

www.budinst.gov.kh www.elibraryofcambodia.org

ឥតនៅផ្ទះទៀត ។ ត្រង់នេះហើយដែលខ្ញុំមើលទៅឃើញថាជាកត្តាបរាជ័យរបស់យើងពីព្រោះទុនយើងកាន់តែចេញច្រើនទៅៗ ហើយការសងមកវិញវាបានតិច។ ឈរលើកត្តាទាំងនេះហើយនិងការបែងចែកមិនបានត្រឹមត្រូវអាចឱ្យមានការថ្ទាំងថ្នាក់ដល់សមាជិកនៅក្នុងធនាគារ ឬក៏សមាជិកដែលខ្ចីមិនបានអាចលើកឡើងថាឯងធ្វើមែនទែនបានពូជតិចអ្នកខ្លះធ្វើតិចពូជច្រើន។ ខ្ញុំយល់ថាទាំងអស់នេះបណ្តាមកពីការគ្រប់គ្រងរបស់ គណៈកម្មការដែលមិនដឹងថាតើយើងបានសិក្សានូវកិច្ចការនេះហើយឬនៅទេ ។ បើសិនយើងអាចធ្វើដូចនេះបានស្រូវពូជយើងអាចសល់ ហើយយើងអាចលើកតំរោងប្រចាំឆ្នាំបានពីព្រោះយើងដឹងផ្ទៃដីសំរាប់ធ្វើស្រែរបស់សមាជិកយើងយើងក៏អាចត្រៀមពូជសំរាប់បែងចែកទៀតផង ។ ខ្ញុំជឿថាស្រូវដែលសល់យើងអាចយកទៅជួយដល់អ្នកអត់ឃ្លានបានតែបើយើងបែងចែកដោយគ្មានផែនការ ឬ ដោយគ្មានវិធានការគឺយើងបែងចែកតាមតែសំណូមពររបស់អ្នកមកខ្ចីតាមគោលការណ៍យកតែការស្រូវមកវិញប្រាកដជាក្ស័យទុនដូចព្រះតេជគុណ វ៉ៀម គឹមតេង មានពុទ្ធដីកាពីព្រឹកមិញថាបើសិនជាធនាគារស្រូវយើងលែងមានគេមកខ្ចីវាជាជោគជ័យរបស់យើងនោះ ។ ពាក្យនេះមានន័យពីរគឺថានៅពេលដែលគេលែងមកខ្ចីយើងតើក្នុងជង្រុកយើងមានស្រូវដែរឬទេ ? បើក្នុងជង្រុកមានស្រូវបានសេចក្តីថា ជោគជ័យហើយជីវភាពអ្នកស្រុកអាចផ្គត់ផ្គង់ពូជខ្លួនឯងបាន ។ តែបើគេលែងមកខ្ចីយើងហើយក្នុងជង្រុកយើងវាអស់ពូជបានសេចក្តីថាមានលទ្ធផលផ្សេងទៅវិញហើយអាចក្ស័យទុន ។ នេះគ្រាន់តែជាការរួមគំនិតនិងជាយោបល់មួយសំរាប់ឱ្យអង្គសិក្ខាសាលាធ្វើការពិភាក្សាហើយខ្ញុំនឹងរង់ចាំទទួលយកគំនិតដទៃទៀត។ ខ្ញុំសូមពញ្ញាក់អារម្មណ៍ផងដែរថាសុំឱ្យព្រះតេជគុណអស់លោកទាំងអស់មេត្តាកុំមានខ្លាចរអែងញញើតអ្វី ពីព្រោះដូច

www.budinst.gov.kh www.elibraryofcambodia.org

លោកយើធន់មានប្រសាសន៍ហើយថា មូលនិធិខុនរ៉ាដ អាដិន ណៅអ៊ែរនេះ បានឧបត្ថម្ភថវិកាច្រើនណាស់សំរាប់សិក្ខាសាលានេះ មិនមែនឱ្យមកអង្គុយតែស្តាប់ទេហើយនៅស្ងៀមឬមកធ្វើទេសចរទេគឺថាចង់បានជាការចូលរួមគំនិត។ ដូច្នេះសូមមេត្តាលើកឡើងនៅយោបល់ឬគំនិតដែលមានដើម្បីយកមកពិភាក្សាគ្នា ។ បើព្រះតេជគុណអស់លោកនៅតែស្ងៀមៗអាចមានន័យពីរ : ទី១ គឺយល់បានគ្រប់ទាំងអស់, ទី២ គឺថាមិនយល់មួយម៉ាត់សោះ ។ ហេតុនេះបើមានសំណួរ ឬមានចម្ងល់អ្វីសុំមេត្តាលើកឡើងដើម្បីបង្ហាញនូវភាពចូលរួមឱ្យបានសកម្មក្នុងការពិភាក្សាទៅលើប្រធានបទពីធនាគារស្រូវនេះព្រោះយើងផ្លាស់ប្តូរបទពិសោធន៍គ្នាមិនថាខេត្តកំពង់ធំបាត់ដំបងស្វាយរៀងទេខេត្តដទៃដូចជាតាកែវ,កំពត,កំពង់ស្ពឺ,ក្រចេះក៏ដោយបើមានរឿងអ្វីសុំមេត្តាលើកឡើង។

សូមនិមន្ត និងអញ្ជើញ !

## ចម្លើយព្រះតេជគុណ ពោជ ម៉ាន

ខាងសមាគមអាត្មាមុនធ្វើធនាគារស្រូវគឺស្គាល់ទាំងពី ដី ក្របី គោមានប៉ុន្មានមានដីភូមិប៉ុន្មានដីស្រែប៉ុន្មានមានមនុស្សប៉ុន្មាននាក់ក្នុងគ្រួសារ។ ពោលគឺល្អិតទាំងអស់សិក្សាស្រាវជ្រាវដឹងអស់មិនមែនចេះតែធ្វើស្មានៗទេ។ ឧទាហរណ៍ភូមិល្បើកមាន ១០០គ្រួសារសរុបមនុស្សរាយមាន ៧៥៥០នាក់ ស្ត្រី ៣០០នាក់មានផ្ទៃដីចំនួន២២០ហិកតាយើងបានទៅសិក្សាដល់គ្រួសារនិមួយៗឱ្យបានល្អិតល្អន់អ្នកណាមានដីស្រែតិចចំនួនមនុស្សច្រើន អ្នកណាមានដីច្រើនមនុស្សតិច ហើយយើងបែងចែកកម្មវិធីនេះឱ្យមានគុណភាព ពិសេសគណៈកម្មការភូមិគេដឹងព្រោះគេនៅផ្ទាល់ ។ ដូច្នេះគណៈកម្មការត្រូវបែងចែកឱ្យច្បាស់អ្នកណាដែលមានសមាជិកគ្រួសារតូច-ធំ ដីតិច-ដីច្រើន។ ទាំងនេះ

www.budinst.gov.kh www.elibraryofcambodia.org

ជារបៀបដែលអាត្មាបានធ្វើកន្លងមកខ្លះដីតិចមនុស្សច្រើនក៏យើងមិនប្រថុយឱ្យខ្ចីច្រើនទេតែយើងត្រូវមើលមនុស្សនោះទៀត តើមនុស្សនោះខ្ជិលឬឧស្សាហ៍ ? ពេលយើងជួយអប់រំបន្ថែមតើគេតាមយើងដែរឬទេ ? ប្រសិនបើមនុស្សនោះគេធ្វើតាមការអប់រំយើងបានហើយ យើងប្រគល់ការងារឱ្យធ្វើគេយកចិត្តទុកដាក់ធ្វើនោះយើងហ៊ានប្រថុយឱ្យខ្ចីច្រើន ។

## ពុទ្ធដីកាបន្ថែមរបស់ព្រះតេជគុណ វៀម គឹមតេង

រឿងដាក់ទុន ឬ ផ្ដល់នូវការខ្ចីនេះគឺមុននឹងទៅបំពេញកិច្ចការនេះយើងមានភ្នាក់ងារសំរាប់ចុះទៅស្រាវជ្រាវពត៌មាននៅតាមមូលដ្ឋានរួចហើយ ការសិក្សានេះគឺសិក្សាយ៉ាងល្អិតល្អន់ទៀតផង ដូចជាសិក្សាពីផ្ទៃដីសំរាប់បង្កបង្កើនផលមានជីវជាតិប៉ុន្មានហិកតា មិនមានជីវជាតិប៉ុន្មាន? ដីភូមិដីស្រែប៉ុន្មាន? ធ្វើស្រែមួយហិកតាបានផលប៉ុន្មាន ? តាំងពី៣ឆ្នាំមុនសិក្សាពីមនុស្សគ្រួសារមួយៗមានមនុស្សប៉ុន្មាន ? ដូចនេះក្នុងភូមិមួយគឺយកពត៌មានល្អិតណាស់ ។ ថែមទាំងបានសិក្សាពីប្រភពចំណូលក្រៅពីមុខរបរស្រែទៀតផងថា តើគេរកប្រភពចំណូលបានពីអ្វីខ្លះមានប៉ុន្មានមុខសញ្ញា? ដូចនេះការផ្ដល់ឱ្យអនុលោមទៅតាមសមាជិកនៃគ្រួសារឬអនុលោមទៅតាមផ្ទៃដីដែលខ្លួនធ្វើ។ ពេលចុះទៅសួរពត៌មានយើងមិនសន្យាថាយើងនឹងឱ្យអ្វីទេ ។ យើងយកពត៌មាននេះមកផ្ទៀងផ្ទាត់មើលពេលដែលឈ្មោះណាម្នាក់មកខ្ចី ដើម្បីងាយស្រួលក្នុងការឱ្យខ្ចី ។ ពេលនេះយើងអាចដឹងបានថាគាត់ខ្ចីលើសពីសេចក្ដីត្រូវការយើងក៏មិនអនុញ្ញាតឱ្យបានទេ នេះនិយាយពីស្រូវពូជតែបើស្រូវហូបគឺយើងធ្វើតាមសមាជិកគ្រួសារវិញ។ម្យ៉ាងវិញទៀតការឱ្យខ្ចីដោយមិនបានគិតមុខគិតក្រោយ

www.budinst.gov.kh www.elibraryofcambodia.org

វាក៏ជាបញ្ហាមួយដែរ ព្រោះមនុស្សនោះអាងថាអាចខ្ចីបានហូបក៏មិនបាច់ធ្វើអ្វីទេបណ្តាលឱ្យកើតរោគខ្ជិលដេកចាំផល់ខែទៅខ្ចីគេទៅ។ ប្រយ័ត្នរឿងនេះឱ្យមែនទែនប្រយ័ត្នកើតជាធនាគារស្រូវធ្វើឱ្យមនុស្សខ្ជិលមនុស្សខូច។ ដូច្នេះការធ្វើធនាគារស្រូវត្រូវមានការប្រុងប្រយ័ត្នណាស់ដើម្បីធ្វើឱ្យមនុស្សឧស្សាហ៍ ។

សូមបន្ថែមបន្តិចដែរពីរឿងនិរន្តរភាពនៃការធ្វើធនាគារស្រូវៈ អាត្មាសូមប្រគេននិងជូនថាមុននឹងធ្វើធនាគារស្រូវយើងបានប្រកាសហើយថាស្រូវដែលគ្រួសារឬអ្នកស្រុកប្រគេនព្រះសង្ឃអ្នកនោះនឹងក្លាយទៅជាសមាជិកធនាគារស្រូវ ។ អញ្ចឹងស្រូវក្នុងធនាគារនោះជាកម្មសិទ្ធិរបស់សមាជិកធនាគារស្រូវហើយមិនមែនជាកម្មសិទ្ធិរបស់គណៈកម្មការធនាគារស្រូវទេ ។ ដូច្នេះរាល់ការចំណាយនិងរាល់ការធ្វើអ្វីទាំងអស់សូម្បីតែចែកចាយដល់សមាជិកក៏យើងត្រូវតែចែកក្នុងសមាគមប្រជាធិបតេយ្យដែរ គឺហៅសមាជិកមកនិយាយសួរថាឆ្នាំនេះស្រូវយើងមានប៉ុណ្ណោះតោនតើយើងនឹងចែកគ្នាខ្ចីប៉ុន្មានគីឡូ? ប៉ុន្មានតៅ ? ពេលនោះសមាជិកជាអ្នកឱ្យយោបល់ព្រោះលក្ខណៈប្រជាធិបតេយ្យគឺយកមតិភាគច្រើនជាធំ ។ ឧទាហរណ៍ ក្នុង ១០០នាក់មាន៨០នាក់ លើកដៃឱ្យចែក៨តៅ ក្នុងមួយគ្រួសារគឺយើងសំរេចយកសំលេង ៨០លើ ១០០នោះឯងជាធំហើយថ្លឹងចែក៨តៅក្នុងមួយគ្រួសារទៅ ។ ធ្វើរបៀបនេះអ្នកស្រុកគេយល់ថា គេជាកម្មសិទ្ធិរបស់ស្រូវគេមានសិទ្ធិខ្ចីគេមានសិទ្ធិសំរេចក្នុងលក្ខណៈប្រជាធិបតេយ្យ។ការនេះវាត្រូវតែមាននិរន្តរភាពអាត្មាជឿថាអញ្ចឹងព្រោះក្នុងចំណោមសមាជិកទាំងអស់គេយល់ថាធនាគារស្រូវវាជារបស់គេបើមានអ្នកណាមិនសងនោះអ្នក៩០នាក់ទៀតគេមិនព្រមទេ ។

www.budinst.gov.kh www.elibraryofcambodia.org

## សំណួររបស់លោក កែន សំបូរ

សុំសួរទៅសមាគមធនាគារស្រូវមូលដ្ឋានដោយផ្អែកទៅលើពាក្យថាទាមទារយកនិរន្តរភាពខាងធនាគារស្រូវឱ្យខាងតែបាន ដោយលើកតែពីចំណុចល្អៗខ្ញុំសុំសួរថាដើម្បីអភិវឌ្ឍន៍ជនបទមួយហើយធនាគារស្រូវដើរបានល្អរហូតនេះ តើសមាគមធនាគារស្រូវនេះបានបំពាក់បច្ចេកទេសការផលិតស្រូវហើយឬនៅ បើមានសុំឆ្លើយបើគ្មានតើមូលហេតុអ្វីបានជាមិនព្រមផ្តល់នូវបច្ចេកទេសឱ្យគេជ្រើសរើសពូជនិងណែនាំឱ្យបានល្អ ឬមួយចាំតែយកស្រូវដែលបណ្តាក់ហើយប្រមូលយកដើមយកចំណេញដាក់ក្នុងសមាគមតែប៉ុណ្ណោះ ?

## ចម្លើយរបស់ព្រះតេជគុណ ញៀម គីមតេង

ខាងសន្តិសេនាមានកម្មវិធីច្បាស់លាស់ គឺ ÷

-កម្មវិធីអប់រំកសិកម្មទំនើបជារៀងរាល់ឆ្នាំមុនរដូវភ្លៀងធ្លាក់យើងបានចុះអប់រំផ្នែកកសិកម្មទំនើបដល់មូលដ្ឋានតាំងពីវិធីភ្ជួរដី, វិធីជ្រើសរើសពូជវិធីទុកពូជ, វិធីពិនិត្យថែទាំពូជស្រូវទៅលើប្រភេទដី វិធីសាប វិធីដក ស្ទូង វិធីប្រើដីប្រើថ្នាំបុរាណដើម្បីដេញសត្វល្អិតវិធីមើលទឹក។ល។ រហូតដល់ពេលច្រូតកាត់យើងបានអប់រំអ្នកស្រុកក្នុងតំបន់ដែលយើងធ្វើសកម្មភាព ។ ឧទាហរណ៍ធ្វើធនាគារស្រូវនៅភូមិណាយើងមានកម្មវិធីអប់រំផ្នែកកសិកម្មទំនើបដល់ភូមិនៅទីនោះមិនមែនគ្រាន់តែដល់ខែទៅប្រមូលនោះទេ ៕

www.budinst.gov.kh www.elibraryofcambodia.org

**បំភ្លឺបន្ថែមដោយលោក ណុប ពោល បុគ្គលិកផ្នែកកសិកម្មអង្គការព.ជ.អ**

សូមបន្ថែមនូវកម្មវិធីមួយហៅថាកម្មវិធីស្រែបង្ហាញដោយពឹងផ្អែកលើការប្រើប្រាស់ជីកំប៉ុស្តសំរាប់បង្កើនទិន្នផល ។ ខាងអង្គការយើងខ្ញុំក្នុងមួយឆ្នាំៗបានបើកវគ្គ២ដងដើម្បីបំប៉នអំពីបច្ចេកទេសកសិកម្មនេះមាន÷

- ដំណាំស្រូវ
- ប្រភេទដី
- ការដាំដើមឈើ
- ការចិញ្ចឹមសត្វ

បន្ទាប់ពីរៀនហើយយើងបានធ្វើការអនុវត្ត ដោយទទួលបាននូវលទ្ធផលជាទីគាប់ចិត្តដូចជាស្រែបង្ហាញក្នុងមួយហិកតាពីមុនយើងឥតមានប្រើជី កំប៉ុស្តទេ យើងធ្វើឥតតាមលក្ខណៈបច្ចេកទេសទេយើងទទួលផលក្នុង១ហិកតាបាន២តោនដល់ពេលយើងធ្វើតាមលក្ខណៈបច្ចេកទេសដោយមានអ្នកបច្ចេកទេសកសិកម្មណែនាំបង្ហាញអំពីរបៀបរបប យើងទទួលផលបាន៣,៧តោនក្នុងមួយហិកតាដោយប្រើពូជស្រូវផ្កាខ្ញី ។

## ការបង្កើត និង ដំណើរការសន្សំប្រាក់របស់អង្គការ ព.ជ.អ

**ដោយ លោក កែវ សុជាតិ មន្ត្រីកម្មវិធីអភិវឌ្ឍន៍ជនបទ**

ទាក់ទងទៅនឹងរឿងឥណទានសាច់ប្រាក់ខ្ញុំព្រះករុណាមានបទពិសោធន៍៣ដែលនឹងត្រូវជំរាបជូនដូចតទៅ ÷

១ - ការសន្សំប្រាក់ និង ដំណើរការឥណទាន មុននឹងចូលដល់បញ្ហា

www.budinst.gov.kh www.elibraryofcambodia.org

នេះខ្ញុំព្រះករុណា ខ្ញុំសុំបង្វែរអារម្មណ៍របស់ព្រះតេជគុណអស់លោកឱ្យគិតពីរបៀបបង្កើតសិន ។ ដូច្នេះបើយើងធ្វើអ្វីគ្មានរបៀបនាំឱ្យយើងធ្វើទៅវាជ្រុលទៅមុខជ្រុលទៅក្រោយ ។ ខ្ញុំព្រះករុណាខ្ញុំបាទជាភ្នាក់ងារឥណទានរបស់អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ខ្ញុំសុំលើកយករបៀបបង្កើតការងារឥណទានសាច់ប្រាក់នៅតាមជនបទដែលជាបទពិសោធន៍របស់ខ្ញុំព្រះករុណា ខ្ញុំបាទមកពិភាក្សាគ្នាក្នុងទីនេះ តែខ្ញុំព្រះករុណាខ្ញុំបាទសុំមិននិយាយពីវិធីសាស្ត្រទេពីព្រោះការបង្កើតគឺមានដូចគ្នានៅគ្រប់កន្លែងទាំងអស់ ។ កិច្ចការអភិវឌ្ឍន៍សំខាន់គឺឱ្យអ្នកស្រុកចូលរួមដើម្បីស្រាវជ្រាវនូវបញ្ហា និងរកដំណោះស្រាយនូវបញ្ហាដើម្បីលើកគំរោងទិសដៅអភិវឌ្ឍន៍ជីវភាពគឺការធ្វើឥណទានតែម្តង ។ យើងរៀបចំរចនាសម្ព័ន្ធការងារនៅក្នុងអង្គការ និង នៅក្នុងសហគមន៍ដែលយើងបំរុងនឹងបង្កើតឱ្យចេញនូវគោលការណ៍ឥណទានលក្ខន្តិកៈ និង គោលបំណងគោលដៅនៃការធ្វើឥណទានជនបទ ។ ដើម្បីសំរេចឱ្យបាននូវគោលបំណងនិងគោលដៅខាងលើនេះ យើងត្រូវមានគណៈកម្មការគ្រប់គ្រងតាមភូមិដែលជ្រើសរើសដោយការបោះឆ្នោតសំងាត់ពីសមាជិកឬពីអ្នកស្រុកផ្ទាល់តែម្តង ។ ក្នុងគោលការណ៍នេះ យើងនិយាយពីកិច្ចសហប្រតិបត្តិការ រវាងក្រុមឥណទាននិងក្រុមគោលដៅផ្អែកទៅលើព្រហ្មវិហារធម៌និងអហិង្សាដើម្បីជាគន្លឹះសំរាប់ដោះស្រាយបញ្ហា និង សេចក្តីត្រូវការរបស់ក្រុមគោលដៅ ។

មួយទៀតគោលការណ៍របស់យើងបានបញ្ជាក់ដែរថា អ្នកស្រុកដែលជាក្រុមគោលដៅតាមសហគមន៍ត្រូវតែចូលរួម សន្សំប្រាក់នៅតាមគ្រួសារ និងតាមបុគ្គល។ជាគោលការណ៍កាលណាយើងបង្កើតនៅក្នុងភូមិណាមួយហើយបើអ្នកភូមិនោះមិនសន្សំទេគឺខុសពីគោលការណ៍ដែលយើងបានកំណត់។ មុខរបររបស់ខ្មែរយើងភាគច្រើនពឹងផ្អែកទៅលើមុខរបរកសិកម្មតែមួយគត់ហើយ

www.budinst.gov.kh www.elibraryofcambodia.org

អាចធ្វើឱ្យជីវភាពរបស់យើងធ្លាក់ចុះ នៅពេលណាយើងជួបបញ្ហាដូចជាទឹកជំនន់,រាំងស្ងួតជាដើម ។ ហេតុនេះហើយបានជាយើងលើកគោលការណ៍៣ទៅជួយក្រុមគោលដៅ គឺយើងឱ្យអ្នកស្រុកឈានទៅរកយុទ្ធសាស្ត្រនៃការធ្វើនិងការអនុវត្តលើ កសិកម្មចំរុះ ជំនួញខ្នាតតូច និង អាជីពផ្សេងៗ ។

ដូច្នេះរឿងឥណទានគឺទាក់ទងទៅនឹងមុខរបរដែលយើងត្រូវឱ្យអ្នកស្រុកមានប្រាក់ចំណូល ឬ បង្កើនប្រាក់ចំណូលប្រចាំគ្រួសារដើម្បីគ្រប់គ្រងគ្រួសារនិងដើម្បីបង្កើនស្បៀងគ្រួសារ សំខាន់គឺឈានទៅរកសុភមង្គលក្នុងគ្រួសារ។ ក្នុងប្រព័ន្ធឥណទានរបស់អង្គការព្រះពុទ្ធសាសនា គឺយើងអនុវត្តទៅតាមបែបប្រជាធិបតេយ្យដោយមានការចូលរួមពីអ្នកស្រុកក្នុងកិច្ចការចាត់ចែងការងារផ្ទាល់តែម្តង ។

មួយទៀតប្រព័ន្ធនៃការគ្រប់គ្រងនេះគឺមានរចនាសម្ព័ន្ធការងារជា ឥណទាន រឿងនេះវាទាក់ទងទៅនឹងសាច់ប្រាក់ ។ បើសាច់ប្រាក់នេះអ្នកស្រុកធ្វើដំណើរការគឺវាទាក់ទងលើសមាជិក ដូច្នេះត្រូវមានទំនាក់ទំនងជាមួយគណៈកម្មការធនាគារស្រូវភូមិហើយត្រូវមានបេឡាសន្សំប្រាក់ ។ បន្ទាប់មកទៀតគណៈកម្មការត្រូវមានការទាក់ទងជាមួយភ្នាក់ងារ ឬ បុគ្គលិកដែលចុះទៅធ្វើសកម្មភាពរបស់អង្គការ ហើយស្នើមកប្រធានឥណទាន ប្រធានឥណទានត្រូវស្នើមកប្រធានអភិវឌ្ឍន៍សហគមន៍ហើយបានស្នើឡើងមកនាយកសកម្មជាអ្នកសំរេច ។ ដូច្នេះនៅក្នុងរចនាសម្ព័ន្ធគឺប្រាក់សន្សំទាំងអស់ត្រូវបញ្ចូលទៅក្នុងបេឡារបស់អង្គការដើម្បីយកទៅដាក់នៅក្នុងធនាគាររដ្ឋ ។

ដំណើរការដែលយើងត្រូវដើរ( បទដ្ឋានរបស់ឥណទាន ) : បទដ្ឋាននៅក្នុងឥណទាននេះវាមានការចូលរួមផ្តល់ពត៌មាន ។ សំខាន់បំផុតរឿងលុយ ។ មិនដូចរឿងស្រូវទេ រឿងស្រូវមួយឆ្នាំយើងជួបគ្នាតែពីរដងទេគឺ

www.budinst.gov.kh www.elibraryofcambodia.org

ពេលសងនិងពេលខ្ចី។ ប៉ុន្តែរឿងលុយវាទាក់ទងជាអចិន្ត្រៃយ៍ជារៀងរាល់ថ្ងៃ ពីព្រោះយើងត្រូវការហូបចុកត្រូវការចាយរាល់ថ្ងៃយើងត្រូវយកប្រាក់ចំណូលជារៀងរាល់ថ្ងៃជាប្រចាំដើម្បីឱ្យជីវិតរបស់យើងរស់នៅ។ ដូច្នេះនៅក្នុងនោះយើងបានបង្កើតទៅតាមដំណើរ តាមជំហានដែលត្រូវដើរនិងជា បទដ្ឋានផ្លូវដែលយើងត្រូវដើរ និង យើងត្រូវធ្វើជាបន្តបន្ទាប់ៗរហូតដល់ទីបញ្ចប់នៃការងាររបស់យើង គឺវាវិលចុះវិលឡើងយើងមិនមែនធ្វើអ្វីចុះពីលើមកក្រោមទេ ជួនកាលយើងធ្វើជារង្វង់ហៅថាប្រព័ន្ធឥណទានបង្វិល។រឿងមួយទៀតដែលទាក់ទងទៅនិងសាច់ប្រាក់នៃការបង្កើតដែរ ។ ដូច្នេះការធ្វើឥណទានរបស់អង្គការវាខុសគ្នាពីឥណទានរបស់នាយទុនហើយវាខុសពីធនាគាររបស់រដ្ឋ។ ព្រោះធនាគារនាយទុន ទាល់តែយើងមានប្លង់ដីទៅបញ្ចាំទើបគេឱ្យសាច់ប្រាក់មក។ តែធនាគារអភិវឌ្ឍន៍វិញគឺមិនមានសាច់ប្រាក់ទេមិនមានភស្តុតាងអីទេគឺឱ្យអ្នកស្រុកខ្ចី បង្កើតក្រុមខ្ចី បង្កើតជាគណៈកម្មការខ្ចីហើយធ្វើសំណើរមកដើម្បីខ្ចីប្រាក់ ។ ដូច្នេះបើសិនណាគេមិនសងតើយើងទៅធ្វើអ្វីគេបានទេ ? ដើម្បីត្រៀមលក្ខណៈនេះយើងត្រូវមានវិធានការទប់ស្កាត់មុន ។ ក្នុងនេះខ្ញុំបាននិយាយរួចហើយថាយើងធ្វើលក្ខណៈវិនិច្ឆ័យមួយទៅលើទ្រព្យសម្បត្តិ ។ ដូច្នេះនៅក្នុងហ្នឹងវាទាក់ទងទៅរឿងសិក្ខាសាលាកន្លងមកអស់រយៈពេល ៤ ឆ្នាំហើយយើងបានពិភាក្សាគ្នាច្រើនហើយតែការងារខ្លះយើងធ្វើចេញការងារខ្លះយើងធ្វើមិនចេញ។ ដូច្នេះយើងត្រូវធ្វើការសិក្សារកហេតុផលឱ្យបានច្បាស់ហេតុអីបានជាយើងធ្វើមិនចេញ? ហើយបើធ្វើចេញវាយ៉ាងម៉េច ? អង្គការ ព.ដ.អ.បង្កើតឥណទានមុនដំបូងតែ ៤ ភូមិទេឥឡូវនេះមានរហូតដល់ ២៤ ភូមិហើយពីមុនឥតមានទឹកប្រាក់ទេទឹកប្រាក់ដែលបង្កើតគឺបានមកពីអ្នកស្រុក។ តែបច្ចុប្បន្ននេះយើងប្រើប្រាស់ទឹកប្រាក់ដល់ទៅជាង ១០០ លានរៀលក្នុងឆ្នាំ

www.budinst.gov.kh www.elibraryofcambodia.org

១៩៩៦-១៩៩៧ ។ ឆ្នាំ១៩៩៧-១៩៩៨ នេះយើងប្រើប្រាស់សាច់ប្រាក់សរុបទៅជាង១០០លានរៀលខាងខ្ញុំប្រើប្រព័ន្ធវិលគេហៅប្រព័ន្ធវិលខ្ចី-សង សង-ខ្ចីហើយទឹកប្រាក់ដែលខ្ចីដំបូងមានចំនួនប្រាំម៉ឺនរៀលគត់ ។ ឥឡូវទឹកប្រាក់អាចឱ្យខ្ចីបានឡើងដល់ទៅកំរិតខ្ពស់រហូតដល់ទៅបីសែនរៀលចំពោះគ្រួសារម្នាក់។ ដូច្នេះប្រាក់បីសែនរៀល តើយើងអាចផ្គត់ផ្គង់អ្នកស្រុកបានទេ? អាចបំពេញនូវសេចក្តីត្រូវការរបស់គេបានទេ? ឃើញថាមិនអាចបំពេញនូវតំរូវការនិងសេចក្តីត្រូវការអ្នកស្រុកបានទេ ។

បញ្ជាក់ : ការរៀបចំធ្វើឥណទានសំខាន់ គឺ ការរៀបចំផ្នែកគណនេយ្យ និងបេឡាគ្រប់ថ្នាក់។ ម្យ៉ាងទៀតការធ្វើលក្ខន្តិកៈសន្សំប្រាក់គឺជាជំហានទី៦,៧ ។

តើអ្នកជាសមាជិកឬទើបអាចខ្ចីប្រាក់បានឬក៏អ្នកក្រៅអាចខ្ចីបានដែរ? គឺខ្ចីបានទៅតាមលក្ខន្តិកៈ។ ការធ្វើការវាយតំលៃគឺអ្នកខាងក្រៅជាអ្នកធ្វើការវាយតំលៃទៅលើ ÷

- ចំណុចខ្សោយ ខ្សោយដោយសារអ្វី ?
- ចំណុចខ្លាំង ខ្លាំងដោយសារអ្វី ?
- ចំណុចកែប្រែ កែប្រែលើចំណុចណាខ្លះ ?
- ចំណាយលើអ្វីខ្លះ ?
- ចំណុចសន្សំប្រាក់
- ចំណុចត្រួតពិនិត្យ
- ចំណុចអនុវត្តការងារនិងការសំរបសំរួល
- ការបង្វិលប្រាក់ឱ្យបាន ៨៥ភាគរយ
- និរន្តរភាពរបស់អង្គការ

www.budinst.gov.kh www.elibraryofcambodia.org

លក្ខណៈវិនិច្ឆ័យ គឺ ចូលរួមធ្វើជាមួយអ្នកស្រុកតែម្តងដោយឱ្យស្រុកធ្វើការវាយតំលៃទៅលើមនុស្សម្នាក់តើមានគោប៉ុន្មានក្បាលមានដីស្រែប៉ុន្មានហិកតា ? មានទឹកប្រាក់សន្សំនៅក្នុងសមាគមប៉ុន្មាន ? រួចហើយយើងធ្វើការពិចារណាថាតើគួរសំរេចឱ្យខ្ចីប្រាក់ប៉ុន្មាន? ហើយត្រួតពិនិត្យគឺជារឿងដូចគ្នាជាមួយធនាគារស្រូវដែរ ព្រោះមានការមានខ្ចីសងដូចគ្នា ។

## ការបង្កើត និង ដំណើរការឥណទាន នៃ អង្គការសន្តិសេនា

ដោយ **ព្រះតេជគុណ ញៀម គឹមតេង**

តាមពិត ខ្ញុំព្រះករុណាមិនមែនជាអ្នកអនុវត្តកម្មវិធីឥណទាននេះដោយផ្ទាល់ទេគឺលោក សួរ គោម ដែលជាអ្នកអនុវត្តកម្មវិធីនេះដោយផ្ទាល់ ហើយថ្ងៃនេះយើងនិយាយអំពីរឿងឥណទានគឺទាក់ទងទៅលើសាច់ប្រាក់ ។ ដូចព្រះករុណាគ្រប់ព្រះអង្គអស់លោកបានជ្រាបស្រាប់ហើយរឿងលុយរឿងកាក់នេះវាជារឿងមួយសំខាន់ណាស់ ដែលមនុស្សភាគច្រើនគេចាប់អារម្មណ៍មែនទែន ។ ដូច្នេះបញ្ហាជាច្រើនក៏កើតមានឡើងពីរឿងលុយនេះដែរ ។ ដូចពាក្យថា*កាលណាមានលុយ វាតែងមានបញ្ហា ប៉ុន្តែបើអត់លុយសោះនោះក៏មានបញ្ហាដែរ* ។ជាងនេះទៅទៀតខ្ញុំព្រះករុណាយល់ថាពិតជាមានទស្សនៈថាលុយជាសត្រូវជាមួយលោកសង្ឃ ក៏ថាបានតែអាត្មាយល់ថាព្រះតេជគុណគ្រប់ព្រះអង្គពិតជាមានគំនិតមួយថា យីស! រឿងលុយរឿងកាក់ឱ្យព្រះសង្ឃចូលទៅប្រឡូកចូលទៅធ្វើអញ្ចឹង វាមិនទាស់នឹងវិន័យឬសិក្ខាបទទេឬ? ព្រោះសិក្ខាបទខ្លះបាននិយាយទាក់ទងទៅនឹងរឿងមាសប្រាក់ហ្នឹង។ ក្នុងសិក្ខាបទទី ១០ និយាយពី*ជាតរូបរជតប្បដិគ្គហនា វេរមណី សិក្ខាបទំសមាទិយាមិ* ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទនេះប្រែថា ខ្ញុំព្រះករុណាសមាទិយាមិ ខ្ញុំព្រះករុណាស្មាលា ឬ ស្មាទានហើយមិនកាន់ជាតរូបហ្នឹងទៀតទេ ( មាសប្រាក់ទៀតទេ ) ។ នេះជានាំងរាំងពីមុខលោកសង្ឃ ធ្វើឱ្យព្រះសង្ឃ យើងរារែកចិត្តធ្វើមិនពេញដៃ ។ នេះជាទស្សនៈមួយជាគំនិតមួយដែល ខ្ញុំព្រះករុណាយល់ថា ព្រះអង្គហើយនិងញាតិញោមក៏គិតអញ្ចឹងដែរ ។ រឿងនេះយើងត្រូវពិចារណាឱ្យបានល្អិតល្អន់ទៅលើវិន័យព្រោះសិក្ខាបទនេះជាវិន័យ ។ ប៉ុន្តែយើងជាអ្នកគោរពជាអ្នកអនុវត្តនូវវិន័យនេះយើងក៏ត្រូវចេះវិន័យនេះដែរ ព្រោះវិន័យជ្រៅដោយកិច្ចវិនយោកិច្ចគគម្ភីរោប្រែថា វិន័យជ្រៅដោយកិច្ចបើយើងចេះកិច្ចគឺបើយើងចេះវិន័យហើយយើងត្រូវចេះកិច្ចរបស់វិន័យផង ។ នោះវាគ្មានអាបត្តិអ្វីទេ ព្រោះទាំងអស់មិនមែនសុទ្ធតែបាប សុទ្ធតែមានទោសកំហុសទាំងអស់នោះទេ ត្រូវយល់ដោយកិច្ចនោះផង ។ ដូចអ្នករក្សាសីលគឺមិនឱ្យចិញ្ចឹមសត្វឧបមាថា ឥឡូវនេះជ្រូកវាកំពុងតែត្រូវបាន់បានថ្លៃជាងគេឯងទៅចិញ្ចឹមជ្រូកទៅ ។ ចុះអ្នកកាន់សីលធ្វើម៉េចដែរគឺយើងត្រូវយល់ពីកិច្ចហ្នឹងដើម្បីរកលុយ គឺ ត្រូវដាំដើមចេកព្រោះបើយើងចិញ្ចឹមជ្រូកគឺខុសនឹងវិន័យរបស់យើង ។ ដូច្នេះយើងត្រូវរករបរអ្វីមួយដែលវាប្រកបដែលសមស្របជាមួយអ្នកចិញ្ចឹមជ្រូកនេះដែរ ដើម្បីឱ្យបានចំណូល។ នៅក្នុងសិក្ខាបទ២២៧របស់ភិក្ខុក៏មានចំណុចច្រើនដែរ ដែលនិយាយពីរឿងហ្នឹង ពិសេសព្រះមហាថេរធំៗ ដែលគង់នៅខាងមុខនេះ ព្រះអង្គសុទ្ធតែយល់ពីតួនាទីព្រោះសុទ្ធតែជាព្រះមេគណព្រះអនុគណជាអ្នកប្រាជ្ញធំៗខាងរឿងនេះ ហើយប៉ុន្មានថ្ងៃមកនេះមិនទាន់ឮព្រះអង្គមានពុទ្ធដីកាសោះហេតុនេះសូមស្នើមហាថេរជួយបំភ្លឺផង ។

និយាយពីរឿងវត្តអារាមមែនទែនទៅវត្តព្រះពុទ្ធសាសនាយើងនេះមានប្រភពចំណូលច្រើនណាស់ក្នុងមួយឆ្នាំៗ គឺមិនតិចលានទេដែលជាចំណូលដូច

www.budinst.gov.kh www.elibraryofcambodia.org

ជាបុណ្យភ្ជុំបិណ្ឌ ១៥ថ្ងៃ យ៉ាងហោចណាស់ក៏ ១លានដែរនេះនិយាយពីវត្ត នៅតាមជនបទផង ហើយបើវត្តនៅតាមទីក្រុងឬវត្តដែលមានព្រះមេគណល្បី ល្បាញវិញកាន់តែធំមែនទែនបុណ្យចូលឆ្នាំ ៣ថ្ងៃ ក៏បច្ច័យចូលមិនតិចដែរ ។ ក្រៅពីនេះនៅមានបុណ្យចូលនិងចេញព្រះវស្សាបុណ្យកឋិននិងបុណ្យតាមផ្ទះ ផ្សេងៗដែលសុទ្ធតែជាចំណូលទាំងអស់។ ប៉ុន្តែប្រភពចំណូលទាំងនោះយើង ធ្វើការគ្រប់គ្រងវាមិនច្បាស់លាស់ គឺយើងច្រើនចាយអត់គំនិតចាយទៅវិញ អស់រហូតដល់មានទៅជំពាក់ចិនវិញទៀត ។ ការចាយរបស់យើងវាហួសព្រំ ដែនបានជាយើងទៅជំពាក់ចិនយ៉ាងនេះ ហើយរឿងដែលជំពាក់ចិននេះមាន នៅស្ទើរតែគ្រប់ខេត្តព្រោះតែយើងសាងសង់វិហារ ឬ កុដិ ។ ហេតុនេះ យើងត្រូវឆ្លៃប្រភពចំណូលរបស់យើងយ៉ាងណា គឺឱ្យចំណូលនិងចំណាយវា មានសមាមាត្រនិងគ្នា បើសង់កុដិវិហារក៏សង់ទៅតែឱ្យសមស្របទៅនិងប្រាក់ ចំណូលបើលុយមានត្រឹមតែធ្វើកុដិឈើ កុំទៅធ្វើកុដិថ្មវានាំឱ្យតែជំពាក់ចិនទេ នាំឱ្យដេកព្រួយរួចដើរអំពាវនាវរកគេឱ្យជួយផង។ ដូច្នេះត្រូវគិតឱ្យច្បាស់ថា ចំណូលរបស់វត្តនេះហើយ ជាមូលនិធិរបស់យើងសំរាប់ចាត់ចែងធ្វើអ្វីមួយកុំ បារម្ភខ្លាចវាក្លាយទៅជាមូលធនឱ្យសោះ។ យើងត្រូវយកមូលនិធិនេះទៅប្រើ ប្រាស់ឱ្យសមស្របក្នុង លក្ខណៈសន្សំសំចៃ ហើយត្រូវសម្លឹងមើលទៅបរិស័ទ របស់យើងផងគ្នាគ្មានលុយតើយើងត្រូវដោះស្រាយយ៉ាងម៉េចដើម្បីឱ្យគ្នាមាន លុយមានកាក់សំរាប់ប្រកបរបរចិញ្ចឹមជីវិតផង ព្រោះជីវិតនេះជាការសំខាន់ ណាស់អ្នកមានគេមកធ្វើបុណ្យ យើងជាព្រះសង្ឃនៅជាកណ្តាលធ្វើម៉េចបែង ចែកឱ្យគ្នាអ្នកក្រផងព្រោះយើងជាម្តាយឪពុកយើងធ្វើចិត្តឱ្យដូច ម្តាយ ឪពុក អញ្ចឹង ។ កូនដែលមានគេជូនលុយ ជូនម្ហូប អាហារ គាត់មិនហ៊ានចាយទេ សន្សំទុកយកទៅឱ្យកូនដែលក្រ ។ ម្ល៉ោះហើយកូនមានគេអន់ចិត្តគេថាជូនឱ្យ

www.budinst.gov.kh www.elibraryofcambodia.org

ហួបមិនហួបជូនឱ្យចាយមិនចាយយកទៅឱ្យអានេះ អានោះវិញ ។ នេះ ! ចិត្តម្តាយឪពុកវាអញ្ចឹង។

ដូច្នេះយើងជាព្រះសង្ឃជាអ្នកកណ្តាលត្រូវមើលជុំវិញរឿងហ្នឹង។ ល្ងាចមិញព្រះសង្ឃបានទស្សនារឿងស្ថានភាពសូន្យ តែខាងឧបាសកបែបមិនបានមើលទេ ។ ពេលនោះមានឧបាសិកាម្នាក់ថាអាណាមិនចង់ធ្វើបុណ្យតែវាគ្មានអ្វីធ្វើគិតតែទៅធ្វើបុណ្យពេកទៅឯងនេះវាគ្មានអ្វីហូប ។ ដូច្នេះអង្គការសន្តិសេនាជាអង្គការមួយដែលមានទុនតិចតួចតែយើងធ្វើការអ្វីៗទាំងអស់ដើម្បីសន្តិភាពដើម្បីជីវភាពដើម្បីបរិស្ថាន ។ សន្តិភាពជាចំណុចមួយសំរាប់មនុស្ស-សត្វនិងធម្មជាតិ។ឯជីវភាពជារឿងសំខាន់ណាស់ព្រោះមនុស្សម្នាក់ៗត្រូវការជីវភាពរស់នៅប្រកបដោយសមស្របទាំងម្ហូបអាហារ សិទ្ធិ សេរីភាពសព្វបែបយ៉ាងហើយបរិស្ថានធម្មជាតិដែលនៅជុំវិញយើងក៏អាស្រ័យយើង ហើយយើង ក៏អាស្រ័យដោយបរិស្ថានឱ្យប្រសើរឡើង ។ ហេតុនេះបានជាយើងមានកម្មវិធីជួយអ្នកក្រីក្រគឺយើងបានបង្កើតជាឥណទានខ្នាតតូចតាមភូមិដើម្បីជួយដល់អ្នកក្រីក្រនៅតាមជនបទដូចជាស្រីមេម៉ាយអ្នកក្រគ្មានដើមទុនរកស៊ីជាដើម ។

## លោក សូរ ឆោម សំអឺតពីរឿងឥណទានរបស់អង្គការសន្តិសេនា

អង្គការសន្តិសេនា ជាអង្គការអភិវឌ្ឍន៍ចំរុះ ហើយមានកម្មវិធី ÷

- កម្មវិធីឥណទាន
- កម្មវិធីធនាគារស្រូវ
- កម្មវិធីអប់រំ
- កម្មវិធីវប្បកម្ម

www.budinst.gov.kh www.elibraryofcambodia.org

- កម្មវិធីផ្តួសផុលផ្លូវ និងជីកស្រះជាដើម ។ល។

កម្មវិធីឥណទាន :

ជំហានទី ១ : ឬហៅថាជំហានរៀបចំ : ដំបូងកំណត់នូវទិសដៅលើតំបន់ដែលគ្មានប៉ះពាល់ដល់កម្មវិធីអង្គការផ្សេងៗ ដើម្បីស្រាវជ្រាវអំពីរបៀបរស់នៅរបស់ប្រជាពលរដ្ឋ អំពីសីលធម៌រស់នៅ អំពីអត្តចរិក អំពីទំនៀមទំលាប់ ដើម្បីវិភាគទៅលើចំណុចនោះ តំបន់នោះ បើសិនជាយើងមើលទៅឃើញថា តំបន់ដែលយើងកំណត់នោះ ជាតំបន់សមស្របនឹងគោលបំណងរបស់យើង យើងនឹងកំណត់យកតំបន់នោះជាតំបន់ទិសដៅសំរាប់ធ្វើការអភិវឌ្ឍន៍។ ក្នុងពេលដែលយើងកំណត់បានហើយយើងទៅសុំរដ្ឋអំណាចដើម្បីប្រមូលពលរដ្ឋមកជួបជុំគ្នាធ្វើការឃោសនា ផ្សព្វផ្សាយពីគោលការណ៍ឥណទានរបស់យើង ដោយបំផុសឱ្យអ្នកភូមិចូលរួមបង់ប្រាក់វិភាគទានសន្សំសំរាប់សហគមន៍ ។ សូមបញ្ជាក់ថា : តើឥណទានជាអ្វី ? ឱ្យខ្ចីត្រូវសងដែរឬទេ ? ដើម្បីជៀសវាងកុំឱ្យគាត់យល់ច្រឡំថាឥណទានគឺជាអំណោយនោះ ។ ឥណទានគឺជាប្រាក់ដែលឱ្យខ្ចីហើយត្រូវសងត្រឡប់វិញ ។ ពេលគឺយើងធ្វើយ៉ាងណាពន្យល់អ្នកស្រុកឱ្យយល់ច្បាស់ពីរឿងនេះហើយយើងបានទុកពេលឱ្យអ្នកស្រុក ៥សប្តាហ៍សំរាប់ធ្វើការពិចារណា ។

ជំហានទី ២ : គឺការចូលរួមគ្នាជំហាននេះគឺធ្វើនៅសប្តាហ៍ទី ៦ បើកការប្រជុំម្តងដើម្បីដកស្រង់គំនិតរបស់អ្នកស្រុកថា តើគាត់យល់ឃើញយ៉ាងណាគាត់ចូលរួមក្នុងសហគមន៍នេះទេ ? កាលបើពិនិត្យឃើញថាគាត់យល់ហើយក៏ប្រមូលជាក្រុមដែលមានគ្នា៥នាក់ ។ ក្នុងការរៀបចំនេះគឺរៀបចំទៅតាមលក្ខខណ្ឌស្ម័គ្រចិត្ត ។ អ្នកណាក៏ដោយឱ្យតែគេយល់ចិត្តយល់ថ្លើមគ្នាអាចធ្វើជាដៃគូបានក៏ប្រមូលបង្កើតជាក្រុមមួយទៅដោយរៀបឱ្យមានប្រធានទទួល

www.budinst.gov.kh www.elibraryofcambodia.org

ខុសត្រូវម្នាក់ផង ។ បន្ទាប់មកយើងបានណែនាំអ្នកស្រុកឱ្យចងក្រងជាគណៈកម្មការមួយហៅថា គណៈកម្មការអភិវឌ្ឍន៍ភូមិមាន៤នាក់ដោយធ្វើការបោះឆ្នោតជ្រើសរើសតាមសម្លេងភាគច្រើន និងតាមរូបមន្ត ៥០+១ ។ គណៈកម្មការនេះ មានប្រធានម្នាក់ លេខាម្នាក់ ហិរញ្ញិកម្នាក់ និងសមាជិកម្នាក់ ។

ជំហានទី ៣ : គឺការចាប់ផ្តើមគំរោងការ ។ ក្នុងជំហាននេះ យើងខ្ញុំមានភារៈកិច្ចបណ្តុះបណ្តាលគណៈកម្មការអភិវឌ្ឍន៍ភូមិ អំពីតួនាទី និងភារៈកិច្ចរបស់ខ្លួនហើយបានណែនាំឱ្យបង្កើតជាលក្ខន្តិកៈមួយសំរាប់សហគមន៍ គឺអ្នកភូមិជាអ្នកចងក្រង និងដោយមានការចូលរួមឧបត្ថម្ភពីអ្នកសំរបសំរួលកម្មវិធីរបស់អង្គការផងដែរ ។ ក្រោយពីការកសាងបាននូវលក្ខន្តិកៈ និងក្រោយពីពិនិត្យឃើញថាការបង់វិភាគទានសន្សំបានគ្រប់គ្រាន់ហើយទើបយើងអនុញ្ញាតឱ្យមានដាក់ពាក្យសុំខ្ចីទុនដោយមានអ្នកធានាដែលជាសមាជិកក្រុម និងដោយការឆ្លងកាត់តាមរយៈប្រធានក្រុមគណៈកម្មការអភិវឌ្ឍន៍ភូមិហើយជាពិសេសត្រូវឆ្លងកាត់រដ្ឋអំណាចភូមិផងដែរ ។

*ជំហានទី ៤ :* ការបញ្ចូលនិងការពង្រីក ។ ក្រោយពីពិនិត្យឃើញថាពាក្យសុំខ្ចីរបស់សមាជិកសហគមន៍នោះ មានហេតុផលសមស្របតាមគោលការណ៍របស់ឥណទានហើយនោះ យើងបានបញ្ចេញលុយឱ្យអ្នកខ្ចី ។ ពេលនោះ គឺការផ្តល់ទុនឱ្យខ្ចីក៏ចាប់ផ្តើម ហើយភ្នាក់ងារឥណទានរបស់អង្គការតែងតែចូលទៅជ្រៅក្នុងតំបន់នោះ ដើម្បីស្វែងយល់ពីការប្រើប្រាស់ឥណទាន និងដើម្បីពង្រឹងសមត្ថភាពរបស់គណៈកម្មការភូមិ ដើម្បីដកពិសោធន៍ពីអ្នកភូមិ និងបំពេញបន្ថែមនៅចំណេះដឹងផ្សេងៗ ។ ពិសេសជាងនេះទៅទៀត គឺដើម្បីចូលរួមពង្រឹងភាពស្និទ្ធស្នាលរបស់ដៃគូ រវាងអង្គការនិងអ្នកស្រុក ។ ក្នុងជំហាននេះផងដែរ ភ្នាក់ងារឥណទាន តែងតែយកចិត្តទុកដាក់រំលឹកជា

www.budinst.gov.kh www.elibraryofcambodia.org

ប្រយោជន៍នៅពេលកំណត់បង់ការប្រាក់ និងពេលសងបំណុលបញ្ចប់អាណត្តិនិមួយៗ។ ទាំងនេះ គឺជាជំហានដែលយើងអនុវត្តកន្លងមក ហើយលទ្ធផលយើងពុំទាន់មានជួបបញ្ហាអ្វីទេ ។ នេះក៏ដោយសារយើងមានគណៈកម្មការដែលមានសមត្ថភាពគ្រប់គ្រាន់ និងដោយសារតែសមាជិកយើងយល់ពីគំរោងឥណទាននិងដោយសារតែភ្នាក់ងារយើងមានភាពស្និទ្ធស្នាលជាមួយអ្នកភូមិជាហេតុធ្វើឱ្យអ្នកភូមិមានការទុកចិត្តនិងការស្រឡាញ់រាប់អាន ។ ប៉ុន្តែយើងនៅមានចំណុចខ្វះខាតដែរ ដោយសារតែសមាជិកខ្លះ១១ ឬ ២គ្រួសារប៉ុណ្ណោះដែលមានការយឺតយ៉ាវក្នុងការបង់ការប្រាក់ ឬប្រគល់ប្រាក់ខ្ចីមិនបានតាមកាលកំណត់បើអនុវត្តទៅតាមលក្ខន្តិកៈនិងកិច្ចសន្យាខ្ចីៗកត្តានេះបណ្តាលមកពីគ្រួសារទាំងនោះខ្លះមានកូនចៅឈឺ, ចាយលុយអស់រកមិនទាន់គ្រួសារខ្លះទៅរកស៊ីឆ្ងាយវិលត្រឡប់មកវិញមិនទាន់ ។

**បទពិសោធន៍ឥណទានរបស់អង្គការ GTZ ខេត្តកំពង់ធំ**

ឧទ្ទេសនាមដោយ **លោកស្រី ម៉ាន់ ស៊ីថាលី**

នាងខ្ញុំព្រះករុណាសូមបកស្រាយបង្ហាញពី បទពិសោធន៍ឥណទានរបស់អង្គការ GTZ ដូចតទៅ ÷ សមាគមប្រាក់នៅក្នុងស្រុកស្នោងរបស់នាងខ្ញុំនេះគឺកើតឡើងតាមបែបប្រពៃណី ហើយធ្លាប់មានតាំងពីយូរយារណាស់មកហើយដែលត្រូវបានគេបង្កើតយ៉ាងផុសផុលនៅក្នុងសម័យសង្គមរាស្ត្រនិយម។ ប៉ុន្តែសមាគមប្រាក់នេះនៅមានបន្សល់ទុកស្លាដែខ្លះនៅឡើយដូចជាកុដិ វិហារជាដើមក្រោយពីសង្គ្រាមស្ងប់នៅតំបន់នោះ ។ តែនៅក្នុងស្រុកស្នោងរបស់នាងខ្ញុំនៅតែមានសង្គ្រាមរាំរៃអូសបន្លាយនៅឡើយ ។ នៅក្នុងឆ្នាំ ១៩៨៧

www.budinst.gov.kh www.elibraryofcambodia.org

សមាគមប្រាក់នេះបានចាប់ផ្តើម រស់ឡើងវិញ នៅតាមវត្តខ្លះដែលនៅជនបទ ដាច់ស្រយាល គឺ វត្តបទុមដែលមានបទពិសោធន៍ក្នុងការបង្កើតមុនគេបង្អស់ ដោយមានការផ្តួចផ្តើមពីលោកព្រឹទ្ធាចារ្យម្នាក់គឺលោកតា គេ ញ៉ា ដែលជា អតីតសិស្សរបស់ព្រះចៅអធិការវត្ត និងជាអតីតសិស្សរបស់សម្តេចព្រះសង្ឃ រាជ ជួន ណាត ដោយគាត់បានបង្ហាត់បង្រៀនពីរបៀបធ្វើសមាគមប្រាក់នេះ។ ក្នុងរបបប៉ុល ពត លោកព្រឹទ្ធាចារ្យបានយកឯកសារដែលសរសេរដោយដៃ តាំងពីឆ្នាំ ១៩៥២ បានសល់រហូតមកដល់សព្វថ្ងៃលោកតានិងគណៈកម្មការ វត្តបទុមបានសហការណ៍យ៉ាងជិតស្និទ្ធ បង្កើតជាសមាគមប្រាក់រហូតមកដល់ សព្វថ្ងៃហើយបទពិសោធន៍នេះត្រូវបានគេយកទៅផ្សព្វផ្សាយនៅតាមវត្តនានា ក្នុងស្រុកស្អាងទាំងមូល ។

*វិធីសាស្ត្រក្នុងការបង្កើត :* ដំបូងរៀបចំជួបជុំពុទ្ធបរិស័ទពន្យល់ពីខ្លឹមសារនិង សារៈប្រយោជន៍នៃសមាគមឱ្យគេយល់ជាមុនសិន ទើបពុទ្ធបរិស័ទឈានទៅ លះបង់បច្ច័យចូលមកបង្កើតសមាគម ។ ក្នុងការពន្យល់នេះយើងមានអាចារ្យ គណៈកម្មការនិងព្រះសង្ឃចុះជួយពន្យល់ដល់ពុទ្ធបរិស័ទយ៉ាងជិតស្និទ្ធ ទើប គណៈកម្មការយើងរៀបចំឱ្យពុទ្ធបរិស័ទធ្វើការបោះឆ្នោតជ្រើសរើស គណៈ កម្មការសមាគមដើម្បីគ្រប់គ្រងការងារនេះ ។ ពេលរើសបានគណៈកម្មការ ហើយគណៈកម្មការនោះបានរៀបចំចែងជាលក្ខន្តិកៈមួយស្តីអំពីសមាគមដែល មានការយល់ព្រមពីពុទ្ធបរិស័ទយើង។ គណៈកម្មការសមាគមរួមជាមួយព្រះ សង្ឃនិងអាចារ្យនិងគណៈកម្មការវត្តផ្តើមធ្វើការផ្សព្វផ្សាយ ការប្រមូលបច្ច័យ រៀងរាល់ថ្ងៃសីលនិងក្នុងពិធីបុណ្យផ្សេងៗក្នុង និងក្រៅវត្តហើយបច្ច័យសំរាប់ ធ្វើសមាគមនេះគឺដាច់ដោយឡែកពីបច្ច័យសំរាប់កសាងវត្ត ។ ដូច្នេះទុនរបស់ សមាគមនេះគឺបានមកពីពុទ្ធបរិស័ទចំណុះជើងវត្តនិងក្រៅវត្ត។ គោលបំណង

www.budinst.gov.kh www.elibraryofcambodia.org

របស់សមាគមនេះបង្កើតឡើងដើម្បីទ្រទ្រង់ការកសាងសមិទ្ធិផលនានាក្នុងពុទ្ធសាសនានិងសង្គម និងជួយដល់ពុទ្ធបរិស័ទក្រីក្រដែលមិនអាចមានដើមទុនប្រកបមុខរបរឱ្យគេមានលទ្ធភាពប្រកបមុខរបររកស៊ីចិញ្ចឹមជីវិតបាន និងជួយឱ្យពុទ្ធបរិស័ទក្រីក្រជៀសផុតពីការប្រាក់ខ្ពស់របស់ឈ្មួញពោលគឺមានសាមគ្គីភាពរវាងអ្នកក្រ និង អ្នកមានគឺអ្នកមានលះបង់បច្ច័យចូលសមាគមជួយឱ្យអ្នកក្របានលុយខ្ចី ។ ម្យ៉ាងទៀតអ្នកមានមធ្យមក៏អាចជួយបញ្ចុះបញ្ចូលឬឱ្យយោបល់ដល់អ្នកក្រឱ្យគេចេះយកលុយទៅរកស៊ីនិងជួយឱ្យអ្នកក្របានខ្ចីលុយ ឬ ជួយដល់ទុគ៌តជន ឬ អ្នកមានគ្រោះថ្នាក់ផ្សេងៗ ។

ដំណើរការរបស់សមាគមៈ រាល់បច្ច័យដែលប្រមូលជាវិភាគទានរបស់ពុទ្ធបរិស័ទ គឺ ជាទុនចាត់ចែងឥណទានត្រឡប់ទៅឱ្យអតិថិជនក្រីក្រខ្ចីវិញ ។ រាល់ចំណូល និង ចំណាយទាំងអស់គណៈកម្មការយើងបានចុះបញ្ជីជាប្រចាំ ។ ការកំណត់រកអតិថិជនគឺជ្រើសរើសដោយអ្នកភូមិឬក៏តាមរយៈអ្នកធានា ឬក៏អ្នកដែលគណៈកម្មការអាចជឿទុកចិត្តបាន ។ អតិថិជនអាចខ្ចីឥណទានបានលុះត្រាតែមានសាក្សីពីររូបជួយធានាឱ្យ ។

ការសំរេចចិត្តឱ្យឥណទាន ជាផ្នែកទាំងពីរ មុខរបរដែលគេត្រូវរក និងការពិភាក្សាក្នុងជួរគណៈកម្មការ ។ គណៈកម្មការឱ្យអតិថិជនទាំងអស់ប្រជុំគ្នាហើយផ្តល់ជាដំបូន្មានឱ្យគេយកលុយទៅប្រកបមុខរបរដែលសមស្របនិងអាចហុចផលយ៉ាងឆាប់រហ័សឱ្យចេះសន្សំសំចៃបណ្តើរៗ ត្រៀមទុកសំរាប់ការសងឬក៏ជួយសុំឱ្យអ្នកដែលធ្លាប់គោកយ៉ាកចេះជួយខ្លួនឯងមកជាគ្រាន់បើដោយសុំឱ្យគេជួយបង្ហាញបទពិសោធន៍របស់គេដល់អ្នកដែលគ្មានច្រកចេញ ។ ភាគច្រើននៃអតិថិជនដែលក្រ ទ័លគំនិតហើយខ្វះដំបូន្មានច្រើនរកស៊ីលក់កំលាំងពលកម្មតែពេលគេបានទទួលលុយឥណទានគេបានប្តេជ្ញាចិត្តឱ្យគណៈកម្មការ

www.budinst.gov.kh www.elibraryofcambodia.org

យើងព្រោះគេជឿបុណ្យនិងបាប។ កំរិតឥណទានដែលសមាគមឱ្យខ្ចីខ្លះចាប់ពីប្រាំពាន់រៀលដល់ប្រាំម៉ឺនរៀលខ្លះចាប់ពីមួយម៉ឺនរៀលដល់១៥០០០០រៀល។ អត្រាការ និងជុំឥណទាន : មុននិងកំណត់ការ មានការសំរេចចិត្តពីពុទ្ធបរិស័ទ និង អតិថិជនក្នុងការប្រជុំ ។ វត្តខ្លះយកការ ៥ភាគរយ វត្តខ្លះយក ៣ភាគរយវត្តខ្លះទៀតអ្នកក្រយកការផ្សេងអ្នកល្មមយកការផ្សេងអាស្រ័យទៅលើការយល់ដឹងពីខ្លឹមសាររបស់សមាគម ។ ជុំឥណទានចេញពីការកំណត់របស់អតិថិជនដែលប្រកបមុខរបរតែមិនឱ្យលើសពី ៤ខែទៅ ៦ខែឡើយ ។ ការពិនិត្យតាមដានលើការប្រើប្រាស់ទុន ក្រោយពីបានឱ្យឥណទានរួចហើយគណៈកម្មការនិងអាចារ្យបានចុះសាកសួរពីការរកស៊ីរបស់គេតើបានចំណេញឬយ៉ាងណា ? តើឥណទានពិតជាបានជួយគេឬយ៉ាងណា ? សាកសួរជាមួយអ្នកក្រដែលត្រូវបានគេជួយធានាតើមានស្ថានភាពបែបណានិងជួយដាស់តឿនជាបណ្តើរៗក្នុងលក្ខណៈត្រៀមសងត្រឡប់មកវិញ ជៀសវាងការជំពាក់បំណុលអ្នកដទៃមួយជាន់ទៀត និងសម្លឹងរកមើលអតិថិជនដែលត្រូវឱ្យខ្ចីនៅជុំក្រោយទៀត ។ ដូច្នេះឥណទានដែលយើងឱ្យពុទ្ធបរិស័ទខ្ចីគឺគេយកទៅរកស៊ីដូចជាតាមឥណទានខ្នាតតូចឬខ្នាតធំដែរ។ប៉ុន្តែអ្នកក្រខ្ចីទៅរកស៊ីភាគច្រើនដូចជា លក់នំបញ្ចុក ធ្វើករញ្ជី ទិញឫស្សីធ្វើចង្រ៉ាងសំរាប់នេសាទ និងដាំដំណាំផ្សេងៗ ។ លទ្ធផលទទួលបានគឺវិភាគទានបន្ថែមទៅលើដើមទុនស្រូវដែលប្រមូលបានជាបន្តបន្ទាប់។ឯការសងត្រឡប់របស់អតិថិជនគឺធ្វើតាមកិច្ចសន្យា។ អ្នកក្រីក្របានខ្ចីឥណទានរកស៊ី បានស្តារជីវភាពរបស់គេឱ្យឈានមកគ្រាន់បើជាបណ្តើរៗខ្លះក៏បានសន្សំប្រាក់ចំណេញពីការរកស៊ីយកមកធ្វើដើមដោយសងផ្តាច់មិនពិបាកខ្ចីពីសមាគមទៅវិញទៀតទេ ហើយការឱ្យខ្ចីតាមបែបសមាគមប្រាក់វត្តនេះអ្នកភូមិដែលខ្ចីមិនហ៊ានបំបាត់ទេព្រោះគេខ្លាចបាប ។ ម្យ៉ាងទៀត

www.budinst.gov.kh www.elibraryofcambodia.org

គេបានចូលរួមបច្ច័យខ្លួនគេផ្ទាល់។ ប៉ុន្តែក៏នៅមានការលំបាកខ្លះៗដែរក្នុងការងារនេះដោយគណៈកម្មការមានការទទួលការរិះគន់ពីមជ្ឈដ្ឋានខាងក្រៅមួយចំនួនតូចដូចជាគេថា សមាគមនេះគិតគូតែអ្នកក្រ ចំពោះអ្នកមានគេមិនឱ្យខ្ចីព្រោះទុនសមាគមនេះតិចមិនសមស្របទៅនិងមុខរបរដែលគេចង់រក។ ម្យ៉ាងគណៈកម្មការភាគច្រើនជាអាចារ្យ និងគណៈកម្មការវត្តនិងជាអ្នកកាន់សីលលំបាកក្នុងការឱ្យជំបូន្មានលើមុខរបរមួយចំនួនដូចជាការរកត្រី ការចិញ្ចឹមសត្វ ។ល។ គណៈកម្មការពុំសូវមានជំនាញក្នុងការធ្វើបញ្ជីស្នាមតាមបែប បច្ចេកទេស ។ រយៈពេល ២ឆ្នាំ កន្លងមកនេះដោយការខំប្រឹងប្រែងពីស្មារតីស្វ័យឧបត្ថម្ភសមាគមប្រាក់វត្តរបស់យើងបានទទួលការជួយឧបត្ថម្ភគាំទ្រពី អង្គការ GTZ ទាំងផ្នែកស្មារតីនិងសម្ភារៈ ធ្វើឱ្យសមាគមយើងទទួលបានបទពិសោធន៍ថ្មីខ្លះៗបន្ថែមពីការយល់ដឹងពីរបៀបកត់ត្រាធ្វើបញ្ជីរបៀបរបបទុកដាក់ឯកសារការត្រួតពិនិត្យការងារដែលបានធ្វើ ។ល។ ម្យ៉ាងទៀតយើងបានទទួលនូវបទពិសោធន៍ពីវត្តនានាតាមរយៈការបើកសិក្ខាសាលា។យើងខ្ញុំសង្ឃឹមថាដំណើរការរបស់សមាគមនេះពិតជាបានចូលរួមចំណែកជួយអ្នកក្រ តោកយ៉ាកដែលមិនធ្លាប់បានទទួលការយកចិត្តទុកដាក់ ឬដែលមិនធ្លាប់បានទទួលនូវជំបូន្មានអ្វីសោះដើម្បីឱ្យពួកគេអាចរកវិធីដោះស្រាយជីវភាពរបស់គេ ហើយអាចឱ្យគេមានជំនឿទុកចិត្តមកលើគណៈកម្មការវត្តរបស់យើងកាន់តែខ្លាំងឡើង ហើយដំណើរការសមាគមយើងពិតជាមានជីវិតរស់ នៅពេលដែលមានពុទ្ធបរិស័ទចូលរួមគ្រប់ៗគ្នា។ ម្យ៉ាងទៀតនាងខ្ញុំបានស្វះស្វែងឆ្លងកាត់ពីខេត្តមួយទៅខេត្តមួយដើម្បីរកបទពិសោធន៍ល្អៗសំរាប់អនុវត្តនៅក្នុងសមាគមទៅអនាគត។

នាងខ្ញុំសូមបញ្ជាក់នៅចំណុចទាំង ១២ សំរាប់ដោះស្រាយបញ្ហាដើម្បីកុំឱ្យបាត់ដើមគឺ ÷

www.budinst.gov.kh www.elibraryofcambodia.org

អង្គការយើងមានគោលបំណងជាចំបង សំខាន់ក្នុងការរួមចំណែកកសាងប្រទេសកម្ពុជាយើងលើកិច្ចការធំៗពីរ ÷

១. និរន្តរភាពនៃសេវាកម្មឥណទាន

២. និរន្តរភាពនៃស្ថាប័នហិរញ្ញវត្ថុ ដែលត្រូវផ្តល់ឥណទាន

ឈរលើគោលការណ៍ពីរនេះ អង្គការអេស៊ីលីដាបានរៀបចំធ្វើផែនការ ៥ឆ្នាំមានន័យថា អង្គការនិងអ្នកទទួលសេវាអេស៊ីលីដាមានកន្លែងមួយដែលមាននិរន្តរភាពគ្រប់គ្រាន់សំរាប់ទទួលហើយផ្តល់សេវាកម្មឱ្យបាន ។ ដើម្បីធ្វើកិច្ចការដែលប្រកបដោយលក្ខណៈនិរន្តរភាពខ្ពស់អង្គការបានលើកយកសេវាកម្មធំៗ ៣ មកធ្វើគឺ ÷

- សេវាកម្មបង្រៀនពីរបៀបគ្រប់គ្រងសហគ្រាសជំនួញចាប់ពីសហគ្រាសធុនតូចបំផុត ធុនតូច ធុនមធ្យម មកបង្រៀនពីរបៀបគ្រប់គ្រងបើយើងផ្តល់ឥណទានផ្តល់យោបល់ក្នុងការធ្វើជំនួញ ។ សេវាកម្មធំទាំង៣នេះគឺយើងផ្តល់រួមគ្នា ។ ក្រុមមនុស្សដែលយើងត្រូវជួយគឺជនក្រីក្រដើម្បីឱ្យមានផ្លូវចេញចូល ឬ អ្នកដែលបានខ្ចីឥណទានពីអង្គការអេស៊ីលីដាលុះត្រាណាតែមនុស្សនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចូលទៅក្នុងវិធីហ្វឹកហ្វឺនជំនួញជាមុនសិនទើបមានផ្លូវចូលទៅដល់ឥណទាន ហើយនិងសេវាមួយទៀតគឺសេវាក្នុងការផ្តល់យោបល់ក្នុងការធ្វើជំនួញ។ កម្មវិធីឥណទានរបស់យើងចែកចេញជា ៣ គឺ ÷

- ឥណទានក្រុម សំរាប់ក្រុមដែលធានាគ្នាទៅវិញទៅមក
- ឥណទានទោល សំរាប់ជំនួញធុនតូច
- ឥណទានទោល សំរាប់ជំនួញធុនមធ្យម ( ជាសាច់ប្រាក់សុទ្ធ )

ក្រៅពីការផ្តល់សេវាកម្មឥណទាន អង្គការអេស៊ីលីដាមានផ្តល់ជាសេវា

www.budinst.gov.kh www.elibraryofcambodia.org

ដែលមិនមែនជាឥណទានដែរគឺសេវាផ្តល់យោបល់ក្នុងការធ្វើជំនួញ។ ឧទាហរណ៍ : អតិថិជនម្នាក់មកជួបយើងដោយគាត់ចង់ចាប់ផ្តើមប្រកបមុខរបរអ្វីមួយ។ យើងអាចផ្តល់ជាយោបល់ថាតើមុខរបរណាគួរធ្វើមុខរបរណាដែលមិនគួរធ្វើ ដោយផ្អែកទៅលើពត៌មានដែលបុគ្គលិករបស់យើងតាមសាខាទាំង១១ខេត្តមាន ហើយយើងបង្រៀនគាត់ពីរបៀបរៀបចំធ្វើផែនការជំនួញរបស់គាត់សំរាប់ឱ្យគាត់មានផ្លូវចេញឥណទានបំពេញផែនការឱ្យបានត្រឹមត្រូវ ហើយនិងបង្រៀនគាត់ឱ្យចេះចងក្រងគ្នាជាក្រុមព្រោះថាកម្មវិធីឥណទានចែកចេញជាពីរគឺឥណទានទោលនិងឥណទានក្រុមហើយឥណទានក្រុម គឺសំរាប់ផ្តល់ឱ្យជនក្រីក្រណាដែលមិនមានអ្នកធានាឱ្យគាត់មានផ្លូវចូលទៅដល់កម្មវិធីឥណទានរបស់យើងគឺតាមរយៈការធានាគ្នាជាក្រុមនោះឯង ។

យោងតាមបទពិសោធន៍របស់អង្គការយើងកន្លងមកចែកចេញជា៣ដំណាក់÷

*ដំណាក់ការទី ១ :* ពីឆ្នាំ១៩៩៣-៩៤ពេលនោះអង្គការឥតបានគិតខ្លួនឯងថាមាននិរន្តរភាពជារៀងរហូត ដើម្បីផ្តល់សេវាកម្មប៉ុណ្ណោះទេ គឺអង្គការគិតតែម្យ៉ាង គឺ ធ្វើម៉េចឱ្យពលរដ្ឋគ្រប់គ្រងមុខរបររកទទួលទានអាចបែងចែកមុខរបររបស់ខ្លួនបាននោះ គឺជាដំណាក់ការសប្បុរសធម៌តែកម្មវិធីរបស់យើង គឺផ្តល់ឱ្យដោយមានការប្រាក់ទាបបំផុតគឺ ១០ភាគរយក្នុងមួយឆ្នាំ ។

*ដំណាក់ការទី ២ :* ជាដំណាក់ការកសាង ស្ថាប័នហិរញ្ញវត្ថុ គឺឆ្នាំ ១៩៩៥-៩៦ ។ ដំណាក់ការនេះអង្គការអេស៊ីលីដារៀបចំខ្លួនឱ្យមានស្វ័យហិរញ្ញវត្ថុ ។ កាលនោះយើងគិតថាយើងយកតែ៧០ភាគរយទេក្នុងបំណាច់ឆ្នាំ១៩៩៦ហេតុម៉េចបានជាយើងត្រូវគិតពីនិរន្តរភាពខ្លួនឯងដែរ ? ព្រោះយើងឃើញថាកម្មវិធីទទួលជំនួយឧបត្ថម្ភនេះមានរយៈពេលយូរមកហើយ គឺពីឆ្នាំ១៩៩៣ ដូច្នេះយើងត្រូវត្រៀមខ្លួនយើងដើម្បីឱ្យខ្លួនយើងមាននិរន្តរភាព

www.budinst.gov.kh www.elibraryofcambodia.org

បន្តកិច្ចការជាវៀងរហូត ។

ក្នុងឆ្នាំ១៩៩៧នេះបើគិតតាមលក្ខណៈប្រាក់ចំណូលពីការប្រាក់របស់ខ្លួនយើងគិតថាសំរាប់ផាច់ឆ្នាំ៩៧នេះអង្គការយើងមានលទ្ធភាពឧបត្ថម្ភកម្មវិធីខ្លួនឯង និងសំរាប់ប្រតិបត្តិការណ៏តទៅទៀតក្នុងប្រទេសយើងដែលចំណាយក្នុងមួយឆ្នាំ១៩៧០០០០ ។ ដូចនេះចាប់ពី១៩៩៨នេះទៅអង្គការយើងមានស្វ័យហិរញ្ញវត្ថុមានន័យថាសាខាទាំង៣០នៅក្នុងប្រទេសមានវត្តមានជាវៀងរហូតដើម្បីបន្តសេវាកម្មដល់ ពលរដ្ឋក្រីក្រ បើទោះបីជាយើងមិនបានទទួលជំនួយបន្ថែមពីម្ចាស់មូលនិធិក៏ដោយ ។ ឈរលើគោលការណ៍និរន្តរភាពនេះយើងមានលទ្ធភាពគ្រប់គ្រាន់សំរាប់ឱ្យអង្គការយើងដើរទៅមុខព្រោះបើយើងគិតពីអង្គការមិនមែនរដ្ឋាភិបាលដែលទទួលជំនួយពីម្ចាស់មូលនិធិជាវៀងរហូតនិងអង្គការមិនមែនរដ្ឋាភិបាលដែលមានផែនការរៀបចំខ្លួនឱ្យមាននិរន្តរភាពទាំងពីរនេះមានលក្ខណៈខុសគ្នាមួយពឹងផ្អែកលើជំនួយបរទេសជាវៀងរហូតអាចរងគ្រោះជាក់ជាមិនខាន ។ ជាក់ស្តែងដូចព្រឹត្តិការណ៏កន្លងមកពេលដែលម្ចាស់មូលនិធិមួយចំនួនកាត់មូលនិធិចេញធ្វើឱ្យអង្គការនោះកាត់បន្ថយឬបង្រួមសកម្មភាពរបស់ខ្លួន។បើដូច្នេះយើងត្រូវរៀបចំខ្លួនឱ្យហើយសំរាប់ឱ្យខ្លួនយើងមានលទ្ធភាពគ្រប់គ្រាន់។ និរន្តរភាពដែលខ្ញុំលើកមកនិយាយនេះមាន៤គឺ ÷

១. និរន្តរភាពខាងកម្មវិធី និងបច្ចេកទេស

២. និរន្តរភាពក្នុងការគ្រប់គ្រង

៣. និរន្តរភាពរចនាសម្ព័ន្ធ

៤. និរន្តរភាពខាងផ្នែកហិរញ្ញវត្ថុ

កាលណាយើងមាននិរន្តរភាពទាំង៤នេះមានន័យថា អង្គការយើងអាចមានភាពរឹងមាំបានហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

## សំណួររបស់លោក គិន ណាន ចំពោះបញ្ហាឥណទានសាច់ប្រាក់

សុំសួរពីការប្រមូលប្រាក់បានហើយរត់បាត់ តើត្រឹះជាទីទុកចិត្តរបស់អង្គការគេរៀបចំជាគ្រឹះយ៉ាងម៉េច ? ទី ២ បើសិនជាថាបង្កើតអង្គការបានទាល់តែមានលុយពីអន្តរជាតិមួយម៉ឺនឬពីរម៉ឺនផង ។ ចុះបើអ្នកស្វាយរៀងព្រះសង្ឃនៅស្វាយរៀងចង់បង្កើតអត់លុយបាតដៃទទេធ្វើនំអត់ម្សៅតើកើត ឬមិនកើត ?

## ចម្លើយរបស់លោក អ៊ិន ចាន់នី

បើតាមខ្ញុំបាទយល់សំណួររបស់លោកសាស្ត្រាចារ្យថាបើប្រសិនណានៅខេត្តស្វាយរៀងនេះត្រូវការបង្កើតឥណទានសន្សំប្រាក់ប៉ុន្តែមានតែបាតដៃទទេតើអាចធ្វើកើតឬទេ ? ចង់ឱ្យផ្តល់ជាបទពិសោធន៍ឬឱ្យខ្ញុំព្រះករុណាបង្ហាញពីការកកើត? តែការកកើតពីរឿងសាច់ប្រាក់គឺទាក់ទងនិងវេនាសម្ព័ន្ធនៃការគ្រប់គ្រងឥណទានសំរាប់បំផុសគឺការប្រគល់ប្រាក់។ ការប្រគល់ប្រាក់បើកាលណាយើងធ្វើនៅក្នុងសហគមន៍កុំប្រគល់ប្រាក់ទៅលើគណៈកម្មការឱ្យកាន់កាប់ យើងត្រូវបង្កើតគណៈកម្មការចំរុះមួយរួមមានគណៈកម្មការភ្នាក់ងារបុគ្គលិក ហើយយកប្រាក់ទៅបង្វិលបញ្ចូលក្នុងធនាគារតែម្តងហើយបើបើកមក តើបើកតាមរយៈណា ? គឺបើកតាមបែបបទធនាគារ ។

www.budinst.gov.kh www.elibraryofcambodia.org

## សំណួររបស់លោក ជុំ នឿម មណ្ឌលអារញ្ញរាសីវ៉ូខសាខាអង្គការ ព.ជ.អ

សុំសួរថា ១-ការធ្វើធនាគារភូមិនេះបើសិនណាជាក្នុងមូលដ្ឋានភូមិណាមួយឬឃុំណាមួយដែលមានអង្គការផ្សេងគេចុះធ្វើហើយតើយើងអាចធ្វើទៀតបានដែរឬទេដោយយើងធ្វើលើសមាជិកផ្សេងពីគេ ?

២ - ប្រសិនបើយើងចង់បើកជាធនាគារភូមិហើយមុននឹងឱ្យសមាជិកខ្ចីលុយតើសមាជិកត្រូវសន្សំលុយចំនួនប៉ុន្មានដង ? ហើយក្រោយពីសន្សំតើអនុញ្ញាតឱ្យខ្ចីលើកទី ១ ប៉ុន្មាន ? លើកទី ២ ប៉ុន្មាន ?

## ចម្លើយរបស់លោក អ៊ុន ចាន់នី

ខ្ញុំព្រះករុណាបានបកស្រាយជូនរួចហើយថា រឿងនេះវាទាក់ទងទៅនឹងគុណភាពរបស់កម្មវិធីព្រោះខ្មែរយើងចង់បានណាស់បើក្នុងភូមិមានកម្មវិធីដូចគ្នាពីរនោះ ជារឿងមួយដែលយើងជួបការលំបាកហើយ ព្រោះយើងធ្វើឡើងដោយសហគមន៍អ្នកស្រុកតាមបែបអ្នកក្រៅបរទេសគឺធ្វើតាមបែបគេអ្នកមានព្រោះគេយកទុនទៅដាក់តែម្តង ដែលជាហេតុធ្វើឱ្យកម្មវិធីយើងស្រុតចុះដូច្នេះយើងត្រូវមានយុទ្ធវិធីគឺបើយើងចង់ធ្វើត្រូវធ្វើផ្សេងពីកម្មវិធីនេះ ។ ក្នុងរឿងបង្កើតធនាគារអ្នកស្រុកអាចធ្វើទៅបានឥតមានបញ្ហាទេព្រោះអ្នកស្រុកធ្វើឡើងដោយខ្លួនឯងតែកុំឱ្យមានអង្គការដទៃទៀតចូលទៅធ្វើដែលវានាំឱ្យមានការបរាជ័យទាំងអស់គ្នា ។

មួយទៀតចំពោះសំណួរថា តើសមាជិកដាក់លុយប៉ុន្មានដងទើបអាចខ្ចីបាន ? ហើយបានប៉ុន្មានដែរ ? សមាជិកដែលសន្សំពីដើមឆ្នាំរហូតមក

www.budinst.gov.kh www.elibraryofcambodia.org

គឺមានរយៈពេល៣ខែគឺស្មើនឹង៦ដងហើយអាចមានសិទ្ធិខ្ចីប្រាក់ជាជំហានទី១ ដោយយើងឱ្យខ្ចីត្រឹមតែ ៥០ ០០០៛ ដល់ជំហានទី ២ ឱ្យខ្ចី ១០០ ០០០៛ តែត្រូវសងប្រាក់មកវិញនៅជំហានទី១សិនទើបអាចឱ្យខ្ចីជំហានទី២បានរហូតដល់ ៣០០ ០០០៛ ។

## សំណួររបស់ព្រះតេជគុណ ហេង គឹមហុន ចិន័យធស្រុកបរិបូរណ៍

នៅស្រុកបរិបូរណ៍ខេត្តកំពង់ឆ្នាំងមានអង្គការប្រាសាក់ I ធ្វើសកម្មភាពឥណទានដោយយកការប្រាក់តែ២ភាគរយទេ ក្នុងរយៈពេលប៉ុន្មានអាត្មាមិនបានដឹងដែរតែបើតាមស្តាប់នៅក្នុងសិក្ខាសាលានេះអង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍យកការស្រូវ៥០ភាគរយក៏មាន៣៥ភាគរយក៏មាន ដល់រឿងឥណទានយកការ៥ភាគរយខ្ញុំព្រះករុណាមិនយល់ទាល់អ្វីទេ ។ នេះជាទស្សនៈរបស់អាត្មាដែលអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ក្លាយទៅជាមូលធនអាត្មាមិនរាំងរាទេតែខ្លាចចុះហេតុអ្វីបានជាយកការថ្លៃជាងគេម្ល៉េះ ?
តើប្រាក់ដែលអ្នកស្រុកសន្សំ គណៈកម្មការយកទៅណា ?
តើអ្នកស្រុកសន្សំមានកាលកំណត់ដែរឬទេ ទើបអង្គការប្រគល់ប្រាក់ឱ្យខ្ចី ?

## ចម្លើយរបស់ព្រះតេជគុណ វៀម គឹមគេង

១-អង្គការសន្តិសេនាមានដើមទុនតិចហើយយើងអនុញ្ញាតឱ្យអ្នកខ្ចីក៏តិចដែរដូច្នេះប្រាក់សងទាំងអស់នេះក្រោយពីប្រមូលបានហើយយើងបញ្ចេញទៅឱ្យអ្នកខ្ចីវិញក្នុងរយៈពេល៦ខែយ៉ាងយូរហើយគ្រប់ជុំរបស់វាគឺ៦ខែអ្នកខ្ចីបាន

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទេរប្រាក់ដើមមកឱ្យគណៈកម្មការឥណទានភូមិ។ គណៈកម្មការគ្រាន់តែយកលុយនេះមកពិនិត្យហើយចាប់ផ្តើមរៀបចំកិច្ចសន្យាផ្តល់ទៅវិញ គឺ មិនបង្វិលចូលធនាគារ ឬយកទុកក្នុងកេះរបស់សន្តិសេនាឬយកមកតម្កល់ទុកនៅក្នុងភូមិទេគឺបញ្ចេញទៅវិញ ។

២ - ការសន្សំនេះយើងមិនបានកំណត់ទេចេះតែអនុវត្តទៅហើយរហូតមកដល់ពេលនេះនៅតែបន្តការសន្សំហើយយើងនិងបន្តការសន្សំទៅមុខទៀត ហើយអ្នកខ្ចីអ្នកខ្វះខាតមានច្រើនដូច្នេះអ្នកដែលខ្ចី ក៏នៅតែមានប្រាក់សន្សំហើយក៏បញ្ចេញទៅឱ្យអ្នកត្រូវការទៀត ។

## សំណួរពីសិក្ខាកាមចំពោះ អង្គការសន្តិសេនា GTZកំពង់ធំ និង ពដស

១ - ទាក់ទងខាងសន្តិសេនាៈមុនទៅអនុវត្តកន្លែងណាគឺថាស្រាវជ្រាវតាមដានសិក្សារកតំបន់ណាដែលត្រូវធ្វើការអភិវឌ្ឍន៍តើការស្រាវជ្រាវជ្រើសរើសតំបន់នេះមានរបៀបយ៉ាងម៉េចដែរ ? តំបន់សម្បូរអ្នកក្រច្រើនឬសម្បូណ៌អ្នកមានច្រើន ឬសម្បូរអ្នកខិលខូចច្រើន ឬសម្បូរអ្នកគុណធម៌ច្រើន ឬក៏ភូមិសាស្ត្រមានប្រភេទដីល្អអាក្រក់យ៉ាងម៉េច?សុំបញ្ជាក់ឱ្យច្បាស់ពីការស្រាវជ្រាវកម្មូលដ្ឋានដែលត្រូវទៅអភិវឌ្ឍន៍នេះ ?

២-ទាក់ទងអ្នកស្រីខាងកំពង់ធំតើការប្រមូលប៉ុន្មានដងទើបអាចយកមកធ្វើជាទុនបាន ? ហើយការដែលចូលនេះកំរិតទាបប៉ុន្មាន ? កំរិតច្រើនប៉ុន្មាន ?

៣ - ទាក់ទងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ហេតុអ្វីបានជាទៅធ្វើនៅខេត្តបាត់ដំបងដែលជាខេត្តសំបូរណ៌ដោយសម្បត្តិធម្មជាតិហើយក៏ជាខេត្ត

www.budinst.gov.kh www.elibraryofcambodia.org

ដែលមិនមានស្ថេរភាពទៀត? ដោយឡែកខគ្គស្វាយរៀងដីតូចជីវជាតិក៏គ្មានសម្បត្តិធម្មជាតិក៏គ្មាន មិនត្រឹមតែមនុស្សទេក្របីគោទៀតផងណើមអុសគ្មានរកតែដាំបាយមិនចង់បាន ។

## ចម្លើយពីអង្គការសន្តិសេនា

សន្តិសេនាបានសិក្សាពីការបរាជ័យក្នុងរបប សង្គមរាស្ត្រនិយម និងរដ្ឋកម្ពុជាទុកជាប្រធានបទមួយ ។ ដូចនេះសុំជំរាបថាការអនុវត្តន៍កម្មវិធីឥណទានពេលនេះយើងជួបប្រទះនូវបញ្ហាច្រើនដោយសារអ្នកមុនធ្វើឱ្យខូច ម៉្លោះហើយឥទ្ធិពលនោះវានៅសល់រហូតមកដល់ពេលនេះ បានជាយើងត្រូវមានការស្រាវជ្រាវពិភាក្សាឱ្យបានល្អិតល្អន់ជាមុនទើបយើងដាក់ទុនទៅកាលដែលយើងមកជាជំហានចុងក្រោយនេះគឺជារឿងលំបាកប្រៀបដូចឈើគេឈូសខូចផ្លុងហើយយកមកកែសំរួល ពិសេសតំបន់ដែលយើងកំពុងតែធ្វើមិននិយាយពីសម័យមុនទេគឺនិយាយពីសម័យរដ្ឋកម្ពុជាបានដាក់ជីទៅលោយជីអស់ ដាក់ស្រូវពូជលោយស្រូវពូជ ក្រោយមកដាក់លុយលោយលុយអស់ដូចនេះវាជាទម្លាប់របស់អ្នកភូមិហ្នឹងទៅហើយ ។ បើយើងចូលទៅដោយមិនសិក្សាស្រាវជ្រាវទេប្រហែលជាយើងត្រូវលោយខ្លួនដូចអ្នកមុនៗដែរព្រោះគាត់ធ្លាប់ផ្តល់បានហើយអ្នកក្រោយមិនប្រយ័ត្នគាត់នឹងផ្តល់ទៀត។ ប៉ុន្តែរហូតមកដល់ពេលនេះយើងបានធ្វើការអស់រយៈពេល៣-៤ឆ្នាំហើយ អ្នកភូមិបានចាប់ផ្តើមមានការយល់រឿងនេះច្រើន ។ នេះជាយុទ្ធសាស្ត្រនៃការធ្វើការងារគឺថាមិនទាន់ជួបប្រទះនៅភាពបរាជ័យទេ អ្នកភូមិនៅតែគោរពនៅតែធ្វើការសងមកវិញគ្រប់ចំនួនដូចលោក សួរ តោម ជំរាបព្រឹកមិញ ។ អាត្មាសុំបន្ថែមលើចំ

www.budinst.gov.kh www.elibraryofcambodia.org

ណុចនេះបន្តិចការដែលធ្វើឱ្យអ្នកភូមិសងមកវិញឱ្យបានត្រឹមត្រូវទៅតាមពេលវេលានិងគ្រប់ចំនួននេះ គឺដើម្បីកែសំរួលឡើងវិញនូវវិបត្តិសីលធម៌របស់ខ្មែរយើងដែលបាត់បង់នៅសច្ចៈភាពក្នុងខ្លួន ចេះកុហក ចេះករ ចេះបោកប្រាស់ ។ អាត្មាបានបញ្ជាក់ពីខាងដើមថាយើងបាត់បង់ព្រលឹងខ្មែរអង្គរអស់ពីខ្លួនហើយបានន័យថាមានការកុហកបោកប្រាស់គ្រប់ទីកន្លែង ។ ដោយសារតែមានទំលាប់ហូរហែរមក ឥឡូវនេះការធ្វើឥណទានមិនមែនគ្រាន់តែជីវភាពប្រចាំថ្ងៃប៉ុណ្ណោះទេគឺជាការស្តារឡើងវិញនូវសីលធម៌របស់ជាតិសាសន៍យើងផង។ អំពីការចុះទៅស្រាវជ្រាវនេះមានសារៈប្រយោជន៍សំខាន់ណាស់តើយើងត្រូវស្រាវជ្រាវដើម្បីអ្វី ?

១. ដើម្បីពត៌មាន

២. ដើម្បីកំណត់ឱ្យដឹងថាគ្រួសារនិមួយៗត្រូវការអ្វីខ្លះ

៣. ដើម្បីកំណត់នូវទំនៀមទំលាប់ប្រពៃណីតំបន់នោះធ្លាប់មានប្រវត្តិដូចម្តេច

៤. ដើម្បីកំណត់ស្ថានភាពភូមិសាស្ត្រ

## ចម្លើយរបស់អ្នកស្រី ខណ្ណ ស៊ីថា

ការរៃអង្គាសនេះទើបតែធ្វើទេពីព្រោះសមាគមនាងខ្ញុំទើបតែកើតនៅក្នុងឆ្នាំ ១៩៩៦ គឺថ្ងៃទី ១៦ ខែ ៦ ឆ្នាំ ១៩៩៦ ក្រោយពេលដែលនាងខ្ញុំបានទៅដកស្រង់បទពិសោធន៍ពីវត្តបុទុមហើយនិងចូលរួមសិក្ខាសាលានៅវត្តព្រះធំរឺឃុំចំណារលើស្រុកស្ទោងខេត្តកំពង់ធំ ។ ពេលត្រឡប់មកវិញដោយយល់ឃើញថាបច្ច័យដែលសន្សំក្នុងថ្ងៃសីលនិងព្រះសង្ឃបិណ្ឌបាត្រវាតិចណាស់ក្នុងការកសាង ហើយគណៈកម្មការវត្តក៏រៀបចំឱ្យក្លាយទៅជាសមាគមវិញដើម្បី

www.budinst.gov.kh www.elibraryofcambodia.org

បង្កើនទុនហើយការរៃអង្គាសក្នុងរយៈពេលតែ១ឆ្នាំ ឬ ២ឆ្នាំប៉ុណ្ណោះទេបាន កើនឡើងរហូតដល់ទៅ៣លានក្នុងនោះមានធ្វើបុណ្យពូនភ្នំស្រូវផង ។

## លោក ឃី ធន់ បញ្ជាក់បន្ថែម

ឈ្មោះថា ព្រះពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ មិនសំដៅតែអង្គការ ដែលនៅតែខេត្តបាត់ដំបងទេអង្គការសន្និសេទាក៏ជាអង្គការដើម្បីអភិវឌ្ឍន៍ទៅ អនាគតយើងត្រូវពង្រីកពាក្យថាអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ឱ្យរាលដាល សាយទូទាំងប្រទេសពីព្រោះព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ហើយព្រះ សង្ឃមាននៅគ្រប់វត្តគ្រប់ទីកន្លែងដែលមនុស្សរស់នៅដូច្នេះទៅអនាគតឈ្មោះ អង្គការនៅតាមខេត្តនានាអាចដូរ ។ នេះអង្គការសន្និសេទាបន្តិចទៀតមាន អង្គការរបស់ព្រះតេជគុណពោធ ម៉ានមួយទៀតបង្កើតឡើងគឺនៅតែក្នុងអង្គ ការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ដដែល។ ដូចនេះអត់មានបែងចែកឈ្មោះនេះ ឈ្មោះនោះ អ្នកនេះ អ្នកនោះនៅខេត្តនេះ នៅខេត្តនោះទេដោយហេតុនេះ ហើយបានហៅថាសិក្ខាសាលាជាតិ ។ ពាក្យថាជាតិមួយម៉ាត់មិនមែនយករដ្ឋា ភិបាលឬអ្នកដឹកនាំនយោបាយមកនៅក្នុងហ្នឹងទេបានសេចក្តីថាមនុស្សទាំងអស់ នៅក្នុងចង្កោមបរិស័ទរបស់ព្រះពុទ្ធរួមគ្នាផ្ដើមតួនាទីរបស់ព្រះពុទ្ធសាសនា មកវិញដើម្បីស្តារកិត្តិយស ព្រះពុទ្ធសាសនា របស់យើងឱ្យមានតួនាទីជាអ្នក កសាងប្រទេសជាតិ ទាំងខាងសីលធម៌ ទាំងខាងសម្ភារៈ ។ ស្មារតីតួនាទី របស់ព្រះសង្ឃធំណាស់ព្រះអង្គមកពីស្រុកបរិបូណ៌មានពុទ្ធដីការពីព្រឹកមិញថា ព្រះអង្គបានធ្វើច្រើនណាស់ម៉េចក៏មិនលើកសរសើរព្រះអង្គផង ? តាមពិត បានសរសើរហើយបើគ្មានព្រះអង្គទេគ្មានវត្តជាជំរកសំរាប់អ្នកក្រីក្រទេវត្តមិន

www.budinst.gov.kh www.elibraryofcambodia.org

មែនសំដៅសំរាប់តែធ្វើបុណ្យមួយមុខទេគឺសំរាប់ខ្មែរបានជាពឹងព្រះអង្គសព្វថ្ងៃ នេះឱ្យព្រះអង្គជួយធ្វើជាបង្គោលដើម្បីឱ្យឧបាសកនៅជុំវិញវត្តគេជឿលើព្រះ អង្គសំខាន់គឺជំនឿ ។ ការបរាជ័យពីមុនមកគឺគេមិនជឿថាឧបាសកកាន់លុយ វាមិនកីបកេង ហេតុនេះបានជាគេមិនសងតែបើពឹងព្រះអង្គដែលបរិបូណ៌ទៅ ដោយព្រហ្មវិហារធម៌បរិបូណ៌ទៅដោយសីលវិន័យ ជាអ្នកដែលបរិសុទ្ធបំផុត មកធ្វើជាបង្គោលធ្វើជាស្នូលហើយសកម្មភាពទុកឱ្យអាចារ្យ គណៈកម្មការធ្វើ ហើយកិច្ចការនេះក្នុងអង្គការពុទ្ធសាសនាយើងនិយាយថា ព្រះសង្ឃ ដូនជី ពុទ្ធបរិស័ទដែលជ្រើសរើសយកសមាជិកឥណទានក្តី សមាគមក្តីសំដៅរកអ្នក ណាដែលជឿទៅលើធម៌ព្រះពុទ្ធ អ្នកដែលពុំជឿបុណ្យបាបអ្នកផឹកស្រាអាឡូ អាឡូកុំឱ្យយកគេយកតែអ្នកមានជំនឿលើធម៌ព្រះពុទ្ធមួយមុខ ព្រោះអ្នកហ្នឹង ងាយស្រួលនឹងជួយងាយស្រួលនឹងណែនាំ។អ្នកដែលជឿថាខ្លួនឯងក្រដោយ បុណ្យដោយបាបដោយព្យេរវេរាត្រូវជួយមុនគេមិនអាចទៅយកអ្នកដែលមិន ជឿលើបុណ្យបាប ឬអ្នកដែលគេកាន់សាសនាផ្សេងៗអ្នកដែលមើលងាយព្រះ ពុទ្ធសាសនាអ្នកដែលមិនគោរពព្រះសង្ឃទេ ។ យើងត្រូវជ្រើសរើសយក មកធ្វើជាគំរូសិន ដល់ពេលបានគំរូហើយហៅថាថ្នាលបណ្តុះទើបយើងពង្រីក ទៅតាមភូមិផ្សេងៗតាមវត្តផ្សេងៗ ។ ហេតុនេះបានជានិមន្តព្រះអង្គគ្រប់ខេត្តមក ដើម្បីឱ្យព្រះអង្គបានទទួលនូវចំណេះដឹងនេះដល់ត្រឡប់ទៅវិញព្រះអង្គសាក ល្បងមើល បើជួបការលំបាកអាចទាក់ទងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ឬអង្គការសន្តិសេនាដល់ក្នុងសិក្ខាសាលាយើងនិងនិយាយគ្នាទៀត។ បើសិក្ខា សាលាចង់ឱ្យអង្គការព.ឌ.អ. ឬ ចង់ឱ្យអង្គការសន្តិសេនាជួយធ្វើយ៉ាងម៉េច សមាជិកនៃអង្គសិក្ខាសាលាអាចលើកជាយោបល់បាន។នេះជារឿងធំណាស់ ព្រោះខ្មែរយើងធ្វើអ្វីក៏បរាជ័យ ធ្វើអ្វីក៏រលាយ នោះវាជារឿងគួរឱ្យឈឺចាប់

www.budinst.gov.kh www.elibraryofcambodia.org

ណាស់គេថាខ្មែរមិនកើត គ្មានកំណើតគេយកទុនរាប់រយលានមកចោះហើយនៅតែមិនកើតទៀត។ហេតុម៉េចបានជាមិនកើត ? នេះហើយដែលអង្គការ ព.ឌ.អ. និងអង្គការសន្តិសេនាបានងើបឈរឡើងដើម្បីសាកល្បងជ្រោងកិត្តិយសកិត្យានុភាពនៃព្រះសង្ឃវិញ។ គ្រាន់តែក្រោយពីមករាក្លាមគោលនយោបាយរបស់រណសិរ្សថាឱ្យមានសាសនាឡើងវិញនេះទុកដូចជាគេជួយសាសនាមួយហើយឥឡូវគេលើកតម្កើងព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋទៀតគឺគេគាំទ្រពេញទំហឹង។បើរដ្ឋមិនជួយទេតើព្រះអង្គធ្វើអ្វីកើត ? ចង់ធ្វើបុណ្យមិនបានគេមិនអនុញ្ញាតចង់បួសមិនបាន គេមិនឱ្យបួសហើយព្រះអង្គដែលបួសមិនចង់បានកេរ្តិ៍ឈ្មោះផលប្រយោជន៍អ្វីទេ គឺដើម្បីសាសនា ដើម្បីផ្សព្វផ្សាយនូវមេត្តាធម៌និងព្រហ្មវិហារធម៌ដើម្បីឱ្យសីលធម៌រីកទៅដល់ប្រជាពលរដ្ឋដើម្បីឱ្យបញ្ញាទៅដល់ប្រជាពលរដ្ឋនិងដើម្បីឱ្យការត្រិះរិះការតំកល់ចិត្តឱ្យហ្នឹង ហ្នំបានដល់មហាជនសីលបញ្ញាសមាធិនិងព្រហ្មវិហារធម៌ទាំងបួន ដែលជាធម៌របស់ព្រះពុទ្ធបានជ្រួតជ្រាបដល់មហាជន។ ដូច្នេះការដែលព្រះអង្គបានធ្វើមកដល់សព្វថ្ងៃនេះគឺវាធំធេងណាស់ហើយព្រះអង្គបានធ្វើដោយគ្មាននរណាជួយ ។

ខ្ញុំព្រះករុណាមានសេចក្តីព្រួយបារម្ភយូរណាស់មកហើយពីរឿងលើក កំពស់គុណភាពព្រះសង្ឃ។ កាលពីឆ្នាំ១៩៩៥ខ្ញុំព្រះករុណាបានធ្វើដំណើរទៅប្រទេសសេរីលង្ការសុំអាហារូបករណ៍គេបាន ៥អង្គ សង្ឃឹមថា ៥អង្គដែលបញ្ជូនទៅរៀនឱ្យបានបណ្ឌិតបានត្រឡប់មកវិញពីព្រោះទៅកន្លែងព្រះហើយ។ព្រះពុទ្ធសាសនាគ្រាន់តែកើតនៅឥណ្ឌាមែនតែអ្នកកាន់ពិតប្រាកដ អ្នកអនុវត្តអ្នកថែរក្សាគម្ពីរមិនមែននៅឥណ្ឌាទេគឺនៅសេរីលង្ការ។ឥណ្ឌាគេដូរសាសនាអស់ហើយគេកាន់សាសនាផ្សេងៗជាង១០០០សាសនាឯណោះ ។ មានតែសាសនាតូចមួយទេហៅថា មហាពោធិសូសាយអ៊ីធី នៅញូដែលីហើយនៅទី

www.budinst.gov.kh www.elibraryofcambodia.org

ក្រុងតូចមួយជិតនោះដែលកាន់ សាសនាព្រះពុទ្ធ មានព្រះសង្ឃបួសមិនដល់ ១០០អង្គទេ សួរថាតើហេតុអ្វីបានជាព្រះលោកកើតនៅស្រុកឥណ្ឌា ?

និយាយពីរឿងព្រះសង្ឃខ្មែរវិញលោក វិបុល សារោ ដែលជានាយក ធំមួយនៅកូលុមបូរលោកថាអាត្មាអាចជួយបាន៣០អង្គឱ្យតែរើសបានតែដំបូង លោកសាក៥អង្គសិន។ ខ្ញុំព្រះករុណាបានទៅជួបលោក ឈន អៀមហើយ ក៏ទៅជួបនិយាយជាមួយគេបានជួបនឹងព្រះសង្ឃមកពីទីបេមកពីរុស្ស៊ី,មកពីម៉ុងហ្គោលី,មកពីកូរ៉េមកពីជប៉ុនក៏សុំទៅកូរ៉េគេជួយបាន ៥អង្គ សុំទៅសេរីលង្កា ឱ្យជួយវត្តលោកបាន២-៣វត្តទៀតឱ្យគេទទួលព្រះសង្ឃខ្មែរ គេក៏ព្រមទទួល ១០អង្គ។ពេលត្រឡប់មកវិញទៅទូលសម្តេចព្រះសង្ឃរាជទូលនាយកសាលា ហើយក៏ធ្វើការប្រលងជ្រើសរើសសមណនិស្សិតដើម្បីបញ្ជូនទៅរៀន។ តែគួរ ឱ្យស្តាយពេលទៅដល់គេឱ្យបោសវត្ត ជូតកុដិ ធ្វើចង្ហាន់ឆាន់ខ្លួនឯង ទៅរៀន ខ្លួនឯងឆាន់បាវីមិនបានធ្វើមិនកើតឥឡូវនេះគេបញ្ជូនមកវិញអស់៤អង្គ ហើយ នៅសល់ ៦អង្គ ទៀតមិនដឹងជាយ៉ាងម៉េចរៀនបានចប់ចុងចប់ដើមឬទេព្រោះ ស្រុកសេរីលង្កាវគេមានចម្បាំង ។

ដូច្នេះមានតែសង្ឃឹមព្រះសង្ឃក្នុងស្រុកទេ ហើយសូមពិតពុទ្ធដីកាផងដែរ ថាឥឡូវយើងមានបើកថ្នាក់មហាវិទ្យាល័យបានមួយថ្នាក់ហើយ ។ ប៉ុន្តែរឿង ចំណេះវិជ្ជានៅឆ្ងាយណាស់ ព្រោះគ្មានអាចារ្យពូកែៗដូចជំនាន់ខ្ញុំព្រះករុណា រៀនសាស្ត្រាចារ្យបាលី សំស្ក្រឹត សុទ្ធតែមកពីឥណ្ឌាហើយធម៌អាថ៌សុទ្ធតែគ្រូ អាចារ្យល្បីៗដូចជា លោកតា សេក នាង, លោកតា ជឹម តូ, លោកតា បាំង ខាត់, លោកតា សួរ្យ ហាយ គឺសុទ្ធតែមេធម៌ ។ ឥឡូវនេះនៅសល់ តែសៀវភៅរបស់គាត់ហើយសៀវភៅរបស់លោកជួនកាលទេសមិនដាច់មើល ខ្លឹមសារដែលលោកសរសេរទុកមិនយល់ទៀតនេះមកពីគ្មានអ្នកណាពន្យល់។

www.budinst.gov.kh www.elibraryofcambodia.org

អាណិតព្រះសង្ឃដែលជាកូនចៅអ្នកក្រីក្រ កូនអ្នកមាន គេមិនបួសទេមានតែកូនអ្នកក្រយើងទេដែលបួសហើយបួសជួយអ្នកក្រ ហើយមានតែអ្នកក្រដូចគ្នាទេដែលយល់ពីទុក្ខលំបាកទុក្ខវេទនា ហើយអ្នកក្រដែលយល់បានទៅនិយាយជាមួយគេអ្នកមានគេមិនយល់ទេ។ ដូចព្រះតេជគុណសួរថាព្រះសង្ឃបច្ចុប្បន្ននិងព្រះសង្ឃពីបុរាណខុសគ្នាយ៉ាងណា ? ខុសគ្នាឆ្ងាយណាស់ហើយសភាពការណ៍សព្វថ្ងៃវាជានិន្នាការទូទៅរបស់សកលលោក ។ ពុទ្ធសាសនាវិចរិលទៅៗមិនមែនតែស្រុកខ្មែរយើងទេ គឺទូទាំងសកលលោកទៅតាមទំនាយរបស់ព្រះដែលលោកបានទាយទុក ហើយវាចេះតែទៅម្តងបន្តិចៗទោះបីខំទប់ស្កាត់យ៉ាងណាក៏វាមិននៅដែរគឺដោយសារការរីកចំរើន ខាងសេដ្ឋកិច្ច ខាងវិទ្យាសាស្ត្រហើយព្រះសង្ឃយើងចេះតែក្លាយបន្តិចម្តងៗមិនដូចបុរាណទេ ពីព្រោះមិនដឹងទៅសួរពីណាហើយអ្នកចេះក្រៅគម្ពីរចេះអត់គម្ពីរមានអ្វីជាសំអាង ។ ក្រោយថ្ងៃរំដោះភ្លាមយើងសួរថាតើគម្ពីរព្រះត្រៃបិដកនៅសល់ប៉ុន្មាន ? ខ្ញុំព្រះករុណាខំទៅរើមើលនៅសារៈមន្ទីរជាតិបណ្ណាល័យជាតិមាននៅសល់បាន ២ចប់តែករណ្តៀរស៊ីខ្លះហើយ។ ដល់ជប៉ុនគេមកជួយគេសួរថាតើសាសនាអ្នកឯងចង់បានអ្វីចង់ឱ្យខ្ញុំជួយអ្វីមុនគេ ? ខ្ញុំព្រះករុណាថាមានតែសៀវភៅ និងគម្ពីរព្រះត្រៃបិដកទេព្រោះបើចង់ស្តារព្រះពុទ្ធសាសនាឱ្យរុងរឿងមានតែគម្ពីរព្រះត្រៃបិដកទេដែលជាមូលដ្ឋានគ្រឹះនៃព្រះពុទ្ធសាសនាបើចង់វែកញែកវិន័យពីព្រះសូត្រព្រះអភិធម្ម ចង់និយាយពីសង្គមពីតួនាទីព្រះសង្ឃគឺមានគម្ពីរនេះឯងព្រោះបើអត់គម្ពីរទាំងនេះមិនដឹងបានអ្វីជាគោលទេ។ ហេតុនេះសូមព្រះអង្គមេត្តាខិតខំសិក្សាស្រាវជ្រាវតាមគម្ពីរព្រះត្រៃបិដកឱ្យមែនទែន ព្រោះបើបញ្ជូនទៅក្រៅខ្លាចបែកទៅតាមរបៀបរបបគេ ។ ខ្ញុំព្រះករុណាបានចូលរួមសិក្ខាសាលាអន្តរជាតិមួយស្តីពីព្រះពុទ្ធសាសនាពីសីលធម៌ព្រះពុទ្ធសាសនា ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះសង្ឃប្រទេសភូមាលោកបានរាយការណ៍ថានៅវត្តមួយវត្តមានព្រះសង្ឃ ៣ពាន់អង្គក៏មាន១ពាន់អង្គក៏មាន ។ ដល់ច្រើនពេកទៅតើសង្ឃរាជវត្តគ្រប់គ្រងយ៉ាងម៉េចកើត ? គឺគ្រប់គ្រងមិនបានមានតែបរិមាណអត់គុណភាព ។ គេសួរមកខ្មែរយើងយ៉ាងម៉េចដែរខ្ញុំឆ្លើយថាបើលោកខ្ញីរស្សាប្រហែលជាមានតែបរិមាណដែរក្នុង៤៧០០០អង្គ ប្រជាពលរដ្ឋចង់បាន១ម៉ឺនអង្គចុះដែលចេះធម៌វិន័យច្បាស់លាស់ប្រព្រឹត្តត្រឹមត្រូវតាមបញ្ញត្តិរបស់ព្រះពុទ្ធ ។ ក្រៅពីនេះឃើញថាពុំទាន់បានត្រឹមត្រូវទេ ព្រោះសព្វថ្ងៃនេះមានអ្នកខ្លះគេស្លៀកស្បង់តែអត់កោរសក់ហើយថា គេជាសាវ័ករបស់ព្រះដែរ ខ្លះទៀតគេឡើងទៅចង្រ្កមភាវនានៅលើភ្នំដល់ទៅផុតមិនផេះគាប់មិនមុត នោះគេថាជាសាវ័ករបស់ព្រះដែរ ។ ដល់អញ្ចឹងទៅអ្នកណាគេចង់បានលាភសក្ការៈគេទៅគោរពទៅប៉ុន្តែអ្នកណាគេមិនជឿតាមលាភសក្ការៈគេជឿតាមព្រះពិតប្រាកដ ព្រោះទស្សនវិជ្ជារបស់ព្រះជាទស្សនវិជ្ជាវិទ្យាសាស្ត្រដែលព្រះអង្គរកឃើញជាង២ពាន់ឆ្នាំមកហើយគ្មានអ្នកណារកឃើញថ្មីជាងព្រះអង្គទេ គឺកើត-ស្លាប់គ្មានអ្នកណាកើតហើយរស់រហូតទេ ។ សេចក្តីទុក្ខដែលព្រះអង្គរកឃើញងាយបំផុតគឺមនុស្សកើតមកត្រូវការបរិភោគ ស្លៀកពាក់ ជំរក និង ឱ្យមានសុខភាព។ សេចក្តីត្រូវការ៤យ៉ាងដែលព្រះពុទ្ធលោករកឃើញនេះបើខ្វះមួយណាហើយនោះសេចក្តីទុក្ខនឹងមកដល់ភ្លាម។ នោះហើយហេតុនៃសេចក្តីទុក្ខរកឃើញផ្លូវស្ងប់ទុក្ខរកឃើញផ្លូវដើរឱ្យផុតទុក្ខគ្មានអ្នកណារកឃើញថ្មីជាងព្រះទេ ហើយងាយបំផុតគ្មានពិបាកសោះគឺមិនប្រមាទការប្រយ័ត្នខ្លួនគ្រប់សកម្មភាពដែលនាំទៅរកសេចក្តីទុក្ខទាំងប៉ុន្មាន ហើយបើប្រមូលមកមានតែ ៣ គឺ ÷

១. ទុក្ខកើតឡើងពីតណ្ហាដែលយើងចង់បាន ហើយមិនបាន

២. ទុក្ខដែលកើតពីការមិនចង់បានតែវាបាន

www.budinst.gov.kh www.elibraryofcambodia.org

៣. ទុក្ខកើតពីរបស់ដែលបានមកហើយបាត់ទៅវិញ ( កើតស្លាប់វិញ )

ទុក្ខទាំង៣នេះជាទុក្ខធំណាស់ ដែលព្រះពុទ្ធលោករកឃើញយូរណាស់មកហើយ ហើយយើងទាំងអស់គ្នាមិនបានដឹងរឿងនេះចេះតែនាំគ្នាភ្លេចនូវអ្វីដែលកំពុងតែវិនាសទៅបាត់បង់ទៅៗ ។ រឿងនេះយើងថាកំពុងស្ថិតស្ថេរជាអមតៈនិងជានិច្ចៈតាមពិតវាជាអនិច្ចៈទាំងអស់កំពុងតែវិវត្តទាំងអស់ ។ ដូចជាគុកៅអីទាំងអស់នេះកំពុងតែធ្វើដំណើរទៅរកសេចក្ដីវិនាសទាំងអស់ចំនែកយើងឥតបានត្រៀមខ្លួនទៅវិនាសឯណាតាមពិតវាកំពុងតែវិនាសកំពុងតែវិវត្តទៅគ្មានអ្វីមួយនៅស្ងៀមបានទេ នេះបើនិយាយពីធម៌ព្រះដែលមានលក្ខណៈវិទ្យាសាស្ត្រហើយក៏គ្មាននរណាម្នាក់រកឃើញថ្មីក្រៅពីនេះឡើយ។ បញ្ហានេះសុំឱ្យព្រះអង្គជួយសីលធម៌ខ្មែរផងចុះសម្បើមណាស់មិនស្គាល់បុណ្យមិនស្គាល់បាបដូចពេលមានចលាចលនៅភ្នំពេញមកតាំងពីកំពង់ស្ពឺអូសរទេះចូលភ្នំពេញដើម្បីយកជ័យភ័ណ្ឌ ម្ចាស់គេនៅនឹងមុខ ឡាសំពះអង្វរហើយមិនព្រមទៀតដណ្ដើមយករបស់គេទាល់តែបាន។យករបស់គេវាធ្ងន់ធ្ងរណាស់ បើរបស់រផ្លវាមិនអីទេតែនេះជារបស់ឯកជនហើយម្ចាស់គេនៅនឹងមុខទៀត ។ ជបុំនគេសួរថា ហេតុអ្វីបានជាសីលធម៌ខ្មែរធ្លាក់ដល់ថ្នាក់ហ្នឹង ? មកពីហេតុអ្វី ? សូមព្រះអង្គជួយរកមូលហេតុផង ហេតុអ្វីបានជាសេចក្ដីលោភលន់ ចង់បានចង់ឆ្អែតតែអញ គិតតែខ្លួនអញ មិនគិតគេ ហើយឥតគិតថា នៅក្នុងពិភពលោកនេះគ្មានអ្វីដែលដាច់គ្នាបានទេទាំងព្រះសង្ឃ គ្រហស្ថ ទឹក ដី គ្មាននរណាថាអានេះដីអញ ។ល។ ទោះជាទន្លេមេគង្គមានប្រវែងណា ក៏ដោយក៏នៅជាប់គ្នាពីចិនមកសមុទ្រដែរ គឺជាប់ទាក់ទងគ្នារហូតគ្មាននរណាម្នាក់ទៅឃាត់ទឹកមិនឱ្យហូរទុកឱ្យអញប្រើម្នាក់ឯងបានទេនេះជាលក្ខណៈជាក្រិតក្រមធម្មជាតិគឺវាត្រូវតែទាក់ទងគ្នា។ ដូច្នេះធ្វើម៉េចឱ្យគេជឿទៅបានហើយថ្ងៃនេះ

www.budinst.gov.kh www.elibraryofcambodia.org

និមន្តព្រះតេជគុណមកដើម្បីធ្វើឱ្យគេជឿរួចហើយទុកឱ្យឧបាសកគេធ្វើការងារធ្វើសកម្មភាពដោយផ្ទាល់ចុះមិនឱ្យព្រះសង្ឃប៉ះពាល់នឹងវិន័យទេ ដោយគ្រាន់តែធ្វើជាបង្គោលដើម្បីឱ្យគេជឿកុំឱ្យគេយកលុយទៅមិនបានធ្វើអ្វីៗបែរជាទៅចាយវាយផ្ដេសផ្ដាស់ ហើយភ្លូតកុហកព្រះសង្ឃគឺបាប ។

www.budinst.gov.kh www.elibraryofcambodia.org

# ការបង្កើត និង ដំណើរការរុក្ខបដ្ឋាន

ដោយ ព្រះតេជគុណ ខៀម គីមតេង នាយកអង្គការសន្តិសេនា

ដោយហេតុថា អាត្មាធ្លាប់បានធ្វើគំរោងហើយបានវាយតំលៃទៅលើការអនុវត្តការងារខ្លះមិនធ្វើខ្លួនឯងទេ គ្រាន់តែធ្វើជាគំរោងផ្តល់ជាមេរៀនសំរាប់គេយកទៅអនុវត្តដូចជាការងារធនាគារស្រូវ,ការងារឥណទានជាដើមនោះខ្ញុំព្រះករុណាអាត្មាភាពគ្រាន់តែជាអ្នកសរសេរជាអ្នករៀបចំគំរោង រៀបប្លង់ឱ្យគេដើរនិងវាយតំលៃទៅលើការធ្វើដំណើររបស់គេតែប៉ុណ្ណោះ។ ការងារបរិស្ថានក៏ដូច្នោះដែររឿងបរិស្ថាននេះជារឿងមួយដ៏ធំហើយមានការទាក់ទងទៅលើជីវភាពនិងការរស់នៅប្រចាំថ្ងៃរបស់យើង។ បរិស្ថានជាការងារដែលយើងទាំងអស់គ្នាត្រូវតែយល់ ហើយចូលរួមថែរក្សាការពារបរិស្ថានគឺអ្វីដែលនៅជុំវិញយើងហើយដែលយើងមានការអាស្រ័យគ្នាទៅវិញទៅមកនោះហៅថាបរិស្ថាន ។ ដូច្នេះយើងរស់នៅសព្វថ្ងៃបានសុខសប្បាយមានសុខភាពល្អក៏អាស្រ័យដោយបរិស្ថានដែលនៅជុំវិញយើងល្អហើយបរិស្ថានល្អបានអាស្រ័យដោយយើងទាំងអស់គ្នាល្អជួយថែរក្សា ជួយការពារ ។ ដូច្នេះវាជាអញ្ញមញ្ញភាព ឬ អញ្ញមញ្ញបច្ចយោនៅមហាបដ្ឋានសូត្រគឺមានហេតុបច្ច័យអាស្រ័យគ្នាទៅវិញទៅមកមិនអាចមានមួយអត់មួយបានទេ។ មនុស្សយើងរស់បានស្រួលក៏អាស្រ័យមកពីបរិស្ថានៗដែលតាំងនៅល្អបានអាស្រ័យពីមនុស្សជួយថែរក្សា " *មនុស្សថែរក្សាបរិស្ថាន បរិស្ថានថែរក្សាមនុស្ស មនុស្សបំផ្លាញបរិស្ថាន បរិស្ថានបំផ្លាញមនុស្ស* " ។ ត្រង់នេះហើយដែលព្រះពុទ្ធមានពុទ្ធដីកាថា *អញ្ញមញ្ញបច្ចយោ* គឺមានការប្រាស្រ័យគ្នាទៅវិញទៅមកហើយបរិស្ថានមានច្រើនមានបរិស្ថានសង្គមនិងបរិស្ថានធម្មជាតិ។បរិស្ថានសង្គមមានចែកជាច្រើន

www.budinst.gov.kh www.elibraryofcambodia.org

ទៀតតែពេលនេះសុំលើកយកតែផ្នែកមួយនៃ បរិស្ថានធម្មជាតិមកនិយាយ ។ ធម្មជាតិគឺអ្វីៗដែលកើតឡើងពីហេតុ បច្ច័យគាត់តែងអំពីសង្ខារដែលបានតាក់តែង ដូចជាទឹក, ដី, ភ្លើង,ខ្យល់, ព្រៃភ្នំក្រមថ្មទាំងអស់នេះគឺជាធម្មជាតិជាអនុបាទិន្នកៈសង្ខារ។សង្ខារមានពីរ ឧបាទិន្នកៈសង្ខារនិងអនុបាទិន្នកសង្ខារគឺជាសង្ខារដែលមានវិញ្ញាណនិងសង្ខារដែលគ្មានវិញ្ញាណ ។ ឧបាទិន្នកសង្ខារបានដល់មនុស្សសត្វមានជីវិតដឹងសុខទុក្ខ ក្តៅត្រជាក់ ស្រេកឃ្លាន ។ល។ អនុបាទិន្នកសង្ខារដែលមិនមានវិញ្ញាណ មិនមានវិចារណញ្ញាណបានសេចក្តីថាមនុស្សក៏ជាធម្មជាតិអ្វីៗដែលនៅលើផែនដីនេះក៏ជាធម្មជាតិ ។ ឥឡូវយើងនិយាយពីផ្នែកមួយ នៃ បរិស្ថានធម្មជាតិគឺរឿងព្រៃឈើ ។ បរិស្ថានធម្មជាតិដែលមានទឹក, ភ្លើង, ខ្យល់, ដី ។ល។ ម្ល៉ោះហើយបានជាយើងឃើញបញ្ហាកំពុងចោទឡើងដូចជាស្រទាប់អូហ្សូនចេះតែស្តើងទៅៗ ។ នេះជាបរិស្ថានធម្មជាតិព្រោះស្រទាប់អូហ្សូននេះសំរាប់ទប់ស្កាត់កំដៅពីព្រះអាទិត្យ ហើយបើកាលណាវាស្តើងធ្វើឱ្យមានបញ្ហាដល់សង្គមមនុស្សព្រោះយើងសព្វថ្ងៃត្រូវកើនកំដៅខ្ពស់ដោយសារតែការរិចរិលនៃស្រទាប់អូហ្សូនដែលជារនាំងសំរាប់ទប់ស្កាត់និងការពារកំដៅព្រះអាទិត្យ។ មួយទៀតទឹកក៏ជាបរិស្ថានដែរដូចជាទឹកទន្លេទឹកស្ទឹងចេះតែក្រខ្វក់ទៅៗវាជាការមួយដែលធ្វើឱ្យខូចបរិស្ថានដែរហើយដីក៏ដូចគ្នាដែរ ។ យើងនិយាយពីព្រៃឈើវិញស្រុកខ្មែរជាស្រុកមួយសំបូរព្រៃឈើបំផុតនៅក្នុងអាស៊ីអាគ្នេយ៍យើងនេះ ។ តាមស្ថិតិនៅមុនឆ្នាំ១៩៧០ស្រុកខ្មែរយើងមានព្រៃឈើដល់ ៧៣ភាគរយ នៃផ្ទៃដីទាំងមូលបានន័យថាព្រៃឈើច្រើនជាងដីទំនេរ ។ ប៉ុន្តែចាប់ពីសង្គ្រាមដើមទសវត្សរ៍ឆ្នាំ ១៩៧០ ព្រៃទាំងនោះត្រូវបានបាត់បង់ទៅម្តងបន្តិចៗដោយសារភ្លើងឆេះ តំបន់ខ្លះមិនមានការគ្រប់គ្រងពិតដល់ តំបន់ខ្លះទៀតត្រូវបានកាប់បំផ្លាញ ដោយគ្មានការត្រួត

www.budinst.gov.kh www.elibraryofcambodia.org

ពិនិត្យផ្នែកបច្ចេកទេស ។ រហូតមកដល់សព្វថ្ងៃនេះការកាប់បំផ្លាញព្រៃឈើជារឿងមួយគួរឱ្យបារម្ភជាទីបំផុតមិនមែនតែពលរដ្ឋខ្មែរ សូម្បីតែអន្តរជាតិក៏មានការព្រួយបារម្ភអំពី ការបាត់បង់ព្រៃឈើ នៅស្រុកខ្មែរព្រោះអ្នកឯកទេសខាងព្រៃឈើដូចជាមានអង្គការមួយហៅថា GLOBAL WITNESSE តាំងនៅទីក្រុងឡុងគេបានសិក្សាអំពីព្រៃឈើនៅស្រុកខ្មែរយើង ហើយគេមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបាត់បង់ព្រៃឈើដ៏លឿនបំផុតនៅក្នុងស្រុកខ្មែរយើងដែលគេពុំដែលធ្លាប់ជួបប្រទះសោះនៅលើពិភពលោកនេះ ។ អង្គការនេះបានធ្វើសេចក្តីប្រកាសប្រាប់ពេញពិភពលោក ព្រោះអង្គការនេះមានឥទ្ធិពលខ្លាំងណាស់។ នៅឆ្នាំ ១៩៩១-៩២ អង្គការកម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិUNDPគេបានធ្វើការសិក្សាស្រាវជ្រាវនិងធ្វើការប៉ាន់ប្រមាណព្រៃឈើនៅក្នុងប្រទេសយើងពីឆ្នាំ ១៩៧០- ១៩៩០ក្នុងរយៈពេល ២០ឆ្នាំនេះនៅសល់តែត្រឹម៤០ភាគរយនៃផ្ទៃដីប្រទេសប៉ុណ្ណោះគឺត្រូវបាត់អស់ ៣២ភាគរយនៃព្រៃឈើដែលមានពីមុន ។ ថ្មីៗនេះ ( ១៩៩៧ ) មានអង្គការមួយដែលមានទីតាំងនៅញូយ៉កសហរដ្ឋអាមេរិក គេបានបង្កើតការគ្រប់គ្រងព្រៃឈើតាមប្រព័ន្ធផ្កាយរណប ដើម្បីគ្រប់គ្រងលើព្រៃឈើដោយមិនបាច់ចុះមកវាស់ដើមឈើទេគេប្រើតែផ្កាយរណបដើម្បីថតយកព្រៃឈើ ជាពិសេសនៅតំបន់អាស៊ីយើងនេះហើយរូបថតដែលគេថតបាននោះបានបញ្ជាក់ថាស្រុកខ្មែរយើងនៅសល់ព្រៃឈើត្រឹមតែ២៨ភាគរយប៉ុណ្ណោះ គឺចុះពី៤០ភាគរយមកនៅ២៨ភាគរយហើយព្រៃឈើដែលមានច្រើននៅខេត្តក្រចេះ,ស្ទឹងត្រែង,កំពង់ធំ, រតនគីរី, មណ្ឌលគីរី, និងព្រះវិហារ ឯខេត្តកំពង់ចាមនៅតិចតួចនិងមានមួយផ្នែកតូចនៅកោះកុង។ នេះជាលទ្ធផលដែលគេប្រកាសឱ្យឃើញពីការស្រុតចុះនៃព្រៃឈើស្រុកខ្មែរ ។ មកទល់ថ្ងៃនេះតើយើងបានដឹងថាការ

www.budinst.gov.kh www.elibraryofcambodia.org

កាប់ព្រៃឈើបានបញ្ឈប់ឬមួយនៅតែបន្ត?ការកាប់ព្រៃឈើនៅស្រុកខ្មែរយើង ជាការកាប់ដោយខ្វះបច្ចេកទេសចេះតែកាប់ដោយអនាធិបតេយ្យ ។ តំបន់ខ្លះ យើងបានឃើញ និងតំបន់ខ្លះយើងមិនបានឃើញ ដូចជាតំបន់ដែលគ្រប់គ្រង ដោយរដ្ឋាភិបាលក៏កំពុងតែកាប់យ៉ាងចំហរកាប់ទាំងស្របច្បាប់ កាប់ទាំងមិន ស្របច្បាប់ឯតំបន់គ្រប់គ្រងដោយខ្មែរក្រហមកំពុងតែកាប់ដោយចំហរនិងកាប់ ដោយរូបភាពផ្សេងៗ ។ ហេតុនេះហើយដែលជាហេតុនាំឱ្យព្រៃឈើធ្លាក់ចុះ យ៉ាងសម្បើម។ ក្នុងរូបភាពទស្សនាវដ្តីមួយផ្ញើពីទីក្រុងឡុងគេបានថតរូបភាព កាប់ព្រៃឈើនៅក្នុងស្រុកខ្មែរដែលមានអាយុ ១៣០០ឆ្នាំ គឺដើមបេងនៅខេត្ត សៀមរាបម្តុំអង្គរវត្តយកទៅលក់ឱ្យថៃ ហើយថៃបានយកដើមឈើនោះទៅ តាំងនៅក្នុងសារៈមន្ទីររបស់គេ។ឥឡូវនេះថៃគេឱ្យគាស់ឫសបេងនោះទៅថ្លឹង លក់ឱ្យគេទៀត។វិលមកវិញគឺខេត្តស្វាយរៀងគ្មានព្រៃឈើ ។ មុនសង្គ្រាម ១៩៧០ស្ថិតិនៅមន្ទីរកសិកម្មខេត្តបានបញ្ជាក់ថា ខេត្តស្វាយរៀងមានព្រៃឈើ ៥ម៉ឺនហិកតា ។ មកដល់សម័យរដ្ឋកម្ពុជាព្រៃឈើនៅសល់ ៥ពាន់ហិកតា ។ ដល់សព្វថ្ងៃនៅសល់ប្រហែល ៥០០ហិកតា គឺវាស្រុតចុះពី ៥ម៉ឺនមក៥ពាន់ រហូតមកនៅត្រឹម៥០០ហិកតា ។ ដូច្នេះការបាត់បង់ព្រៃឈើខេត្តស្វាយរៀង ក៏ដូចជានៅទូទាំងប្រទេសដែរ ធ្វើឱ្យយើងជួបនូវបញ្ហាជាច្រើនដូចជាការប្រែ ប្រួលនៃអាកាសធាតុ ក្តៅពេក ត្រជាក់ពេក ភ្លៀងធ្លាក់ខុសរដូវមិនទៀង ជួនកាលរាំង ជួនកាលភ្លៀង ជួនមានកើតខ្យល់ព្យុះជាញឹកញាប់នេះ ដោយ សារតែយើងបាត់បង់ព្រៃឈើ ។ ដោយមើលឃើញនូវភាពយ៉ាងនេះហើយ ទើបខ្ញុំព្រះករុណាបានបង្កើតជាអង្គការមួយឈ្មោះថា អង្គការសន្តិសេនា ជា អង្គការពុទ្ធសាសនាសន្តិសេនា ព្រោះកាលបើយើងធ្វើក្នុងនាមជាបុគ្គលម្នាក់ នោះគ្មានកំលាំងទេ ទាល់តែយើងបង្កើតជាអង្គការទើបយើងអាចធ្វើការងារ

www.budinst.gov.kh www.elibraryofcambodia.org

នេះបាន។ អង្គការសន្តិសេនាព្រះអង្គជ្រាបហើយថាសន្តិមានន័យថាសន្តិភាព ហើយសេនាមានន័យថាជាកំលាំងប្រដាប់អាវុធ។ដូច្នេះកំលាំងទ័ពរបស់យើង គឺយើងទាំងអស់គ្នាជាកំលាំងសន្តិភាព ជាកំលាំងដ៏ស្ងប់គឺធ្វើសកម្មភាពដោយ សេចក្តីស្ងប់ដោយសន្តិវិធីមិនធ្វើការក្តុងក្តាំងទេ។ខ្ញុំព្រះករុណាបានគូសបួងទុក ថាកងទ័ពសន្តិសេនាគឺជាបរិស័ទព្រះសង្ឃគ្រហស្ថជាអ្នកចូលរួមក្នុងពុទ្ធសាស នា ។ និយាយដោយខ្លីកងទ័ពសន្តិសេនានៅក្នុងប្រទេសយើងមានជាង៤ម៉ឺន រាប់តែពាក់ឯកសណ្ឋានជាង៤ម៉ឺន ចុះនៅអ្នកដែលមិនពាក់ឯកសណ្ឋានទៀត ប៉ុន្មានទៅ? ហើយយើងមានបន្ទាយ(វត្ត)ដែលជាទីតាំងឈរជើងរបស់យើង ៣៦០០ នៅក្នុងស្រុកខ្មែរ ។

## សកម្មភាពការងារកសិកម្មនិងការធ្វើជីកំប៉ុស្តរបស់អង្គការ ព.ជ.អ

ដោយ លោក ណុប ពោល មន្ត្រីកសិកម្ម ព.ជ.អ

ការបណ្តុះ និងការដាំដើមឈើ :

តាមការសិក្សាស្រាវជ្រាវឃើញថាការដាំដុះព្រៃឈើជាបញ្ហាសំខាន់ទើប អង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ បានបង្កើតជាកម្មវិធីរុក្ខវប្បកម្មនេះឡើង ក្នុងគោលបំណងលើកកំពស់ការពារនិងថែរក្សាបរិស្ថានធម្មជាតិ និង បង្កើន ការយល់ដឹងពីប្រយោជន៍នៃរុក្ខជាតិ ។ ទន្ទឹមនឹងនេះដែរយើងក៏បានបណ្តុះ នូវ កំលាំងស្មារតី ដល់អ្នកស្រុកឱ្យដាំឡើងវិញនូវរុក្ខជាតិគ្រប់ប្រភេទដោយ លើកជាគោលការណ៍ដែលទាក់ទងទៅនិងរឿងរ៉ាវក្នុងព្រះពុទ្ធសាសនា ។ ព្រះតេជគុណឯកឧត្តម អស់លោក ជ្រាបហើយថា ព្រះសម្មាសម្ពុទ្ធនៃយើង ព្រះអង្គទ្រង់ធុតង្គក្តី សំណាក់ធម៌ក្តី ពិសេសកាលព្រះអង្គប្រសូត្រ ត្រាស់ដឹង

www.budinst.gov.kh www.elibraryofcambodia.org

និងបរិនិញ្វានសុទ្ធតែស្ថិតនៅក្រោមដើមឈើ ហើយមានសាវ័ករបស់ព្រះអង្គសួរទៅព្រះអង្គថា តើអ្វីខ្លះដែលផ្តល់ឱ្យមានកុសលកម្មដល់យើងគ្រប់គ្នា ? ព្រះអង្គក៏មានពុទ្ធដីកាថា គឺមានតែការថែរក្សាព្រៃឈើដែលនៅជុំវិញលំនៅទេជាអំពើកុសល ។ ទាក់ទងទៅនឹងបញ្ហានេះហើយទើបអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍បង្កើតជាកម្មវិធីនេះឡើង ។

អង្គការព.ផ.អ.បានរៀបចំជារុក្ខវប្បដ្ឋានគំរូមួយ នៅក្នុងបរិវេណស្នាក់ការព.ផ.អ.ដែលមានបណ្តោយ១២ម៉ែត្រទទឹង៩ម៉ែត្រនិងកំពស់២,៥០ម៉ែត្រ និងមានប្រក់ផ្លាស្ទីកសំរាប់ការពារកំដៅហើយនៅមានរៀបចំជា ថ្នាលបណ្តុះជាច្រើនទៀតនៅតាមវត្តនានាក្នុងខេត្តបាត់ដំបង និង ខេត្តបន្ទាយមានជ័យ។ ចំពោះកូនឈើដែលបណ្តុះបានយើងតែងតែបានចែកចាយទៅដល់ក្រុមគោលដៅនិងបានយកទៅដាំតាមទីសាធារណៈតាមសាលារៀនតាមគ្រួសារនិងតាមវត្តអារាមនានា ។ កូនឈើដែលយើងបណ្តុះបានមានពីរប្រភេទរុក្ខជាតិហូបផ្លែនិងរុក្ខជាតិសំណង់ ។ ក្នុងមួយឆ្នាំៗយើងបណ្តុះបានពី១៥០០០ដើមទៅ ២០០០០ដើម។ កម្មវិធីនេះយើងបានផ្សព្វផ្សាយដល់អ្នកស្រុកឱ្យចេះស្រឡាញ់និងចង់ដាំដើមឈើ យកចិត្តទុកដាក់ក្នុងការថែទាំហើយយើងក៏បានបញ្ចូលកម្មវិធីនេះទៅក្នុងកម្មវិធីសិក្ខាសាលាទៀតផងដើម្បីឱ្យសិក្ខាកាមយល់ដឹងនិងយកទៅអនុវត្តនៅតាមកន្លែងរបស់គេ ។

## *អំពីការធ្វើជីកុំប៉ុស្ត :*

ការធ្វើជីកំប៉ុស្តវាជាការងាយស្រួល ដោយយើងគ្រាន់តែធ្វើទ្រុងហើយប្រមូលសំរាមមកដាក់ឱ្យពេញ ។ នៅចំកណ្តាលទ្រុងយើងត្រូវដោតឈើមួយដើម្បីឱ្យមានខ្យល់ចេញ-ចូល ហើយយើងឧស្សាហ៍ស្រោចទឹកដើម្បីរក្សាជាតិ

www.budinst.gov.kh www.elibraryofcambodia.org

សើមប៉ុន្តែមិនត្រូវឱ្យមានទឹកជោគជាំទេ ។ យើងត្រូវរកស្លឹកចេកមកគ្របលើ ទ្រុងដើម្បីមានអុកស៊ីហ្សែន និង ជាតិកាបោន ជាតិអាហ្សូតទៅជួយរំលាយ សំរាម។ ម្យ៉ាងទៀតព.ផ.អ.បានបង្កើតជាក្រោងជីកំប៉ុស្តតាមគ្រួសារដោយជីក ជារណ្តៅទៅតាមលទ្ធភាពរបស់គេហើយឱ្យគាត់ប្រមូលលាមកសត្វនិងបោស សំរាមដែលនៅជុំវិញផ្ទះមកដាក់ៗការផលិតនេះ គឺ ជាលក្ខណៈនៃការសន្សំ សំចៃជីសំរាប់ធ្វើស្រែ ។ ក្នុងមួយឆ្នាំៗការផលិតជីកំប៉ុស្តតាមគ្រួសារមានចំនួន ជាង២តោន ។

ចំពោះការប្រើប្រាស់ជី :ជីដែលផលិតបាននេះយើងបានយកវាទៅប្រើប្រាស់ លើដំណាំកសិកម្មសំរាប់គ្រួសារ ដែលបានផលិតហើយលទ្ធផលដែលយើង ទទួលបានពីការប្រើជីកំប៉ុស្តគឺបានជាទីគាប់ចិត្ត២តោនទៅ៣តោនក្នុងមួយហិកតា ។ បើនៅការិយាល័យ យើងយកវាទៅធ្វើការ បណ្តុះកូនឈើ ។

*ផ្នែកធារាសាស្ត្រ* : យើងបានស្តារអូរមួយខ្សែដែលមានប្រវែង១៥គីឡូម៉ែត្រ នៅក្នុងឆ្នាំ១៩៩៥ដោយកំលាំងអ្នកស្រុកចូលរួមស្តារនិងសហការណ៍ជាមួយ អង្គការស្បៀងអាហារពិភពលោកនិងមានការចូលរួមពីអ្នកបច្ចេកទេសកសិ-កម្មខេត្តហើយយើងក៏បានសង់ជាសំណង់ស្នាក់ទឹកផងដែរសំរាប់បែងចែកទឹក ឱ្យអ្នកស្រុកប្រើប្រាស់ ។

## មតិចូលរួមរបស់សិក្ខាកាម

- ព្រះតេជគុណ កែវ ហេង ក្រុងកំពុងសោម

របៀបបណ្តុះកូនគគីរគឺមុនដំបូងត្រូវយកគ្រាប់គគីរដែលទើបនិងជ្រុះថ្មីៗ គ្រាប់គគីរដែលជ្រុះមួយអាទិត្យហើយមិនអាចយកទៅបណ្តុះដុះទេ ត្រូវយក

www.budinst.gov.kh www.elibraryofcambodia.org

គ្រាប់ដែលទើបនិងជ្រុះទៅដាក់ក្នុងរណ្តៅហើយរោយដីពីលើជាស្រទាប់ៗរួច ស្រោចទឹក ។ រយៈពេលមួយអាទិត្យចាប់ផ្តើមរីរណ្តៅកូនគគីរហើយជ្រើស រើសយកគ្រាប់ណាដែលវាដុះល្អ ។ យើងត្រូវថែរក្សាកូនគគីរនេះក្នុងរយៈ ពេល១ ឬ២ឆ្នាំទើបអាចយកវាទៅដាំបានដោយដាំចម្ងាយពីមួយដើមទៅមួយ ដើមប្រហែល៤ឬ៥ម៉ែត្រ ។ លទ្ធផលកន្លងមកអាត្មាបណ្តុះបានចំនួន៥០០០ ដើមហើយបានចែកទៅតាមវត្តនានានិងតាមអង្គភាពនានាទៀតផងដែរ ។

**- លោកអាចារ្យ ប្រាក់ ជាវ ចន្ទ្រសាលគរ ខេត្តកំពង់ធំ**

សូមបញ្ជាក់ពីការដាំដើមឈើនេះ គឺ មានមកតាំងពីសម័យពុទ្ធកាលមក ម្ល៉េះ ។ ខ្ញុំព្រះករុណាសូមលើកយកព្រះសូត្រមួយកន្លែងដែលមានទេវតាមួយ អង្គចូលទៅគាល់សួរព្រះសម្មាសម្ពុទ្ធថា " បពិត្រព្រះអង្គដ៏ចំរើនបុគ្គលម្នាក់ៗ ត្រូវធ្វើកុសលអ្វីដើម្បីឱ្យបានបុណ្យទាំងយប់ទាំងថ្ងៃ? "ព្រះអង្គទ្រង់បញ្ជាក់ថា "*អារាមរោបា វនរោបា* ។ល។ម្នាលទេវតាបុគ្គលណាមួយដែលចង់បានបុណ្យទាំង យប់ទាំងថ្ងៃបុគ្គលនោះត្រូវដាំដើមឈើធ្វើជាសួនជាម្លប់ ។ល។ និងជីកស្រះ ជីកអណ្តូងសង់សាលាជាដើម" ។បញ្ហានេះបញ្ជាក់ថាមានតាំងពីសម័យព្រះពុទ្ធ មកម្ល៉េះ ។

www.budinst.gov.kh www.elibraryofcambodia.org

# បទពិសោធន៍ក្នុងការអប់រំ សីលធម៌-ចរិយាធម៌

ដោយ លោក ញឹម គិរក្ស នាយកសកម្មអង្គការ ព.ដ.អ

ហេតុអ្វីបានជាអង្គការនេះដាក់ឈ្មោះថាជា អង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ ( ព.ដ.អ.) ? ដោយក្រុមយើងមានព្រះសង្ឃ ព្រមទាំងគ្រហស្ថដែលមានគំនិតផ្តួចផ្តើមគោលទៅលើទស្សនៈមួយ ដែលក្រោយសង្គ្រាមជាងពីរទស្សវត្សរ៍បានបន្សល់ទុកនៅសោកនាដកម្មផ្សេងៗដូចជាពិការភាព, វិបត្តិផ្លូវចិត្ត, ទីទ័លក្រ, ស្ត្រីមេម៉ាយ, ពោះម៉ាយ, ខ្វះដីធ្លី, ខ្វះថវិកា ។ល។ បង្កើនតែការចងគំនុំអាឃាតព្យាបាទ ច្រណែន ឈ្នានីស ឆបោក លួចឆក់កាប់សម្លាប់ រំលងយល់គ្នាឯងគ្នាគេ ដោយសារតែការបាត់បង់សីលធម៌នេះដូចលោកបណ្ឌិតមានប្រសាសន៍រួចហើយ។ អាស្រ័យហេតុដូចសោកនាដកម្មខាងលើនេះនិងដោយមនសិការៈនៃអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ក៏បានចាប់ផ្តើមបង្កើតផ្នែកមួយក្នុងចំណោមផ្នែកទាំង៣នេះឡើងគឺមត្តេយ្យសិក្សាបុត្រ, អភិវឌ្ឍន៍សហគមន៍ជាពិសេសផ្នែកដែលត្រូវនិយាយក្នុងឱកាសនេះគឺផ្នែកអប់រំព្រះសង្ឃ ។ ព្រះករុណាជាម្ចាស់ អស់លោក លោកស្រី ហេតុអ្វីបានជាទិសដៅយើងបាញ់ទៅរកយុវជនហើយនិងពុទ្ធបរិស័ទ? តែយើងដាក់ឈ្មោះថាជាផ្នែកអប់រំព្រះសង្ឃទៅវិញ? ត្រង់នេះខ្ញុំព្រះករុណាសូមប្រគេននិងជូនថានេះជាដើមចមនៃបញ្ហា ហើយវានឹងវិលវល់មិនចេះចប់នៅក្នុងវដ្តសង្សារដែលទុកជាវដ្តចក្រសំរាប់បង្កបង្កើតឱ្យរអិះរាលដាល រហូតដល់បណ្តាលឱ្យកើតទៅជាអំពើហិង្សាស្ទើរតែគ្រប់តំបន់តាំងពីសង្គមធំរហូតដល់សង្គមគ្រួសារមួយៗ ការធ្លាក់ចុះនៃសីលធម៌នេះគឺរកសន្តិសុខមិនឃើញទេហេតុនេះបានជា *ព.ដ.អ.*យើងមានសេចក្តីព្រួយបារម្ភហើយយល់ឃើញថា មានតែព្រះសង្ឃទេ

www.budinst.gov.kh www.elibraryofcambodia.org

ដែលអាចទៅជាបង្គោលដ៏ចំណានបាន ក្នុងការអប់រំស្តារឡើងវិញនូវអ្វីដែលធ្លាក់ចុះនិងអ្វីដែលជាកត្តានាំឱ្យកើតជាអំពើហឹង្សាគ្រប់ច្រកល្ហកបាន ។ ព្រះករុណាអស់លោកបានដឹងហើយថាកាលពីសង្គមមុនៗកិច្ចការងារសង្គមរបស់ខ្មែរគឺពឹងផ្អែកទៅលើព្រះសង្ឃស្ទើរតែទាំងស្រុង ។ ហេតុអ្វីបានជាអញ្ចឹង ? ព្រោះថា ព្រះសង្ឃជាគ្រូបង្រៀនអក្សរសាស្ត្រនិងសិល្បសាស្ត្រគ្រប់យ៉ាងដល់បរិស័ទហើយព្រះសង្ឃជាក៏ជាអ្នកថែរក្សាក្បួនខ្នាតទៀតផង ។ ដូចសម័យបាំងអក្សរសាស្ត្រស្ថិតនៅក្នុងវត្ត សម័យ៣ឆ្នាំ៨ខែ២០ថ្ងៃគេយកព្រះត្រៃបិដកទៅហែកជក់ ។ ដូច្នេះព្រះសង្ឃមានតួនាទីសំខាន់ណាស់ក្នុងការស្តារឡើងវិញនូវសីលធម៌ និង ថែរក្សានូវអ្វីៗដូចជាព្រះសង្ឃគឺជាគ្រូពេទ្យខាងជម្ងឺផ្លូវកាយក្តី ផ្លូវចិត្តក្តី ព្រះសង្ឃជាទីពឹងរបស់មនុស្សចាស់ជរា,ព្រះសង្ឃក៏ជាអ្នករំលាយនូវវណ្ណៈព្រះសង្ឃជានិមិត្តរូបនៃសន្តិភាព ។ល។ ហេតុនេះបានជាយើងសំរេចយកព្រះសង្ឃជាបង្គោលក្នុងការអប់រំសីលធម៌ដល់ពុទ្ធបរិស័ទ ។ ថ្វីត្បិតតែសព្វថ្ងៃនេះព្រះសង្ឃបានផុសឡើងចាប់ពី១៩៧៩មក ស្ទើរតែស្មើនឹងពីដើមក៏ដោយក៏នៅពុំទាន់មានសមត្ថភាពគ្រប់អង្គបានទេអង្គខ្លះមាន អង្គខ្លះក៏អត់ព្រោះតែព្រះអង្គខ្លះអត់បានសិក្សាឱ្យបានជ្រៅជ្រះកាលនៅជាគ្រហស្ថ។ កត្តា៣យ៉ាងដែលអាចឱ្យកម្មវិធីនេះមានដំណើរការបានល្អប្រសើរទៅបានគឺ÷

១. ទំនាក់ទំនងដ៏ល្អ ជាមួយរដ្ឋអំណាចមូលដ្ឋាន

២. ស្ថាប័នសិក្សា

៣. ស្ថាប័នពុទ្ធសាសនា

យើងត្រូវចូលទៅធ្វើទំនាក់ទំនងដោយទន់ភ្លន់ហើយពន្យល់ណែនាំឱ្យគេបានយល់ច្បាស់ដើម្បីឱ្យគេមានឆន្ទៈ ឱ្យគេពេញចិត្ត ឱ្យគេស្តាប់បានឱ្យគេជួយយើងយ៉ាងសកម្មក្នុងការបង្កបង្កើតការអប់រំសីលធម៌ និង ចរិយាធម៌ដល់ពុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

បរិស័ទ។ បុគ្គលិកសិក្សាអ្នកមានឧត្តមគតិខ្ពស់ជាគ្រូអាសាស្ម័គ្របាននិយាយថាគេចង់ជួយ ជាងចង់បានហេតុនេះហើយបានជាគ្រូទាំងនេះពុំសូវទាមទារកំរៃដ៏ខ្លាំងលើសលប់នោះទេហើយគ្រូទាំងនេះយើងជ្រើសរើសចេញពីលោកគ្រូអ្នកគ្រូនិងនិស្សិតខ្លះដែលគេអាចមានសមត្ថភាពបង្រៀនបាន ។ ឯការអប់រំសីលធម៌វិញគឺបានមកពីការបរិច្ចាគដ៏សប្បុរសរបស់ព្រះតេជគុណដែលជាម្ចាស់វត្តនិងបណ្ឌិតដែលបានលាចាកសិក្ខាបទ ។ អាគារសិក្សាយើងពឹងផ្អែកទៅលើអាគារសិក្សារបស់ក្រសួងអប់រំជាតិទាំងស្រុងដែលស្ថិតនៅទីនោះតែម្តង ។ ប៉ុន្តែយើងត្រូវមានទំនាក់ទំនងជាមួយ លោកគ្រូ-អ្នកគ្រូ និង លោកនាយកសាលាដើម្បីឱ្យគេជួយចូលរួមជាមួយយើង ។

ដើម្បីឱ្យកម្មវិធីបណ្តុះបណ្តាលរបស់យើងមានប្រសិទ្ធិភាព និងមានគុណប្រយោជន៍ចំពោះសង្គមជាតិ យើងមាន ៧ចំណុចសំខាន់ៗ គឺ ÷

១- ជាបង្អែកសំរាប់ទាក់ទាញទឹកចិត្តរបស់យុវជន យុវតីហើយសមស្របទៅតាមកាលៈទេសៈបច្ចុប្បន្នដែលគេកំពុងនិយមគឺភាសាបរទេស ។

២- សីលធម៌តាមបែបព្រះពុទ្ធសាសនា

៣- សិទ្ធិមនុស្ស និងទំនៀមទំលាប់ប្រពៃណីជាតិ

៤- លទ្ធិប្រជាធិបតេយ្យ តាមបែបពុទ្ធសាសនា

៥- ទស្សនកិច្ចសិក្សា

៦- វិធីបំបួស (រយៈពេល ១ខែ) ក្នុងពេលវិស្សមកាល

៧- ការសន្សំប្រាក់

សកម្មភាពអប់រំដែលអាចចាប់ផ្តើមទៅបានអាស្រ័យទៅលើការងារទាំងឡាយដែលបានរៀបចំរួចហើយដូចជា ÷

- ការសុំដាក់ពាក្យចូលរៀនរបស់យុវជន-យុវតី

www.budinst.gov.kh www.elibraryofcambodia.org

- ប្រវត្តិរូប និង កិច្ចសន្យា

ភាសាបរទេសដែលយើងបានបញ្ចូល ក្នុងគោលបំណងទាក់ទាញទឹកចិត្តរបស់យុវជន-យុវតី មាន ÷

- ភាសាអង់គ្លេស ៣៤២ថ្នាក់
- ភាសាបារាំង ៣៥ថ្នាក់
- ភាសាថៃ ២០ថ្នាក់

ក្នុងថ្នាក់នីមួយៗមានសិស្ស២០នាក់ហើយការអប់រំសីលធម៌នេះមាន ÷

១- ឱ្យកូនខ្មែរចេះសំពះ
  - ក្រាបសំពះព្រះសង្ឃ ដល់ថ្ងាស
  - សំពះឪពុក-ម្តាយ ដល់ច្រមុះ
  - សំពះញាតិវង្សា ដល់បបូរមាត់

២- ឱ្យកូនខ្មែរចេះដេក-ដើរ-ឈរ-អង្គុយ

៣- សង្គហធម៌ - ការគោរពច្បាប់-គោរពសិទ្ធិ - កាត់បន្ថយ អំពើហិង្សា

៤- សូត្រធម៌នមស្សការ -ពុទ្ធប្បវត្តិ

៥- អប់រំវិបស្សនាកម្មដ្ឋាន-ប្រពៃណី (រាល់ថ្ងៃសីល)

៦- សិទ្ធិមនុស្សមានព្រំដែនតាមបែបព្រះពុទ្ធសាសនាមានសីល៥ជាមូលដ្ឋាន និងកម្មបថ ១០ = កុសលកម្មបថ ១០

៧- លិទ្ធិប្រជាធិបតេយ្យ បែបព្រះពុទ្ធសាសនា

លទ្ធិប្រជាធិបតេយ្យមានក្នុងព្រះពុទ្ធសាសនា២៥៤១ឆ្នាំមកហើយ!

www.budinst.gov.kh www.elibraryofcambodia.org

## សន្ទស្សន៍នៃអំពើបុណ្យហេតុនៃ ការអប់រំ រៀនសូត្រ សីលធម៌

ដោយ ព្រះមហាចិមលធម្ម ពិន សែម ខេត្តសៀមរាប

ខ្ញុំព្រះករុណាតែងតែឮពាក្យរបស់ខ្មែរក្រហមពោលរាល់ពេលប្រជុំថា : *អ្វីដែលជាសិទ្ធិមនុស្ស អ្វីដែលជាមនុស្សធម៌ គេត្រូវតែកំទេចចោលឱ្យអស់* នេះជាពាក្យដែលខ្ញុំព្រះករុណាបានទទួលអំពីលទ្ធិខ្មែរក្រហម ។ សំដីទាំងពីរឃ្លានេះធ្វើឱ្យខ្ញុំព្រះករុណាតក់ស្លុត ញាប់ញ័រភ័យខ្លាចយ៉ាងខ្លាំងហើយភាសាខ្មែរក្រហមអាចញ៉ាំងឱ្យប្រទេសខ្មែរវិនាសរកទីប្រមាណពុំបាន។បើគិតពីនោះមកដល់ឆ្នាំ ១៩៧៩ ដែលយើងបានរួចខ្លួនចេញពីខ្មែរក្រហមកពេលនោះព្រះករុណាគ្រប់ព្រះអង្គបានជ្រាបហើយមុនដំបូងវាប្រសេចប្រសាចមិនថា ឯណាឯណីទេ ឥតមេ ឥតកោយ វាច្របូកច្របល់ កោលាហលពេញទាំងសង្គមឃើញតែភាពឥតមានសីលធម៌ដូចលោក ញឹម កិរក្សបានលើកឡើងហើយ ។ ខ្ញុំព្រះករុណាបានត្រិះរិះក្នុងចិត្តនូវពាក្យខ្មែរក្រហមពោលខាងលើពីព្រោះបានឃើញច្បាស់ដូចភាសិតរបស់បុរាណយើងពោលថា *ជនសាងជាតិ ជាតិសាងសាសនា សាសនារលំ ជាតិរលាយ* ។ ពេលសង្គមខ្មែរអស់សាសនារលីងអស់លោកឃើញហើយខ្ទេចខ្ទីអស់វត្តអារាមនិងព្រះសង្ឃ។ បើអស់សាសនាហើយជាតិមុខតែរលាយព្រោះសីលធម៌របស់សង្គមយើងបានទទួលយកពីព្រះពុទ្ធសាសនារាប់រយរាប់ពាន់ឆ្នាំមកហើយដោយសារតែព្រះសង្ឃដ៏កំពូលៗនៅក្នុងសង្គមខ្មែរពីបុរាណ ។ លោកញឹម កិរក្សូ ក៏បានលើកហើយដែរថាព្រះសង្ឃមានតួនាទីជាអ្វី វត្តជាមហាវិទ្យាល័យសំរាប់កូនខ្មែរ តាំងពីសម័យមហានគរមក ។ មានឯកសារមួយសរសេរដោយលោក ជីវតាខ្វាន់ គាត់បានមកឃើញ ព្រះសង្ឃខ្មែរ ស្លៀកដណ្តប់ចីវរចេញស្មាម្ខាងហើយនៅក្នុង

www.budinst.gov.kh www.elibraryofcambodia.org

វត្តមិនមានរោងបាយទេ ពួកព្រះសង្ឃទាំងអស់ដើរសុំអាហារពីអ្នកស្រុកមកចិញ្ចឹមជីវិត ហើយលោកមិនឆាន់សាច់ មិនផឹកស្រាទេ ។ ពេលព្រះរាជាមានកិច្ចការអ្វីមួយតែងតែនិមន្តព្រះសង្ឃមកជំនុំ ពិគ្រោះសុំមតិយោបល់ពីព្រះសង្ឃ។ម្យ៉ាងទៀតក្នុងច្បាប់លោកបានចែងថាបើចង់ឱ្យសង្គមមានសន្តិភាពល្អិតណាតែបុគ្គលហ្នឹងមានសន្តិភាពជាមុនសិន ហើយបុគ្គលដែលអាចមាន សន្តិភាពបាននោះល្អិតណាដែលបុគ្គលនោះមានសីលធម៌ ។ គឺវាមានហេតុមានបច្ច័យអញ្ចឹងតាមពុទ្ធសាសនាបុគ្គលណាមិនមានសីលធម៌
បុគ្គលនោះមិនមានសន្តិភាពទេ ។

អាស្រ័យហេតុនេះ ទើបខ្ញុំព្រះករុណាអាត្មាក៏ផ្តួចផ្តើមជ្រើសរើសក្នុងកិច្ចការដែលនឹងជួយដល់សង្គម ។ សង្គមពុទ្ធសាសនាគឺជួយជាតិនេះឯងព្រោះព្រះសង្ឃជួយជាតិទាំងអស់ ទោះបីព្រះសង្ឃខំបង្ហាត់បង្រៀនអ្វីសព្វបែបយ៉ាងក៏មិនទទួលផលកំរៃអ្វីធំដុំទេគឺចូលរួមជួយជាវិភាគទានដល់រាជរដ្ឋាភិបាលគឺខំអស់ពីសមត្ថភាពដើម្បីជួយជាតិធ្វើឱ្យមនុស្សមានសីលធម៌ ទើបខ្ញុំព្រះករុណាអាត្មាចាប់បង្កើតគ្រោងការនេះតាំងពីឆ្នាំ១៩៩៣ តែធ្វើទៅដូចជាមិនសូវបានជឿនលឿនទេ ព្រោះធ្វើតាមកំលាំងបាយបាត្រតែក៏មិនលះបង់ការព្យាយាមនេះទេចេះតែធ្វើបន្តជាបណ្តើរៗ ។ រហូតមកដល់បច្ចុប្បន្នបានកសាងសាលាបាលីដើម្បីឱ្យព្រះសង្ឃបានទទួលការសិក្សារៀនសូត្រ ព្រោះព្រះសង្ឃយើងលោកនៅក្មេងៗដែរមិនទាន់ចេះដឹងហើយព្រះសង្ឃចាស់ៗក៏នៅតិចតួចដែលចេះដឹងដូច្នេះត្រូវពឹងលើគ្រហស្ថដែលធ្លាប់បានបួសបានសិក្សារៀនសូត្រពីសង្គមចាស់មកជួយផងព្រោះកត្តាអប់រំវាសំខាន់ជាងគេបង្អស់តាមបែបពុទ្ធសាសនា។ព្រះពុទ្ធបរមគ្រូព្រះអង្គឱ្យពុទ្ធបរិស័ទកំចាត់នូវកិលេសគឺ លោភៈទោសៈ មោហៈចេញព្រោះវាជាមូលហេតុដែលប្រាកដដល់វែ្នក ហៅថាកិលេសគ្រោតគ្រាត

www.budinst.gov.kh www.elibraryofcambodia.org

យើងត្រូវកំចាត់វាចេញ ។ យើងដឹងហើយថាការកំចាត់លោភៈនេះគឺដោយប្រើធម៌សន្តោសសេចក្តីដែលវាចង់បានហួសប្រមាណហួសព្រំដែនយើងបង្កើតធម៌សន្តោសឡើងយើងត្រូវគ្រេកអរតាមសទ្ធារទើបទប់នឹងសេចក្តីលោភហួសប្រមាណបាន។ *ទោសៈ* ចិត្តគិតប្រទូស្តរាយទៅនឹងជនដទៃដែលបានប៉ះពាល់មកលើខ្លួនដោយវាចាខ្លះក្តី គឺយើងត្រូវបង្កើតមេត្តាធម៌ឱ្យមាននៅក្នុងខ្លួនទើបយើងអាចទប់បាន ។ *មោហៈ* ជារបស់អវិជ្ជាបានន័យថាវង្វេងកាលដែលមិនដឹង មិនយល់ មិនស្គាល់ ។ ដូច្នេះយើងអាចទប់ទល់និងអវិជ្ជាបានល្គឹកណាតែយើងមានការសិក្សារៀនសូត្របើមិនបានរៀនសូត្រក៏មិនអាចកំចាត់នូវអវិជ្ជានេះបានទេ ។ ខ្ញុំព្រះករុណាអាត្មាខិតខំប្រឹងប្រែងក្នុងកម្មវិធីសិក្សានេះដោយមិនទាន់បាក់នធ្វើអ្វីទេទោះ កុដិក្តី វិហារក្តី សាលាក្តី ក៏អត់ធ្វើដែរ ហេតុនេះហើយទើបនៅវត្តរាជបូណ៌របស់ខ្ញុំព្រះករុណាមិនទាន់មានកុដិមានទីសេនាសនៈទេហើយកំផែងវត្តក៏នៅលន្ទង់លន្ទោចដែរ។

កម្មវិធីអប់រំដែលអាត្មាបានរៀបចំមាន ÷

១- សំរាប់ព្រះសង្ឃ :

- ភាសាបាលី, ចំណេះទូទៅខាងផ្លូវលោក
- ភាសាបរទេសមាន ភាសាអង់គ្លេស, ថៃ

២- សំរាប់គ្រហស្ថ :

- សិក្សាភាសាអង់គ្លេស, ថៃ
- សិក្សាពីសីលធម៌ពុទ្ធសាសនា, ធម៌នមស្ការ, សីល ៥, កងធម៌, មង្គលសូត្រ, សមថ, សមាធិ, ពុទ្ធប្បវត្តិប្រវត្តិសាស្ត្រ ។

៣- សំរាប់អប់រំកុមារា-កុមារី នៅបឋមសិក្សា :

- ចរិយាធម៌

www.budinst.gov.kh www.elibraryofcambodia.org

- នមស្ការ
- ការទំនាក់ទំនងរវាងព្រះសង្ឃ និង កុមារ

៤- បង្រៀនខាងសិប្បកម្ម :

- គូររូបលើក្រណាត់ និងលើក្រដាស់
- ឆ្លាក់ចម្លាក់លើឈើ, លើថ្ម និងស្ពាន់

៥- ការដាំកូនឈើ :

- បណ្តុះកូនឈើជូនអ្នកស្រុកដាំ
- គ្រូបង្រៀនភាសាបាលី គឺពឹងលើអ្នកស្រុកជួយចេញជាបច្ច័យមិនមានរាជការជួយទេ ។

## ពុទ្ធសាសនិក និង ការបោះឆ្នោត

ដោយ **បណ្ឌិត ឡៅ ម៉ុងហៃ ស្តីអំពី**

ខ្ញុំព្រះករុណាយល់ថា ប្រធានបទនេះទាក់ទងទៅនឹងប្រធានបទ ពីព្រឹកមិញអំពីសីលធម៌ ដែលយើងបានជជែកគ្នានោះដែរ ។ ប្រទេសកម្ពុជា ជាប្រទេសមានអធិបតេយ្យភាព មានឯករាជ្យភាព ប៉ុន្តែប្រទេសនេះមានជាប់ជំពាក់នឹងកិច្ចព្រមព្រៀងអន្តរជាតិមួយដែលបានកំណត់នូវប្រព័ន្ធគ្រប់គ្រង និង ភារៈកិច្ចគោរព សិទ្ធិមនុស្ស ដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ។ កិច្ចព្រមព្រៀងនោះគឺកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងឆ្នាំ ១៩៩១ មកហើយក្នុងបាឋកថានេះ ខ្ញុំព្រះករុណានិងរៀបរាប់បន្តិចអំពីច្បាប់ដែលចែងអំពីការបោះឆ្នោតពាក់ព័ន្ធនិងការបោះឆ្នោត ។ ចំណុចទី ២ គឺដំណើរការ និង ដំណាក់ការទាំងឡាយនៃការបោះឆ្នោត ភារៈកិច្ចរបស់ពុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

សាសនិកហើយ និងផលប្រយោជន៍សារៈសំខាន់នៃព្រះធម៌និងព្រះពុទ្ធសាសនាក្នុងការជួយដំណើរការបោះឆ្នោត ។ ជាពិសេសដើម្បីឱ្យប្រព្រឹត្តទៅប្រកបដោយអហិង្សានិងសន្តិភាព។ ចំណុចចុងក្រោយបើសិនជាមានពេលនឹងពណ៌នាបន្តិចអំពីមេដឹកនាំហើយចែកមេដឹកនាំជា ២ ក្រុមគឺ ÷

១- មេដឹកនាំអសីលធម៌

២- មេដឹកនាំសីលធម៌

ចំណុចមួយនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសបានចែងយ៉ាងច្បាស់ហើយកិច្ចព្រមព្រៀងនេះមានប្រទេស១៨និងអង្គការសហប្រជាជាតិរួមជាមួយនិងខ្មែរចូលរួមចុះហត្ថលេខាព្រមព្រៀងទាំងអស់គ្នា ហើយកិច្ចព្រមព្រៀងអន្តរជាតិក៏ដូចជាកិច្ចសន្យារវាងបុគ្គលទាំងឡាយនៅក្នុងប្រទេសដែរគឺតែកាលណាចុះហត្ថលេខា ហើយជាការសន្យាជាមួយគេ យើងត្រូវតែគោរពកិច្ចសន្យារបស់យើងបើមិនគោរពទេបើនិយាយតាមបែបព្រះពុទ្ធសាសនាគឺបាបហើយគឺមុសាវាទ ។ គេចែងថារដ្ឋធម្មនុញ្ញប្រទេសកម្ពុជាត្រូវប្រកាសថាប្រទេសកម្ពុជានិងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យដោយសេរីឈរលើមូលដ្ឋានពហុបក្ស។ រដ្ឋធម្មនុញ្ញ ត្រូវកំណត់ឱ្យមានការបោះឆ្នោតដ៏ ត្រឹមត្រូវ និង តាមកាលវេលា ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតសិទ្ធិសំរាប់បោះឆ្នោត និង ឈរឈ្មោះបោះឆ្នោត ។ តាមរបៀបបោះឆ្នោតដោយសកលនិងស្មើភាព ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតឱ្យមានការបោះឆ្នោតដោយសម្ងាត់ ដោយតំរូវឱ្យមានទំរង់នៃការបោះឆ្នោតត្រូវផ្តល់ឱកាសគ្រប់គ្រាន់និងសមរម្យដើម្បីរៀបចំ និងចូលរួមក្នុងដំណើរការបោះឆ្នោត។ នេះជាភារកិច្ចរបស់ខ្មែរហើយយើងត្រូវតែចងក្រងក្នុងរដ្ឋធម្មនុញ្ញ ។ ដូច្នេះនៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ក៏យើងបានអនុវត្តប្រព័ន្ធនយោបាយប្រជាធិបតេយ្យសេរីពហុបក្សធានាសិទ្ធិមនុស្ស គោរពច្បាប់ទទួលខុសត្រូវខ្ពស់

www.budinst.gov.kh www.elibraryofcambodia.org

ចំពោះ វាសនាអនាគតជាតិ នេះមានចែងនៅក្នុងបុព្វកថារដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ។ ហើយភាសាច្បាប់ពាក្យមួយម៉ាត់ៗគេមិនដាក់គ្រាន់តែឱ្យណែងណាងដូចជាកាព្យឃ្លោងនោះទេ ។ មានន័យអ្វីទៅហៅថាប្រជាធិបតេយ្យ ? អ្វីទៅហៅថាសេរី ? អ្វីទៅហៅថាពហុបក្ស ? អ្វីទៅហៅថាសិទ្ធិមនុស្ស ? អ្វីទៅហៅថាការគោរពច្បាប់ ? អ្វីទៅហៅថាការទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ? រដ្ឋធម្មនុញ្ញក៏បានចែងដែរថាប្រជាពលរដ្ឋខ្មែរជាម្ចាស់នៃប្រទេសជាតិរបស់ខ្លួនអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈ រដ្ឋសភា រដ្ឋាភិបាល និង សាលាជំរះក្តី នេះមានចែងក្នុងរដ្ឋធម្មនុញ្ញហើយរដ្ឋធម្មនុញ្ញក៏បានចែងទៀតថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋហើយមានសារៈសំខាន់ណាស់ ។ ហេតុម៉េចបានជាដាក់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ? ក្រែងលោព្រះធម៌នៃព្រះពុទ្ធសាសនាអាចជួយទ្រទ្រង់ ពង្រឹង លទ្ធិប្រជាធិបតេយ្យនោះបានហើយយើងគ្រប់គ្រងឱ្យរដ្ឋនោះទៅជារដ្ឋមានសេរីភាព មានសន្តិភាពសេចក្តីចំរើនរុងរឿងសំរាប់យើងទាំងអស់គ្នា ។ ក្រោយពេលដែលយើងបានជួបប្រទះនូវសោកនាដកម្មដ៏មហិមានៅក្នុងប្រវត្តិសាស្ត្រថ្មីរបស់យើងនេះ ដូច្នេះក៏ដូចជាបុគ្គលម្នាក់ៗដែរប្រទេសកម្ពុជាត្រូវពឹងផ្អែកលើខ្លួនឯងគឺ *អត្តាហិ អត្តនោ នាថោ* ខ្លួនទីពឹងខ្លួនក្នុងការសម្រេចវាសនារបស់ខ្លួន។ នេះមានន័យទូលំទូលាយណាស់ដែលពុទ្ធសាសនាបានប្រដៅយើងមក។ បុគ្គលម្នាក់ៗទទួលខុសត្រូវចំពោះខ្លួនឯងទៅលើវាសនាខ្លួនឯង។ រីឯប្រទេសក៏អញ្ចឹងដែរគឺត្រូវតែទទួលខុសត្រូវលើវាសនារបស់ខ្លួនមិនចាំបាច់ឱ្យបរទេសគេមកត្រួតត្រា ដឹកច្រមុះទេ ហើយប្រជាពលរដ្ឋខ្មែរត្រូវប្រើប្រាស់អំណាចខ្លួនដើម្បីកាត់តែងវាសនារបស់ខ្លួន ។ ប៉ុន្តែប្រជាពលរដ្ឋទាំងអស់គ្នាមិនចាំបាចទៅចូលរួមក្នុង កិច្ចប្រជុំធំ ណាមួយ

www.budinst.gov.kh www.elibraryofcambodia.org

ដើម្បីធ្វើសេចក្តីសម្រេចនានាក្នុងការគ្រប់គ្រងរដ្ឋនោះទេ គឺចាំបាច់ត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យទៅធ្វើ សេចក្តីសំរេច ទាំងឡាយដើម្បីគ្រប់គ្រងរដ្ឋ ហើយនិងអនុវត្តសេចក្តីសំរេចទាំងឡាយនោះ ។ ដូច្នេះក្នុងចំណោមពលរដ្ឋ ១១លាននាក់យើងត្រូវជ្រើសរើសតែ១២០នាក់ទេជាតំណាងរបស់យើងចូលក្នុងសភាហើយអ្នកទាំងនោះគឺរៀបចំតែងតាំងគណៈរដ្ឋមន្ត្រី និងរចនាសម្ព័ន្ធរដ្ឋបាលផ្សេងៗទៀតដើម្បីធ្វើមេដឹកនាំប្រទេស ។ តាមពិតយើងជ្រើសរើសតំណាងយើងផងហើយអ្នកដឹកនាំយើងផង ពេលជាមួយគ្នានេះរដ្ឋធម្មនុញ្ញក៏បានកំណត់គោលធំៗក្នុងការចូលរួម ជ្រើសរើសតំណាងរបស់ ប្រជាពលរដ្ឋដែរការកំណត់នេះមានជាអាទិដូចតទៅ :

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត។ប្រជាពលរដ្ឋទាំងពីរភេទដែលមានអាយុយ៉ាងតិច២៥ឆ្នាំអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រគឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោតហើយមានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើតមក។តំណាងរាស្ត្រត្រូវជ្រើសរើសដោយការបោះឆ្នោតជាសកលដោយសេរីដោយស្មើភាព ដោយចំពោះតាមវិធីជ្រើសរើសឆ្នោតជាសំងាត់ ។ នីតិកាលរបស់រដ្ឋសភាកំណត់៥ឆ្នាំហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។ ក្នុងករណីព្រះមហាក្សត្ររំលាយរដ្ឋសភាមុនផុតអាណត្តិ ការបោះឆ្នោតជ្រើសរើសរដ្ឋសភានឹងប្រព្រឹត្តទៅក្នុងរយៈពេលហុកសិបថ្ងៃយ៉ាងយូរចាប់ពីថ្ងៃរំលាយរដ្ឋសភាមក។ អ្នករៀបចំការបោះឆ្នោតនិងការប្រព្រឹត្តទៅនៃការបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់នោះ ។

តំណាងរាស្ត្រក្នុងរដ្ឋសភាជា តំណាងប្រជាជនជាតិខ្មែរទាំងមូលពុំមែនគ្រាន់ជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនទេ ។ អាណត្តិអាថ្វាបញ្ញា

www.budinst.gov.kh www.elibraryofcambodia.org

ទាំងឡាយត្រូវទុកជាមោឃៈទាំងអស់ ។ នេះមានន័យទូលំទូលាយហើយត្រូវការអ្នកចេះដឹងច្រើនក្នុងការពិចារណាច្រើន ដើម្បីយល់ន័យឱ្យបានច្បាស់លាស់ ហើយតំណាងរាស្ត្រនេះគេមិនអាចដកចេញពីមុខតំណែងក្នុងរដ្ឋសភាបានទេបើសិនណាជាគ្មានច្បាប់ចែងហើយច្បាប់នោះទាល់តែចែងពីឧក្រិដ្ឋកម្មការប្រព្រឹត្តអំពើខ្លាំងក្លាធ្ងន់ធ្ងរនោះទើបគេអាចបណ្តេញចេញបាន ។ នេះជាច្បាប់តែកាលណាយើងដេញដោយ បំពារបំពាន អាចមានផលវិបាកហើយទំនាស់ក្នុងការរៀបចំការបោះឆ្នោតតើអ្នកណាជាអ្នកកាត់សេចក្តី? រដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ថា ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញមានសិទ្ធិពិនិត្យ និង សម្រេចពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនេះគឺច្បាប់អញ្ចឹងតុលាការអត់មានសិទ្ធិអំណាចអ្វីទេ គឺទៅជាក្រុមប្រឹក្សាធម្មនុញ្ញទេដែលមានភារៈកិច្ចបកស្រាយច្បាប់ និង ពិនិត្យមើលធម្មនុញ្ញភាពរបស់ច្បាប់ដែលសភាអនុមតិទាំងឡាយ។ ក្រៅពីច្បាប់ទំលាប់នេះគេត្រូវធ្វើច្បាប់ចែងអំពីបែបបទនានាទៀត ។ ឥឡូវនេះកំពុងតែធ្វើឱ្យមានច្បាប់សញ្ជាតិធ្វើឱ្យដឹងថាតើនរណាជាខ្មែរហើយដែលត្រូវមានសិទ្ធិបោះឆ្នោត។ ច្បាប់គណៈបក្សក៏បានធ្វើហើយក៏បានអនុមតិហើយដែរតែឥឡូវនេះសភាកំពុងតែពិនិត្យពិភាក្សាពីច្បាប់បោះឆ្នោត ។ ការបោះឆ្នោតគេអាចប្រព្រឹត្តទៅតាមប្រព័ន្ធផ្សេងៗ ។ ទំនោរសព្វថ្ងៃហាក់ដូចជាមានការអនុមតិមូលមាត់គ្នាទៅរក ប្រព័ន្ធសមាមាត្រ គឺគេយកខេត្តជាមណ្ឌល ។ ក្នុងខេត្តនីមួយៗអាចមានតំណាងរាស្ត្រច្រើនដូចជានៅស្វាយរៀង ប៉ុន្តែខេត្តតូចៗដែលមានមនុស្សតិច និង តាមក្រុងដែលមានមនុស្សតិចដូចជា ក្រុងព្រះសីហនុ ខេត្តមណ្ឌលគិរី ខេត្តរតនគិរីមានតំណាងរាស្ត្រតែម្នាក់ទេ។ មានប្រព័ន្ធពីរគឺ១ប្រព័ន្ធសមាមាត្រៈចំនួនកៅអីដែលគណៈបក្សនិមួយៗអាចមានជាប់ឆ្នោតនោះ វាអាស្រ័យនឹងចំនួនសន្លឹកឆ្នោតដែល

www.budinst.gov.kh www.elibraryofcambodia.org

គណៈបក្សនោះបានទទួល។ ដូចជារដ្ឋសភាសព្វថ្ងៃមាន១២០កៅអីបើសិនជាបានសន្លឹកឆ្នោត៥០ភាគរយបានចំនួន៦០កៅអី។ នេះនិយាយនៅក្នុងប្រទេសទាំងមូល បើនិយាយក្នុងខេត្តតំណាងរាស្ត្រខេត្តស្វាយរៀងចំនួន៥រូបហើយបើសិនជាគណបក្សណាមួយបានទទួលសន្លឹកឆ្នោត៦០ភាគរយត្រូវបាន៣កៅអីហើយ២០ភាគរយត្រូវបានកៅអី១។ទី២ប្រព័ន្ធឯកត្តនាមឬប្រព័ន្ធភាគច្រើនដោយគេចែកមណ្ឌលទៅតាមចំនួនមណ្ឌលនៅក្នុងប្រទេសគឺមួយមណ្ឌល ស្មើនឹងតំណាងរាស្ត្រម្នាក់ក្នុងរដ្ឋសភា ដូចជាមាន១២០ត្រូវចែកប្រទេសខ្មែរជា១២០មណ្ឌលហើយមានបេក្ខជនទៅចូលប្រឡូកក្នុងមណ្ឌលនោះ។

បេក្ខជនណាដែលបានឆ្នោតច្រើនជាងគេ នឹង ត្រូវបានជាប់ជាតំណាងរាស្ត្រ។ តើដំណើរការនិងដំណាក់កាលនៃការបោះឆ្នោតមានអ្វីខ្លះ? គេត្រូវការចុះឈ្មោះអ្នកបោះឆ្នោត ចុះឈ្មោះគណបក្សនិងបេក្ខជនឈរឈ្មោះរៀបចំយុទ្ធនាការឃោសនាសំរាប់គណៈបក្សនិងបេក្ខជនដោយផ្សព្វផ្សាយទស្សនៈនយោបាយរៀងៗខ្លួនដើម្បីសុំសន្លឹកឆ្នោតពីពលរដ្ឋ។ ក្រោយពេលយុទ្ធនាការបោះឆ្នោត គេឈប់សំរាក២-៣ថ្ងៃ ដើម្បីឱ្យបរិយាកាសធូរស្រាលឡើងវិញហើយក៏មានការបោះឆ្នោតជ្រើសរើសគណៈបក្ស ឬ បេក្ខជន ។

អ៊ុនតាក់រៀបចំពេល ៦ថ្ងៃនៅស្រុកខ្មែរគេធ្វើតែមួយថ្ងៃទេ ។ មុនៗនេះស្រុកខ្មែរគេធ្វើតែមួយថ្ងៃក្រោយពីការបោះឆ្នោតហើយនៅថ្ងៃបោះឆ្នោតចប់គេរាប់សន្លឹកឆ្នោត. គេប្រកាសលទ្ធផលជាក្រោយមកទៀតហើយតំណាងរាស្ត្រដែលជាប់ឆ្នោតចូលទៅកាន់មុខតំណែងរបស់ខ្លួន។ ការចូលកាន់មុខតំណែងនេះរដ្ឋសភាថ្មីក៏ចាប់ផ្ដើមអាណត្តិរបស់ខ្លួនដែរ ។ ទន្ទឹមនឹងដំណាក់កាលនេះអាជ្ញាធរមានសមត្ថកិច្ចក៏រៀបចំចាត់តាំងឱ្យមាន គណៈកម្មការរៀបចំការបោះឆ្នោតតាមលំដាប់ជាតិ លំដាប់ខេត្តលំដាប់ការិយាល័យហើយក៏មានការរៀបចំ

www.budinst.gov.kh www.elibraryofcambodia.org

បច្ចេកទេសទាំងឡាយដូចជាសន្លឹកឆ្នោតប្រអប់ឆ្នោតបញ្ជូនទៅកន្លែងណា និង ធ្វើការអប់រំហ្វឹកហ្វឺនបុគ្គលិករៀបចំការបោះឆ្នោតនោះទៀត។ ពាក្យខ្មែរយើង តែងពោលថា " *ចាននៅក្នុងការ តែងតែប៉ះទង្គិចគ្នា* " ម្ល៉ោះហើយការ ឃោសនាការប្រណាំងប្រជែងគ្នាតែងតែមានវិវាទទំនាស់ជាមិនខាន។ ដូច្នេះ គេត្រូវមានយន្តការសំរាប់ដោះស្រាយវិវាទទាំងនោះ ដែលអាចពាក់ព័ន្ធទៅ នឹងការបោះឆ្នោត ។ ក្នុងដំណើរការបោះឆ្នោតគេអាចរំពឹងទុកថាមានការ សំដែងនៅ តណ្ហា មានៈ និង ទិដ្ឋិ ហើយព្រះពុទ្ធបរមគ្រូរបស់យើងបាន សំដែងយ៉ាងច្បាស់រួចមកហើយដែរ ។ តណ្ហា មានៈ និង ទិដ្ឋិ នេះការសំ ដែងនេះជួនកាលដឹងជួនកាលមិនដឹងខ្លួនទេចេះតែខំប្រឹងប្រែងទៅគឺថាលោភ លំនិង លោភៈ ទោសៈ មោហៈជាដើម ។ អកុសលហេតុនេះរឹតតែខ្លាំងទៀត បើសិនជាគេយកអំណាច ឬ ចង់បានអំណាចដើម្បីស្វែងរកទ្រព្យសម្បត្តិ និង ដើម្បីការពារទ្រព្យសម្បត្តិរបស់គេ ។ ពេលនោះអាចនិងមានអំពើហិង្សាយង់ ឃ្នង់កាប់សម្លាប់គ្នានិងការពោលពាក្យអសុរសផ្សេងៗជាមិនខានឡើយ។ ក្នុង ប្រវត្តិសាស្ត្រយើងនៅឆ្នាំ១៩៩៣គឺមានការកាប់សម្លាប់ ការវាយតប់គ្នាគួរឱ្យ សោកស្តាយ ។ អំពើហិង្សាការគំរាមកំហែងរវាងគូប្រជែងនានាគឺតែងតែ មានតិចឬច្រើនទៅតាមកាលៈទេសៈតាមប្រទេសទៀតផង។ សូមកត់សំគាល់ ថាខ្មែរបានរៀបចំការបោះឆ្នោតជាញឹកញាប់មកហើយគឺតាំងពីឆ្នាំ១៩៤៦ ជា ហូរហែរមកដល់ឆ្នាំ១៩៩៣ លើកលែងតែឆ្នាំ១៩៩៣ដែលមានការវាយតប់ គ្នាច្រើនកាប់សម្លាប់គ្នាច្រើនដែលបាញ់សំលាប់គ្នាព្យាបាទគ្នា ។ ពីមុនៗមកគឺ ថាទី១ បើសិនជាមានការប្រណាំងប្រជែងគ្នាក្នុងការបោះឆ្នោតប្រជាពលរដ្ឋ ទៅបោះឆ្នោតច្រើន៦០ឬ ៥០ឬ ៦៥ភាគរយនេះបើប្រៀបធៀបប្រទេសជឿន លឿនទាំងឡាយគឺយើងចេះប្រើសិទ្ធិរបស់យើងបានច្រើនមិនចាញ់គេទេ។

www.budinst.gov.kh www.elibraryofcambodia.org

ពីដើមខ្ញុំព្រះករុណាបានសិក្សាដូចជាមិនដែលឃើញមានបេក្ខជនតំណាងរាស្ត្រណាមួយស្លាប់ ដោយគេបាញ់ប្រហារនៅពេលឃោសនាបោះឆ្នោតនោះទេគឺយើងទៅបោះឆ្នោតជាទូទៅដោយសន្តិវិធី។ខ្ញុំព្រះករុណាផ្ទាល់ចង់ឃើញសន្តិវិធីនេះប្រើប្រាស់ជាបន្តទៅទៀតហើយសង្ឃឹមថាព្រះធម៌ពុទ្ធសាសនាអាចជួយច្រើនយ៉ាងណាស់ក្នុងការទប់នឹង តណ្ហា មានៈ ទិដ្ឋិ ទោសៈ លោភៈ និងមោហៈនៅពេលឃោសនាបោះឆ្នោតនេះ។ បើទាំងបេក្ខជនទាំងអ្នកគាំទ្របេក្ខជនសុទ្ធតែជាពុទ្ធសាសនិកគួរភ្ជាប់ទៅជាមួយនូវព្រះធម៌ជានិច្ចក្នុងការធ្វើសកម្មភាពការឃោសនាដើម្បីទាក់ទាញយកសន្លឹកឆ្នោតរៀងខ្លួន ។ ច្បាប់ជួយដល់ការបោះឆ្នោតឱ្យប្រព្រឹត្តទៅដោយអហិង្សា និងដោយសន្តិវិធីនេះជាមោទនៈភាពរបស់ជាតិយើងទាំងមូលព្រោះខ្ញុំព្រះករុណាតែងតែឮបរទេសគេសួថាខ្មែរកាន់ព្រះពុទ្ធសាសនាហេតុអ្វីក៏ ប៉ុល ពត សម្លាប់មនុស្សច្រើនម្ល៉េះ? ខ្ញុំព្រះករុណាឆ្លើយថា ប៉ុល ពត បំផ្លាញព្រះពុទ្ធសាសនាចោលបានជាសម្លាប់គ្មានរង្គាលរបៀបនេះតែបើសិនជា ប៉ុល ពត គោរពព្រះពុទ្ធសាសនាគេពិតជាមិនអាចសម្លាប់របៀបនេះទេ។

ព្រះអាចជួយអ្នកបោះឆ្នោតឱ្យជ្រើសរើសអ្នកដឹកនាំខ្លួនបានច្រើនណាស់ហើយបើផ្តេកផ្តួលទៅលើព្រះពុទ្ធសាសនា ព្រះធម៌ប្រហែលជាគួរជ្រើសរើសមេដឹកនាំដែលប្រកបដោយសីលធម៌ព្រោះមេដឹកនាំមានពីរប្រភេទ មួយសីលធម៌ និងមួយអសីលធម៌ ហើយយើងរងគ្រោះដោយសារតែមេដឹកនាំដែលអសីលធម៌នេះដែរ (ប៉ុល ពត) ។ ប៉ុន្តែនៅមានមេដឹកនាំសាហាវយង់ឃ្នង់ដែលធ្វើទុកបុកម្នេញសំលាប់ប្រជាជនឯងដោយចោទប្រកាន់ថាប្រឆាំងនឹងប្រយោជន៍ជាតិ ក្បត់ជាតិ ប្រឆាំងនឹងនយោបាយខ្លួន ប្រឆាំងនឹងខ្លួននេះក៏មានរបៀបដូច ប៉ុល ពត ដែរ ។ អ្នកដឹកនាំដែលយកចិត្តទុកដាក់នឹងសុខមាល

www.budinst.gov.kh www.elibraryofcambodia.org

ភាពរបស់អ្នកដើរតាមខ្លួនតែជំរុញអ្នកនោះឱ្យធ្វើបាបអ្នកដទៃក៏មាន។ មេដឹកនាំអាចស្លូតអាចកាចសាហាវតែអាចលើកយកអស្មិមានះជឿស្លុងមានការស្ញប់ក្នុងការចងកំហឹងសងសឹកការភ័យខ្លាច ឬ ក៏មានជំនឿអកុសលរបស់មនុស្សទូទៅបំផុសបំផុលឱ្យប្រជាពលរដ្ឋជឿតាមខ្លួន ស្តាប់តាមបញ្ជារបស់ខ្លួនហើយទៅធ្វើបាបគេឯង។ មានមេដឹកនាំខ្លះទុកប្រជាពលរដ្ឋរបស់ខ្លួនដូចជាកូនក្មេងឱ្យនៅតែពឹងផ្អែកលើខ្លួនជានិច្ចគឺក្នុងប្រវត្តិសាស្ត្រមាន មិនឱ្យគ្នារីកធំធាត់ទៅជាមនុស្សដឹងក្តីអាចប្រកបអាជីវកម្ម ហើយរស់នៅដោយឯករាជ្យខ្លួនឯងបានទេ។ មានមេដឹកនាំខ្លះទៀតបំបាត់សេរីភាពនិងភាពយុត្តិធម៌សេចក្តីថ្លៃថ្នូរបស់មនុស្ស។ មេដឹកនាំខ្លះដើម្បីអំណាចដើម្បីនយោបាយរបស់ខ្លួនហ៊ានឃោសនាបំភ័ន្តធ្វើឱ្យប្រជាពលរដ្ឋឡប់ឡិន វង្វេងវង្វាន់ដូចកំណាព្យអ្នកប្រាជ្ញយើងបានសរសេរទុកថា " *ឈ្លីគមនុស្សឥឡូវ យកខុសជាត្រូវ យកឆ្កួតធ្វើជាអំពើអាក្រក់ ឡិឡប់លីលា ព្រហើនពានពារ អាងមាស អាងប្រាក់ អាងកើល អាងប្រាជ្ញ អាងកោង អាងកាច អាងកាប់អាងចាក់ អាងជើង អាងដៃ អាងវាយ. អាងធាក់ អាងគុកច្រវាក់ អាងម៉ាស៊ីនកាត់ក* " ។ មេដឹកនាំទី២គឺ *មេដឹកនាំមានសីលធម៌* មេដឹកនាំនេះគោរពមនុស្សទាំងឡាយដែលគេដឹកនាំទុកមនុស្សជាមនុស្សមិនមែនទុកដូចជាសត្វទេហើយជាមេដឹកនាំដែលប្រកបដោយភាពថ្លៃថ្នូរ មិនចាត់ទុកមនុស្សជាឧបករណ៍ឱ្យខ្លួនប្រើប្រាស់តាមតែអំពើចិត្តនោះទេ។ មេដឹកនាំរបៀបនេះយល់ផលប្រយោជន៍រាស្ត្រជាធំយកចិត្តទុកដាក់ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់រាស្ត្រហើយតែងតែមានទំនាក់ទំនងជាមួយរាស្ត្រមិនបង្ខិតបង្ខំកៀបសង្កត់រាស្ត្រតែព្យាយាមពន្យល់ឱ្យគេជឿនិងធ្វើតាមខ្លួន ។ មេដឹកនាំក្នុងប្រភេទនេះតែងទុកខ្លួនគេជាអ្នកបំរើប្រជាពលរដ្ឋគឺជួយថែរក្សាសុខមាលភាពរបស់ប្រជាពលរដ្ឋដូចពាក្យមួយឃ្លា

www.budinst.gov.kh www.elibraryofcambodia.org

ដែលពណ៌នាអំពីព្រះទ័យព្រះបាទជ័យវរ្ម័នទី៧ថា " *ទ្រង់មានព្រះទ័យព្រួយបារម្ភរោគរបស់ប្រជាពលរដ្ឋព្រះអង្គ ជាងព្រះអាពាធព្រះអង្គទៅទៀត* " ព្រោះសេចក្តីទុក្ខរបស់រាស្ត្រគឺជាសេចក្តីទុករបស់អ្នកគ្រប់គ្រងទាំងឡាយ។មេដឹកនាំមានសីលធម៌គេយកពាក្យស្លោកនេះទៅស្លជាសកម្មភាពជាក់ស្តែងដើម្បីជួយប្រជាពលរដ្ឋ ហើយគេមិនដែលបន្ទោសរាស្ត្រទេទោះបីរាស្ត្រមានគុណវិបត្តិឥតសីលធម៌ក៏ដោយ គឺគិតតែពីបន្ទោសខ្លួនឯងទៅវិញដែលមិនបានអប់រំរាស្ត្ររបស់ខ្លួនឱ្យបានល្អ។មានមេដឹកនាំមួយប្រភេទទៀតគឺទសពិតរាជធម៌និងព្រហ្មវិហារធម៌ ។ ត្រង់នេះកុលបុត្រខ្មែរទាំងឡាយនិងពុទ្ធសាសនិកក៏គួរតែពិចារណាដើម្បីសំរេចធ្វើការជ្រើសរើសមេដឹកនាំរបស់ខ្លួន ។

ទសពិតរាជធម៌គឺមាន ÷

១. ទាន: = ការធ្វើជាអំណោយ

២. សីល: = រក្សាសីល

៣. បរិច្ចាគ:= ការលះបង់

៤. អជ្ជវ: = ភាពស្មោះត្រង់

៥. មទ្ទវ: = ភាពទន់ភ្លន់

៦. តប: = ការកំចាត់អំពើអាក្រក់

៧. អក្កោធ: = ភាពមិនក្រេវក្រោធ

៨. ខន្តី = ការអត់ឱន, ការសណ្ដោស, ការអំណត់

៩. អហឹង្សា = ការមិនបៀតបៀន

១០.អវិរោធន:= ការមិនធ្វើខុស

ព្រហ្មវិហារធម៌ មាន ៤ គឺ ÷

១. មេត្តា = មានចិត្តអាណិតស្រឡាញ់

www.budinst.gov.kh www.elibraryofcambodia.org

២. ករុណា = មានករុណាជួយសង្គ្រោះ គេឱ្យរួចទុក្ខ

៣. មុទិតា = ត្រេកអរ ពេលគេបានសុខ

៤. ឧបេក្ខា = ដាក់ចិត្តជាកណ្តាល

ទាំងនេះជាគោលៗនៃមេដឹកនាំដូចនេះពុទ្ធសាសនិកគួរកុំជ្រើសរើសយកមេដឹកនាំដែលគ្មានសីលធម៌ ត្រូវជ្រើសរើសយកមេដឹកនាំ ដែលមានសីលធម៌ ព្រោះសីលធម៌នេះផ្តេកផ្តួលទៅលើសីលធម៌របស់ព្រះពុទ្ធ ដែលបានត្រាស់ដឹងហើយបានទូន្មានប្រៀនប្រដៅពុទ្ធសាសនិកអស់ជាង២៥៤១ឆ្នាំមកហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

## ព្រះរាជសារព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ផ្ញើជូនក្នុងឱកាសបិទសិក្ខាសាលាជាតិលើកទី៤

**អានដោយ លោក រស់ ចាន់សន មន្ត្រីជំនួយការនៃមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ**

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរពឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការ-សាសនា
- សូមគោរពឯឧត្តម ស្រី មណ្ឌល អភិបាលរងទី ១ ខេត្ត
- សូមគោរពលោក ឡៅ មុំងហៃ ឯត្តម លោក លោកស្រី ជាទីគោរព

បន្តិចទៀតនេះខ្ញុំព្រះករុណាខ្ញុំបាទនិងចាប់ផ្តើមអាននូវព្រះរាជសារដ៏ថ្លៃថ្លារបស់ព្រះករុណាជាអម្ចាស់ ដែលព្រះអង្គសព្វព្រះរាជហឫទ័យផ្ញើមកជូនចូលរួមចំណែកនៅក្នុងសិក្ខាសាលាជាតិយើងលើកនេះ ។ នេះគឺជាព្រះរាជសារទី ២ របស់ព្រះអង្គហើយ ។ ព្រះរាជសារទី ១ សំរាប់សិក្ខាសាលាជាតិយើងដែលព្រះតេជគុណ ញ៉ែម គឹមតេង នាយកអង្គការសន្តិសេនាបានអានប្រគេននិងជំរាបជូននៅពេលដែលបើកសិក្ខាសាលា។ពេលនេះទៀតសំរាប់ពេលបិទសិក្ខាសាលា យើងក៏មានកិត្តិយសដែល ព្រះករុណាព្រះអង្គសព្វព្រះរាជហឫទ័យផ្ញើព្រះរាជសារមួយច្បាប់ទៀតសំរាប់សិក្ខាសាលាយើងនេះ ។ ជាបន្ទាប់ទៅនេះខ្ញុំព្រះករុណាខ្ញុំបាទសុំអនុញ្ញាតអាននូវព្រះរាជសារនេះដែលមានសេចក្តីដើមទាំងស្រុងដូចតទៅ ( បកប្រែក្រៅផ្លូវការព្រោះព្រះករុណាព្រះអង្គបានផ្ញើជាភាសាបារាំង ) ។

ព្រះរាជសារក្រៅផ្លូវការនៃព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាជូនចំពោះលោកភីធ័រស្មៀរ នៃ មូលនិធិខុន

www.budinst.gov.kh www.elibraryofcambodia.org

វ៉ាំងអាដិនណោអ៊ែរព្រមទាំងអស់លោកអ្នករៀបចំចាត់ចែងសិក្ខាសាលាជាតិលើកទី៤ ស្តីអំពី *ព្រះពុទ្ធសាសនា និងការអភិវឌ្ឍន៍ សង្គមខ្មែរ* ។ ជាង ២៥សតវត្សរ៍បានកន្លងផុតមកហើយ តាំងតែព្រះពុទ្ធជាអម្ចាស់នៃយើងបានបន្សល់ទុកនូវការអប់រំសិក្សា គតិបណ្ឌិតដ៏ឧត្តុង្គឧត្តម បំផុតរបស់ព្រះអង្គនូវសំរាំងព្រះធម៌ជាសារវ័ន ដែលពិភពលោកទទួលស្គាល់នោះគឺលទ្ធិប្រៀនប្រដៅនេះហើយដែលធ្វើឱ្យជាពិសេសខ្មែរជឿស៊ុបនៅក្នុងកាលសម័យដ៏មានឫក្សល្អនៃប្រវត្តិសាស្ត្រដ៏ច្របូកច្របល់របស់គេ ហើយថ្មីៗកន្លងមកនេះនៅសម័យសង្គមរាស្ត្រនិយមជាកាលសម័យដែលគេបានទទួលគុណប្រយោជន៍និងយុគមួយមានសន្តិភាព មានយុត្តិធម៌សង្គម ហើយដែលជាតិមានការស្រុះស្រួលគ្នាដ៏ល្អដែលដឹកនាំដោយឧត្តមគតិអត់ឱនត្រាប្រណីគ្នា ដោយសេចក្តីអាណិតអាសូរដោយអហិង្សាធម៌ដោយយុត្តិធម៌សង្គម និង ជួយគ្នាទៅវិញទៅមកយ៉ាងសកម្ម ។ បច្ចុប្បន្ននេះការគោរពនូវសិទ្ធិមនុស្សសិទ្ធិបុរសសិទ្ធិស្ត្រីសិទ្ធិកុមារជាមូលដ្ឋានមួយ នៃ កាតព្វកិច្ចដោយបង្ខំសំរាប់ប្រជារាស្ត្រគ្រប់ៗរូបនៅលើភពផែនដីយើងនេះ ។ ទោះជាសិទ្ធិទាំងនេះគេមិនបានដឹងដោយវិញ្ញាណថាជាករណីយកិច្ចក៏ដោយតែសិទ្ធិអាចប្រាប់អាចយល់បានដោយខ្មែរគ្រប់ៗរូប តាមរយៈលទ្ធិពុទ្ធសាសនា ដែលព្រះធម៌មិនឈប់មិនឈរបានប្រកាសឱ្យប្រើលទ្ធិទាំងនោះតាំងតែពីយូរអង្វែងហើយដែរ ។

ខ្ញុំព្រះករុណាខ្ញុំ សូមអរគុណជាអនេកដល់លោក ភីធ័រ ស្មៀរ ដល់មូលនិធិ-ខុនរ៉ាដ-អាដិនណោអ៊ែរ ដែលបង្ហាញឱ្យឃើញជាតំណាងដ៏ថ្លៃថ្នូរដ៏មានប្រសិទ្ធិភាពនៅព្រះរាជាណាចក្រកម្ពុជា ដែលបានយល់ហើយផ្តួចផ្តើមគំនិតយោបល់ទៅតាមសំណូមពរប្រញាប់ បន្ទាន់នៃជនរួមជាតិយើងមួយចំនួនដែលចេះដឹងមានបទពិសោធន៍ច្រើនជាងគេ ហើយប្រាថ្នាសមរម្យទៀងត្រង់

www.budinst.gov.kh www.elibraryofcambodia.org

ដែលបប្អូលគ្នាប្រជុំទាំងព្រះសង្ឃ ដូនជី លោកអាចារ្យ ព្រមទាំងគ្រហស្ថ ជាច្រើនដែលកំពុងទទួលខុសត្រូវជាពិសេសនៅក្នុងសង្គមយើង ដែលបាននាំមកមិនត្រឹមតែផ្សព្វផ្សាយគោលសីលធម៌ ដែលជាវិញ្ញាបនព្រះធម៌គឺទាំងធ្វើឱ្យរស់ឡើងវិញនូវគោលធម៌ទាំងនោះ ព្រមទាំងធ្វើឱ្យមានផ្លែផ្កាឆ្លងកាត់រាល់អំពើទាំងឡាយនៃជីវិតរួមបញ្ចូលទាំង អន្តរាគមន៍ ជាច្រើនដែលសំរាប់តែតស៊ូប្រឆាំងនឹងភាពក្រីក្រដ៏លំបាកដ៏ធំធេង។ ការប្រតិបត្តិលើកកំពស់សុខាភិបាល និងការអប់រំជាមូលដ្ឋាននិងការគោរពសមតាបរិស្ថានការរក្សាគាំពារបរិស្ថានធម្មជាតិ។

ខ្ញុំព្រះករុណាខ្ញុំ មានសោមនស្សរីករាយប្រគេនគារវកក្តីជាពិសេសព្រះតេជគុណ ក្រៀម គីមតេង ដែលមានសកម្មភាពគួរឱ្យគោតសរសើរលើស្នាព្រះហស្តនៃការដាំដើមឈើឡើងវិញដល់ អង្គការក្រៅរដ្ឋាភិបាលទាំងឡាយ សន្តិសេនា និង ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ដែលតាំងតែពី ឆ្នាំ១៩៩៤ជារៀងរហូតមកបានចូលរួមយ៉ាងសកម្មនៅក្នុងការចាត់ចែង សិក្ខាសាលា ទាំងនេះ ។

ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងនូវកតវេទិតាគុណដ៏ជ្រាលជ្រៅថ្វាយ ព្រះសង្ឃ ជូនដូនជី លោកអាចារ្យ គ្រហស្ថ អស់លោក ព្រមទាំង បងប្អូនជនរួមជាតិគ្រប់ៗរូប ។ ប្រជារាស្ត្រតូចតាចប្រកបទៅដោយកុសលបុណ្យឈ្នះអស់ហឹង្សានិងការប្រមាទដែលគេបានប្រឈមមុខជារៀងរាល់ថ្ងៃជាក្រុមឈានមុខនៃជីវិតរស់នៅក្នុងសង្គម ។ ជួនកាលធ្វើការដោយអនាមិកលាក់ឈ្មោះប៉ុន្តែពោរពេញទៅដោយគុណូបការៈគឺជាការងាររបស់បងប្អូន កសិករ កម្មករ និយោជិកមន្ត្រីរាជការគ្រូបង្រៀន និង អស់លោកបំរើការងារសង្គមកិច្ចទាំងឡាយដែលស្ថាបនាសហគមន៍ជាតិយើង ហើយឧបត្ថម្ភធានាការដែលរស់នៅ

www.budinst.gov.kh www.elibraryofcambodia.org

បន្តទៅមុខឱ្យប្រកបដោយសុខមាលភាពគ្រប់ៗរូប។ ទាំងអស់នេះហើយដែលសមរម្យបំផុតធ្វើឱ្យយើង ពិនិត្យ ពិចារណាជានិច្ចនូវការងារដ៏ធំអនេកដែលផ្តល់ប្រយោជន៍ជូនសង្គមទាំងមូល ធ្វើឱ្យមានជីវិតរស់នៅឡើងវិញ នៅក្នុងសហគមន៍មូលដ្ឋាននៅតាមទំហំសំខាន់នៃមនុស្សតាមឃុំតាមស្រុក ក្នុងស្មារតីជួយគ្នាទៅវិញទៅមក និងសហប្រតិបត្តិការឈរលើវិន័យ សីលធម៌ ដោយគ្មានច្បាប់ព្រៃគឺបានសាងសង់រួចមកហើយនូវស្ថាប័នកម្មសង្គម ដែលទាក់ទងគ្នាជាហូរហែរដើកដែលការស្វែងរកយុត្តិធម៌និងសមធម៌ផណ្តើមយកឈ្នះលើគន្ធៈនៃអានុភាពនិងអំណាចសង្កត់សង្កិន ។

សព្វថ្ងៃនេះហឹង្សាស្ថិតនៅគ្រប់កន្លែងរហូតដល់បេះដូងនៃគ្រួសារខ្មែរ។ ការអាងរបស់គេក្លាយទៅជាមធ្យោបាយបុព្វសិទ្ធដើម្បីដោះស្រាយរាល់ជម្លោះនោះ ។ គឺម្នាក់ៗអាងលើអាវុធ ប៉ុន្តែអាវុធគ្រាន់តែជាឧបករណ៍បំរើគោលបំណងទាំងឡាយដែលមិនថ្លៃថ្នូរ។ ការពិតហឹង្សាជ្រួតជ្រាបយ៉ាងជ្រៅនៅក្នុងវិញ្ញាណទៅហើយ។

ភាពក្រីក្រវេទនាដ៏ធំធេង ពិតជាបង្កបង្កើតជាចលករសំខាន់អាងតែប្រើហឹង្សា។ ម្នាក់ៗតស៊ូដើម្បីបន្តរស់នៅ ។ នៅក្នុងសង្គមមានតែភាពមិនស្មើគ្នាជាច្រើនខាងផលទុន និងភាពសំបូរភោគទ្រព្យវាជាជម្ងឺកាន់តែធ្ងន់ធ្ងរឡើងៗហើយ ។ ប៉ុន្តែទុរគតភាពដែលមាននៅក្នុងរង្វង់ប្រជារាស្ត្រក្រីក្រ តូចតាចយើងមិនបានបញ្ជាក់បង្ហាញទាំងអស់ទេ ។ ជំរៅនៃបញ្ហាស្ថិតនៅក្នុងការខ្វះការវិនិច្ឆ័យផ្តល់ឱ្យដល់ ដំណើរការរស់នៅ ឱ្យដល់ការប្រមើល មើលទៅអនាគត។ ជាសរុបដើម្បីឆ្ពោះទៅរកពិភពលោកមួយដ៏ប្រសើរឡើងហើយជាពិសេសឱ្យដល់ការដៅចំណាំអភិសម្មាចារទាំងឡាយ ។ ដូច្នេះសេរីនិយមហួសហេតុនិងសម្ភារនិយមហួសហេតុ ឆ្លាស់ចុះឆ្លាស់ឡើងជូនកាលច្រឡំ

www.budinst.gov.kh www.elibraryofcambodia.org

បល់គ្នាលើអ្វីស្តីពីជំរៅនៃសង្គ្រាមនិងបួន់ ចចេស មានៈ ផ្តាច់ឫសគល់គំរែសីលធម៌ជាប្រពៃណីយើងឱ្យអស់ ។ ជាពិសេសខាងព្រះពុទ្ធសាសនាគេបានផ្លាស់ប្តូរអ្វីៗទាំងនោះដោយភ្ជួររាក់នឹងកំទេចសត្រូវ នៃមនោគមវិជ្ជាថ្មីដោយបញ្ចូញឱ្យមើលឃើញនូវការប្រមាថមើលងាយទាំងស្រុងទៅលើអ្នកដែលមិនមានគំនិតដូចខ្លួនក្នុងពេលនោះឬដោយនាំចូលនូវកាសែតល្បែង ឬវីឌីអូរឿងដែលជំរុញទឹកចិត្តឱ្យឃើញតែពិភពមួយពោរពេញដោយហិង្សា ។ ពំនឹងវីឌីអូកាសែតធំធេងណាស់ យើងរកបានងាយៗនៅតាមទីផ្សារ ជាវត្ថុប៉ះទង្គិចយ៉ាងឃោរឃៅដល់យុវជនយើងជាពិសេសដែលកំពុងរក ឬស្រឡាញ់តួឯកវីរៈជនដ៏ក្លាហានរបស់គេដោយគ្មានចលនាថយចុះដែលចាំបាច់ឱ្យយកមកគិតដល់រឿងពិត ឬ រឿងប្រឌិតឡើយៗគេផ្តិតគំរូទាំងនោះអ្វីដែលគេបានសំរេចវាយតំលៃពិតដូចជាមាយាទប្រព្រឹត្តប្រចាំថ្ងៃរបស់គេៗ

ចំពោះអ្នកដែលជឿជាក់ ឬ សង្ឃឹមលើអនាគតដ៏ល្អសំរាប់ប្រទេសយើងដែលកំពុងកើតទុក្ខទោសអ្នកទាំងនោះពេលនោះមានករណីយកិច្ចចូលរួមនៅក្នុងយុទ្ធនាការនៃការស្តាបនាឡើងវិញនៅក្នុងគតិចរិកនៃការអត់ឱនឱ្យគ្នានិងសេចក្តីអាស្សូរនៃព្រះពុទ្ធសាសនា ។ ជាពិសេសបុរស-ស្ត្រីទាំងឡាយដែលមានឥទ្ធិពលអ្នកដែលគេរាប់ទុកថាជាអ្នកមានតំលៃជាប់នឹងខ្លួនព្រោះមាយាទប្រព្រឹត្តជាវិជ្ជមាន ឬ អវិជ្ជមានរបស់អ្នកដឹកនាំយើងមានឥទ្ធិពលលើសង្គមយើងទាំងស្រុងគឺទៅរកស្ថាប័នកម្មសង្គមបែបនេះ ដែលអស់លោកនាំយកថ្មរបស់អស់លោកមកសាងសង់ ហើយខ្ញុំព្រះករុណាខ្ញុំ សូមសំដែងនូវកតញ្ញូតាដឹងគុណជាអនេកៗ អនាគតនឹងស្តីបន្ទោសបើឱ្យកំលាំងទ័ពច្បាំងប្រឈមមុខគ្នាប្រើហិង្សាឃោរឃៅដែលមានចម្បាំងឆាបឆេះមកហើយបង្ហូរឈាមគ្នាលើមាតុភូមិដ៏សែនវេទនារបស់យើងអស់រយៈកាលជាង ២៥ឆ្នាំ មកហើយនោះ

www.budinst.gov.kh www.elibraryofcambodia.org

បែរជាឈ្នះមានប្រៀបលើស្មារតីអហិង្សា ស្មារតីជួយគ្នាទៅវិញទៅមក និង ស្មារតីសហប្រតិបត្តិការគ្នាទៅវិញទៅមក។ ការជ្រើសរើសនេះវាស្ថិតនៅលើ ជាអចិន្ត្រៃយ៍នៅក្នុងថ្ងៃណាមួយរវាងយើងទាំងអស់គ្នា ។ វាត្រូវតែទទួល រាប់ដោយមនសិការនិងដោយអភិញ្ញាណស្គាល់ដឹងរាល់មូលហេតុ។ការរើស យកបែបព្រះសង្ឃ ដូនជី អាចារ្យ គ្រហស្ថ បានជ្រើសយកមកនោះពិតជា ថ្លៃថ្នូរបំផុត។ ប៉ុន្តែក៏ពិបាកណាស់ដែរក្នុងការដាក់ឱ្យប្រើនៅក្នុងបរិស្ថានមួយ ដែលនិស្ស័យតែខាងការប្រកួតដ៏កាចសាហាវតែខាងប្រជែងដេញដើងគ្នានៅ ក្នុងការធ្វើឱ្យលែងមានរបៀបរៀបរយឥតព្រំដែន តែខាងការកើនឡើងនូវ វិសមភាពសង្គមជាច្រើន តែខាងការធ្វើអាជីវកម្មដោយឥតអៀនខ្មាស់ហើយ បំផ្លិចបំផ្លាញបរិស្ថានយើង ធនធានធម្មជាតិ តែខាងអាងអីប្រើអាវុធដោះ ស្រាយនូវទំនាស់។ ម្យ៉ាងទៀតអាចថាជាពិភពមួយកំពុងឆ្កួតវង្វេងបណ្តោយ តាមតែច្បាប់តែមួយគត់ គឺច្បាប់អ្នកខ្លាំង ។ ប៉ុន្តែការបណ្តោយឱ្យធ្វើស្រួលៗ បណ្តោយឱ្យទៅស្រួលៗយ៉ាងនេះ វាបណ្តាល ឱ្យវិស័យហិរញ្ញកិច្ច សេដ្ឋកិច្ច យុត្តិធម៌ សីលធម៌ ជួបប្រទះតែវិនាសកម្មទាំងស្រុង ។ អ្វីដែលគេបង្កើត មកនោះមិនយូរមិនឆាប់ បុរស ស្ត្រីទាំងឡាយនឹងយកចិត្តទុកដាក់ពីភាពមិនទំ នងនៃរបៀបគ្រប់គ្រងពីអំពើឃោរឃៅ អមនុស្សធម៌ ពីផលវិបាកខាងនយោ បាយនិងខាងសង្គម ។ ព្រះពុទ្ធជាអម្ចាស់នៃយើងលោកបានបង្ហាញផ្លូវនូវ ភាពមិនប្រក្រតីនៃវត្ថុទាំងឡាយនូវការចាំបាច់ ដើម្បីពុះពារលើការឈឺចាប់នៃ ការសង្កត់ចិត្តឱ្យឈ្នះតណ្ហានូវការគោរពមនុស្សដូចគ្នា នូវការត្រិះរិះយកផ្លូវ កណ្តាលគ្រប់កាលៈទេសៈហើយបដិសេធន៍ផ្លូវហួសហេតុ ។

ខ្ញុំព្រះករុណាខ្ញុំ មានសទ្ធាឆ្ពុះបញ្ចាំងឱ្យឃើញសេចក្តីប្រាថ្នាដ៏ជ្រាលជ្រៅ នៃប្រជារាស្ត្រខ្មែរតូចតាចនូវតំលៃរបស់គេពីសន្តិភាព ពីការស្រុះស្រួលគ្នាពី

www.budinst.gov.kh www.elibraryofcambodia.org

មនុស្សធម៌ដោយក្រើនរំលឹកឱ្យបន្តបេសសកម្មដែល ព្រះសង្ឃ ដូនជី លោកអាចារ្យ គ្រហស្ថ អស់លោក ជ្រើសរើសដោយថ្លៃថ្នូរដើម្បីស្រោចស្រង់ប្រទេសកម្ពុជានិងប្រជារាស្ត្រខ្មែរ ។

ខ្ញុំព្រះករុណាខ្ញុំ សូមអរព្រះគុណ និង អរគុណដែលបានសំដែងមេត្តាធម៌យកចិត្តទុកដាក់ស្តាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

## សុន្ទរកថារបស់លោក គីធ័រ សៅរ៍ តំណាងមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ ក្នុងឱកាសបិទបវត្តសិក្ខាសាលាជាតិលើកទី ៤

ជាដំបូងខ្ញុំព្រះករុណាសូមថ្លែងអំណរគុណចំពោះសម្តេចព្រះ នរោត្តម សីហនុ ដែលបានផ្ញើព្រះរាជសារដ៏មានតំលៃជាលើកទី ២ មកកាន់សិក្ខាសាលានេះ។ ព្រះរាជសារនេះជាសារពាំនាំនូវព្រះរាជហឫទ័យនិងដំណោះស្រាយរបស់ព្រះអង្គដែលឆ្លុះឱ្យឃើញពីដំណោះស្រាយនៅក្នុងសង្គម ថ្វីត្បិតតែព្រះអង្គជួបនូវបញ្ហាដែលកំពុងតែកើតមានច្រើននៅក្នុងសង្គម តែក្នុងព្រះរាជសាររបស់ព្រះអង្គនោះព្រះអង្គបានបង្ហាញនូវដំណោះស្រាយ។ ជាមួយគ្នានោះដែរខ្ញុំព្រះករុណាខ្ញុំបាទមានសេចក្តីសង្ឃឹមថា ដើម្បីធ្វើឱ្យព្រះរាជសារនេះបានសម្រេចទៅតាមបំណងរបស់ព្រះករុណា ហើយនិងដើម្បីឱ្យសម្រេចនូវបញ្ហាទាំងឡាយដែលកំពុងតែកើតមាននៅក្នុងសង្គម គឺពឹងផ្អែកទាំងស្រុងទៅលើព្រះសង្ឃគ្រប់ព្រះអង្គលោកលោកស្រីដូនជីដែលបានចូលរួមនៅទីនេះ និងពឹងផ្អែកទាំងស្រុងទៅលើការខិតខំប្រឹងប្រែងផ្ទាល់របស់ ព្រះតេជគុណព្រះសង្ឃ គ្រប់ព្រះអង្គ និង ដូនជីទាំងអស់ ដើម្បីធ្វើឱ្យបានសម្រេចទៅតាមព្រះរាជសារនេះ។ ជាមួយនេះដែរខ្ញុំព្រះករុណាខ្ញុំមានការចាប់អារម្មណ៍ទៅលើសេចក្តីប្រកាសរួមរបស់សិក្ខាសាលាជាតិលើកនេះលើចំណុចទី៤ដែលបានលើកឡើងស្តីអំពីការគ្រប់គ្រង និងការប្រើប្រាស់ថវិកាដែលនៅក្នុងនោះខ្ញុំព្រះករុណាខ្ញុំសុំសង្កត់ថាត្រូវផ្តោតយកចិត្តទុកដាក់នៅលើចំណុចទី៤ នោះគឺនៅលើការជួយខ្លួនឯង ប្រឹងប្រែងជួយខ្លួនឯង ។ ពេលបើកសិក្ខាសាលាថ្ងៃដំបូងមានព្រះតេជគុណជាច្រើនអង្គបាននិមន្តមកឈរនៅជុំវិញខ្ញុំព្រះករុ-

www.budinst.gov.kh www.elibraryofcambodia.org

ណាហើយក៏បានលើកនៅសំណើរថាយើងទាំងអស់គ្នាចង់ចាប់ផ្តើមនៅកម្មវិធីនេះណាស់ ក៏ប៉ុន្តែយើងគ្មាននរណាជួយហើយយើងខ្វះលុយទៅទៀតសំរាប់ធ្វើ។ យើងទាំងអស់គ្នាដឹងហើយថាមធ្យោបាយសំរាប់ផ្តល់ជូនពីរដ្ឋាភិបាលគឺមានចំនួនតិចបំផុត ជាមួយនេះដែរជំនួយពីបរទេសក៏មានកំរិតសំរាប់ប្រទេសកម្ពុជា។ឈរនៅលើបញ្ហាទាំងពីរនេះខ្ញុំព្រះករុណាខ្ញុំសុំឱ្យព្រះតេជគុណគ្រប់ព្រះអង្គ និង លោក លោកស្រីទាំងអស់ដែលបានចូលរួមនៅពេលនេះមេត្តាសាកល្បងក្រោកឈរដោយខ្លួនឯងជាមួយនិងកំលាំងរបស់ខ្លួនយើងផ្ទាល់ជាដំបូងសិន ។ តាមផ្លូវព្រះពុទ្ធសាសនាយើងមានបុណ្យទានច្រើនក្នុងមួយឆ្នាំៗ ចំណូលថវិកាសំរាប់វត្តអារាមក៏បានច្រើនទៅតាម ដំរូវបុណ្យទាន ទាំងនោះដែរ។ សំណួមពរលើកថាតើចំណូលបានមកពីរដូវបុណ្យទានទាំងនោះយើងប្រើប្រាស់ទៅលើអ្វីខ្លះ ? បើសិនរូបខ្ញុំព្រះករុណាជាព្រះសង្ឃវិញនោះខ្ញុំព្រះករុណានឹងកាត់ភាគរយពីចំណូលទាំងនោះប្រចាំឆ្នាំ គឺខ្ញុំព្រះករុណាសុំសន្មតិថា៣០ភាគរយពីចំណូលទាំងនោះសំរាប់យកទៅជួយ ឬ ចាប់ផ្តើមធ្វើថ្នាលបណ្តុះកូនឈើការចាប់ផ្តើមកសាងធនាគារស្រូវ ឬ ក៏ធនាគារសន្សំប្រាក់តាមប្រព័ន្ធឥណទាន។ ព្រះពុទ្ធលោកគ្មានកម្មសិទ្ធិអ្វីទេហើយក៏លោកអត់ត្រូវការកសាងអ្វីដែលជាដំរេករបស់ព្រះអង្គដែរ ។ ចុះហេតុអ្វីបានជាយើងចាត់ទុកការកសាងព្រះវិហារដ៏ស្តឹមស្តៃវត្តល្អមានរបងស្អាត កុដិល្អៗយើងចាត់ថាជារឿងសំខាន់ទៅវិញយើងជួយប្រជាពលរដ្ឋក្រីក្រយ៉ាងណាយើងជួយជាដំបូងគឺការអប់រំ ។ ការជួយខ្លួនឯងដោយខ្លួនឯងនេះមានន័យថានៅពេលដែលព្រះតេជគុណ លោក លោកស្រីនិងអ្នកជីត្រឡប់ពីសិក្ខាសាលាទៅវិញនោះគឺយើងត្រូវតែប្រមូលផ្តុំនៅចលនា ដើម្បី ឱ្យមកចូលរួមជាមួយនឹងយើងព្រោះអ្វីដែលយើងបាននិយាយគ្នានៅក្នុង សិក្ខាសាលានេះ យើងសាកល្បង

www.budinst.gov.kh www.elibraryofcambodia.org

ចេញដំណើរៗសេចក្តីសម្រេចរាល់តែសិក្ខាសាលាទាំងអស់ដូចជាសេចក្តីថ្លែងការណ៍រួមនៅសិក្ខាសាលាជាតិលើកនេះ គឺ ជាសេចក្តីសម្រេចរបស់អ្នកទាំងអស់គ្នាដែលមានវត្តមាននៅទីនេះហើយសេចក្តីសម្រេចនេះនឹងស្ថិតនៅក្នុងដៃរបស់ព្រះតេជគុណព្រះសង្ឃគ្រប់អង្គ លោក លោកស្រី និងដូនជីទាំងអស់គឺមិនមែនស្ថិតនៅក្នុងដៃលោកជាមន្ត្រីរាជការ អ្នកមុខអ្នកការធំៗនៅខាងលើនោះទេ ។ ព្រះតេជគុណ លោក លោកស្រីទាំងអស់ត្រូវតែធ្វើការសាកល្បងបង្ហាញសកម្មភាពទៅតាមអ្វីដែលយើងបានកំណត់គ្នានៅក្នុងសេចក្តីថ្លែងការណ៍រួមនេះហើយយើងចេញដំណើរម្តងបន្តិចៗ ដោយធ្វើចលនាព្រមៗគ្នាដើម្បីជួយនិងធ្វើយ៉ាងណាឱ្យក្លាយជាទៅជាសកម្មភាពជាក់ស្តែង ដើម្បីយើងអាចមើលឃើញថាតើវាមានកំរិតត្រឹមប៉ុណ្ណា ។ ជាពិសេសទៅទៀតយើងធ្វើតែម្នាក់ឯងក៏វាមិនអាចទៅរួចដែរត្រូវសហការណ៍ជាមួយនឹងអាជ្ញាធរដែនដីដូចជាជាមួយមន្ត្រីធម្មការនៅតាមខេត្តនិមួយៗដែរ ។ ជាមួយគ្នានេះដែរខ្ញុំសូមអនុញ្ញាតជំរាបជូនឯកឧត្តមរដ្ឋលេខាធិការសុំឱ្យជួយជំរុញគាំទ្រពិសេសណែនាំដល់មន្ត្រីក្រោមឱវាទរបស់ក្រសួង ដែលមានមន្ទីរធម្មការនៅតាមគ្រប់ខេត្តទាំងអស់សុំមេត្តាឱ្យជួយសហការណ៍ និងគាំទ្រដឹកនាំនៅក្នុងចលនានេះគឺចលនាព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ជួយដល់សហគមន៍ៗ

នៅក្នុងចំណុចទី ២ នៃសេចក្តីថ្លែងការណ៍រួម នៃ អង្គសិក្ខាសាលានេះគឺសុំឱ្យបង្កើតនូវយន្តការត្រួតពិនិត្យ ហើយចំណុច ទី៣ នោះគឺការភ្ជាប់នូវបណ្តាញផ្សព្វផ្សាយពត៌មានឱ្យគ្នាទៅវិញទៅមក ។ ដោយឈរលើចំណុចទាំង២នេះខ្ញុំក៏សូមសំណូមពរនៅពេលនេះសំរាប់ពេលក្រោយថា សុំឱ្យបង្កើតនៅគណៈកម្មការមួយសំរាប់រៀបចំសិក្ខាសាលាជាតិសំរាប់ឆ្នាំក្រោយទៀត ។ សមាជិកនៃគណកម្មាធិការដើម្បីរៀបចំសិក្ខាសាលាជាតិសំរាប់ឆ្នាំក្រោយនោះ

www.budinst.gov.kh www.elibraryofcambodia.org

គឺសមាសភាពដែលត្រូវចូលរួមមាន ÷ អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍, អង្គការសន្តិសេនា ហើយនិងសមាគមជីទីហ្សែត (GTZ) ពីខេត្តកំពង់ធំ ។ ពេលដែលគណៈកម្មការនេះបង្កើតហើយតាមយោបល់ខ្ញុំត្រូវតែជួបគ្នាឱ្យបានទៀងទាត់ក្នុងរយៈពេល៣ខែម្តងនៅទីក្រុងភ្នំពេញ ។ នៅពេលដែលជួបជុំគ្នាត្រូវធ្វើ *ការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក* ដើម្បីវាយតំលៃទៅលើសកម្មភាពតាមតំបន់ឈរជើងនិមួយៗ តើយើងត្រូវធ្វើយ៉ាងម៉េចទៀតទៅថ្ងៃអនាគតចំពោះផែគូសហប្រតិបត្តិការរបស់យើង ? ឬមួយក៏អាចមានលទ្ធភាពថាទៅអនាគតយើងអាចមានលទ្ធភាពធ្វើជាសិក្ខាសាលាតូចៗដោយឡែកមួយ ។ ឧទាហរណ៍ក្នុងឆ្នាំនេះនៅខែ៦អង្គការសន្តិសេនាបានធ្វើសិក្ខាសាលាមួយរយៈពេល២-៣ថ្ងៃស្តីពីការដាំដើមឈើឡើងវិញ។ សិក្ខាសាលាប្រភេទនេះវាចំណេញ : ទី១ មិនចាយលុយច្រើន ដូចយើងធ្វើសិក្ខាសាលាជាតិលើកនេះ ហើយយើងផ្តោតអារម្មណ៍តែមួយមុខទៅលើការដាំដើមឈើ ។ យើងធ្វើដូចនេះដែរ សំរាប់ធនាគារស្រូវ, ការសន្សំប្រាក់ ។ល។ គឺយើងជជែកគ្នាតែពីរឿងមួយៗទេ ហើយគណៈកម្មការរៀបចំសិក្ខាសាលា ក៏អាចជួយទំនុកបំរុងពីការចាប់ផ្តើមការងារ ។ ក្នុងគំរោងជួយផ្តួចផ្តើមថវិកាក្នុងសកម្មភាព និង គំរោងនេះក៏មានការឧបត្ថម្ភពីស្ថានទូតសហព័ន្ធអាល្លឺម៉ង់ផងដែរហើយការសំរេចថាជួយផ្តួចផ្តើមពីជំហានដំបូងយ៉ាងណានោះគឺ គណៈកម្មការចុះទៅវាយតំលៃធ្វើការសិក្សាហើយយកមកជជែកគ្នាហើយសំរេចគ្នាអ្វីដែលមាន អ្វីដែលបានជជែក អ្វីដែលបានធ្វើ ។ នៅក្នុងសិក្ខាសាលានេះពេលដ៏ខ្លីសៀវភៅមួយនឹងត្រូវបានគេបោះពុម្ពចេញឡើង ហើយនេះក៏ជាលទ្ធផលដែលចេញពីសិក្ខាសាលាជាតិលើកទី៤ ។ តែគួរឱ្យស្តាយសៀវភៅដែលស្តីការពីការជជែកដេញដោលគ្នានៅក្នុងសិក្ខាសាលាជាតិលើកទី៣ មិនទាន់

www.budinst.gov.kh www.elibraryofcambodia.org

បោះពុម្ពចេញហើយសៀវភៅនេះមានឈ្មោះថា *ដាក់អាវុធ ចាប់យកព្រះធម៌* ហើយគួរឱ្យស្តាយដែរដោយព្រឹត្តការណ៍ក្នុងខែកក្កដាវាមានលក្ខណៈផ្ទុយទៅនឹងចំណងជើងសៀវភៅ *ដាក់អាវុធ ចាប់យកព្រះធម៌* ។ ការយឺតយាវមិនបានបោះពុម្ពនេះមិនមែនជាកំហុសរបស់អង្គការ *ព. ធ. អ.* ឬ កំហុសរបស់សហការីឬបុគ្គលិកមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរដែរ ។ មូលបទដាក់អាវុធចាប់យកព្រះធម៌នៅតែមានប្រជាប្រិយភាពនៅឡើយទេ ។ ដូច្នេះហើយបានជាខ្ញុំសំរេចប្រគេននិងចែកជូននូវវត្ថុអានុស្សាវរីយ៍ពីរគឺ ឆ័ត្រ១ ដែលមានអក្សរខ្មែរនិងអង់គ្លេសផងសរសេរនៅលើឆ័ត្រដាក់ថា *ដាក់អាវុធ ចាប់យកព្រះធម៌* ។ តាមពិតទៅយើងក៏អាចយកនូវមូលបទមួយសំរាប់សិក្ខាសាលាលើកនេះដែរ គឺ “ *ដាក់គ្រាប់កាំភ្លើងចុះ ហើយចាប់យកសន្ទឹកឆ្នោត* ” ។ គោលបំណងនៃចំណងជើងនេះគឺថាមិនមានគំនុំអ្វីផ្តេសផ្តាសទេគឺថាធ្វើយ៉ាងណាវំលាយអំពើហឹង្សាទាំងប៉ុន្មាននៅក្នុងខ្លួនឬបណ្តេញចេញពីខ្លួនហើយយកសីលធម៌មកជំនួសវិញ ។ មួយទៀតក្នុងន័យនេះគឺបោះចោលនូវអំពើហឹង្សាហើយបញ្ចប់នូវសង្គ្រាមហើយចាប់យកនូវសន្តិភាព។ ខ្ញុំព្រះករុណាសូមរំលឹកឡើងវិញថា ព្រះសង្ឃក្តី យោធាក្តី កងកំលាំងប្រដាប់អាវុធក្តី ក៏ដូចជាមន្ត្រីរាជការស៊ីវិលគឺត្រូវតែមានគោលជំហរអព្យាក្រឹត្យ។ ប្រសិនបើព្រះសង្ឃមិនគង់នៅជាអព្យាក្រិត្យទេសំណួរនឹងលើកឡើងថា តើព្រះសង្ឃឈរលើជំហរសីលប្រាំឬទេ ? ពីព្រោះព្រះសង្ឃជាអ្នកការពារនូវគោលការណ៍សីល៥ ។ ឈរលើគោលការណ៍នេះព្រះសង្ឃត្រូវតែការពារឱ្យបានខ្ជាប់មិនត្រូវឱ្យមានអ្នកណារំលោភបានឡើយនូវគោលការណ៍ : មេត្តា, ករុណា, មុទិតា, ឧបេក្ខានេះ។ ព្រះសង្ឃគ្រប់ព្រះអង្គត្រូវយល់ខ្លួនឯងឱ្យច្បាស់ថាគឺមានតែព្រះសង្ឃនេះហើយដែលមានសារៈសំខាន់ជាអ្នកកំណត់នូវ ជំហរក្នុងសង្គមសង្ឃ

www.budinst.gov.kh www.elibraryofcambodia.org

ជាដំបូលនៃព្រហ្មវិហារធម៌និងសីលធម៌ ហើយត្រូវតែធ្វើជាគំរូសំរាប់ឱ្យពលរដ្ឋទូទៅ ហើយត្រូវធ្វើនិងរក្សាការពារឱ្យបាននូវការគោរពសិទ្ធិមនុស្ស ។ គោលការណ៍នៃសិទ្ធិមនុស្សគឺមិនមែនមកពីបស្ចិមប្រទេសឡើយ ឫសគល់ នៃគោលការណ៍សិទ្ធិមនុស្សគឺចេញមកពីលទ្ធិពុទ្ធសាសនានេះហើយ ។ សីលទី១ក្នុងចំណោមសីលទាំង៥ គឺមិនអនុញ្ញាតឱ្យសំលាប់គឺមានតំលៃសំរាប់មនុស្សទូទៅនៅក្រោមមេឃគឺ ឧបេក្ខា ។

ចុងបញ្ចប់ខ្ញុំព្រះករុណាសូមថ្លែងអំណរព្រះគុណ អំណរគុណ ចំពោះព្រះតេជគុណ លោក លោកស្រី ដែលបានចូលរួមក្នុងអង្គសិក្ខាសាលានេះ និងសូមថ្លែងអំណរគុណផងដែរចំពោះអ្នករៀបចំចាត់ចែង ដែលបានផ្តល់នូវវិភាគទានចូលរួមយ៉ាងច្រើនធ្វើឱ្យសិក្ខាសាលានេះត្រូវបានបញ្ចប់ទៅតាមអ្វីដែលយើងចង់បាន។ ខ្ញុំមិនចង់និយាយថាជោគជ័យនៃអង្គសិក្ខាសាលានេះបានមកដោយសារតែការខំប្រឹងប្រែងរបស់អ្នកណាម្នាក់ទេគឺជាជោគជ័យបានមកពីការធ្វើវិភាគទានរបស់យើងទាំងអស់គ្នា ។ ខ្ញុំព្រះករុណាសុំព្រះទ័យព្រះតេជគុណគ្រប់ព្រះអង្គ សុំចិត្តសុំថ្លើមអស់លោកទាំងអស់គ្នាដែលមានវត្តមាននៅទីនេះសុំកុំឱ្យគិតថាសិក្ខាសាលានេះគឺជាថ្នាក់បង្រៀនទ្រឹស្ដីឱ្យសោះសុំឱ្យប្រែក្លាយសិក្ខាសាលានេះពីអ្វីដែលយើងបានរៀនសូត្រយកទៅអនុវត្តជាក់ស្តែងឱ្យបានសកម្មដោយចេញពីគំនិតនិងចេញពីបេះដូងពិតៗ ។

សូមអរព្រះគុណ និងសូមអរគុណ ។

www.budinst.gov.kh www.elibraryofcambodia.org

**សុន្ទរកថាឯកឧត្តម ហៀន វណ្ណិរិទ្ធ រដ្ឋលេខាធិការក្រសួងធម្មការ-សាសនា ក្នុងឱកាសបិទអង្គសិក្ខាសាលាជាតិលើកទី ៤**

- ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គសិក្ខាសាលាជាតិលើកទី ៤និងសហការីទាំងអស់
- ឯកឧត្តមអភិបាលខេត្ត អភិបាលខេត្តរង
- ឯកឧត្តមទីប្រឹក្សាក្រសួងធម្មការ និងមន្ត្រីទាំងអស់
- ឯកឧត្តម ឡៅ ម៉ុង ហៃ
- ព្រះតេជគុណគ្រប់ព្រះអង្គ ដូនជី តាជី ទាំងអស់ ។

ខ្ញុំសូមសរសើរដោយស្មោះចំពោះលោក ភីធ័រ ស្មៀមូលធិនិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ ដែលបានធ្វើនូវមនុស្សធម៌ដល់ប្រទេសកម្ពុជាយើងនេះ និងសំរាប់ជាតិខ្មែរ។ ថ្ងៃនេះខ្ញុំមានការក្តុកក្តួលក្នុងចិត្តជាអតិបរិមាចំពោះព្រះរាជសារលិខិតនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូងដែលបានផ្ញើជូននូវសារដ៏មានតំលៃខ្ពង់ខ្ពស់បំផុតជូនលោកបណ្ឌិត ភីធ័រ ស្មៀរ ។ ដូចព្រះតេជគុណអស់លោកបានស្តាប់សារលិខិតរបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ហើយខ្ញុំមានអារម្មណ៍ក្តុកក្តួលចិត្តខ្លាំងណាស់ ហើយគិតទៅដល់ទុក្ខវេទនារបស់ខ្មែរដែលមានច្រើនសតវត្សរ៍មកហើយបានទទួលនូវការឈឺចាប់ដោយសារខ្មែរក្រដូចលោក ភីធ័រ ស្មៀរ គាត់មានប្រសាសន៍អញ្ជើងគឺដោយសារតែសង្គ្រាម។

មូលបទថ្ងៃនេះបាននិយាយថា ឱ្យចាប់យកនូវព្រះធម៌ ហើយយើងឈប់ប្រើកាំភ្លើងគ្រឿងអាវុធហើយឈប់កាប់សំលាប់គ្នាទៅវិញទៅមកទៅ។ដូច្នេះយើងត្រូវតែចាប់យកព្រះធម៌ទាំងអស់គ្នា ហើយយើងធ្វើនូវសន្តិភាពដើម្បីឱ្យ

www.budinst.gov.kh www.elibraryofcambodia.org

ប្រទេសកម្ពុជាមានជំហររឹងប៉ឹង ក្នុងកិច្ចការកសាងសេដ្ឋកិច្ចរបស់យើងឱ្យបានរឹងមាំ។ព្រះពុទ្ធបានបរិនិព្វានទៅជាង២៥០០ឆ្នាំមកហើយ តែធម៌ព្រះពុទ្ធស្ថិតនៅជាប់ក្នុងបេះដូងរបស់ខ្មែរគ្រប់រូបទាំងអស់។ ហេតុនេះយើងទាំងអស់ត្រូវគោរពព្រះធម៌ហើយថ្ងៃនេះខ្ញុំបានឃើញនូវសេចក្តីថ្លែងការណ៍រួមនិយាយអំពីសីលធម៌ចរិយាធម៌និងបរិស្ថានសង្គមខ្មែរ។សីលធម៌គឺព្រះពុទ្ធបានប្រៀនប្រដៅយើងយូរយារណាស់មកហើយកន្លែងណាក៏ព្រះពុទ្ធមានពុទ្ធដីកាអំពីសីលធម៌ដែរគឺចង់ឱ្យយើងគោរពនូវសីលធម៌គោរពគ្រប់កន្លែងគឺមិនឱ្យសំលាប់សត្វ ។ ឯចរិយាធម៌ក៏ដូចគ្នាដែរធ្វើម្តេចឱ្យមានចរិយាធម៌ល្អនិងបាននិយាយពីបរិស្ថានទៀត ។ កាលពីជំនាន់ព្រះពុទ្ធបរិស្ថានល្អណាស់ព្រោះព្រះអង្គអត់បានធ្វើកុដិទេទ្រង់គង់នៅក្នុងព្រៃហេមពាន្តដូច្នេះគ្មានការបំផ្លាញបរិស្ថានទេមិនកាប់ដើមឈើទេគឺព្រះពុទ្ធបានទុកទាំងអស់ ហើយបានអប់រំប្រជាពលរដ្ឋឱ្យស្គាល់នូវតំលៃបរិស្ថានឱ្យគោរពនូវជីវិតសត្វឱ្យមានសោភ័ណភាពគ្រប់យ៉ាង។ សព្វថ្ងៃនេះសួរថាតើខ្មែរយើងមានសីលធម៌ត្រឹមណា ? មានចរិយាធម៌ល្អដល់កំរិតណាដែរ ? ហេតុនេះសូមព្រះតេជគុណនិងបងប្អូនទាំងអស់យកមកពិចារណាដើម្បីជួយលើកតំលៃសីលធម៌ ចរិយាធម៌ហើយនិងការគ្រប់គ្រងថែរក្សាបរិស្ថានផងហើយធ្វើតាមការអំពាវនាវរបស់លោក ភីធ័រ ស្វៀរ ដូចជាដាំដើមឈេ។ល។សុភាសិតឥណ្ឌាមួយបានពោលថា “ *នរណាបានដាំដើមឈើមួយដើមមុននឹងអនិច្ចកម្មទៅមនុស្សនោះកើតមកក្នុងលោកមិនអត់ប្រយោជន៍ឡើយព្រោះគេបានថែមវត្ថុធាតុមួយដល់មនុស្សគឺដាំដើមឈើមួយដើម ប្រសិនបើស្លាប់ទៅ ក៏នៅមានដើមឈើមួយដើមដែរ* ” ។ តាមពិតទៅយើងមិនចង់និយាយពីដើមឈើមួយដើមទេ គឺចង់និយាយថា នៅពេលដែលយើងស្លាប់ទៅ យើងគួរទុកវត្ថុអ្វីមួយសំរាប់ឱ្យមនុស្សជំនាន់ក្រោយយើងគេដឹង ដូចជា

www.budinst.gov.kh www.elibraryofcambodia.org

ដើមឈើមួយដើម, ផ្ទះមួយខ្នង, ស្រះទឹកមួយ, ផ្លូវមួយខ្សែ ឬក៏អ្វីក៏ដោយ ឱ្យតែយើងបានទុកជាផលប្រយោជន៍ដល់មនុស្សជំនាន់ក្រោយយើង ព្រោះវាមានសារៈសំខាន់ណាស់សំរាប់មនុស្សជាតិ ។ ដូចលោក ភីធ័រ ស្មៀរ និងព្រះតេជគុណអស់លោកបានដឹងហើយថាសង្គមយើងមានការគោរពសីលធម៌ ហេតុនេះខ្មែរយើងគួរធ្វើយ៉ាងណាដើម្បីប្រកាន់ឱ្យបាននូវសីលធម៌ និងចរិយាធម៌ល្អ។ ព្រះសង្ឃក៏ដូចេ្នះដែរនិមន្តទៅទីណាត្រូវប្រកាន់យកនូវសីលធម៌ជាធំ ហើយធ្វើកិច្ចការផ្សេងៗត្រូវប្រកាន់យកនូវសីលធម៌ និងគោរពទៅតាមគោលការណ៍ព្រះពុទ្ធដើម្បីឱ្យសង្គមរបស់យើងមានវឌ្ឍនភាពទៅមុខ ។

ខ្ញុំព្រះករុណាសូមមានមតិដូចតទៅ ÷

១- សុំឱ្យយើងមានសន្តិសុខ និងស្ថេរភាពនយោបាយ ។

២- គឺការស្តារសេដ្ឋកិច្ចឡើងវិញដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិ

៣- ត្រូវគោរពលទ្ធិប្រជាធិបតេយ្យបើសិនជាយើងមិនគោរពលទ្ធិប្រជាធិបតេយ្យទេ យើងមិនងាយរកសន្តិភាពបានទេ ។

ហេតុនេះវត្ថុទាំង៣យ៉ាងនេះ គឺយើងត្រូវតែខិតខំពួតដៃគ្នាឱ្យមានវឌ្ឍនភាពឡើងដើម្បីឱ្យសង្គមយើងមានភាពប្រសើរឡើង ។

ចុងក្រោយនេះ ខ្ញុំព្រះករុណាសូមថ្វាយព្រះពរដ៏បវរដល់ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ដែលព្រះអង្គបានខិតខំផ្ញើនូវព្រះរាជសារដ៏ មានតំលៃ និងខ្លឹមសារដើម្បីប្រគេនព្រះតេជគុណគ្រប់ព្រះអង្គ និងអង្គសិក្ខាសាលាជាតិទាំងមូលសូមឱ្យព្រះអង្គមានព្រះជន្មាយុយឺនយូរនិងមានព្រះកាយពលមាំមួនដើម្បីជាម្លប់ដ៏ត្រជាក់ដល់កូនចៅតរៀងទៅហើយខ្ញុំព្រះករុណាក៏សូមគាំទ្រនូវអ្វីៗដែលអង្គសិក្ខាសាលាបានសំរេច និងរួមសហការគ្នាដើម្បីឱ្យសេចក្តីសំរេចរបស់អង្គសិក្ខាសាលាមានដំណើរការល្អប្រសើរជារៀងរហូតតទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

# របាយការណ៍បិទអង្គសិក្ខាសាលាជាតិលើកទី ៤

អានដោយ លោក ញឹម តិរក្ស នាយកសកម្មអង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍

- ជាបឋម ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ ព្រះមេគណ ព្រះអនុ គណ ចៅអធិការ និងព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីសក្ការៈ
- សូមគោរពឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការ-សាសនា
- សូមគោរពឯកឧត្តមអភិបាលរងខេត្តស្វាយរៀង- សូមគោរពលោក ភីធ័រ សៀវ តំណាំងមូលនិធិ ខុនរ៉ាដ អាដិន ណៅអ៊ែរ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- សូមគោរពលោក យី ធន់ ទីប្រឹក្សាក្រសួងធម្មការ សាសនា
- សូមគោរពលោកបណ្ឌិត ឡៅ មុំងហៃ

ខ្ញុំព្រះករុណាសូមអនុញ្ញាតពីព្រះតេជគុណគ្រប់ព្រះអង្គនិងសុំអនុញ្ញាតពីឯកឧត្តម លោក លោកស្រីព្រមទាំងសមាជិកសមាជិកាអង្គសិក្ខាសាលាជាតិទាំងមូលដើម្បីរាយការណ៍ជូនពីចំនួនសិក្ខាកាមដែលបានចូលរួមក្នុងអង្គសិក្ខាសាលាជាតិលើកទី៤នេះ ដូចតទៅ ÷

ខេត្តបាត់ដំបងវត្តមានចូលរួមមាន : ៤៦រូប

- ព្រះសង្ឃ ១៩អង្គ
- ដូនជី ៣នាក់
- គ្រហស្ថ ១៤នាក់

ខេត្តបន្ទាយមានជ័យវត្តមានចូលរួមមាន : ១០រូប

- ព្រះសង្ឃ ៦អង្គ

www.budinst.gov.kh www.elibraryofcambodia.org

- ដូនជី ០នាក់
- គ្រហស្ថ ៤នាក់

ខេត្តកំពង់ធំ វគ្គមានចូលរួមមាន : ១៩រូប
- ព្រះសង្ឃ ៤អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ១៥នាក់

ខេត្តសៀមរាប វគ្គមានចូលរួមមាន : ៣រូប
- ព្រះសង្ឃ ២អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ១នាក់

ក្រុងប៉ៃលិន វគ្គមានចូលរួមមាន : ១រូប
- ព្រះសង្ឃ ០អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ១នាក់

ក្រុងភ្នំពេញ វគ្គមានចូលរួមមាន : ១រូប
- ព្រះសង្ឃ ០អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ១នាក់

ខេត្តពោធិសាត់ វគ្គមានចូលរួមមាន : ៥រូប
- ព្រះសង្ឃ ២អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ៣នាក់

www.budinst.gov.kh www.elibraryofcambodia.org

ខេត្តកំពង់ឆ្នាំង វត្តមានចូលរួមមាន : ៥រូប

- ព្រះសង្ឃ ២អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ៣នាក់

ខេត្តកណ្តាល វត្តមានចូលរួមមាន : ៨រូប

- ព្រះសង្ឃ ៤អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ៤នាក់

ខេត្តកំពត វត្តមានចូលរួមមាន : ៤រូប

- ព្រះសង្ឃ ៣អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ១នាក់

ខេត្តកំពង់ស្ពឺ វត្តមានចូលរួមមាន : ៤រូប

- ព្រះសង្ឃ ០អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ៤នាក់

ខេត្តតាកែវ វត្តមានចូលរួមមាន : ៧រូប

- ព្រះសង្ឃ ៣អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ៤នាក់

ក្រុងព្រះសីហនុ វត្តមានចូលរួមមាន : ៦រូប

- ព្រះសង្ឃ ២អង្គ

www.budinst.gov.kh www.elibraryofcambodia.org

- ដូនជី ២នាក់
- គ្រហស្ថ ២នាក់

អង្គការ JSRC វត្តមានចូលរួមមាន : ៤រូប

ខេត្តស្វាយរៀង វត្តមានចូលរួមមាន : ២១រូប

- ព្រះសង្ឃ ៨អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ១៣នាក់

ខេត្តព្រៃវែង វត្តមានចូលរួមមាន : ៥រូប

- ព្រះសង្ឃ ៣អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ២នាក់

ខេត្តក្រចេះ វត្តមានចូលរួមមាន : ៥រូប

- ព្រះសង្ឃ ៣អង្គ
- ដូនជី ០នាក់
- គ្រហស្ថ ២នាក់

បូកសរុបសមាជិក សមាជិកាដែលបានចូលរួមមាន : ១៨៨រូប ។

ក្នុងនាមនៃអ្នករៀបចំ និង ក្នុងនាមខ្ញុំព្រះករុណាជានាយកសកម្មនៃអង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍សូមថ្លែងនូវអំណរព្រះមហាករុណាធិគុណចំពោះព្រះរាជបិតាជាអង្គម្ចាស់នៃយើងព្រះអង្គបានយកព្រះរាជហឫទ័យទុកដាក់មកលើសិក្ខាសាលាជាតិតាំងពីលើក ទី១ ទី២ ទី៣ រហូតមកដល់លើកទី៤នេះទៀត ។ ក្នុងនាមទូលព្រះបង្គំខ្ញុំព្រះករុណាជាសមាជិកសមាជិកានៃអង្គសិក្ខាសាលាជាតិទាំងមូលសូមថ្លែងនូវអំណរព្រះមហាករុណាធិគុណនិង

www.budinst.gov.kh www.elibraryofcambodia.org

សូមលើកដៃប្រណម្យស្ទួងដល់ទេវតាម្ចាស់ទឹក-ដីព្រះមហាការុណាធិគុណ នៃ ព្រះរាជព្រះវិញ្ញាណក្ខន្ធនៃព្រះរាជាណាចក្រកម្ពុជានិងព្រះរតនត្រ័យទាំងបីមាន ព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ សូមលោកជួយតាមបីបាច់ថែរក្សាព្រះរាជតាទូតនៃយើងទាំងអស់គ្នាសូមឱ្យព្រះអង្គបានជាសះស្បើយនូវព្រះរោគាពាធ ដើម្បីជាម្លប់ និង ជាមគ្គុទ្ទេសន៍ ដ៏ឆ្នើមក្នុងការដឹកនាំកោះសន្តិភាពនៃប្រទេសកម្ពុជាតរៀងទៅ ។

សូមថ្លែងអំណរគុណចំពោះឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការ និង សាសនាថ្វីត្បិតតែឯកឧត្តមមានការងារមមាញឹក តែឯកឧត្តមបានឆ្លៀតឱកាសមកចូលរួមក្នុងទិវាបិទវគ្គអង្គសិក្ខាសាលាជាតិលើកទី ៤នេះ ។

សូមថ្លែងអំណរគុណចំពោះឯកឧត្តមអភិបាលនិងអភិបាលខេត្តរងដែលបានឆ្លៀតឱកាសមកចូលរួមក្នុងទិវានេះហើយគុណបំណាច់របស់ឯកឧត្តមទាំងពីរចាត់ទុកថាជាការលើកទឹកចិត្តដល់ គណៈកម្មការរៀបចំសិក្ខាសាលាសមាជិក សមាជិកា និង ដល់ព្រះតេជគុណគ្រប់ព្រះអង្គ ។

ហេតុនេះតាងនាមខ្ញុំព្រះករុណាជាអ្នករៀបចំសិក្ខាសាលាជាតិ សូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះលោក ភីធ័រ ស្បេរ តំណាងអចិន្ត្រៃយ៍មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរប្រចាំនៅកម្ពុជាដែលមាន ឆន្ទៈ ជួយស្តារឡើងវិញនូវ ហិនភាពរបស់ប្រជាពលរដ្ឋខ្មែរ តាំងពីឆ្នាំ ១៩៩៣ រហូតដល់ ១៩៩៧ហើយគុណបំណាច់របស់លោក ខ្ញុំពុំអាចមានអ្វីតបស្នងទៅវិញបានទេគឺមានតែសេចក្តីថ្លែងអំណរគុណ និងសូមជូនពរដល់លោក សូមឱ្យលោកប្រកបដោយសុខមាលភាព សិរីសួស្តី ជ័យជំនះ និងសូមឱ្យលោកទទួលបាននូវជោគជ័យគ្រប់ទិវារាត្រីកុំបីឃ្លាតឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

សូមថ្លែងអំណរគុណចំពោះវាគ្មិនទាំង ១៦ខេត្ត ថ្វីត្បិតតែលោកមិនមានវត្តមានគ្រប់ថ្ងៃក៏ដោយ ក៏ខ្ញុំជឿថាចិត្តរបស់លោក អារម្មណ៍របស់លោក នៅតែតាមជួយជំរុញយើងខ្ញុំឱ្យបានសំរេចដល់គោលដៅជាដរាប ។

សូមថ្លែងនូវអំណរព្រះគុណចំពោះ សមាជិក សមាជិកា ព្រះតេជគុណ និងគណៈកម្មការសិក្ខាសាលាដែលបានចំណាយកំលាំងកាយចិត្តជួយជំរុញឱ្យអង្គសិក្ខាសាលាជាតិទាំងមូលទទួលបាននូវជោគជ័យទាំងស្រុង ក្នុងការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ដើម្បី ឈានទៅរកភាពរីកចំរើនក្នុងការកសាងប្រទេសជាតិយើង ។

## សុន្ទរកថាបិទសិក្ខាសាលាជាតិលើកទី៤

**ថ្លែងដោយ ឯកឧត្តម ឡូយ សុផាត អភិបាលខេត្តស្វាយរៀង**

- សូមក្រាបថ្វាយបង្គំព្រះតេជគុណ ញ៉ែម គឹមតេង ជាទីសក្ការៈ
- សូមក្រាបថ្វាយបង្គំព្រះតេជគុណគ្រប់ព្រះអង្គ ជាទីសក្ការៈ
- សូមគោរពឯកឧត្តម ហៀន វណ្ណារ័ត្ន រដ្ឋមន្ត្រីក្រសួងធម្មការ-សាសនា
- សូមគោរពលោក ភីធ័រ ស្បេរ តំណាងមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- សូមគោរពបណ្ឌិត ឡៅ ម៉ុងហៃ នាយកវិទ្យាស្ថានខ្មែរដើម្បីលិទ្ធិប្រជាធិបតេយ្យ
- សូមគោរពលោក លោកស្រី ដែលជាសមាជិក សមាជិកានៃ អង្គសិក្ខាសាលាជាតិទាំងមូល

www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងឱកាសនេះ ខ្ញុំព្រះករុណា មានសេចក្តីរីករាយជាអតិបរិមា ដោយមានកិត្តិយសបានទទួលរៀបចំក្នុងឋានៈជាម្ចាស់ផ្ទះដើម្បីឱ្យសិក្ខាសាលាជាតិលើកទី៥ប្រព្រឹត្តទៅ និងប្រកបដោយលទ្ធផលយ៉ាងល្អប្រសើរក្នុងបរិយាកាសដែលព្រះតេជគុណគ្រប់ព្រះអង្គនិង ឯកឧត្តម លោក លោកស្រី បានបញ្ចេញមតិយោបល់យ៉ាងជ្រាលជ្រៅទៅលើអង្គសិក្ខាសាលាជាតិ ព្រមទាំងមានការសំរេចចិត្ត នៃអង្គសិក្ខាសាលាជាតិទាំងមូលដែលឆ្លុះបញ្ចាំងនូវជំនឿទុកចិត្តយ៉ាងរឹងមាំទៅលើខ្លឹមសាររបស់ប្រទេសជាតិ និង ពុទ្ធសាសនាជាទីសក្ការៈរបស់យើង ដែលព្រះអង្គធ្លាប់បានដឹកនាំអប់រំឱ្យមនុស្សយើងទាំងអស់គ្នាទៅរកផ្លូវល្អ ។

អង្គសិក្ខាសាលាជាទីគោរពសភាពការណ៍ប្រទេសកម្ពុជានៅឆ្នាំ១៩៩៧នេះមានសភាពការណ៍ស្មុគ្រស្មាញនិងវិវត្តន៍ច្រើនបែបយ៉ាងឆាប់រហ័ស ដែលជាចំណែកមួយប៉ះពាល់ដល់ជីវភាពសង្គមជាតិទាំងមូលទាំងផ្នែកនយោបាយសេដ្ឋកិច្ចព្រមទាំងការអភិវឌ្ឍន៍លើវិស័យផ្សេងៗទៀត។នោះគឺជានយោបាយរបស់ប្រទេសជាតិយើង ដែលត្រូវប្រឈមមុខដោះស្រាយ ដើម្បីឱ្យមានស្ថេរភាពឡើងវិញជូនប្រជាពលរដ្ឋនិងប្រគេនចំពោះព្រះសង្ឃហើយនោះក៏ជាភ័ព្វវាសនាមួយដែលប្រទេសជាតិយើងមិនចង់ជួបប្រទះនូវស្ថានភាពបែបនេះ ។ ប៉ុន្តែអ្វីដែលតំរូវឱ្យការដោះស្រាយពេលនេះ គឺជាវិធានការមួយដែលចាំបាច់ខានមិនបាន ហើយជាហេតុដែលធ្វើឱ្យយើងទាំងអស់គ្នាមានការសោកស្តាយយ៉ាងក្រៃលែង ។ ឆ្លៀតក្នុងឱកាសនេះខ្ញុំព្រះករុណាសូមសំដែងនូវសេចក្តីសង្ឃឹមនិងជឿជាក់អស់ពីដួងចិត្តចំពោះព្រះតេជគុណគ្រប់ព្រះអង្គ ដែលបានធ្វើសេចក្តីប្រកាសថ្លែងការទៅលើសិក្ខាសាលាទាំងមូលក្នុងការរួមចំណែកការពារសន្តិភាពដើម្បីឈានទៅរកការរីកចំរើនក្នុងគោលបំណងឱ្យប្រជាពលរដ្ឋ

www.budinst.gov.kh www.elibraryofcambodia.org

ស្គាល់តែសេចក្តីសុខក្សេមក្សាន្តដើម្បីអភិវឌ្ឍន៍សង្គមខ្មែរ ឈានទៅរកភាពរីកចំរើន និង អភិវឌ្ឍន៍ប្រទេសឱ្យដូចបណ្តាប្រទេសនានាលើសកលលោក ។ ក្នុងនាមអាជ្ញាធរដែនដីនិងក្នុងនាមតំណាងឱ្យប្រជាពលរដ្ឋព្រះសង្ឃក្នុងខេត្តស្វាយរៀងទាំងមូលខ្ញុំសូមសំដែងនូវការគាំទ្រទាំងស្រុងចំពោះសេចក្តីសំរេចចិត្តដ៏មានតំលៃនៃអង្គសិក្ខាសាលាជាតិដែលព្រះតេជគុណអស់លោក លោកស្រី ដែលបានបញ្ចេញមតិយ៉ាងផុសផុលក្នុងការទទួលខុសត្រូវចំពោះជោគវាសនារបស់ប្រទេសជាតិ។ ពិតណាស់ហើយដែលប្រទេសយើងបានឆ្លងកាត់នូវសង្គ្រាមដ៏យូរ ហើយស្លាកស្នាមនៃការបាក់បែកប្រេះស្រាំវាបានបន្សល់ទុកនៅក្នុងទំព័រប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំ ។ ប៉ុន្តែអ្វីៗដែលព្រះតេជគុណគ្រប់ព្រះអង្គបានបញ្ចេញនៅទីនេះគឺឈានទៅរកអំពីអហឹង្សា និង ការមិនបៀតបៀនគ្នាសំខាន់គឺការបំបាត់នូវអំពើ លោភៈ ទោសៈ មោហៈ ដែលជាដើមហេតុនៃក្តីមហន្តរាយរបស់មនុស្សគ្រប់រូប។ ប្រសិនបើយើងទាំងអស់គ្នាប្រកាន់ខ្ជាប់នូវសីលធម៌និងចរិយាធម៌ល្អនោះសង្គមយើងនឹងមានវឌ្ឍនភាពជាមិនខាន ។ ជាថ្មីម្តងទៀតតាងនាមឱ្យថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ប្រជាពលរដ្ឋ ព្រះសង្ឃ ក្នុងខេត្តស្វាយរៀងទាំងមូល ខ្ញុំសូមសំដែងនូវសេចក្តីគោរព ចំពោះការខិតខំប្រឹងប្រែងរបស់ព្រះតេជគុណគ្រប់ព្រះអង្គ លោក លោកស្រីដែលជាសមាជិក សមាជិកាដែលបានយកព្រះទ័យនាំមុខពុទ្ធបរិស័ទចូលរួមយ៉ាងសកម្មក្នុងកិច្ចការទ្រទ្រង់ព្រះពុទ្ធសាសនា និង ចូលរួមក្នុងការអភិវឌ្ឍន៍សង្គមខ្មែរតាំងពីអតីតកាលបច្ចុប្បន្នក៏ដូចជាទៅអនាគត ។ សូមសំដែងនូវការកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍និងអង្គការសន្តិសេនាលោកបណ្ឌិត ភីធ័រ ស្បែរ ព្រមទាំងសហការី និង សកម្មជនដទៃទៀតដែលបានដំណើរការយ៉ាងល្អក្នុងអង្គសិក្ខា

www.budinst.gov.kh www.elibraryofcambodia.org

សាលាដែលមានសារៈសំខាន់ និង សូមសំដែងនូវអំណរគុណចំពោះវត្តមាន ឯកឧត្តមព្រមទាំងអស់លោក លោកស្រី ដែលបានអញ្ជើញមកចូលរួមយ៉ាងកុះករញ៉ាំងឱ្យសិក្ខាសាលាបានប្រព្រឹត្តទៅប្រកបដោយភាពអធិអធម និងក្នុងបរិយាកាសរីករាយ ហើយសំរេចបានលទ្ធផលយ៉ាងខ្ពង់ខ្ពស់ទៀតផង ។ ឆ្លៀតពេលនេះដែរក៏សូមថ្លែងអំណរគុណចំពោះប្រជាពលរដ្ឋអាល្លឺម៉ង់ដែលបានផ្តល់ជំនួយដ៏មានប្រសិទ្ធភាពទាន់ពេលក្នុងកិច្ចការជួយសង្គ្រោះប្រជាពលរដ្ឋកម្ពុជាយើងខ្ញុំ ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា សូមប្រគេនពរចំពោះព្រះតេជគុណគ្រប់ព្រះអង្គ និងសូមប្រសិទ្ធិពរជូនឯកឧត្តម លោក លោកស្រី លោកតា លោកយាយចាស់ព្រឹទ្ធាចារ្យ ព្រមទាំងសហការីទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតំលៃបានចូលរួមក្នុងអង្គសិក្ខាសាលាទាំងមូលសូមឱ្យប្រកបនូវពរទាំង ៥ប្រការ គឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ និងសូមអរព្រះគុណ !

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្ដីថ្លែងការណ៍រួម
# របស់អង្គសិក្ខាសាលាជាតិលើកទី៤
# ស្ដីអំពី "ពុទ្ធសាសនានិងការអភិវឌ្ឍន៍សង្គមខ្មែរ"

អាត្មាភាព យើងខ្ញុំទាំងឡាយ ជាសិក្ខាកាមក្នុងអង្គសិក្ខាសាលាជាតិលើកទី៤ ស្ដីពី *ពុទ្ធសាសនានិងការអភិវឌ្ឍន៍សង្គមខ្មែរ* ដែលបានប្រព្រឹត្តទៅនៅសាលប្រជុំក្រុងស្វាយរៀង ខេត្តស្វាយរៀង ចាប់តាំងពីថ្ងៃទី ២៤-៣០ វិច្ឆិកា ព.ស២៥៤១ គ.ស ១៩៩៧ ក្នុងគោលបំណង :

- ដើម្បីរួមចំណែកស្តារឡើងវិញនូវសីលធម៌ ចរិយាធម៌ និងបរិស្ថាននៃសង្គមខ្មែរ ។
- ដើម្បីរួមចំណែកធ្វើអោយប្រសើរឡើងនូវជីវភាពបរិស័ទក្នុងសង្គមខ្មែរ ។

<u>សំរេច</u>

ដោយឆន្ទៈមោះមុត និងមានការប្ដេជ្ញាចិត្តខ្ពស់ ដើម្បីអនុវត្តអោយបាននូវប្រការទាំងឡាយ ដូចខាងក្រោម :

១- បន្តអនុវត្តសេចក្ដីថ្លែងការណ៍របស់សិក្ខាសាលាជាតិលើកទី ២ និងលើកទី ៣ អោយបានសុក្រឹត្យឡើងថែមទៀត ។

២- សុំអោយបង្កើតយន្តការត្រួតពិនិត្យការអនុវត្តន៍សេចក្ដីថ្លែងការណ៍រួមនៃសិក្ខាសាលាជាតិ ស្ដីអំពី ពុទ្ធសាសនានិងការអភិវឌ្ឍន៍សង្គមខ្មែរ លើកទី២ និងលើកទី៣ ។

៣- បង្កើតឡើងនូវបណ្ដាញផ្សព្វផ្សាយព័ត៌មាន ដល់សមាជិកដែលធ្លាប់ចូលរួមសិក្ខាសាលាជាតិ ។

៤- គ្រប់វត្តអារាម ត្រូវបង្កើនគុណភាពការគ្រប់គ្រង និងការប្រើប្រាស់ថវិកាវត្តអោយបានសមស្រប និងអោយបានជាប្រយោជន៍ដល់បរិស័ទ ។

៥- សុំអោយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ សហប្រតិបត្តិការ និងជួយគាំទ្រ សកម្មភាពព្រះសង្ឃ ដូនជី និងពុទ្ធបរិស័ទ ក្នុងការអនុវត្តន៍សេចក្ដីថ្លែងការរួមនេះ។

ធ្វើនៅក្រុងស្វាយរៀង ថ្ងៃទី៣០ វិច្ឆិកា ព.ស២៥៤១ គ.ស១៩៩៧

| តំណាងព្រះសង្ឃ | តំណាងដូនជី | តំណាងពុទ្ធបរិស័ទ | តំណាងក្រសួងធម្មការនិងសាសនា |
|---|---|---|---|

| តំណាងកងកម្លាំងប្រដាប់អាវុធ | តំណាងអាជ្ញាធរខែត្រ |
|---|---|

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org



១ - បន្តអនុវត្តតាមសេចក្ដីថ្លែងការរបស់សិក្ខាសាលាជាតិលើកទី២ និង លើកទី៣ឱ្យបានសុក្រិត្យឡើងថែមទៀត ។

២ - សូមឱ្យបង្កើតជាយន្តការត្រួតពិនិត្យការអនុវត្តសេចក្ដីថ្លែងការរួមនៃសិក្ខាសាលាជាតិស្ដីពីពុទ្ធសាសនា និង ការអភិវឌ្ឍន៍សង្គមខ្មែរលើកទី២ និង លើកទី៣ ។

៣ - បង្កើតឡើងនូវបណ្ដាញផ្សព្វផ្សាយព័ត៌មានដល់សមាជិកសមាជិកាដែលធ្លាប់ចូលរួមក្នុងសិក្ខាសាលាជាតិ ។

៤ - គ្រប់វត្តអារាមត្រូវបង្កើនគុណភាពការគ្រប់គ្រងនិងការប្រើប្រាស់ថវិការវត្តឱ្យសមស្រប និង ឱ្យបានជាប្រយោជន៍ដល់ពុទ្ធបរិសទ័ ។

៥ - សូមឱ្យរាជរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់សហប្រត្តិបត្តិការ និង ជួយគាំទ្រសកម្មភាព ព្រះសង្ឃ ដូនជី និងពុទ្ធបរិសទ័ ក្នុងការអនុវត្តន៍សេចក្ដីថ្លែងការរួមនេះ ។

(សេចក្ដីសំរេចចិត្តរួមរបស់អង្គសិក្ខាសាលាជាតិលើកទី៤)

www.budinst.gov.kh www.elibraryofcambodia.org